# ក្នុងនាមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទនៅអាស៊ី(BEING LGBT IN ASIA)៖ របាយការណ៍របស់ប្រទេសកម្ពុជា

*ការពិនិត្យឡើងវិញតាមបែបចូលរួម និងការវិភាគបរិយាកាស ច្បាប់និងសង្គម សម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) និងសង្គមស៊ីវិល*


USAID FROM THE AMERICAN PEOPLE
UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER
UNDP
Empowered lives.
Resilient nations.

ឯកសារយោងដែលស្នើឡើង៖

UNDP, USAID (២០១៤). *ក្នុងនាមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទនៅអាស៊ី (Being LGBT in Asia): របាយការណ៍របស់ប្រទេសកម្ពុជា។* បាងកក។

របាយការណ៍នេះត្រូវបានពិនិត្យឡើងវិញលើទិដ្ឋភាពបច្ចេកទេសដោយ UNDP និង USAID ជាផ្នែកមួយនៃគំនិតផ្តួចផ្តើម 'Being LGBT in Asia'។ របាយការណ៍នេះផ្អែកលើការសង្កេតរបស់អ្នកនិពន្ធនៃកិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពី សហគមន៍មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) កាលពីខែមករា ឆ្នាំ២០១៤ ការសន្ទនាជាមួយអ្នកចូលរួម និងការពិនិត្យឡើងលើឯកសារដែលមានស្រាប់។ ទស្សនៈនិងមតិយោបល់នៅក្នុងរបាយការណ៍នេះ មិនសុទ្ធតែឆ្លុះបញ្ចាំងពីគោលជំហរនៃគោលនយោបាយផ្លូវការ របស់កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ឬទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ នោះឡើយ។

UNDP ធ្វើការជាដៃគូជាមួយមនុស្សនៅគ្រប់កម្រិតថ្នាក់នៃសង្គមដើម្បីកសាងប្រទេសដែលអាចទប់ទល់បានចំពោះវិបត្តិព្រមទាំងទទួលបានកំណើនយូរអង្វែងដែលលើកកម្ពស់គុណភាពជីវិតរបស់មនុស្សគ្រប់រូប។ជាមួយនឹងវត្តមាននៅថ្នាក់មូលដ្ឋានផ្ទាល់ ក្នុងជាង ១៧០ប្រទេសនិងទឹកដី យើងផ្តល់ជាទស្សនវិស័យសកល និងគំនិតនៅក្នុងស្រុក ដើម្បីជួយផ្តល់សិទ្ធិអំណាចដល់ជីវិត និងកសាងប្រទេសជាតិដែលមានភាពធន់។

រក្សាសិទ្ធិ© UNDP ២០១៤
កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ
មជ្ឈមណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិកនៃ UNDP
អគារសេវាអង្គការសហប្រជាជាតិ ជាន់ទីបី
ផ្លូវ Rajdamnern Nok, បាងកក ១០២០០, ព្រះរាជាណាចក្រថៃ
អ៊ីមែល៖ aprc.th@undp.org
ទូរស័ព្ទ៖ +៦៦ (០)២ ៣០៤-៩១០០
ទូរសារ៖ +៦៦ (០)២ ២៨០-២៧០០
គេហទំព័រ៖ http://asia-pacific.undp.org/

រចនាម៉ូដ៖ Safir Soeparna/Ian Mungall/Steven Andy Reitz/UN

# ក្នុងនាមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ នៅអាស៊ី(BEING LGBT IN ASIA)៖ របាយការណ៍របស់ប្រទេសកម្ពុជា

ការពិនិត្យឡើងវិញតាមបែបចូលរួម និងការវិភាគបរិយាកាសច្បាប់និងសង្គម
សម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្ស
ស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) និងសង្គមស៊ីវិល

# មាតិកា


សេចក្តីថ្លែងអំណរគុណ 4

អក្សរកាត់ 6

សង្ខេបប្រតិបត្តិ 10

## សេចក្តីផ្តើម 24

ប្រវត្តិដើមនៃការតស៊ូមតិសម្រាប់ មនុស្សLGBT នៅក្នុងប្រទេសកម្ពុជា 26

កិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហាគមន៍ LGBT 42

ក្នុងនាមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទនៅអាស៊ី (BEING LGBT IN ASIA) 43

## ទិដ្ឋភាពរួមនៃសិទ្ធិមនុស្សរបស់បុគ្គលLGBT នៅក្នុងប្រទេសកម្ពុជា 45

បរិយាកាសច្បាប់និងគោលនយោបាយ 45

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាតិ 45

ក្រមរដ្ឋប្បវេណីកម្ពុជាថ្មី៖ ការទទួលស្គាល់មិនច្បាស់លាស់នៃការរៀបការភេទដូចគ្នា? 48

អាជ្ញាធរមូលដ្ឋាន និងនគរបាល៖ បំណកស្រាយផ្សេងៗគ្នាចំពោះច្បាប់ផ្សេងៗគ្នា 50

អាកប្បកិរិយាវប្បធម៌និងសង្គមនិងទស្សនៈចំពោះបុគ្គល LGBTនៅក្នុងប្រទេសកម្ពុជា 52

អាកប្បកិរិយារបស់បុរសចំពោះការស្រឡាញ់ភេទដូចគ្នា៖ ជាការអាម៉ាស់ ប៉ុន្តែច្បាប់គួរការពារពួកគេ ពីការរើសអើង 55

ទស្សនៈរបស់ព្រះពុទ្ធចំពោះឥរិយាបថផ្លូវភេទ 55

វិមជ្ឈការ និងភាពខុសគ្នានៅទូទាំងប្រទេសកម្ពុជា៖ ទំនាក់ទំនង និងភាពជាដៃគូរបស់ LGBT 56

ស្ថាប័នសំខាន់ៗសម្រាប់ការពារសិទ្ធិរបស់ LGBT 57

## ការការពារសិទ្ធិរបស់បុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា 60

កិច្ចការគ្រួសារ 60

សហាគមន៍ និងសង្គម 72

សុខភាព រួមបញ្ចូលទាំងមេរោគអេដស៍ 77

ប្រព័ន្ធផ្សព្វផ្សាយ រួមទាំង បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង 83

បញ្ហា និងក្តីកង្វល់ដទៃទៀត 85

**សមត្ថភាពរបស់អង្គការ LGBT នៅក្នុងប្រទេសកម្ពុជា 89**

ឯកសារយោង 99

ឧបសម្ព័ន្ធទី១៖ បញ្ជីអង្គការដែលចូលរួម 106

ឧបសម្ព័ន្ធទី ២៖ សន្ទានុក្រមនៃពាក្យដែលប្រើជាទូទៅ 107

# សេចក្តីថ្លែងអំណរគុណ


របាយការណ៍នេះកត់ត្រាបទបង្ហាញ និងការពិភាក្សានៅក្នុងកិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហគមន៍LGBTដែលបានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី២១-២២ ខែមករា ឆ្នាំ២០១៤ នៅសណ្ឋាគារ អ៊ីមភើរៀល។ ព័ត៌មានបន្ថែមត្រូវបានទទួលពីការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ និងការអង្កេត របស់អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ដែលធ្វើការលើបញ្ហាLGBT។ សូមកត់សម្គាល់ថា ដោយសារតែមានការផ្លាស់ប្តូរជាប្រចាំនៅក្នុងការតស៊ូមតិនិងនយោបាយនៃសហគមន៍LGBT អាចមានការវិវឌ្ឍថ្មីៗដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះនៅពេលបោះពុម្ពផ្សាយ។

អ្នករៀបចំកិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហគមន៍LGBT សូមថ្លែងអំណរគុណដល់អ្នកចូលរួម អ្នកសម្របសម្រួល និងវាគ្មិនទាំងអស់ ដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សាថ្នាក់ជាតិនេះ និងអ្នកដែលបានចូលរួមនៅក្នុងការអង្កេតស្តីពី អង្គការក្រៅរដ្ឋាភិបាល LGBT ដែលបានផ្តល់ធាតុចូល ដ៏មានតម្លៃសម្រាប់របាយការណ៍នេះ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ ស្រ៊ុន ស្រ៊ន អ្នកសម្របសម្រួលនៃកិច្ចពិភាក្សាថ្នាក់ជាតិ និងអ្នកធ្វើរបាយការណ៍ ដែលរួមមាន៖ ហែម សិលា, យ៉េម សុជា, ឈឿង រចនា, វ៉ាន សុកវណ្ណ, ផេង សាញ់, ណាយ ស៊ីថា, អ៊ុក ផល្លី និង ប៊ូ សកលកិត្យា។ បញ្ជីឈ្មោះអង្គការចូលរួមក្នុងកិច្ចពិភាក្សានេះ មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី១ នៃរបាយការណ៍នេះ។

របាយការណ៍នេះត្រូវបានសរសេរដោយ Vicente S. Salas ដោយមានការជួយពី Sathaboramana Kheang ជាមន្ត្រីសិទ្ធិមនុស្សLGBT នៃគំនិតផ្តួចផ្តើម 'Being LGBT in Asia' ដែលតាំងមូលដ្ឋាននៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅកម្ពុជា។

រូបថតទាំងអស់នៅក្នុងរបាយការណ៍នេះ គឺជាអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហគមន៍ LGBT។ រូបថតទាំងនេះត្រូវបានផ្តល់ដោយ Veronika Jemelikova, អ្នកស្ម័គ្រចិត្តយុវជនអង្គការសហប្រជាជាតិផ្នែកប្រាស្រ័យទាក់ទង អប់រំផ្សព្វផ្សាយ និង យុវជន និង Shuji Sekine, អ្នកស្ម័គ្រចិត្តសកលវិទ្យាល័យ របស់អង្គការសហប្រជាជាតិ ផ្នែកកម្មវិធីយុវជនស្ម័គ្រចិត្ត។

យោបល់និងធាតុចូលដ៏មានតម្លៃទៅលើសេចក្តីព្រាងនៃរបាយការណ៍នេះ ត្រូវបានផ្តល់ដោយ Thomas White អនុប្រធាន ការិយាល័យអភិបាលកិច្ចនិងប្រជាជនងាយរងគ្រោះ នៃបេសកកម្មអភិវឌ្ឍន៍តំបន់អាស៊ីរបស់ USAID (RDMA); Vy Lam, សមាគមអាមេរិកសម្រាប់លើកកម្ពស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា; Dhulce-Janice McGuire, មន្ត្រីប្រជាធិបតេយ្យនិងអភិបាលកិច្ច, និងSerey Chan, អ្នកឯកទេសផ្នែកគ្រប់គ្រងគម្រោង, USAID/កម្ពុជា; និង Adam Schumacher, អនុប្រធានការិយាល័យកិច្ចការអាស៊ីបូព៌ា, ការិយាល័យអាស៊ី,

USAID; ក៏ដូចជា Edmund Settle,ទីប្រឹក្សាគោលនយោបាយ និង Saurav Jung Thapa, មន្ត្រីបច្ចេកទេសសិទ្ធិមនុស្ស និង LGBT, មកពីមកពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិការិយាល័យតំបន់អាស៊ីប៉ាស៊ីហ្វិក (UNDP APRC)។ Andy Quan គឺជាអ្នករៀបរៀងនៃរបាយការណ៍នេះ។

សូមថ្លែងអំណរគុណជាពិសេសដល់បុគ្គលទាំងឡាយខាងក្រោមនេះ ដែលបានផ្តល់ឯកសារយោងសំខាន់ៗ ការណែនាំ និងការបកប្រែ នៅក្នុងអំឡុងពេលរៀបចំរបាយការណ៍នេះ ៖ គង់ ប៊ុនថន តំណាងបណ្តាញបុរសរួមភេទជាមួយបុរសនិងមនុស្សប្តូរភេទ; Kazumi Nakagawa, គ្រូមកពីសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា; Mark West មកពីវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ទឹម; និង សាស្ត្រាចារ្យ Gary Atkins, សាស្ត្រាចារ្យផ្នែកប្រាស្រ័យទាក់ទងនៅសកលវិទ្យាល័យស៊ីអាថល ។

ចុងក្រោយ ដៃគូកិច្ចពិភាក្សាថ្នាក់ជាតិ សូមថ្លែងអំណរគុណចំពោះការរួមចំណែកដ៏ឆ្នើមរបស់ Marie-Dominique Parent, តំណាងរង, OHCHR កម្ពុជា; Amara Bou, អ្នកវិភាគកម្មវិធី, កម្រងជំងឺអេដស៍/អភិបាលកិច្ច, UNDP កម្ពុជា; Isabelle Devylder, មន្ត្រីកម្មវិធី, និង Markara Nuon, ជំនួយការកម្មវិធី, ពីកម្មវិធីស្មគ្រ័ចិត្តអង្គការសហប្រជាជាតិកម្ពុជា; Sinet Seap, មន្ត្រីគម្រោងសមភាពយេនឌ័រ, ស្ថាប័នអង្គការសហប្រជាជាតិសម្រាប់សមភាព និងការផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women); Saurav Jung Thapa, មន្ត្រីបច្ចេកទេសសិទ្ធិមនុស្ស និង LGBT, UNDP APRC; និង Sathaboramana Kheang, មន្ត្រីសិទ្ធិមនុស្ស LGBT សម្រាប់គំនិតផ្តួចផ្តើម 'Being LGBT in Asia' ដែលតាំងមូលដ្ឋាននៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដែលបានចូលរួមដល់ភាពជោគជ័យនៃកិច្ចពិភាក្សានេះ។

កិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហគមន៍ LGBT និងរបាយការណ៍របស់ប្រទេស ត្រូវបានគាំទ្រដោយ UNDP, USAID, និង OHCHR កម្ពុជា តាមរយៈគម្រោងគំនិតផ្តួចផ្តើម 'Being LGBT in Asia' ។ គ្របដណ្តប់ប្រទេសចំនួន៨ ដែលរួមមាន កម្ពុជា ចិន ឥណ្ឌូនេស៊ី ម៉ុងហ្គោលី នេប៉ាល់ ហ្វីលីពីន ថៃ និង វៀតណាម គំនិតផ្តួចផ្តើមសិក្សារួមគ្នានេះមានគោលបំណងស្វែងយល់ពីបញ្ហាប្រឈមផ្នែកច្បាប់ នយោបាយ និងសង្គមដែលបុគ្គល LGBT ជួបប្រទះ, ច្បាប់និងគោលនយោបាយពាក់ព័ន្ធ និងការទទួលបានយុត្តិធម៌និងសេវាសុខភាពរបស់ពួកគេ។ គំនិតផ្តួចផ្តើមនេះនឹងពិនិត្យមើលតម្រូវការរបស់អង្គការ LGBT, ទីកន្លែងដែលពួកគេធ្វើការ, សមត្ថភាពរបស់ពួកគេដើម្បីចូលរួមក្នុងកិច្ចពិភាក្សាស្តីពីសិទ្ធិមនុស្សនិងគោលនយោបាយនិងតួនាទីរបស់បច្ចេកវិទ្យាថ្មីនៅក្នុងការគាំទ្រដល់ការតស៊ូមតិរបស់មនុស្ស LGBT ។

# អក្សរកាត់

| | |
|---|---|
| APCOM | សម្ព័ន្ធភាពអាស៊ីប៉ាស៊ីហ្វិកស្តីពីសុខភាពផ្លូវភេទបុរស |
| APTN | បណ្តាញមនុស្សប្តូរភេទអាស៊ីប៉ាស៊ីហ្វិក |
| ART | ការព្យាបាលដោយឱសថប្រឆាំងវីរុស |
| BC | បណ្តាញចតុមុខ (បណ្តាញបុរសរួមភេទជាមួយបុរសជាតិ) |
| CACHA | សម្ព័ន្ធកម្ពុជាដើម្បីប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ |
| CARD | ក្រុមប្រឹក្សា អភិវឌ្ឍន៍កសិកម្មនិងជនបទ |
| CBO | អង្គការនៅសហគមន៍ |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CDHS | ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| CITA | សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា |
| CLS | សេវាច្បាប់នៅសហគមន៍ |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា |
| CPN+ | បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា |
| CSO | អង្គការសង្គមស៊ីវិល |
| CSSD | អង្គការសហប្រតិបត្តិការសម្រាប់សេវាសង្គមនិងការអភិវឌ្ឍ |
| EIDHR | លិខិតូបករណ៍អឺរ៉ុបសម្រាប់ប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស |
| EW | នារីបម្រើសេវាកម្សាន្ត |
| FGD | ការពិភាក្សាក្រុមគោលដៅ |
| FHI 360 | អតីតអង្គការសុខភាពគ្រួសារអន្តរជាតិ |
| GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GFATM | មូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ (ត្រូវបានស្គាល់ផងដែរថាជា "មូលនិធិសកល") |
| HACC | គណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍/ជំងឺអេដស៍ |
| HIV | វីរុសដែលធ្វើឲ្យប្រព័ន្ធភាពស៊ាំមនុស្សចុះខ្សោយ |
| HRC | ក្រុមប្រឹក្សាសិទ្ធិមនុស្ស |
| ICFRW | ក្រុមប្រឹក្សាអន្តរជាតិស្តីពីការស្រាវជ្រាវសម្រាប់ស្ត្រី |
| ICJ | គណៈកម្មការគណៈវិនិច្ឆ័យអន្តរជាតិ |
| ICT | ព័ត៌មាន និងបច្ចេកវិទ្យាប្រាស្រ័យទាក់ទង |
| IDAHOT | ទិវាអន្តរជាតិប្រឆាំងការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា និងការ ស្អប់មនុស្សប្តូរភេទ |
| IDPoor | កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |
| IPPF | សហព័ន្ធមាតុបិតុភាពអន្តរជាតិ |

| | |
|---|---|
| KI | អ្នកផ្តល់ព័ត៌មានគន្លឹះ |
| LGBT | មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ |
| LICADHO | សម្ព័ន្ធកម្ពុជាដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស |
| MCH | សុខភាពមាតា និងកុមារ |
| MHC | សុខភាពបុរសកម្ពុជា |
| MHSS | សេវាសង្គមនិងសុខភាពរបស់បុរស |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MoWA | ក្រសួងកិច្ចការនារី |
| MSI | អង្គការម៉ារីស្តូប អន្តរជាតិ |
| MSM | បុរសដែលរួមភេទជាមួយបុរស |
| MSMGF | វេទិកាសកលស្តីពីបុរសរួមភេទជាមួយបុរស និងមេរោគអេដស៍ |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| NAPVAW | ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NSPS | យុទ្ធសាស្ត្រជាតិគាំពារសង្គម |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| PACT | ទីភ្នាក់ងារឯកជនសហការរួមគ្នា |
| PFLAG | ឪពុកម្តាយ គ្រួសារ និងមិត្តភក្តិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា |
| PSI | អង្គការសេវាសុខភាពប្រជាជនអន្តរជាតិ |
| PYD | Paz Y Desarollo (សន្តិភាព និងការអភិវឌ្ឍ) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RHAC | សមាគមសុខភាពគ្រួសារកម្ពុជា |
| RoCK | អង្គការសហគមន៍ឥន្ទធនូកម្ពុជា |
| SMS | សេវាសារខ្លី |
| SOGI | ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ |
| SPU | ផ្នែកគាំពារសុខភាពសង្គម |
| SRH | សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ |
| STIs | ជំងឺកាមរោគ |
| UNAIDS | កម្មវិធីអង្គការសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍/ជំងឺអេដស៍ |

| | |
|---|---|
| UNDP APRC | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ការិយាល័យតំបន់អាស៊ីប៉ាស៊ីហ្វិក |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| UNFPA | អង្គការមូលនិធិប្រជាជននៃអង្គការសហប្រជាជាតិ |
| UNICEF | អង្គការមូលនិធិកុមារអន្តរជាតិនៃអង្គការសហប្រជាជាតិ |
| UNGASS | កិច្ចប្រជុំពិសេសនៃមហាសន្និបាតអង្គការសហប្រជាជាតិ |
| UNV | កម្មវិធីស្ម័គ្រចិត្តអង្គការសហប្រជាជាតិ |
| UN WOMEN | ស្ថាប័នអង្គការសហប្រជាជាតិសម្រាប់សមភាព និងការផ្តល់ភាពអង់អាចដល់ស្ត្រី |
| UPR | ការត្រួតពិនិត្យតាមពេលកំណត់ជាសកល |
| USAID RDMA | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ បេសកកម្មអភិវឌ្ឍន៍តំបន់អាស៊ី |
| VAW | អំពើហិង្សាលើស្ត្រី |
| VCSP | គោលនយោបាយភូមិឃុំមានសុវត្ថិភាព |
| VCT | ការផ្តល់ប្រឹក្សានិងធ្វើតេស្តដោយស្ម័គ្រចិត្ត (សម្រាប់មេរោគអេដស៍) |
| WHO | អង្គការសុខភាពពិភពលោក |
| WNU | បណ្តាញស្ត្រីដើម្បីរួបរួម |
| YVC | សម្លេងយុវជនមានសារៈសំខាន់ |

# សង្ខេបប្រតិបត្តិ

## Being LGBT in Asia: កិច្ចពិភាក្សាថ្នាក់ជាតិស្តីពីសហគមន៍ LGBT នៅកម្ពុជា

របាយការណ៍នេះពិនិត្យឡើងវិញលើបរិយាកាសច្បាប់ និង សង្គមសម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) នៅក្នុងប្រទេសកម្ពុជា។ នេះគឺជាផលិតផលមួយដែលបានមកពីកិច្ចពិភាក្សាថ្នាក់ជាតិស្តីពីសហគមន៍LGBT នៅកម្ពុជា ដែលបានធ្វើឡើងកាលពីខែមករា ឆ្នាំ២០១៤ នៅក្នុងរាជធានីភ្នំពេញ។ កិច្ចពិភាក្សាថ្នាក់ជាតិនេះមានអ្នកចូលរួមចំនួន ៥៩ នាក់ មកពី ១៨ខេត្ត ដែលតំណាងឲ្យអង្គការ LGBT នានានៅក្នុងប្រទេសកម្ពុជា រួមជាមួយតំណាងអង្គការពហុភាគីនិងទ្វេភាគី ដៃគូអភិវឌ្ឍ សកលវិទ្យាល័យ អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ដែលធ្វើការពាក់ពន្ធ័ទៅនឹងផ្នែកសិទ្ធិរបស់មនុស្ស LGBT។ កិច្ចពិភាក្សាថ្នាក់ជាតិនេះត្រូវបានរៀបចំឡើងរួមគ្នា ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និង មជ្ឈមណ្ឌលថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកនៃ កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP APRC) សហការជាមួយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។

របាយការណ៍របស់ប្រទេសនេះ គឺជាផលិតផលមួយនៃគំនិតផ្តួចផ្តើមទូលំទូលាយមួយដែល មានឈ្មោះថា ‛Being LGBT in Asia′: ការពិនិត្យឡើងវិញនិងការវិភាគតាមបែបចូលរួមនៃបរិយាកាសច្បាប់និងសង្គមសម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) និងសង្គមស៊ីវិល។ ដោយបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការក្នុងឱកាសទិវាសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១២ គំនិតផ្តួចផ្តើម ‛Being LGBT in Asia′ គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីរៀនសូត្រនៅទូទាំងតំបន់អាស៊ីដំបូងបំផុតមួយ ដែលត្រូវបានអនុវត្តឡើងដោយអង្គការ LGBT នៅថ្នាក់មូលដ្ឋាននៅអាស៊ី និងមេដឹកនាំសហគមន៍ រួមជាមួយ UNDP និង USAID។ នៅក្នុងប្រទេសកម្ពុជា គម្រោងនេះបានសហការជាដៃគូបន្ថែមទៀតជាមួយ OHCHR។ ផ្តោតទៅលើប្រទេសចំនួន ៨ ដែលរួមមាន កម្ពុជា ចិន ឥណ្ឌូនេស៊ី មុងហ្គោលី នេប៉ាល់ ហ្វីលីពីន ថៃ និង វៀតណាម កិច្ចខិតខំប្រឹងនេះពិនិត្យមើលបទពិសោធន៍ក្នុងជីវិតរបស់មនុស្ស LGBT ដោយឈរលើទស្សនវិស័យអភិវឌ្ឍន៍ និងសិទ្ធិ។

គំនិតផ្តួចផ្តើម‛Being LGBT in Asia′មានគោលដៅមួយចំនួន ដោយលើកទឹកចិត្តដល់ការធ្វើការជាបណ្តាញរវាង LGBT នៅទូទាំងតំបន់, កសាងមូលដ្ឋានចំណេះដឹង និងស្វែងយល់អំពីសមត្ថភាពរបស់អង្គការ LGBT ក្នុងការចូលរួមនៅក្នុងកិច្ចសន្ទនាគោលនយោបាយ និងការកៀងគរសហគមន៍។ តាមរយៈការងារនេះ ‛Being LGBT in Asia′លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់មនុស្ស LGBT និងបញ្ហាមាក់ងាយនិងរើសអើងដែលពួកគេជួបប្រទះនៅ

ទូទាំងតំបន់នេះ។គំនិតផ្តួចផ្តើមនេះដាក់ចេញនូវជំហាននានាឆ្ពោះទៅរកការងារអភិវឌ្ឍន៍ដែលរួមបញ្ចូល LGBT សម្រាប់ UNDP និងប្រព័ន្ធអង្គការសហប្រជាជាតិ; USAID និងរដ្ឋាភិបាលសហរដ្ឋអាមេរិក; និងដៃគូអភិវឌ្ឍន៍ដទៃទៀត តាមរយៈការស្រាវជ្រាវដូចជារបាយការណ៍នេះជាដើម និងផលិតផលសង្គមនិងពហុបច្ចេកវិទ្យាដទៃទៀត។ ចុងក្រោយ គំនិតផ្តួចផ្តើមនេះរំលេចពីទស្សនៈនានាដែលផ្តល់ដោយអ្នកចូលរួមដែលជាបុគ្គល LGBT នៅឯកិច្ចពិភាក្សាសហគមន៍ ដោយផ្សារភ្ជាប់ជាមួយភាគីពាក់ព័ន្ធនានាដែលកំពុងធ្វើការដើម្បីលើកកម្ពស់សិទ្ធិមនុស្សរបស់ LGBT នៅទូទាំងអាស៊ី។

## *ប្រវត្តិសង្ខេបនៃបញ្ហាទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រនៅក្នុងប្រទេសកម្ពុជា*

ឥរិយាបថផ្លូវភេទចម្រុះ និងអត្តសញ្ញាណយេនឌ័រនៅក្នុងប្រទេសកម្ពុជាមានមកតាំងពីសតវត្សរ៍ទី១៣ ប៉ុន្តែអត្តសញ្ញាណផ្សេងៗទៀតទំនងជាត្រូវបានបំផ្លាញចោលអស់នៅក្នុងរបបខ្មែរក្រហម។មានការអង្កេតនិងការសិក្សាខ្លះអំពីចំណង់ផ្លូវភេទដូចគ្នារវាងបុរសនៅក្នុងទសវត្សរ៍៥០ និងក្រោយមកទៀត និងរបាយការណ៍តាមកាសែតខ្លះអំពីស្រ្តីប្តូរភេទនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជាពីទសវត្សរ៍៥០ ដល់៧០។ការសិក្សាអំពីផ្លូវភេទនិងឥរិយាបថដែលបានចាប់ផ្តើមក្នុងទសវត្សរ៍៩០ ដែលជំរុញដោយការរីករាលដាលមេរោគអេដស៍ក្នុងសកលលោកនោះបានធ្វើឲ្យមានការយល់ដឹងនិងការពិភាក្សាគ្នាកាន់តែច្រើនឡើងពីទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ (SOGI)។ នៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ព្រឹត្តិការណ៍មោទនភាព ត្រូវបានគេប្រារព្ធឡើងចាប់តាំងពីឆ្នាំ២០០៣ ហើយសេចក្តីថ្លែងការណ៍ជាសាធារណៈមួយត្រូវបានធ្វើឡើងដោយព្រះមហាវីរក្សត្រកម្ពុជា ព្រះករុណាព្រះបិតាជាតិ នរោត្តម សីហនុ ជាការគាំទ្រដល់ទំនាក់ទំនងភេទដូចគ្នានៅក្នុងឆ្នាំ២០០៤។ នៅក្នុងទសវត្សរ៍នេះដែរ មានការបង្កើតឡើងជាលើកដំបូងបំផុតនូវបណ្តាញបុរសរួមភេទជាមួយបុរស និងមនុស្សប្តូរភេទ នៅក្នុងឆ្នាំ២០០៦ និងអង្គការ LGBT ដែលត្រូវបានគេទទួលស្គាល់ជាផ្លូវការដំបូងបំផុតក្នុងឆ្នាំ២០១៤។ចាប់តាំងពីពេលនោះមក គេសង្កេតឃើញថា សហគមន៍មនុស្សLGBTនៅក្នុងប្រទេសនេះ បាននិងកំពុងលេចមុខលេចមាត់ខ្លាំងឡើងៗ និងមានការចងក្រងជាសហគមន៍ ក៏ដូចជាសកម្មភាពសង្គមកាន់តែច្រើនឡើងៗផងដែរ។

## *របកគំហើញ*

របាយការណ៍នេះផ្តល់នូវទិដ្ឋភាពជារួមមួយអំពីសិទ្ធិរបស់មនុស្សLGBT នៅក្នុងប្រទេសកម្ពុជា ដែលទាក់ទងយ៉ាងទូលំទូលាយទៅនឹងច្បាប់ និងគោលនយោបាយ អាកប្បកិរិយាសង្គមនិងវប្បធម៌ ព្រមទាំងសាសនា និងជាក់លាក់ជាងនេះគឺទាក់ទងទៅនឹងកិច្ចការគ្រួសារ ការអប់រំ និងការសិក្សា ការងារ និងមុខរបរ សហគមន៍និងសង្គម សុខភាព រួមទាំងមេរោគអេដស៍ ប្រព័ន្ធផ្សព្វផ្សាយរួមទាំងព័ត៌មាន បច្ចេកវិទ្យាប្រាស្រ័យទាក់ទង (ICT) និងសមត្ថភាពស្ថាប័ននៃអង្គការ LGBT។

សេចក្តីសង្ខេបនៃបរិបទជារួមសម្រាប់សិទ្ធិរបស់មនុស្សLGBT នៅក្នុងប្រទេសកម្ពុជា មានដូចខាងក្រោម៖

- **ច្បាប់ និងគោលនយោបាយជាតិ៖** ទោះបីជាសកម្មភាពរួមភេទដូចគ្នាមិនមែនជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ប៉ុន្តែច្បាប់និងគោលនយោបាយនៅក្នុងប្រទេសកម្ពុជាមិនបានចែងអំពីមនុស្ស LGBT និងសិទ្ធិរបស់ពួកគេឡើយ។ ពុំមានច្បាប់ប្រឆាំងនឹងការរើសអើង និងទណ្ឌកម្មសម្រាប់អ្នកដែលរំលោភសិទ្ធិរបស់មនុស្ស LGBT ឬចែងអំពីបញ្ហាមរតក ពន្ធ ឬសិទ្ធិគ្រួសារ នោះឡើយ។ ក្រមរដ្ឋប្បវេណីបច្ចុប្បន្ន មិនបានចែង ឬកំណត់ពីភេទរបស់សហព័ទ្ធឡើយ ដូច្នេះគេអាចបកស្រាយថាវាអនុញ្ញាតឲ្យមានការរៀបការភេទដូចគ្នា ប៉ុន្តែគេមិនទាន់បានសាកល្បងបកស្រាយបែបនេះឡើយទេ។ មានរបាយការណ៍អំពីអាជ្ញាធរមូលដ្ឋាន និងនគរបាលដែលប្រើច្បាប់ផ្សេងៗដើម្បីរំលោភលើសិទ្ធិរបស់ LGBT រួមទាំងការបំបែកបំបាក់ដោយបង្ខំនូវគូស្រករភេទដូចគ្នា ដើម្បីឆ្លើយតបនឹងការទាមទាររបស់ឪពុកម្តាយ និងការរើសអើងដោយនិយាយភ្ជាប់បុគ្គលLGBT ជាមួយបញ្ហាសង្គមនានា ដូចជាការប្រើគ្រឿងញៀន ឬលក់សេវាភេទ។
- **អាកប្បកិរិយាសង្គម និងវប្បធម៌៖** ប្រជាពលរដ្ឋកម្ពុជាយល់ពីភេទ និងសកម្មភាពផ្លូវភេទ ជាពាក្យដែលមានលក្ខណៈស្រាលជាងពាក្យរបស់បស្ចឹមប្រទេស "ប្រុស" និង "ស្រី"។ មនុស្សLGBTសញ្ជាតិកម្ពុជាជាច្រើន កំណត់អត្តសញ្ញាណខ្លួនឯង យោងតាមបទដ្ឋានយេនឌ័រ ជាជាងទំនោរផ្លូវភេទ។ ស្រដៀងគ្នានេះដែរ សង្គមមានការជំទាស់ទៅនឹងបុគ្គលដោយសារតែ បទដ្ឋានយេនឌ័ររបស់ពួកគេ ជាជាងអត្តសញ្ញាណជាមនុស្សLGBT។ ចំពោះការធ្វើបាបដល់បុគ្គល LGBT វិញ គេហាក់ដូចជាមិនឃើញមានការធ្វើទុកបុកម្នេញដោយចំហទៅលើមនុស្សLGBT ឡើយ ហើយបុគ្គលLGBT ខ្លះ ត្រូវបានគេអត់ឱនឲ្យប្រសិនបើពួកគេមិនរំលោភច្បាប់និងបទដ្ឋានសង្គម។ មានការរាយការណ៍មកថា គូស្រករភេទដូចគ្នាខ្លះត្រូវបានគេទទួលស្គាល់នៅក្នុងភូមិរបស់ពួកគេ។
- **សាសនា៖** សាសនារបស់ជាតិ គឺសាសនាព្រះពុទ្ធ ដែលមិនមានការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា និងការស្អប់មនុស្សប្តូរភេទ ព្រមទាំងមិនបានបែងចែករវាងការស្រឡាញ់ភេទផ្ទុយគ្នា និងការស្រឡាញ់ភេទដូចគ្នានោះទេ នៅក្នុងធម៌វិន័យរបស់ខ្លួនអំពីសកម្មភាពផ្លូវភេទ។ ព្រះពុទ្ធ មានពុទ្ធដីកាថា ការជៀសវាងកាមគុណគឺជាជំហានមួយឆ្ពោះទៅរកសេចក្តីសុខ ហើយថា ឥរិយាបថកាមគុណ គួរតែមានការគោរព ថ្នាក់ថ្នម និងរីករាយ។

របាយការណ៍នេះ ថែមទាំងពិនិត្យមើលភាពខុសគ្នានៅក្នុងការទទួលស្គាល់បុគ្គល LGBT នៅទូទាំងប្រទេសកម្ពុជា។ គេបានរកឃើញថា បុរសដែលរួមភេទជាមួយបុរស និងស្ត្រីប្តូរភេទ ជាទូទៅ ប្រមូលផ្តុំគ្នានៅក្នុងទីក្រុងធំៗ និងទីរួមខេត្ត។ មនុស្សស្រីស្រឡាញ់ភេទដូច

គ្នា និងមនុស្សប្រុសប្តូរភេទ ត្រូវបានគេទទួលស្គាល់ និងមានភាពងាយស្រួលជាងគេក្នុងការរស់នៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា។

របាយការណ៍នេះក៏ពិនិត្យផងដែរលើផ្នែកនានានៃកិច្ចការគ្រួសារ ការអប់រំ និងការសិក្សា មុខរបរនិងការងារ សហគមន៍និងសង្គម សុខភាព ប្រព័ន្ធផ្សព្វផ្សាយ និងបញ្ហាដទៃទៀត។

- **កិច្ចការគ្រួសារ៖** បញ្ហាជាច្រើនត្រូវបានរាយការណ៍ឲ្យដឹងទាក់ទងទៅនឹងការប្រព្រឹត្តមិនគប្បីទៅលើបុគ្គល LGBT ដោយគ្រួសាររបស់ពួកគេ ដោយមានតាំងពីការបង្ខំឲ្យរៀបការ ការប៉ុនប៉ងព្យាបាលបុគ្គល LGBT, ការបដិសេធរបស់គ្រួសារ និងការត្រួតត្រាលើឥរិយាបថរបស់ពួកគេ។ លទ្ធផលចំពោះបុគ្គល LGBT រួមមាន ការរត់ចេញពីផ្ទះ មានបញ្ហាផ្លូវចិត្ត ថប់បារម្ភ និងមានគំនិតចង់ធ្វើអត្តឃាតកាន់តែច្រើន។
- **ការអប់រំ និងសាលារៀន ៖** អត្រាបោះបង់ចោលការសិក្សាក្នុងចំណោមយុវជន LGBT គឺខ្ពស់ជាងសិស្សទូទៅក្នុងសាលារៀន ដោយសារតែមានការធ្វើបាបពីសំណាក់មិត្តភក្តិ និងបញ្ហាសេដ្ឋកិច្ចដោយសារតែគ្រួសារមិនទទួលស្គាល់។ [1] បរិយាកាសសាលារៀននៅបឋមសិក្សាច្រើនតែពង្រឹងតួនាទីយេនឌ័រតាមបែបបុរាណ។ មានសកម្មភាពបង្កើនការយល់ដឹងខ្លះអំពីបញ្ហា LGBT នៅក្នុងតាមបណ្តាសកលវិទ្យាល័យក្នុងប្រទេសកម្ពុជា។
- **មុខរបរ និងការងារ៖** មនុស្សLGBT នៅកម្ពុជា មិនចង់បើកចំហអំពីទំនោរផ្លូវភេទរបស់ពួកគេនៅទីកន្លែងធ្វើការឡើយ ហើយពួកគេមានឱកាសការងារតិចតួចដោយសារមានការរើសអើង និងការមិនរាប់រកពីអ្នកដទៃ។ មានការងារតិចតួចដែលត្រូវបានធ្វើឡើងដើម្បីលើកឡើងពីបញ្ហាទំនោរផ្លូវភេទនិងអត្តសញ្ញាយេនឌ័រក្នុងចំណោមនិយោជក។ ជារឿយៗ អ្នកប្តូរភេទត្រូវបានគេធ្វើបាបដោយសារតែរូបរាងរបស់ពួកគេ និងមុខរបររបស់ពួកគេជាអ្នកធ្វើការក្នុងសេវាកម្សាន្ត ឬអ្នកប្រកបរបរផ្លូវភេទ។ អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ ដែលធ្វើការជាមួយបុរសរួមភេទជាមួយបុរស និងមនុស្សប្តូរភេទ មិនជួលបុគ្គល LGBT ឲ្យធ្វើការទេ ឬបើទោះបីជាពួកគេជួល គឺជួលសម្រាប់តែការងារកម្រិតទាប និងមានប្រាក់ឈ្នួលទាប។

---

[1] របាយការណ៍របស់ CCHR ឆ្នាំ២០១២, ទំព័រ ១៩, យោងតាមក្រសួងអប់រំ យុវជន និងកីឡា ១៩,៦ភាគរយនៃសិស្សនៅថ្នាក់មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៧ ដល់ ៩) បានបោះបង់ការសិក្សាក្នុងអំឡុងឆ្នាំសិក្សា ២០១០-២០១១។ ទោះបីជាពុំមានការសិក្សាស្រាវជ្រាវអំពីមូលហេតុនៃការបោះបង់ចោលការសិក្សាដ៏ច្រើនសន្ធឹកសន្ធាប់នេះក្តី ហើយថាតើអត្រានេះមានទាក់ទងទៅនឹងការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា និងការស្អប់មនុស្សប្តូរភេទ ភ័ស្តុតាងតាមការនិយាយតៗគ្នាដែលប្រមូលបានពីបេសកកម្មចុះស្រាវជ្រាវរបស់ CCHR នៅខេត្តសៀមរាបកាលពីខែមករា ឆ្នាំ២០១២ បង្ហាញយ៉ាងច្បាស់ថា អត្រាបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់ខ្លាំងក្នុងចំណោមបុគ្គល LGBT វ័យក្មេង។ មូលហេតុចំពោះការបង់ចោលការសិក្សា រួមមានបញ្ហាផ្នែកសេដ្ឋកិច្ចដែលកើតឡើងដោយសារការមិនទទួលស្គាល់ដោយគ្រួសារពួកគេ និងការហៅឈ្មោះ និងការបន្លាចពីសំណាក់មិត្តរួមថ្នាក់ ទាក់ទងទៅនឹង ផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។

- **សហគមន៍ និងសង្គម៖** ការវាយប្រហារដោយស្អប់អ្នកស្រឡាញ់ភេទដូចគ្នា និងការរំលោភបំពាន ត្រូវបានគេរាយការណ៍ឲ្យដឹងនៅតាមទីសាធារណៈនានា ដូចជាទីផ្សារ ក្លឹបកំសាន្ត និងនៅក្នុងបរិបទសហគមន៍នានា ដូចជាអ្នកជិតខាង ឬគ្រួសារ។ បញ្ហានេះគឺវាផ្ទុយគ្នាទៅនឹងរបាយការណ៍ខ្លះ អំពីការទទួលស្គាល់គូស្រករភេទដូចគ្នានៅថ្នាក់ភូមិ។
- **សុខភាព រួមទាំងមេរោគអេដស៍៖** មេរោគអេដស៍គឺជាបញ្ហាសុខភាពយ៉ាងសំខាន់មួយសម្រាប់បុរសដែលរួមភេទជាមួយបុរស និងមនុស្សស្រីប្តូរភេទ នៅក្នុងប្រទេសកម្ពុជា ហើយអត្រាឆ្លងមេរោគអេដស៍ និងការប្រឈមមុខចំពោះការចម្លងក្នុងចំណោមពួកគេ គឺមានកម្រិតខ្ពស់។ ជារឿយៗ បុរសដែលរួមភេទជាមួយបុរស និងមនុស្សប្តូរភេទត្រូវបានគេចាត់ទុកថាជាក្រុមតែមួយ ដោយមិនបានយកចិត្តទុកដាក់ពីតម្រូវការជាក់លាក់របស់ពួកគេ ប៉ុន្តែមានវឌ្ឍនភាពខ្លះនៅក្នុងគោលនយោបាយ និងក្នុងចំណោមបុគ្គលិកសុខាភិបាល ក្នុងការបែងចែកភាពខុសគ្នារវាងក្រុមមនុស្សទាំងនេះ។ ការមាក់ងាយ និងការរើសអើងនៅក្នុងវិស័យសុខាភិបាលកើតមានឡើងចំពោះបុរសដែលរួមភេទជាមួយបុរស និងមនុស្សប្តូរភេទ។ មនុស្សប្តូរភេទត្រូវការការយកចិត្តទុកដាក់ទៅលើបញ្ហាសុខភាពនានា ក្រៅពីមេរោគអេដស៍ ដូចជាការវះកាត់ប្តូរភេទ ការព្យាបាលដោយអ័រម៉ូន និងការប្រើឱសថសម្រាប់បំលែងភេទ។ ពុំមានសេវាសុខភាពជាក់លាក់សម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នានោះទេ ហើយក៏គ្មានសេវាសុខភាពផ្លូវចិត្តសម្រាប់បុគ្គល LGBT ដែរ។
- **ប្រព័ន្ធផ្សព្វផ្សាយ រួមទាំង បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង៖** ប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជាបង្ហាញបុគ្គល LGBT ក្នុងន័យអវិជ្ជមាន ជាពិសេសមនុស្សស្រីប្តូរភេទ។ ពួកគេខ្វះខាតព័ត៌មាន និងការបណ្តុះបណ្តាលអំពីបញ្ហាសិទ្ធិមនុស្ស និង ទំនោផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រ។ ទោះបីជាយ៉ាងណាក្តី ការផលិតខ្សែភាពយន្ត LGBT ខ្លះៗនាពេលថ្មីៗនេះ គឺជាការវិវឌ្ឍវិជ្ជមានមួយ។ បុគ្គល LGBT វ័យក្មេងនៅកម្ពុជា ប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម និងបច្ចេកវិទ្យាប្រាស្រ័យទាក់ទងផ្សេងៗទៀតដើម្បីប្រាស្រ័យទាក់ទងជាមួយគ្នា និងចែករំលែកព័ត៌មាន។
- **បញ្ហាផ្សេងៗទៀត៖** អត្រាដ៏ខ្ពស់ (បើប្រៀបធៀបជាមួយប្រជាជនទូទៅ) នៃអំពើហិង្សាក្នុងគ្រួសារនិងផ្លូវភេទដែលជួបប្រទះដោយបុគ្គល LGBT គឺជាបញ្ហាដ៏ធំមួយ រួមទាំងអំពើហិង្សាក្នុងគ្រួសារដែលបង្កឡើងដោយសមាជិកគ្រួសារប្រឆាំងនឹងបុគ្គល LGBT។ របាយការណ៍មួយពីអង្គការ*សម្លេងយុវជនមានសារៈសំខាន់* បានឲ្យបង្ហាញពីការមាក់ងាយរើសអើងប្រឆាំងខ្លួនឯងក្នុងចំណោមមនុស្សប្រុសវ័យក្មេងដែលស្រឡាញ់ភេទប្រុសដូចគ្នា និងមនុស្សស្រីប្តូរភេទវ័យក្មេងនៅអាស៊ី។ កិច្ចពិភាក្សាក៏បានផ្តល់អនុសាសន៍ផងដែរឲ្យពិនិត្យមើលតម្រូវការរបស់បុគ្គល LGBT វ័យចំណាស់ ក៏ដូចជា ធ្វើការកត់ត្រាទុកនូវបទពិសោធន៍ក្នុងជីវិតរបស់បុគ្គល LGBT នៅកម្ពុជា ក៏ដូចជាយន្តការដោះស្រាយនិងគាំទ្ររបស់ពួកគេផងដែរ។

កិច្ចពិភាក្សាថ្នាក់ជាតិនេះ បានពិនិត្យមើលសមត្ថភាពស្ថាប័នរបស់អង្គការ LGBT កម្ពុជា។ កិច្ចការនេះរួមមាន ការពិនិត្យមើលឡើងលើឯកសារដែលមានស្រាប់ ដែលបានធ្វើឡើងដោយអង្គការ LGBT ចំនួន ១២អង្គការ និងការឆ្លើយតបតាមរយៈការអង្កេតលម្អិតដែលបានមកពីអង្គការចំនួន៨។ ក្នុងចំណោមផ្នែកសមត្ថភាពបួន អ្នកឆ្លើយតបនឹងការអង្កេតបានផ្តល់ចំណាត់ថ្នាក់លើសមត្ថភាពស្ថាប័នរបស់ពួកគេខ្ពស់បំផុត (៦.៦/១០) បន្ទាប់មកមាន ធនធានមនុស្ស (៥.៦/១០)។ រីឯធនធានហិរញ្ញវត្ថុត្រូវបានផ្តល់ចំណាត់ថ្នាក់ ៥/១០។ ពិន្ទុទាបបំផុតត្រូវបានផ្តល់ទៅលើសមត្ថភាពរបស់អង្គការ LGBT ក្នុងការសហការ និងកសាងសម្ព័ន្ធភាព (៣.៣/១០)។ អង្គការ LGBT មានភាពខុសគ្នាយ៉ាងខ្លាំងទាក់ទងទៅនឹងចំណុចផ្តោតរបស់ស្ថាប័ន និងសមត្ថភាពផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។

## អនុសាសន៍

របាយការណ៍នេះ បានផ្តល់អនុសាសន៍មួយចំនួន ដោយផ្អែកលើកិច្ចពិភាក្សានាឯកិច្ចពិភាក្សាថ្នាក់ជាតិ ក៏ដូចជាពីការស្រាវជ្រាវនៅមូលដ្ឋានជាក់ស្តែង។[2]

## កិច្ចការគ្រួសារ

- បុគ្គល LGBTត្រូវបានគេណែនាំអោយ"ស្គាល់ខ្លួនឯង និងយល់ពីសិទ្ធិផ្ទាល់របស់ខ្លួន។ ត្រូវប្រព្រឹត្តខ្លួនឲ្យល្អ ផ្តល់តម្លៃដល់ខ្លួនឯង និងរស់នៅក្នុងភាពថ្លៃថ្នូរក្នុងនាមជាមនុស្ស និងការប្រកបរបរចិញ្ចឹមជីវិត"។
- ពួកគេគួរប្រើប្រាស់មធ្យោបាយនានាដើម្បីស្វែងយល់ខ្លួនឯងជាបុគ្គល LGBT និងរិះរកមធ្យោបាយដើម្បីអប់រំគ្រួសាររបស់ពួកគេ ឧទាហរណ៍ ដូចជា ទៅរកអង្គការរ៉ុក (RoCK) ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលបានផលិតកូនសៀវភៅព័ត៌មានស្តីពី "ការបើកជំហាពីភេទរបស់ខ្លួន" និង "សំណួរដែលគេនិយមសួរញឹកញាប់អំពីបុគ្គលLGBT"។
- ពួកគេគួរតែស្វែងរកការជំនួយពីខាងក្រៅ ដូចជាក្រុមគាំទ្រ ជាពិសេស នៅពេលជួបប្រទះវិបត្តិ ឬបញ្ហា ដើម្បីនិយាយអំពីបញ្ហាជាមួយអ្នកដទៃទៀត និងជួយគ្នាទៅវិញទៅមក។
- អ្នកចូលរួមបានកត់សម្គាល់ថា នៅពេលពួកគេបានចាប់ផ្តើមរកប្រាក់បានខ្លះ និងជួយគ្រួសារ និងសហគមន៍ ក៏ដូចជាសង្គម ពេលនោះមានការទទួលស្គាល់កាន់តែច្រើនថែមទៀត។ បន្ទាប់មកពីគេអាចមានឥទ្ធិពល និងអំណាចកាន់តែច្រើននៅក្នុងគ្រួសារ។
- សមាជិកគ្រួសារគួរត្រូវបានអប់រំ និងបញ្ជ្រាបអំពីបញ្ហា និងផលប៉ះពាល់នៃការរើសអើសប្រឆាំងកូនរបស់ពួកគេដែលជាមនុស្ស LGBT រដ្ឋាភិបាលគួរតែពិនិត្យឡើង

[2] ឯកសារយោងសម្រាប់អនុសាសន៍នីមួយៗមានបង្ហាញនៅក្នុងផ្នែកពាក់ព័ន្ធនានានៅក្នុងរបាយការណ៍នេះ។

វិញលើច្បាប់ សារាចរ និងគោលនយោបាយរបស់ស្ថាប័នដើម្បីការពារមនុស្ស LGBT និងសិទ្ធិរបស់ពួកគេ។ កិច្ចការនេះអាចឡើងដោយមានការគាំទ្រពីក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងរដ្ឋសភាជាតិ។ អនុសាសន៍ជាក់លាក់រួមមាន៖

- ○ បន្ថែម ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ(SOGI) ជាក់លាក់ទៅលើបទប្បញ្ញត្តិ "ឋានៈដទៃទៀត" ដែលមានចែងនៅក្នុងបទប្បញ្ញត្តិរបស់រដ្ឋធម្មនុញ្ញកម្ពុជាទាក់ទងនឹងការមិនរើសអើង។ SOGI គួរត្រូវបានបង្ហាញជាក់លាក់ថាជាឋានៈមួយដែលគួរទទួលបានការការពារពីការរើសអើង។
- ○ បង្កើតច្បាប់ប្រឆាំងការរើសអើងមួយដែលចែងច្បាស់លាស់អំពីបុគ្គល LGBT ស្របតាមសំណើសុំធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញ។
- ○ ធ្វើវិសោធនកម្មច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ដើម្បីអនុញ្ញាតដល់ការរៀបការភេទដូចគ្នា។ ជាជម្រើសផ្សេងទៀត ធ្វើការផ្សព្វផ្សាយនៅគ្រប់កម្រិតអំពីនិរាករណ៍នៃច្បាប់អាពាហ៍ពិពាហ៍ឆ្នាំ១៩៨៩ ដោយជំនួសមកវិញនូវច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ដែលជំនួសឲ្យបទប្បញ្ញត្តិដែលហាមឃាត់ការរៀបការភេទដូចគ្នានៅក្នុងច្បាប់ឆ្នាំ១៩៨៩នេះ។

- ក្រសួង និងស្ថាប័នរដ្ឋទាំងអស់ គួរពិចារណាអំពីបញ្ហាដែលបុគ្គលកំពុងជួបប្រទះ LGBT ក៏ដូចជាដំណោះស្រាយ និងដាក់បញ្ចូលបញ្ហាទាំងនេះទៅក្នុងកម្មវិធីការងារ និងឯកសារគោលនយោបាយរបស់ខ្លួន។ ឧទាហរណ៍ ក្រសួងកិច្ចការនារី គួរបញ្ចូលបញ្ហាLGBT ទៅក្នុងផែនការសកម្មភាពជាតិរយៈពេល៥ឆ្នាំស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ (២០១៣-២០១៧) របស់ក្រសួងនេះ។
- អាជ្ញាធរមូលដ្ឋានគួរត្រូវបានជម្រាបប្រាប់អំពីបញ្ហា ឬផលប៉ះពាល់នៃការរើសអើងមកលើបុគ្គល LGBT ពីសំណាក់គ្រួសាររបស់ពួកគេ។ អាជ្ញាធរមូលដ្ឋានគួរសម្រុះសម្រួល និងណែនាំឪពុកម្តាយកុំឲ្យប្រើហិង្សាមកលើកូនរបស់ខ្លួនដែលជាមនុស្ស LGBT ព្រមទាំងផ្តល់យន្តការនានាដើម្បីការពារ ឬបញ្ឈប់អំពើហិង្សាក្នុងគ្រួសារដែលទាក់ទងនឹង SOGI។ ពួកគេគួរធ្វើអន្តរាគមន៍នៅពេលមានអំពើហិង្សាក្នុងគ្រួសារ ទាំងផ្លូវកាយទាំងផ្លូវចិត្ត ឬនៅពេលឪពុកម្តាយ និងបងប្អូនបង្ខំកូននិងសាច់ញាតិរបស់ពួកគេដែលជាមនុស្ស LGBT ឲ្យរៀបការមនុស្សដែលមានភេទផ្ទុយពីគ្នាប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។ មេឃុំមិនគួរចេញលិខិតអាពាហ៍ពិពាហ៍ដល់គ្រួសារណាដែលបង្ខំកូន LGBT របស់ខ្លួនឲ្យរៀបការនោះឡើយ។
- សង្គមស៊ីវិល គួរមានយន្តការដើម្បីផ្តល់ការអប់រំជាសាធារណៈអំពីផលប៉ះពាល់នៃអំពើហិង្សាដែលទាក់ទងនឹង SOGI ដែលបង្កឡើងដោយគ្រួសារប្រឆាំងនឹងសមាជិកគ្រួសាររបស់គេដែលជាមនុស្ស LGBT ។ ពួកគេគួរពិចារណារៀបចំក្រុមពិភាក្សាអំពីការទទួលយករបស់គ្រួសារ និងរៀបចំផែនការគម្រោងនានាដែលស្រដៀងគ្នាទៅនឹងអង្គការ *ឪពុកម្តាយ គ្រួសារ និងមិត្តភក្តិរបស់មនុស្សស្រីស្រឡាញ់*

*ភេទដូចគ្នា និងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា* (PFLAG) នៅក្នុងប្រទេសដទៃទៀតក្នុងតំបន់ដូចជា ចិន និងវៀតណាម ជាដើម។

- អង្គការសង្គមស៊ីវិលគួរប្រើវិធី និងមធ្យោបាយថ្មីៗ ដូចជា សិល្បៈ ភាពយន្ត និងតន្ត្រី ដើម្បីផ្សព្វផ្សាយអំពីសិទ្ធិរបស់ LGBT។ ឧទាហរណ៍រួមមាន ចម្រៀង "កំហុសអ្នកណា?" ដោយ ណយ ស៊ីថា ឬ គម្រោង "ក្រម៉ាឥន្ទធនូ " របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ដែលលក់ក្រម៉ាឥន្ទធនូ ដើម្បីទ្រទ្រង់ដល់សកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតរបស់ស្ត្រីក្រីក្រ ខណៈពេលជាមួយគ្នានោះផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីនិមិត្តសញ្ញា និងបញ្ហារបស់ LGBT ។
- ឯកសារច្បាប់នានា ដូចជាអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ឯកសារធ្វើដំណើរ និងប័ណ្ណក្រីក្រ[3] ដែលផ្តល់ដោយមន្ត្រីភូមិនៅមូលដ្ឋាន អាចជាបង្កឲ្យមានការលំបាកសម្រាប់ LGBT ឧទាហរណ៍នៅពេលឯកសារទាំងនេះមិនមានឆ្លុះបញ្ចាំងពីភេទរបស់បុគ្គលដែលបានជ្រើសរើសយក។ ភាគីពាក់ព័ន្ធគួរបង្ហាញ និងចែករំលែកជាមួយមន្ត្រីមូលដ្ឋានដទៃទៀតនៅថ្នាក់ឃុំ ស្រុក និងខេត្ត នូវការប្រតិបត្តិការនានាដែលទាក់ទងនឹងឯកសារច្បាប់ ដែលជំរុញការរាប់អានពីអ្នកដទៃក្នុងសង្គម។

## ការអប់រំ និងសាលារៀន

- ក្រសួងអប់រំ យុវជន និងកីឡា គួរដាក់បញ្ចូលសិទ្ធិមនុស្ស និងបញ្ហា SOGI ទៅក្នុងកម្មវិធីសិក្សា និងនៅក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយនៅពេលអនាគត។
- ក្រសួងអប់រំ យុវជន និងកីឡា គួរតែបង្កើតធនធានដែលទាក់ទងនឹង SOGI សម្រាប់គ្រូប្រើនៅក្នុងថ្នាក់រៀន។
- ក្រសួងអប់រំ យុវជន និងកីឡា គួរចាត់វិធានការដើម្បីលុបបំបាត់ការរើសអើងនៅក្នុងថ្នាក់រៀន។
- ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើការជាមួយអង្គការ UNESCO និងអង្គការសង្គមស៊ីវិល ដើម្បីចាប់ផ្តើមយុទ្ធនាការមួយប្រឆាំងនឹងការបន្លាចដែលទាក់ទងនឹង SOGI នៅក្នុងសាលារៀន ជាពិសេស នៅថ្នាក់មធ្យមសិក្សា និងដាក់ទណ្ឌកម្មដល់អ្នកដែលបន្លាច ឬរើសអើងប្រឆាំងនឹងបុគ្គល LGBT។ អង្គការ UNESCO មានឯកសារពាក់ព័ន្ធអំពីការបន្លាចក្នុងន័យស្អប់មនុស្សស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀន ដោយពិចារណាអំពីឧទាហរណ៍នៃការប្រតិបត្តិល្អៗនៅក្នុងប្រទេសផ្សេងៗទៀត ដើម្បីកាត់បន្ថយការបន្លាច។

[3] IDPoor គឺជាអក្សរកាត់មួយសម្រាប់កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដែលជាកម្មវិធីគាំពារសង្គមរបស់រដ្ឋាភិបាលមួយដែលធ្វើចំណាត់ថ្នាក់គ្រួសារយោងតាមកម្រិតនៃប្រាក់ចំណូល និងភាពក្រីក្រនៃធនធាន។ អ្នកដែលស្ថិតនៅក្នុងកម្រិតប្រាក់ចំណូលទាបត្រូវបានចាត់ទុកថាជាអាទិភាពសម្រាប់ទទួលបានការគាំទ្រឬជំនួយសង្គ្រោះបន្ទាន់ សេវាសង្គមនិងសុខភាព។ (កម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ក្រសួងផែនការ)

- ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តល់អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់សិស្ស LGBT ។
- សាលា និងសកលវិទ្យាល័យ គួរមានភាពទន់ភ្លន់នៅក្នុងការអនុវត្តគោលនយោបាយស្តីពីឯកសណ្ឋានសាលារៀន និងគួរតែអនុញ្ញាតឲ្យសិស្សពាក់សំលៀកបំពាក់ដែលពួកគេចង់ពាក់នៅពេលចូលរៀននៅក្នុងថ្នាក់។
- កម្មវិធីសិក្សារបស់សាលារៀនគួរតែដាក់បញ្ចូលការអប់រំអំពីសិទ្ធិមនុស្ស និងការយល់ដឹងអំពីស្ថានភាព និងបញ្ហាប្រឈមរបស់បុគ្គល និងធានាថា កម្មវិធីសិក្សាទាំងនេះពិចារណាអំពីជីវិតរបស់បុគ្គល LGBT ។
- រដ្ឋាភិបាលគួរ និងសង្គមស៊ីវិល គួរតែធ្វើការអង្កេតមួយដើម្បីកំណត់ពីវិសាលភាពនៃការបោះបង់ចោលការសិក្សារបស់យុវជន LGBT និងចាត់វិធានការដោះស្រាយដើម្បីទប់ស្កាត់ទំនោរនេះ។
- សាលារៀនរដ្ឋ និងឯកជន មិនគួរមានការរើសអើងនៅក្នុងការជួលមនុស្ស LGBT ឲ្យធ្វើការជាគ្រូបង្រៀននោះទេ ហើយគួរប្រើពួកគេជាជនគំរូសម្រាប់សិស្ស តាមការគួរ។
- អង្គការសហប្រជាជាតិគួរលើកទឹកចិត្តដល់ក្រសួងអប់រំ យុវជន និងកីឡា ឲ្យដាក់បញ្ចូលសិទ្ធិមនុស្ស និងបញ្ហា SOGI ទៅក្នុងប្រព័ន្ធអប់រំរបស់កម្ពុជា ដើម្បីទប់ស្កាត់ការរើសអើងដែលទាក់ទងនឹង SOGI។
- នៅក្នុងបរិបទអប់រំ និងសាលារៀន សមាជិកសហគមន៍ LGBT ត្រូវបានលើកទឹកចិត្តឲ្យព្យាយាមបើកចំហអំពីអត្តសញ្ញាណរបស់ពួកគេ និងនិយាយអំពីអារម្មណ៍ពិតពីធម្មជាតិរបស់ពួកគេអំពីការប្រតិព័ទ្ធភេទដូចគ្នា។ បញ្ហានេះគួរត្រូវធ្វើឡើងតែនៅពេលណាដែលពួកគេត្រៀមខ្លួនជាស្រេចប៉ុណ្ណោះ និងនៅពេលដែលពួកគេគិតថាវាមានសុវត្ថិភាពក្នុងការធ្វើបែបនេះ។

## មុខរបរ និងការងារ

- រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល គួរបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ថែមទៀតដែលបើកចំហសម្រាប់ទាំងអស់គ្នា រួមទាំងបុគ្គល LGBT ព្រមទាំងផ្តល់ជំនួយសម្រាប់បុគ្គល LGBT ដើម្បីស្វែងរកការងារធ្វើ។
- ក្រសួងពាក់ព័ន្ធ និងស្ថាប័នច្បាប់ ដូចជាក្រសួងការងារ ក្រសួងមហាផ្ទៃ គណៈរដ្ឋមន្ត្រី រដ្ឋសភាជាតិ និងព្រឹទ្ធសភា គួរបង្កើតគោលនយោបាយហាមឃាត់ការរើសអើងនៅទីកន្លែងធ្វើការ និងធ្វើវិសោធនកម្មច្បាប់ការងារ ដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិនានាដែលការពារបុគ្គល LGBT ពីការរើសអើងទាក់ទងនឹង SOGI។
- ក្រសួងការងារ គួរអនុវត្តយុទ្ធនាការមួយអំពីសិទ្ធិរបស់បុគ្គល LGBT នៅកន្លែងធ្វើការ ដើម្បីអប់រំអ្នកគ្រប់គ្រង និងបុគ្គលិកនៅក្នុងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នសាធារណៈ និងឯកជន ឲ្យយល់ពីសិទ្ធិស្មើភាពចំពោះការងារ និងបញ្ហា

SOGI; បញ្ឈប់ការរើសអើងនៅកន្លែងធ្វើការ ព្រមទាំងបង្កើតគោលនយោបាយប្រឆាំងការរើសអើងដែលស្រដៀងគ្នាទៅនឹងគោលនយោបាយដែលបានបង្កើតឡើងក្រោមច្បាប់ស្តីពីជំងឺអេដស៍ដែរ។

- អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលធ្វើការលើបញ្ហាមនុស្ស LGBT គួរតែពិចារណាជ្រើសរើសបុគ្គល LGBT មកធ្វើការជាមួយ នៅពេលអាចធ្វើបែបនេះបាន។
- និយោជកគួរគោរពសិទ្ធិរបស់ក្រុមភាគតិចនៃផ្លូវភេទនិងយេនឌ័រ ដោយប្រកាន់ខ្ជាប់នូវច្បាប់ការងារ និងច្បាប់ដែលពាក់ព័ន្ធដទៃទៀត ដែលការពារនិងលើកកម្ពស់សិទ្ធិរបស់បុគ្គល LGBT ក្នុងការធ្វើការងារ; ដាក់បញ្ចូលគោលការណ៍ SOGI ទៅក្នុងសកម្មភាពកាន់តែទូលំទូលាយ ជាមួយសមាគមនិយោជក និងនិយោជិត រួមទាំងធុរកិច្ច; និងអំពាវនាវដល់សហជីពឲ្យការពារសិទ្ធិរបស់កម្មករដែលជាមនុស្ស LGBT។
- សហគមន៍LGBT កម្ពុជា គួរធ្វើការខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួននិងសហគមន៍ ទាំងបុគ្គលនិងសមូហភាព តាមរយៈការធ្វើការងារជាកូនជាង និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ ការបណ្តុះបណ្តាលគួររួមបញ្ចូលជំនាញវិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ សិទ្ធិមនុស្ស និងការប្រាស្រ័យទាក់ទង។

## សហគមន៍ និងសង្គម

- រដ្ឋាភិបាលគួរបង្កើតច្បាប់នានា ដើម្បីការពារបុគ្គល LGBT ពីការរើសអើង ឬអំពើហិង្សា ទាំងផ្លូវកាយនិងផ្លូវចិត្ត យកចិត្តទុកដាក់ចំពោះមនុស្សទាំងអស់ស្មើគ្នានៅក្រមច្បាប់ និងដាក់ឲ្យអនុវត្តច្បាប់ប្រឆាំងបទឧក្រិដ្ឋនៃការស្អប់។
- រដ្ឋាភិបាលគួរធ្វើការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធ ទៅលើគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងវិធីដែលគេប្រើប្រាស់គោលនយោបាយនេះដើម្បីធ្វើបាបបុគ្គលLGBT ក្រោមលេសទប់ស្កាត់បទឧក្រិដ្ឋ។ វាមិនគួរស្ថិតនៅជាច្បាប់មួយក្រៅប្រព័ន្ធនោះឡើយ ប៉ុន្តែគួរតែត្រូវបានពិនិត្យឡើងវិញ ដើម្បីកុំឲ្យគេអាចប្រើដើម្បីរំលោភសិទ្ធិរបស់ LGBT ហើយបន្ទាប់មក អនុម័តជាច្បាប់ ដោយមានការណែនាំដល់មន្ត្រីអនុវត្តច្បាប់ និងសាធារណជនទូទៅ អំពីរបៀបប្រើច្បាប់នេះដោយសមស្របនោះ។
- ក្រសួងផែនការ និងអាជ្ញាធរមូលដ្ឋាន គួរពិនិត្យមើលការចេញប័ណ្ណ ដែលផ្តល់សិទ្ធិឲ្យអ្នកកាន់ទទួលបានសេវាសង្គម និងអត្តសញ្ញាណប័ណ្ណ ដោយសារវាទាក់ទងទៅនឹងបុគ្គល LGBT:
    - ក្រសួងផែនការ គួរធានាថា បុគ្គល LGBT មិនត្រូវបានគេផាត់ចេញពីការទទួលប័ណ្ណដែលពាក់ព័ន្ធ ដោយសារតែការរើសអើង ឬការមិនទទួលស្គាល់ដៃគូភេទដូចគ្នាឡើយ។

    - អាជ្ញាធរមូលដ្ឋានគួរផ្តល់អត្តសញ្ញាណប័ណ្ណដោយមានបញ្ជាក់ភេទដែលបុគ្គលចង់បាន មិនចាំបាច់តែភេទពីកំណើតនោះឡើយ។ គួរមានការស៊ើបអង្កេតបន្ថែមទៀតដើម្បីឲ្យស្គាល់អ្នកដែលមានសិទ្ធិចេញ និងផ្លាស់ប្តូរអត្តញ្ញាណប័ណ្ណ។
- ក្រសួងសង្គមកិច្ចគួរអនុញ្ញាតជាផ្លូវការឲ្យបុគ្គល LGBT សុំកូនគេចិញ្ចឹម។
- ភាគីពាក់ព័ន្ធទាំងអស់ គួរអប់រំផ្សព្វផ្សាយនៅក្នុងគ្រួសារ សាលារៀន មន្ទីរពេទ្យ និងទីសាធារណៈនានា អំពីសិទ្ធិមនុស្ស ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ កម្មវិធីសម្ភាសន៍តាម វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព/ឌីជីថល) សិល្បៈ និងសកម្មភាពវប្បធម៌នានា សំដៅលុបបំបាត់ការរើសអើង។
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ គួរតែបណ្តុះបណ្តាលសកម្មជនអំពីសិទ្ធិរបស់បុគ្គល LGBT, បញ្ហា SOGI និងអំពីការតស៊ូមតិនិងការគាំទ្រផ្នែកច្បាប់ ក៏ដូចជាផ្តល់សេវាច្បាប់ និងប្រឹក្សាយោបល់ដែលសមស្របចំពោះស្ថានភាពរបស់បុគ្គល LGBT។
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ គួរប្រើប្រាស់និងផ្សព្វផ្សាយបន្ថែមទៀតនូវធនធានដែលមានស្រាប់អំពីការប្រឆាំងនឹងការមាក់ងាយ ដូចជាឯកសារជំនួយស្មារតីស្តីពីការប្រឆាំងនឹងការមាក់ងាយជាភាសាខ្មែរសម្រាប់បុរសដែលរួមភេទជាមួយបុរសនិងមនុស្សប្តូរភេទ ដែលបានបង្កើតឡើងដោយអង្គការទីភ្នាក់ងារឯកជនសហការរួមគ្នា (PACT) និងក្រុមប្រឹក្សាអន្តរជាតិស្តីពីការស្រាវជ្រាវសម្រាប់ស្ត្រី (ICFRW); គោលការណ៍យ៉កយ៉ាក៌ាតា; គម្រោង "ក្រម៉ាឥន្ទធនូ"; កូនសៀវភៅព័ត៌មានអំពី "ការបើកជំហាពីភេទរបស់ខ្លួន" និង "សំណួរដែលគេចូលចិត្តសួរញឹកញាប់អំពីបុគ្គលLGBT" ផលិតដោយអង្គការ RoCK, និងព័ត៌មានសង្ខេបអំពី SOGI និងសិទ្ធិមនុស្សដែលផលិតឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។
- រដ្ឋាភិបាល និងសង្គម គួរតែគាំទ្រដល់អង្គការនៅសហគមន៍ដែលផ្តោតជាក់លាក់លើ LGBT និងក្រុមគាំទ្រក្រៅប្រព័ន្ធនានា ដូចជាសមាគមមិត្តភក្តិ ឪពុកម្តាយ វត្តអារ៉ាម និងព្រះសង្ឃ។ ក្រុមជួយខ្លួនឯងគួរត្រូវបានលើកទឹកចិត្តផងដែរ។
- យន្តការគាំទ្រសហគមន៍មូលដ្ឋាន (ឧទា. សមាគមសន្សំប្រាក់ ជំនួយសម្រាប់បុណ្យសព បុណ្យសហគមន៍ និងការរៀបចំប្រារព្ធថ្ងៃបុណ្យជាតិ យន្តការធ្វើការសម្រេចចិត្តថ្នាក់ភូមិ) គួរតែរួមបញ្ចូល និងទទួលយកបុគ្គល LGBT ឲ្យបានកាន់តែច្រើន។

## សុខភាព រួមទាំង មេរោគអេដស៍/ជំងឺអេដស៍

- ចាំបាច់ត្រូវធ្វើការវាយតម្លៃលើសុខភាពរបស់ មនុស្សLGBT រួមទាំងការអនុវត្តន៍ និងឥរិយាបថស្វែងរកការថែទាំសុខភាពផងដែរ។
- ក្រសួងសុខាភិបាល, អង្គការក្រៅរដ្ឋាភិបាល LGBT និងអ្នកផ្តល់សេវាសុខភាព (រួមទាំងអ្នកដែលធ្វើការជាមួយមេរោគអេដស៍/ជំងឺអេដស៍ផងដែរ) គួរផ្តល់ព័ត៌មាននិងការបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាអំពីបញ្ហារបស់ LGBT, SOGI និងការយល់ដឹងអំពីយេនឌ័រ។
- គួរតែមានការផ្តល់ប្រឹក្សា សម្រាប់បុគ្គល LGBT ដែលមានបញ្ហាផ្លូវចិត្ត ឬបញ្ហាសុខភាពផ្លូវចិត្តផ្សេងៗ ក៏ដូចជាសមាជិកគ្រួសាររបស់បុគ្គល LGBT; អ្នកដែលផ្តល់ប្រឹក្សាត្រូវការការបណ្តុះបណ្តាលនិងជំនាញដើម្បីផ្តល់សេវាប្រឹក្សាបានសមស្របដល់បុគ្គល LGBT។
- អ្នកផ្តល់ប្រឹក្សាអំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងអ្នកផ្តល់ប្រឹក្សាខាងសុខភាពផ្លូវចិត្ត គួរផ្តល់ព័ត៌មានដែលមានតុល្យភាពនិងទូលំទូលាយអំពីបញ្ហានិងកង្វល់របស់ LGBT។ អ្នកផ្តល់សេវាបែបនេះមិនគួរគ្រាន់តែផ្តល់ដំបូន្មាន "ធ្វើតាមឪពុកម្តាយរបស់អ្នក" នោះឡើយ។ពួកគេត្រូវតែផ្តល់នូវជម្រើសឲ្យបានច្រើនដល់អតិថិជន។
- គេចាំបាច់ត្រូវប្រើសេវាប្រឹក្សាយោបល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនិងអនឡាញ ឲ្យបានកាន់តែច្រើនថែមទៀត; ទំហំនិងវិសាលភាពនៃគំនិតផ្តួចផ្តើមទាំងនេះគួរត្រូវបានពង្រីកឲ្យកាន់តែធំ។
- អ្នកផ្តល់សេវាថែទាំសុខភាព និងមនុស្សប្តូរភេទ ត្រូវពិភាក្សា និងស្វែងយល់អំពីបញ្ហា និងផលរំខាននៃការប្រើឱសថផ្សេងៗ។ ឱសថទាំងនេះរួមមាន ថ្នាំគ្រាប់ការពារកំណើតប្រភេទផ្សេងៗ និងសារធាតុបន្ថែមនិងឱសថដទៃទៀត សារធាតុដែលធ្វើឲ្យស្បែកស ការចាក់ថ្នាំស៊ីលីកូន និងសារធាតុដទៃទៀតដូចជា អ័រម៉ូនដែលប្រើសម្រាប់ធ្វើឲ្យខ្លួនមានលក្ខណៈជាមនុស្សស្រីឬមនុស្សប្រុស។
- អ្នកផ្តល់សេវាសុខភាពនិងសេវាមេរោគអេដស៍ គួរតែពិចារណាអនុសាសន៍បន្ថែមខាងក្រោមនេះ ពី*ប័ណ្ណរាយការណ៍ស្តីពីការបង្ការមេរោគអេដស៍*សម្រាប់បុរសដែលរួមភេទជាមួយបុរស និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា៖
  - ស្វែងរកវិធីបង្កើនសេវាឲ្យបានច្រើនថែមទៀតនៅឯគ្លីនិកសុខភាពផ្លូវភេទ និងសុខភាពគ្រួសារ ដោយដាក់បញ្ចូលការពិនិត្យរោគស្ត្រី និងរន្ធគូថ ការចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ សេវាកាត់បន្ថយគ្រោះថ្នាក់ និងបញ្ហាសុខភាពពាក់ព័ន្ធផ្សេងៗទៀតរបស់បុគ្គល LGBT។
  - ពង្រីកការផ្តល់សេវាសុខភាព រួមទាំង គ្លីនិក LGBT, ការបង្ការវិជ្ជមានសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍, គ្លីនិកចល័ត, ការផ្តល់ប្រឹក្សាអំពីក្តីកង្វល់ SOGI, និងការដាក់បញ្ចូលជាមួយសេវាដែលមានស្រាប់។

- បណ្តុះបណ្តាលបុគ្គលិកគ្លីនិកទាំងអស់ (អ្នកផ្តល់សេវា អ្នកទទួលភ្ញៀវ អ្នកយាម បុគ្គលិកមន្ទីរពិសោធន៍) អំពីយេនឌ័រ និងការមិនរើសអើងប្រឆាំងទំនាក់ទំនងរវាងបុគ្គល LGBT និងអតិថិជនរបស់ពួកគេ។
- បណ្តុះបណ្តាលអ្នកផ្តល់សេវាថែទាំសុខភាព (វេជ្ជបណ្ឌិត គិលានុបដ្ឋាក គ្រូពេទ្យមធ្យម) អំពីបញ្ហាសុខភាពរបស់ LGBT, បង្កើតភាពស្និទ្ធស្នាល ធ្វើការពិនិត្យសុដន់ ប្រដាប់បន្តពូជ និងរន្ធគូថ និងពិនិត្យសុខភាពទាំងមូល។
- ធានាថាម៉ោងធ្វើការរបស់គ្លីនិកមានភាពងាយស្រួលរបស់បុគ្គល LGBT ជាពិសេសសម្រាប់អ្នកដែលធ្វើការពេលយប់នៅក្នុងឧស្សាហកម្មផ្លូវភេទ។
- ដាក់បញ្ចូលបុគ្គល LGBT ជាមនុស្សធនធាន សម្រាប់ការបណ្តុះបណ្តាលអ្នកផ្តល់សេវាថែទាំសុខភាព។
- ដាក់បញ្ចូលបុរសដែលរួមភេទជាមួយបុរស និងមនុស្សប្តូរភេទ នៅក្នុងការតាមដានមេរោគអេដស៍ជាទៀងទាត់ និងបញ្ចេញលទ្ធផលទាន់ពេលវេលាដើម្បីប្រើប្រាស់សម្រាប់តាក់តែងកម្មវិធី និងអន្តរាគមន៍។
- បុគ្គល LGBT គួរតែចូលរួមនៅក្នុងការវាយតម្លៃសេវាសុខភាព និងការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ដោយយកគំរូតាមគ្លីនិកនានា ដូចជាគ្លីនិកអង្គការរ៉ាក់ (RHAC)។

## ប្រព័ន្ធផ្សព្វផ្សាយ (រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងប្រាស្រ័យទាក់ទង)

- ក្រសួងព័ត៌មាន គួរអនុម័តច្បាប់/បទបញ្ញានានាដើម្បីការពារបុគ្គល LGBT ពីការរើសអើង និងការបែងចែកវណ្ណៈ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។
- ប្រព័ន្ធផ្សព្វផ្សាយគួរគោរពតាមក្រមសីលធម៌របស់ខ្លួន និងត្រូវផ្អែកលើភាពពិតជាក់ស្តែង និងមានតុល្យភាពនៅក្នុងការបង្ហាញព័ត៌មានអំពីបុគ្គល LGBT ។
- គេចាំបាច់ត្រូវអនុវត្តសកម្មភាពផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស SOGI និង មនុស្សLGBT ជាពិសេស សម្រាប់អ្នកសារព័ត៌មានខ្មែរនៅក្នុងស្រុក។
- បុគ្គល LGBT គួរតែចូលរួមឲ្យបានកាន់តែច្រើននៅក្នុងសកម្មភាពប្រព័ន្ធផ្សព្វផ្សាយដើម្បីចែករំលែករឿងរ៉ាវអំពីជីវិត ក៏ដូចជារឿងនិទានជោគជ័យរបស់ពួកគេ។ បុគ្គល LGBT ដែលទទួលបានជោគជ័យ គួរត្រូវបានរំលេចដើម្បីឲ្យសង្គមអាចទទួលបានទស្សនៈវិជ្ជមានអំពីបុគ្គល LGBT ។
- ការបណ្តុះបណ្តាលគួរត្រូវបានផ្តល់ដល់បុគ្គល LGBT និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ អំពីរបៀបដោះស្រាយបញ្ហានៃការរាយការណ៍អវិជ្ជមាននិងមិនពិត នៅតាមប្រព័ន្ធផ្សព្វផ្សាយអំពី LGBT នៅកម្ពុជា (ឧទា. តាមរយៈការផ្ញើលិខិតទៅកាន់អ្នករៀបរៀង ឯកសារគោលជំហរ ឬអត្ថបទពិសេសនានា)។
- អង្គការក្រៅរដ្ឋាភិបាល អង្គការនៅសហគមន៍ និងបុគ្គល LGBT គួរបង្កើតគេហទំព័រ និងចូលរួមជាមួយក្រុមបណ្តាញសង្គម ដើម្បីផ្តល់ព័ត៌មានចាប់អារម្មណ៍ មានសារៈ

ប្រយោជន៍ និងមានតុល្យភាព អំពីបញ្ហាផ្លូវភេទ បំណិនជីវិត និងជីវិតពិតរបស់ LGBT ។

- គម្រោងផ្តល់រង្វាន់និងការទទួលស្គាល់ គួរត្រូវបានផ្តល់ដល់អង្គការនិងបុគ្គលដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលមានស្នាដៃការងារល្អក្នុងការបង្ហាញបុគ្គល LGBT ជាមនុស្សជាតិ ឬក្នុងការរួមចំណែកកាត់បន្ថយការរើសអើសនៅក្នុងអង្គការនិងអត្ថបទបោះពុម្ពផ្សាយរបស់ពួកគេ។

# សេចក្តីផ្តើម

មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ(LGBT) នៅក្នុងពិភពលោក នៅតែជួបប្រទះបញ្ហាប្រឈមជាច្រើន។ ឧទាហរណ៍ រួមមាន កង្វះខាតឱកាសការងារ[4], និងមានការរើសអើងនៅក្នុងទៅរកសេវាថែទាំសុខភាព[5], លំនៅស្ថាន[6] និងការអប់រំ[7]។ នៅក្នុងករណីផ្សេងទៀត "ការរំលោភសេពសន្ថវៈដើម្បីកែប្រែ" ត្រូវបានគេប្រព្រឹត្តប្រឆាំងនឹងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា[8], ខណៈពេលដែលការសម្លាប់សមាជិករបស់សហាគមន៍ LGBT នៅតែបន្តនៅក្នុងប្រទេសជាច្រើនទោះបីជាមានការអំពាវនាវកាន់តែច្រើនថែមទៀតឲ្យមានសមភាព និងសេរីភាពរួចផុតពីការរើសអើងគ្រប់ទម្រង់ និងការជិះជាន់។ អង្គការមនុស្សប្តូរភេទនៅអឺរ៉ុប បានរាយការណ៍ក្នុងឆ្នាំ២០១២ ថាមនុស្សប្តូរភេទចំនួន ១០៨៣នាក់ បានក្លាយជាជនរងគ្រោះដោយការសម្លាប់ ពីឆ្នាំ២០០៨ ដល់ ២០១២។

នៅក្នុងឆ្នាំ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (UNHRC) បានអនុម័តសេចក្តីសម្រេចចិត្តលេខ 17/19, ដែលបានត្រួសត្រាយផ្លូវដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីចេញរបាយការណ៍របស់អង្គការសហប្រជាជាតិលើកទីមួយស្តីពីសិទ្ធិមនុស្ស និងទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រ (SOGI)។ នៅក្នុងរបាយការណ៍នេះ ភ័ស្តុតាងនៃការរើសអើងដែលមនុស្សខ្លះប្រឈមមុខដោយសារតែទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់ពួកគេ ត្រូវបានបង្ហាញដោយរួមបញ្ចូលទាំងវិសមភាពនៅក្នុងការងារនិងមុខរបរ ការទទួលបាន ការព្យាបាល ការថែទាំ និងការគាំទ្រ និងការអប់រំ ក៏ដូចជា ការដាក់ទោសឧក្រិដ្ឋ អំពើហិង្សាផ្លូវកាយ និងការ

---

[4] Sears, B. & Mallory, C. (2011). ភ័ស្តុតាងជាឯកសារនៃការរើសអើងក្នុងការងារ និងផលប៉ះពាល់របស់វាមកលើបុគ្គល LGBT។ វិទ្យាស្ថានវីលាម. ទាញចេញនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ពីគេហទំព័រ
http://williamsinstitute.law.ucla.edu/wp-content/ uploads/Sears-Mallory-Discrimination-July-20111.pdf

[5] Winter, C. (2012) ឆ្លើយតបនឹងអយុត្តភាពសុខភាពរបស់ LGBT ។ Ryan Barker & Thomas McAuliffe (Eds.). មូលនិធិមីស្សួរីសម្រាប់សុខភាព។ ទាញចេញថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ពីគេហទំព័រ
http://www.mffh.org/mm/files/LGBTHealthEquityReport.pdf

[6] Grant, J. M., Mottet, L. A., Tanis, J. et al. (2011) អយុត្តិធម៌នៅរាល់ពេលផ្លាស់ប្តូរ: របាយការណ៍ពីការអង្កេតជាតិស្តីពីការរើសអើងប្រឆាំងមនុស្សប្តូរភេទ។ វ៉ាស៊ីនតោន៖ មជ្ឈមណ្ឌលជាតិសម្រាប់សមភាពមនុស្សប្តូរភេទ និងក្រុមការងារជាតិនៃមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា។ ទាញចេញពីគេហទំព័រ
www.thetaskforce.org/downloads/reports/reports/ntds_full.pdf

[7] Burns, C. (2011). ទំព័រពិត : ការរើសអើងប្រឆាំងបុគ្គល LGBT នៅក្នុងជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់កម្រិតឧត្តមសិក្សា។ មជ្ឈមណ្ឌលសម្រាប់វឌ្ឍនភាពអាមេរិក ។ ទាញចេញថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ ពីគេហទំព័រ
http://www.americanprogress.org/wp-content/uploads/issues/2011/08/pdf/ lgbt_factsheet.pdf.

[8] Brown, R. (2012). ការរំលោភសេពសន្ថវៈដើម្បីកែប្រែនៅក្នុងទ្វីបអាហ្វ្រិកខាងត្បូង: ទុក្ខវេទនានៅតែបន្តទោះបីជាមានការឆ្លើយតបចំពោះសិទ្ធិមនុស្សអន្តរជាតិ។ ការអង្កេតប្រចាំឆ្នាំ២០១២នៃច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀប (Spring, 2012). សកលវិទ្យាល័យច្បាប់ហ្គោលដិនហ្គេត

សម្លាប់[9]។ ឧត្តមស្នងការ ណាវី ភីឡាយ បានស្នើឲ្យរដ្ឋជាសមាជិកអង្គការសហប្រជាជាតិជួយសរសេរជំពូកថ្មីមួយនៅក្នុងប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិ ដោយបញ្ចប់ការរើសអើងដែលបុគ្គល LGBT ប្រឈមមុខ។ ការអំពាវនាវនេះត្រូវបានបន្ទរឡើងវិញនៅក្នុងសុន្ទរកថាមួយដែលថ្លែងនៅក្នុងខែធ្នូ ឆ្នាំ២០១១ ដោយអតីតរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ហ៊ីឡារី គ្លីនតុន ស្តីពីសិទ្ធិរបស់មនុស្ស LGBT នៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ។ ដូចដែលលោកស្រី គ្លីនតុន បានគូសបញ្ជាក់ស្រាប់ បុគ្គល LGBT គឺជា "ក្រុមភាគតិចដែលគេមើលមិនឃើញ" ដែលត្រូវបានគេចាប់ខ្លួន វាយដំ បំផិតបំភ័យ ហើយថែមទៀតប្រហារជីវិតទៀតផង។ បុគ្គល LGBT ជាច្រើន "ត្រូវបានប្រមាថមើលងាយ និងប្រើហឹង្សាដោយប្រជាពលរដ្ឋដទៃទៀត ខណៈពេលដែលអាជ្ញាធរដែលមានសមត្ថកិច្ចការពារពួកគេមិនយកចិត្តទុកដាក់ ឬជាញឹកញាប់ថែមទៀតចូលរួមក្នុងការរំលោភបំពាននោះទៀតផង"។ ឧទាហរណ៍ នៅក្នុងឆ្នាំ២០០៩ ច្បាប់មួយត្រូវបានគេដាក់ឲ្យអនុវត្តនៅក្នុងប្រទេសអ៊ូហ្គាន់ដាដែលទាមទារឲ្យមានទោសដាក់ពន្ធនាគារមួយជីវិតចំពោះបទល្មើសស្រឡាញ់ភេទដូចគ្នា។ បន្ទាប់ពីមានការពន្យារពេលយ៉ាងយូរមក ជាការគួរឲ្យក្រៀមក្រំ នៅក្នុងខែធ្នូ ឆ្នាំ២០១៣ ច្បាប់ប្រឆាំងការស្រឡាញ់ភេទដូចគ្នាឆ្នាំ២០១៤របស់ប្រទេសអ៊ូហ្គាន់ដា ត្រូវបានអនុម័តដោយរដ្ឋសភា និងចុះហត្ថលេខាជាច្បាប់ដោយប្រធានាធិបតី នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤។ ទំនាក់ទំនងភេទដូចគ្នា និងអាពាហ៍ពិពាហ៍ អាចត្រូវបានដាក់ទោសដោយជាប់ពន្ធនាគារមួយជីវិត សូម្បីតែ "ការផ្សព្វផ្សាយ" អំពីការស្រឡាញ់ភេទដូចគ្នា ក៏ត្រូវបានដាក់ទោសឲ្យជាប់ពន្ធនាគារដែរ។ ទន្ទឹមគ្នានឹងនោះ នៅក្នុងខែមិថុនា ឆ្នាំ២០១៣ ច្បាប់មួយត្រូវបានអនុម័តនៅក្នុងប្រទេសរុស្ស៊ី ដោយមានបទប្បញ្ញត្តិហាមឃាត់ "ការឃោសនាអំពីទំនាក់ទំនងផ្លូវភេទខុសពីប្រពៃណីក្នុងចំណោមអនីតិជន" ដោយមានដាក់ពិន័យចំពោះការផ្តល់ព័ត៌មានអំពីការស្រឡាញ់ភេទដូចគ្នាដល់មនុស្សអាយុក្រោម ១៨ឆ្នាំ ពី ៤០០០រូប៊ិល (១២១ដុល្លារអាមេរិក) ចំពោះបុគ្គល ដល់ ១លានរូប៊ិល សម្រាប់អង្គការឬស្ថាប័ន។[10] ថ្មីៗនេះ នៅក្នុងខែធ្នូ ឆ្នាំ២០១៣ ប្រទេសឥណ្ឌា បានដាក់ជាទោសឧក្រិដ្ឋឡើងវិញដល់ការស្រឡាញ់ភេទដូចគ្នាក្រោមផ្នែកទី ៣៧៧ នៃក្រមព្រហ្មទណ្ឌឥណ្ឌា ដែលបានបង្កើតឡើងតាំងពីឆ្នាំ១៨៦១។ រហូតមកទល់ពេលនេះ ប្រទេសនិងទឹកដីចំនួន ៨៣ នៅតែដាក់ទោសឧក្រិដ្ឋដល់ឥរិយាបថមនុស្ស LGBT; ប្រទេសចំនួន៧ មានទោសប្រហារជីវិតចំពោះទំនាក់ទំនងភេទដូចគ្នា; ប្រទេសតិចជាង ៥០ ប្រទេស ដាក់ទណ្ឌកម្មដល់ការរើសអើងប្រឆាំងប្រុសស្រឡាញ់ប្រុស

---

[9] ការិយាល័យឧត្តមស្នងការ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) (2011), "ច្បាប់និងការប្រតិបត្តិរើសអើង និងអំពើហិង្សាប្រឆាំងបុគ្គលដោយផ្អែកលើទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ", របាយការណ៍ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ទាញចេញថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ពីគហទំព័រ
http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/ Session19/A-HRC-19-41_en.pdf.

[10] BBC (2013) Q&A: សិទ្ធិរបស់មនុស្សប្រុសស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសរុស្ស៊ី (ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣)។ ទាញចេញថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ ពីគេហទំព័រ http://www.bbc.co.uk/news/ world-europe-23604142

ដូចគ្នាទាំងស្រុង ឬដោយផ្នែក; ហើយមានតែ ១៩ប្រទេសប៉ុណ្ណោះ ដែលហាមឃាត់ការរើសអើងទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ។[11] [12]

មេដឹកនាំពិភពលោកកំពុងតែចាត់វិធានការដើម្បីប្រយុទ្ធនឹងការមាក់ងាយ ការរើសអើង និងការរំលោភសិទ្ធិមនុស្សប្រឆាំងបុគ្គល *LGBT*។ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ ប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា បានចេញអនុស្សរណៈមួយស្តីពីគំនិតផ្តួចផ្តើមអន្តរជាតិដើម្បីលើកកម្ពស់សិទ្ធិមនុស្សរបស់បុគ្គល LGBT។ អនុស្សរណៈនេះបានណែនាំឲ្យស្ថាប័នទាំងអស់នៅក្រៅប្រទេសឲ្យធានាថា ការទូតនិងជំនួយបរទេសរបស់សហរដ្ឋអាមេរិក លើកកម្ពស់ និងការពារសិទ្ធិមនុស្សរបស់បុគ្គល *LGBT*។ នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន បានថ្លែងសារមួយនៅក្នុងអំឡុងកិច្ចប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីអំពើហិង្សានិងការរើសអើងទាក់ទងនឹង SOGI។ ដោយកត់សម្គាល់ពីលំនាំនៃអំពើហិង្សានិងការរើសអើងសំដៅលើមនុស្សដោយសារតែទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ លោកបានមានប្រសាសន៍ថា ៉នេះគឺជាសោកនាដកម្មដ៏ធំសម្បើមមួយសម្រាប់អ្នកដែលប៉ះពាល់ និងជាស្នាមប្រឡាក់មួយមកលើមនសិការរួមរបស់យើង។ វាក៏ជាការរំលោភលើច្បាប់អន្តរជាតិផងដែរ៉។ លោកបានបន្តថា ៉ពេលវេលាបានមកដល់ហើយ៉ដើម្បីចាត់វិធានការ។

## ប្រវត្តិដើមនៃការតស៊ូមតិសម្រាប់ មនុស្សLGBT នៅក្នុងប្រទេសកម្ពុជា

### *ប្រវត្តិដើមមិនពេញលេញ*

ការពិភាក្សានៅក្នុងប្រទេសកម្ពុជា ដូចជានៅក្នុងប្រទេសភាគច្រើនដែរ គឺឆ្លុះបញ្ចាំងពីប្រវត្តិដើមមួយនៃមនុស្សដែលមិនអនុលោមតាមសញ្ញាណជាប្រពៃណីនៃទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ ការពិពណ៌នាមួយដែលបានសរសេរឡើងដោយអ្នកការទូតចិនគោចរម្នាក់នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ១២៩៦ កាលពីជាង៧០០ឆ្នាំមុន រៀបរាប់អំពីបុរសដែល

[11] ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ. (n.d.) ភាពជាដៃគូសម្រាប់ការអភិវឌ្ឍទូទាំងសកលលោក នៃ LGBT: ការលើកកម្ពស់ការអភិវឌ្ឍរួបញ្ចូលគ្នាសម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរ ភេទ។ ទាញចេញថ្ងៃទី២០ ខែសីហា ២០១៣ ពី http://www.usaid.gov/sites/default/files/documents/2496/USAID%20Fact%20Sheet%20LGBT%20Global%20Partnership.pdf

[12] សមាគមមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ (ILGA) (2014) ការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នាដោយមានការឧបត្ថម្ភដោយរដ្ឋ : ការអង្កេតច្បាប់ទូទាំងពិភពលោក: ឧក្រិដ្ឋនីយកម្ម (ការដាក់ជាទោសឧក្រិដ្ឋ), កិច្ចការពារ និងការទទួលស្គាល់ស្នេហាភេទដូចគ្នា។ Itaborahy and Zhu. បោះពុម្ពលើកទី៩ ខែឧសភា ឆ្នាំ២០១៤។ ទាញចេញថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ពីគេហទំព័រ http://old.ilga.org/Statehomophobia/ILGA_SSHR_2014_Eng.pdf

ស្លៀកពាក់សំលៀកបំពាក់ស្ត្រីនៅក្នុងសម័យកាលអង្គរវត្ត។[13] ជូ តាគ័ន (Chou Ta-kuan) (ត្រូវបានគេសរសេរផងដែរជា Zhou Daguan) បានសរសេរថា, *"...នៅក្នុងប្រទេសនេះមានដៃគូក្មេងៗរបស់មនុស្សប្រុសស្រឡាញ់ប្រុសដូចគ្នាជាច្រើនដែលដើរលេងទៅមកនៅក្នុងផ្សារ ជាក្រុមដែលមានគ្នាដប់នាក់ឬច្រើនជាងនេះ។ ពួកគេតែងតែព្យាយាមទាក់ទាញបុរសចិនដើម្បីបានកាដូដ៏អស្ចារ្យ... វាគួរឲ្យអាម៉ាស់ អាក្រក់ណាស់..."*

អាចមានឯកសារបន្ថែមទៀតអំពីកម្ពុជា ដែលនិយាយអំពីការទាញ់ទាញ ឥរិយាបថ និងទំនាក់ទំនងរវាងភេទដូចគ្នាពីសម័យអង្គរ រហូតដល់ទសវត្សរ៍៥០។ ទោះបីជាយ៉ាងណាក្តី ឯកសារភាគច្រើនត្រូវបានបំផ្លាញនៅក្នុងអំឡុងឆ្នាំមានជម្លោះក្នុងប្រទេសកម្ពុជាពីទសវត្សរ៍ ១៩៧០ ដល់ពាក់កណ្តាលទសវត្សរ៍៩០។ នៅក្នុងអំឡុងសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ប្រទេសនេះស្ថិតក្នុងស្ថានភាពរឹករវ មនុស្សប្រមាណមួយភាគបួនរបស់ប្រទេសនេះបានស្លាប់បាត់បង់ជីវិត ហើយប្រជាពលរដ្ឋភាគច្រើនត្រូវបានជម្លៀសចេញទៅកាន់តំបន់ផ្សេងៗនៅក្នុងប្រទេស។ ប្រព័ន្ធគ្រួសារ សាលារៀន វិជ្ជាជីវៈ សាសនា និងប្រព័ន្ធវប្បធម៌និងសេដ្ឋកិច្ច ត្រូវបានបំផ្លាញខ្ទេចខ្ទី ហើយប្រវត្តិសាស្ត្រ និងអក្សរសាស្ត្រក៏ត្រូវបានបំផ្លាញអស់ដែរ។

ឯកលេខនា "ជាតិពន្ធុសាស្ត្រនៃទំនាក់ទំនងផ្លូវភេទរវាងបុរសនិងបុរសនៅក្នុងប្រទេសកម្ពុជា" នៅក្នុងចំណោមការសិក្សានិងការអង្កេតដទៃទៀត រៀបរាប់អំពីបំណងស្រឡាញ់ភេទដូចគ្នា និងបទពិសោធន៍រវាងបុរសនៅក្នុងប្រទេសកម្ពុជា ពីទសវត្សរ៍១៩៥០មក។ [14] កាសែតភាសាអង់គ្លេសក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា បានបោះពុម្ពអត្ថបទជាច្រើននៅពេលនោះអំពីក្នុងភាពជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ឬ "អ្នកប្លែងភេទ" នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជាក្នុងទសវត្សរ៍១៩៥០ និង ១៩៧០។[15] ទោះបីជាប្រវត្តិសាស្ត្រនេះមានលក្ខណៈមិនពេញលេញក្តី វាជាការច្បាស់ណាស់ដែលថា ទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រចម្រុះនៅក្នុងបរិបទកម្ពុជា មិនមែនជាតក្កកម្មបស្ចឹមប្រទេសនោះឡើយ។

---

[13]Daguan, Zhou (AKA Chou Ta-kuan) (1296) *ប្រពៃណីរបស់កម្ពុជា*. រៀបរៀង និងបកប្រែថ្មីចេញពីភាសាបារាំងដោយ Michael Smithies. The Siam Society, Bangkok, 2006. លោក Smithies ប្រើពាក្យ "មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា" ប៉ុន្តែការបកប្រែផ្សេងៗទៀត (ពីភាសាដើមចិន ឬការបកប្រែជាភាសាបារាំងដទៃទៀត ដូចជារបស់ Pelliot និង Paul, ពីឆ្នាំ១៩៨៧ ដល់ ១៩៩២ ប្រើពាក្យ "ដៃគូរួមភេទរបស់មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា"។

[14] Tan, Phong (2008) "ជាតិពន្ធុសាស្ត្រនៃសកម្មភាពផ្លូវភេទរវាងបុរសនិងបុរសនៅក្នុងប្រទេសកម្ពុជា" កម្មវិធីមេរោគអេដស៍/ជំងឺអេដស៍របស់ UNESCO ភ្នំពេញ. ទំព័រ ៤៩-៨៣. ការសិក្សាដទៃទៀតរួមមាន Catalla, Sovanara & Van Mourik (2003) "ចេញពីស្រមោល" ឥរិយាបថផ្លូវភេទរវាងបុរសនិងបុរសនៅក្នុងប្រទេសកម្ពុជា, អង្គការKHANA និងសម្ព័ន្ធភាពមេរោគអេដស៍/ជំងឺអេដស៍អន្តរជាតិ HIV/AIDS.

[15]Menghourng, Ngo (2010) "សម្លេងសម្រាប់អ្នកងាយរងគ្រោះ", ៧ថ្ងៃ, ភ្នំពេញប៉ុស្ត៍ ១៤-២០ ឧសភា ២០១០។ ចេញផ្សាយលេខ ៩១, ទំព័រ១៦-១៨; Gharbi, Sylvain (2012) "ជីវិភាពគ្មានស្នេហា៖ អ្នកប្លែងភេទ (Ladyboy) នៅតាមខេត្ត. ៧ថ្ងៃ, ភ្នំពេញប៉ុស្ត៍, ១៤-២០ ធ្នូ ២០១២, ទំព័រ ៨

## *ដំណើរឆ្ពោះទៅមុខយ៉ាងរហ័ស៖ ការសិក្សាអំពីឥរិយាបថផ្លូវភេទ និងមេរោគអេដស៍*

ទស្សនទាននៃ "ការស្រឡាញ់ភេទដូចគ្នា" ដូចដែលប្រជាជននៅបស្ចឹមប្រទេសយល់ឃើញ គឺមិនមែនសុទ្ធតែអាចផ្ទេរបានដោយផ្ទាល់ ឬយល់បាននៅក្នុងបរិបទកម្ពុជា នោះទេ។ ពុំមានពាក្យជាភាសាខ្មែរដើម្បីរៀបរាប់អំពីឥរិយាបថមនុស្សស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទផ្ទុយគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ឬមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ឡើយ។ យោងតាម ផុង តាន់ ជនជាតិកម្ពុជាយល់ពីយេនឌ័រ និងទំនាក់ទំនងផ្លូវភេទ ក្នុងន័យស្រាលជាងពាក្យបស្ចឹមប្រទេស "ប្រុស" និង "ស្រី" ។[16] ទស្សនទាននៃយេនឌ័រ និងភេទ មិនត្រូវបានគេបែងចែកច្បាស់លាស់ឡើយ ហើយអត្តសញ្ញាណគឺផ្អែកលើមិនមែនចំណង់ផ្លូវភេទទេ ប៉ុន្តែលើចរិតលក្ខណៈជាស្រីនិងប្រុសទៅវិញ ដូចជាថាតើមនុស្សម្នាក់ស្លូត ឬកាច។

កម្មវិធីជំងឺអេដស៍ពីបស្ចឹមប្រទេស បានផ្តល់ការលើកទឹកចិត្តដល់ការទទួលយកអត្តសញ្ញាណបុរសដែលរួមភេទជាមួយបុរស (MSM) និងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីការរីករាលដាលជំងឺអេដស៍យ៉ាងខ្លាំងក្លាដែលប៉ះពាល់ទៅលើមនុស្សប្រុសស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសលោកខាងលិច ក្រោយពីករណីជំងឺអេដស៍ដំបូងៗត្រូវបានគេរកឃើញក្នុងចំណោមមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា នៅក្នុងសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៨១មក ការសិក្សាអំពីឥរិយាបថផ្លូវភេទរបស់បុរសទៅលើបុរសត្រូវបានគេផ្តួចផ្តើមឡើងនៅក្នុងប្រទេសផ្សេងៗទៀតក្នុងពិភពលោក។ ពាក្យថា "បុរសដែលរួមភេទជាមួយបុរស" (MSM) ត្រូវបានគេយកមកប្រើជាការពិពណ៌នាអំពីការប្រពឹត្តិមួយនៅក្នុងពាក់កណ្តាលទសវត្សរ៍១៩៨០ និងត្រូវបានគេទទួលយកកាន់តែច្រើននៅក្នុងវិស័យជំងឺអេដស៍និងសុខភាពសាធារណៈ។ នេះគឺជាការទទួលស្គាល់ថា ការប្រព្រឹត្តិផ្លូវភេទគឺជាកត្តាជំរុញការចម្លងជំងឺអេដស៍ ហើយថា នៅក្នុងបរិបទវប្បធម៌ជាច្រើន អត្តសញ្ញាណ "មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា" (ដូចដែលគេប្រើនៅក្នុងបស្ចឹមប្រទេស) មិនបានកើតមាននោះទេ។ កម្មវិធីមេរោគអេដស៍និងជំងឺអេដស៍ ដែលផ្តោតគោលដៅលើ "មនុស្សប្រុសស្រឡាញ់ប្រុសដូចគ្នា" នឹងគ្មានប្រសិទ្ធភាពនោះទេ នៅទីណាដែលបុរសដែលរួមភេទជាមួយបុរស មិនបានជ្រើសរើស "មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា" ជាអត្តសញ្ញាណមួយនោះ។

ផ្ទុយទៅវិញ ពាក្យបុរសដែលរួមភេទជាមួយបុរស ដែលមានបំណងរៀបរាប់ពីឥរិយាបថតែមួយគត់ ត្រូវបានគេប្រើប្រាស់នៅតាមទីកន្លែងខ្លះជាអត្តសញ្ញាណមួយ។[17] នៅក្នុងប្រទេស

---

[16] Earth, Barbara. (2006). ពិពិធកម្មយេនឌ័រ: អត្តសញ្ញាណមនុស្សប្រុសក្លែងខ្លួនជាងស្រី) និងកម្មវិធីមេរោគអេដស៍ក្នុងទីក្រុងភ្នំពេញ កម្ពុជា។ យេនឌ័រ និងការអភិវឌ្ឍ ១៤:២, ២៦០.

[17] Altman, Dennis (2001) "ស្រមើស្រមៃជំងឺអេដស៍: និងការតាមដានថ្មីនៅក្នុងការរួមភេទជាសកល ទីក្រុងស៊ីដនី Allen & Unwinទំព័រ ៦៨-៨៥

កម្ពុជា បុរសខ្លះដែលត្រូវបានគ្របដណ្តប់ដោយកម្មវិធីមេរោគអេដស៍និងជំងឺអេដស៍ ប្រើអក្សរកាត់ អឹម.អែស.អឹម (MSM) ជាអត្តសញ្ញាណមួយ ដោយសំដៅលើខ្លួនឯងថាជា "បុរសដែលរួមភេទជាមួយបុរស"។ ទោះបីជាយ៉ាងនេះក្តី នៅខាងក្រៅវិស័យសុខភាពសាធារណៈនិងមេរោគអេដស៍ ពាក្យថា អឹម.អែស.អឹម មិនត្រូវបានគេដឹងច្រើនប៉ុន្មានទេ។[18] បន្ថែមពីលើនេះ អ្នកដឹកនាំខ្លះនៃអង្គការបុរសដែលរួមភេទជាមួយបុរស នៅសហគមន៍ កត់សម្គាល់ថា ការបកប្រែ MSM ជាភាសាខ្មែរថា *ប្រុសស្រឡាញ់ប្រុស* ដែលមានន័យត្រង់ជាភាសាអង់គ្លេសថា "men who love men", ដោយបង្ហាញពីការស្រឡាញ់ថ្នាក់ថ្នម និងអារម្មណ៍ ក៏ដូចជាឥរិយាបថផ្លូវភេទ[19]។

កត្តានេះបង្ហាញពីផលវិបាកនៃអត្តសញ្ញាណទាំងយេនឌ័រ និងទំនោរផ្លូវភេទ។ មានអត្តសញ្ញាណដែលជនជាតិកម្ពុជា ប្រកាន់យកដោយខ្លួនឯង។ មានអត្តសញ្ញាណផ្សេងៗដែលអ្នកខាងក្រៅ ដូចជាអ្នកស្រាវជ្រាវ ឬអ្នកធ្វើការខាងអភិវឌ្ឍន៍ ប្រើដើម្បីកំណត់អត្តសញ្ញាណក្រុមគោលដៅ។ ពាក្យរបស់ប្រទេសលោកខាងលិច ដូចជា "gay" និង "MSM" ដែលត្រូវបានប្រើដោយអ្នកខាងក្រៅទាំងនេះ មិនសុទ្ធតែមានន័យដូចគ្នានៅក្នុងតំបន់នីមួយៗនោះឡើយ ទោះបីជាបុគ្គលLGBT អាចប្រើ ជ្រើសរើសយក ឬកែប្រែពាក្យសម្រាប់អត្តសញ្ញាណក៏ដោយ។ ខណៈពេលដែលពុំមានការសិក្សាណាមួយដើម្បីបង្ហាញពីថាតើកម្មវិធីមេរោគអេដស៍ និងការចម្លងមេរោគអេដស៍ មានផលប៉ះពាល់ដូចម្តេចទៅលើអត្តសញ្ញាណមនុស្សប្រុសស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ក៏គេមានការពិភាក្សាគ្នាយ៉ាងច្បាស់អំពីភេទ និងបញ្ហាផ្លូវភេទផងដែរ ទោះបីជាវាមិនរួមចំណែកដល់ការជ្រើសរើសយកអត្តសញ្ញាណ LGBT និងជំរុញដល់ការចងក្រងសហគមន៍ដែលនៅជុំវិញពួកគេក្តី។

ការសិក្សាអំពីសកម្មភាពផ្លូវភេទរបស់មនុស្សវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងជាលើកដំបូងដោយ Tarr នៅក្នុងឆ្នាំ១៩៩៤ ដោយមានការគាំទ្រពីអតីតកម្មវិធីសកលលោកស្តីពីមេរោគអេដស៍/ជំងឺអេដស៍របស់អង្គការសុខភាពពិភពលោក (WHO)។[20] ការសិក្សានេះបានឲ្យដឹងថា បុរសវ័យក្មេង "ជាង ២០នាក់" ក្នុងចំណោម ១៨៦នាក់ ដែលបានសម្ភាស បានសារភាពថាបានរួមភេទជាមួយបុរសម្នាក់ទៀត។ ដៃគូខ្លះក្នុងចំណោមដៃគូទាំងនេះ ត្រូវបានគេចាត់ទុកថា *ខ្ទើយ* ឬមនុស្សស្រីបំលែងភេទ។ ឯកសារនេះបានដាក់បញ្ចូលការពិពណ៌អំពីបុរសដែលចូលចិត្តរួមភេទជាមួយមនុស្សភេទដូចគ្នា។ ពុំមានការ

---

[18] Earth, Barbara. (2006) "ពិពិធកម្មយេនឌ័រ: អត្តសញ្ញាណមនុស្សប្រុសក្លែងភេទជាស្រី និងកម្មវិធីមេរោគអេដស៍ក្នុងទីក្រុងភ្នំពេញ កម្ពុជា" យេនឌ័រ និងការអភិវឌ្ឍ ១៤:២, ២៥៩-២៧១

[19] ការប្រាស្រ័យទាក់ទងបុគ្គល ប៉ាល់ សុផាត ២០១៣។

[20] Ogden, John. "ការអង្កេតអំពីភេទជួយប្រយុទ្ធជំងឺអេដស៍"។ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤។ ទាញចេញថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ពីគេហទំព័រ http://www.phnompenhpost.com/national/sex-survey-help-aids-fight

របាយការណ៍ឲ្យដឹងពីការរួមភេទរវាងមនុស្សស្រីក្នុងចំណោមស្ត្រីចំនួន ១៣៥នាក់ ដែលបានសម្ភាសឡើយ[21]។

ការសិក្សាដទៃទៀត បានកើតឡើងនៅក្នុងចុងទសវត្សរ៍៩០ និងដើមទសវត្សរ៍២០០០។ នៅក្នុងឆ្នាំ១៩៩៩ អង្គការសុខភាពគ្រួសារអន្តរជាតិ កម្ពុជា (FHI ឥឡូវនេះ ត្រូវបានគេស្គាល់ថាជា FHI 360) បានគូសផែនទី MSM នៅក្នុងរាជធានីភ្នំពេញ ដោយផ្តល់ព័ត៌មានអំពីទីកន្លែងដែល MSM ប្រមូលផ្តុំ និងជួបរាប់អានគ្នា។[22] ការអង្កេតអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត(KAP) ឆ្នាំ១៩៩៩ ទៅលើនិស្សិតសកលវិទ្យាល័យភេទប្រុសចំនួន ៦៧៨នាក់ នៅក្នុងរាជធានីភ្នំពេញ បានឲ្យដឹងថា ៥៤%នៃបុរសដែលបានអង្កេត ធ្លាប់មានទំនាក់ទំនងផ្លូវភេទ ហើយក្នុងចំណោមចំនួននេះ ៨%ធ្លាប់បានមានទំនាក់ទំនងផ្លូវភេទជាមួយបុរសម្នាក់ទៀត។[23] ការសិក្សាដំបូងដែលបង្ហាញការរាលដាលមេរោគអេដស៍ក្នុងចំណោម MSM ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០០ ដោយចេញលទ្ធផលនៅចុងឆ្នាំ២០០២។ ការសិក្សាដំបូងនេះបានបង្ហាញថា ១៤ភាគរយនៃ MSM ក្នុងរាជធានីភ្នំពេញ បានធ្វើតេស្តឃើញមានផ្ទុកមេរោគអេដស៍[24]។

Catalla et al. បានធ្វើការសិក្សាពិពណ៌នាបែបគុណវិស័យដំបូងបំផុតទៅលើឥរិយបថផ្លូវភេទរបស់បុរសជាមួយបុរសនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០០២ រួមទាំងអនុក្រុមផ្សេងៗ ស្វ័យអត្តសញ្ញាណ ចំណង់ចំណូលចិត្តដៃគូរួមភេទ និងពាក្យនៅមូលដ្ឋានដែលគេប្រើប្រាស់។ [25] នៅក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងសៀមរាប ពាក្យខ្លះសម្រាប់អនុក្រុមនានាដែលគេប្រើ រួមមាន សក់ខ្លី សក់វែង ស្រីស្រស់ ប្រុសស្អាត បុរសពិតប្រាកដ ស្រីវ័ត្តបំបាំងកាយ ជនជាតិភាគតិច ក្រុមអ្នករាំង និងប្រុសលក់ខ្លួន។[26] ពាក្យថា ខ្ទើយ ត្រូវបានចាត់ទុកថាជាពាក្យមើលងាយ នៅពេលប្រើដោយអ្នកដទៃទៀតដែលមិនស្ថិតនៅក្នុង MSM និងក្រុមមនុស្សប្តូរភេទ។

---

[21]Tarr, Chou Meng and Aggleton, Peter (1999) "មនុស្សវ័យក្មេង និងមេរោគអេដស៍នៅកម្ពុជា - អត្ថន័យ និងបរិបទ និងវប្បធម៌ផ្លូវភេទ", ទំព័រ ១៣ & ១៦ http://www.racha.org.kh/rc2008/142/HAP-05F.pdf ទាញចេញថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤

[22]Girault, P. and Thaiy, 1999 មិនបានបោះពុម្ពផ្សាយ. ការគូសផែនទីទីតាំងបុរសដែលរួមភេទជាមួយបុរស។ ភ្នំពេញ FHI

[23]Glaziou,P. Bodet et al. (1999). "ចំណេះដឹង អាកប្បកិរិយា និងការប្រព្រឹត្តិរបស់និស្សិតទាក់ទងនឹងការឆ្លងមេរោគអេដស៍ក្នុងរាជធានីភ្នំពេញ ឆ្នាំ១៩៩៩។ ជំងឺអេដស៍: Volume ១៣ (១៤), តុលា ១៩៩៩

[24]Girault, P. Saidel, T. Ngak, S.et al: (2002). "ការប្រព្រឹត្តិផ្លូវភេទ កាមរោគ និងមេរោគអេដស៍ក្នុងចំណោមបុរសដែលរួមភេទជាមួយបុរសនៅក្នុងរាជធានីភ្នំពេញ"។ FHI ទិន្នន័យអំពីនិស្សិតគឺបានមកពី Glaziou et al., កត់សម្គាល់ក្នុងរបាយការណ៍នេះ។

[25]Catalla, TAP, Sovanara, K & Van Mourik, G. (2003). "ចេញក្រៅស្រមោល" - ការប្រព្រឹត្តិផ្លូវភេទរវាងបុរសនិងបុរសនៅក្នុងប្រទេសកម្ពុជា"។ សម្ព័ន្ធភាពមេរោគអេដស៍/ជំងឺអេដស៍អន្តរជាតិ និង សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ Khmer HIV/AIDS NGO Alliance (KHANA) ទំព័រ ១៥-១៩

[26]Catalla et al., Ibid. ទំព័រ ១៦

របាយការណ៍នេះក៏បានកត់សម្គាល់ផងដែរថា អនុក្រុមផ្សេងៗដែលបានរៀបរាប់នេះ មិនងាយលាយបញ្ចូលគ្នាក្នុងសង្គមតែមួយបានទេ។ ជាទូទៅ ក្រុម"សក់ខ្លី" (ដែលគេពិពណ៌នាថា ធ្វើខ្លួនដូចជាមនុស្សប្រុស មិនចង់ស្លៀកពាក់សំលៀកបំពាក់របស់ភេទមួយទៀត ឬមានអារម្មណ៍និងស្លៀកពាក់ដូចស្រី) ច្រើនតែមើលងាយ ក្រុម"សក់វែង" (ដែលជា MSM ដែលមានឫកពាដូចស្រី ចូលចិត្តស្លៀកពាក់ខោអាវស្រី និងលាបម្សៅ) និងចាត់ទុកខ្លួនឯងជា "សក់ខ្លី" ជា ក្រុមដោយឡែកមួយ។[27] ក្រុមដទៃទៀតត្រូវបានពិពណ៌នាថាជា "សក់ខ្លី" នៅពេលថ្ងៃ និង "សក់វែង" នៅពេលយប់ —ដោយបង្ហាញពីភាពទន់ភ្លន់ និងភាពបត់បែននៃអត្តសញ្ញាណយេនឌ័រនិងការសំដែងអាការៈខាងក្រៅ។ ពាក្យទាំងនេះជាន់គ្នា ហើយក្នុងបរិបទខ្លះ "សក់វែង" អាចត្រូវបានគេហៅថា "ស្រីស្អាត" ហើយ "សក់ខ្លី" គឺជា "ប្រុសសង្ហា" ឬជា "បុរសពិត"។ ទំនោរផ្លូវភេទ ហាក់ដូចជាមិនមានភាពខុសគ្នាទេ នៅក្នុងពាក្យរបស់ខ្មែរទាំងអស់។ ដូច្នេះ ចាប់ពីពេលនេះតទៅ ពាក្យ "មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា", "បុរសដែលរួមភេទជាមួយបុរស", និង "មនុស្សស្រីស្រឡាញ់ភេទដូចគ្នា" នឹងត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ស្មានពីការយល់ដឹងនៅមូលដ្ឋានអំពីទំនោរផ្លូវភេទ និងអត្តសញ្ញាណឌ័រយេនដែលផ្ទុយពីនិយមន័យរបស់បស្ចឹមប្រទេស"

## *ការបង្កើនការយល់ដឹងអំពីសិទ្ធិមនុស្ស, SOGI និងបញ្ហារបស់មនុស្ស LGBT នៅក្នុងប្រទេសកម្ពុជា និងការកៀងគរសហគមន៍*

ការងារមេរោគអេដស៍ ជាពិសេសជាមួយ MSM និងមនុស្សប្លូរភេទ បានបើកឱកាសសម្រាប់ការតស៊ូមតិទាមទារសុខភាពនិងសិទ្ធិរបស់មនុស្ស LGBT នៅក្នុងប្រទេសកម្ពុជា។ ការងារជាច្រើនឆ្នាំទៅលើមេរោគអេដស៍ជាមួយ MSM (ដែលភាគច្រើនកំណត់អត្តសញ្ញាណខ្លួនឯងថាជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា) បានធ្វើឲ្យមានការយល់ដឹងកាន់តែច្រើននៅក្នុងប្រទេសកម្ពុជាអំពីទំនោរផ្លូវភេទផ្សេងៗ និងអត្តសញ្ញាណយេនឌ័រ និងអំពីការរើសអើងដ៏ខ្លាំងប្រឆាំងអ្នកដែលធ្វើផ្ទុយពីបទដ្ឋានភេទពីប្រពៃណី។ ការងារមេរោគអេដស៍ ក៏បានបង្កើនផងដែរនូវការយកចិត្តទុកដាក់កាន់តែច្រើនក្នុងចំណោម MSM និងមនុស្សប្លូរភេទ មកលើសហគមន៍ និងទំនាក់ទំនងសមាជិកក្រុមរបស់ពួកគេ ដែលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការកៀងគរមនុស្សឲ្យហួសពីចំណាត់ថ្នាក់របស់ពួកគេទៅតាមសកម្មភាពផ្លូវភេទ ទៅក្នុង "ក្រុមប្រឈមមុខ"។ មានការទទួលស្គាល់កាន់តែច្រើនឡើងនៅក្នុងប្រទេសកម្ពុជា ដែលថាមេរោគអេដស៍គឺគ្រាន់តែជាបញ្ហាមួយដែល MSM និងមនុស្សប្លូរភេទ ជួបប្រទះ ហើយថា បញ្ហានេះ គឺមានទំនាក់ទំនងទៅនឹងការរើសអើង ការផាត់ចេញ និងការធ្វើឲ្យឯកោ។ ទោះបីជាយ៉ាងណាក្តី ការសិក្សាផ្សេងៗ រួមទាំងការសិក្សាអំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ បង្ហាញថា ក្រុម

---

[27] Lesley, E. and Rith, S. (2005) "ដើរចេញ", ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥។

នានា ដូចជាក្រុមមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ត្រូវបានគេផាត់ចេញពីការពិភាក្សាអំពីមេរោគអេដស៍។

នៅក្នុងឆ្នាំ២០០៦ បណ្តាញការងារដំបូងនៃ MSM និងមនុស្សប្លូរភេទ ដែលគេស្គាល់ថាជាបណ្តាញចតុមុខ (BC) ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា។ បណ្តាញចតុមុខ គឺជាក្រុមអ្នកផ្តល់ថវិកានិងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើមេរោគអេដស៍។ ទោះបីជាចក្ខុវិស័យរបស់ខ្លួនចែងថា "សិទ្ធិរបស់បុរសដែលរួមភេទជាមួយបុរស (MSM) គឺជាសិទ្ធិមនុស្ស"ក្តី តាមការពិនិត្យឡើងវិញលើការងាររបស់ខ្លួនក្នុងឆ្នាំ២០១០បានបង្ហាញថា "ពុំមានសកម្មភាពជាក់លាក់ លទ្ធផល ឬគោលដៅណា ដែលដោះស្រាយដោយផ្ទាល់នូវគោលដៅរួមទីមួយរបស់បណ្តាញចតុមុខដែលត្រូវការពារសិទ្ធិមនុស្សរបស់បុរសដែលរួមភេទជាមួយបុរស និងមនុស្សប្លូរភេទ និងសមភាពរបស់ MSM និងមនុស្សប្លូរភេទ ជាមួយប្រជាពលរដ្ឋកម្ពុជាដទៃទៀត នោះឡើយ។"[28]

អង្គការសិទ្ធិមនុស្សមួយនៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បាននិងកំពុងអនុវត្តគម្រោងមួយស្តីពីសិទ្ធិរបស់មនុស្សLGBT និង SOGI ចាប់តាំងពីឆ្នាំ២០១០។ CCHR បានបោះពុម្ពផ្សាយការប៉ាន់ប្រមាណស្ថានភាពលើកទីមួយរបស់មនុស្ស LGBT នៅក្នុងប្រទេសកម្ពុជា និងបានផ្តួចផ្តើមកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ។[29] អង្គការក្រៅរដ្ឋាភិបាលដទៃទៀត បានចាត់ទុកបុគ្គល LGBT ថាជាផ្នែកមួយនៃក្រុមគោលដៅរបស់ពួកគេ, "អ្នកទទួលផលខ្លះរបស់យើងគឺជា មនុស្សLGBT" ប៉ុន្តែយើងធ្វើការមិនជាក់លាក់ចំពោះអត្តសញ្ញាណរបស់ LGBT នោះទេ ឧទាហរណ៍ ដូចជា នៅក្នុងផ្នែកតស៊ូមតិគាំទ្រសិទ្ធិក្នុងការទទួលបានការងារ និងប្រឆាំងនឹងការជួញដូរផ្លូវភេទ។

អង្គការ LGBT ដំបូងបំផុតដែលត្រូវបានទទួលស្គាល់ជាផ្លូវការនៅក្នុងប្រទេស គឺអង្គការឥន្ទធនូកម្ពុជា (RoCK), ដែលត្រូវបានចុះបញ្ជីជាផ្លូវការជាអង្គការក្រៅរដ្ឋាភិបាលមួយកាលពីដើមឆ្នាំ២០១៤។ ពីមុនអង្គការនេះគឺជាបណ្តាញអ្នកស្ម័គ្រចិត្តក្រៅផ្លូវការមួយ ដែលភាគច្រើនគឺជាមនុស្ស LGBT។ ការប្រារព្ធពិធីមោទនភាពរយៈពេលមួយសប្តាហ៍លើកទីមួយនៅក្នុងរាជធានីភ្នំពេញ ត្រូវបានរៀបចំឡើងដោយក្រុមក្រៅផ្លូវការមួយរបស់អង្គការ RoCK ក្នុងឆ្នាំ២០០៩។

---

[28] Salas, Vicente. របាយការណ៍ប្រឹក្សាជូនគណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍/ជំងឺអេដស៍ទៅលើ "តម្រូវការ និងកង្វល់របស់បុរសរួមភេទជាមួយបុរសនៅកម្ពុជា ប្រវត្តិរូបនៃអង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍ បុរសរួមភេទជាមួយបុរស និងអនុសាសន៍សំរាប់យុត្តិសាស្ត្រអភិវឌ្ឍបណ្តាញបុរសរួមភេទជាមួយបុរសជាតិ (បណ្តាញចតុមុខ) " ខែមករា ឆ្នាំ២០១០។

[29]ttp://cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=SOGI&pro_id=7&show=show

ថ្មីៗនេះ សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលបានកត់ត្រាទុកជាឯកសារនូវការរើសអើង និងការមាក់ងាយដែលកំពុងកើតមានឡើងកាន់តែច្រើនឡើងៗប្រឆាំងបុគ្គលLGBT។ បញ្ហានេះធ្វើឲ្យប៉ះពាល់ដល់បុគ្គល LGBT នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ពួកគេ តាំងពីគ្រួសារ និងអ្នកជិតខាង រហូតដល់សាលារៀន និងការសិក្សា ទីកន្លែងធ្វើការ និងទិដ្ឋភាពដទៃទៀតនៃសហគមន៍ និងសង្គម។[30]

## *ការស្រាវជ្រាវដែលផ្តោតលើ មនុស្សLGBT*

បញ្ហាមនុស្ស LGBT ដែលជំនាញមួយនៃការសិក្សា កំពុងតែចាប់ផ្តើមនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០១២ ការសិក្សាទៅលើអ្នកឆ្លើយតបនឹងការសម្ភាសន៍ដែលជា មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទ ចំនួន ១៩៩ នាក់ (មនុស្សស្រឡាញ់ភេទទាំងពីរ មិនត្រូវបានដាក់បញ្ចូលទេ) នៅក្នុងរាជធានីភ្នំពេញ និងភូមិពីរនៅតំបន់ជនបទ បានបង្ហាញពីការផាត់ចេញ ការមាក់ងាយ និងការរើសអើងក្នុងកម្រិតយ៉ាងខ្ពស់នៅតាមទីកន្លែងនានាជាច្រើន។ [31] បញ្ហាទាំងនេះមានតាំងពីការព្រងើយកន្តើយ មិនអនុញ្ញាតឲ្យបញ្ចេញមតិ និងការផាត់ចេញពីសាលារៀន និងសកម្មភាពសហគមន៍ (ដូចជាគម្រោងគាំពារសង្គមខ្លះ) រហូតដល់ការប្រមាថមាក់ងាយ វាយប្រហារ និងទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ។ "សំណាញ់សុវត្ថិភាព" តាំងពីបុរាណ កន្លងមក ពោលគឺគ្រួសារ បានក្លាយទៅជាប្រភពនៃការជិះជាន់ទៅវិញ។ មនុស្សប្តូរភេទពីប្រុសទៅស្រី បានរាយការណ៍ឲ្យដឹងពីការរើសអើង ការមាក់ងាយ និងករណីអំពើហិង្សាកាន់តែច្រើន បើប្រៀបធៀបនឹងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ដែលនេះគឺប្រហែលជាពួកគេចេញមុខចេញមាត់ខ្លាំងជាងគេ។ មានកម្លាតផងដែរនៅក្នុងការទទួលបានការអប់រំនៅថ្នាក់ឧត្តមសិក្សា។ មនុស្សស្រីប្តូរភេទមួយចំនួនតូច បានរៀនខ្ពស់ជាងកម្រិតមធ្យមសិក្សា ហើយពួកគេជាច្រើនទៀតបានរាយការណ៍ថា គ្រួសារពួកគេ បាន "បង្ខំឲ្យឈប់ធ្វើការ ឬឈប់រៀន"។ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា ក៏បានរាយការណ៍ផងដែរអំពីអំពើហិង្សាក្នុងគ្រួសារដែលបានកើតឡើងចំពោះពួកគេ ក្នុងកម្រិតច្រើនជាងប្រជាពលរដ្ឋជាស្ត្រីទូទៅ នៅក្នុងការអង្កេតប្រជាសាស្ត្រជាតិ។ ៣១%នៃអ្នកឆ្លើយតបនឹងការសម្ភាសន៍វ័យក្មេងជាងនេះ (អាយុក្រោម ១៩ ឆ្នាំ) បានរាយការណ៍ឲ្យដឹងពីការយកទទួលស្គាល់របស់គ្រួសារច្រើនជាងបន្តិច បើប្រៀបធៀបនឹងអ្នកអាយុលើស ១៩ឆ្នាំ (២៣%)។

---

[30] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR). (2010) "ចេញជាជំហានៅព្រះរាជាណាចក្រ៖ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា '(២០១០) និង "ឥន្ទធនូខ្មែរ"៖ ពីបុរេនិច្ឆ័យទៅមោទនភាព" (២០១២)

[31] Salas, V. and Srorn, S. (2013). "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃមនុស្សស្រីស្រឡាញ់ស្រីដូចគ្នា មនុស្សប្រុសស្រឡាញ់ប្រុសដូចគ្នា និងមនុស្សបំលែងភេទនៅក្នុងគ្រួសារ និងសហគមន៍ និងវិធីដោះស្រាយរបស់ពួកគេ"។ របាយការណ៍ស្រាវជ្រាវ។ ផ្នែកសម្របសម្រួលការគាំពារសង្គម ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មជនបទ (SPCU-CARD) ភ្នំពេញ

ប្រភពព័ត៌មានដទៃទៀតអំពីមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា គឺការសិក្សាដែលបានធ្វើឡើងនៅក្នុងគ្រប់ហាងម៉ាស្សាបុរសទាំងអស់។ ការសិក្សាឆ្នាំ២០១២ ស្តីពី "បុរសម៉ាស្សា" និងអំពើធ្វើអាជីវកម្មផ្លូវភេទ[32] ក្នុងខេត្តសៀមរាប បានបង្ហាញថា អ្នកឆ្លើយតបនឹងការសម្ភាសន៍ ៥០នាក់ ប្រហែលជា ៥០% បាននិយាយថា ពួកគេចូលចិត្តរួមរួមភេទជាមួយបុរស ៤៧% ចូលចិត្តរួមភេទជាមួយស្ត្រី ១១ភាគរយចូលចិត្តរួមភេទជាមួយបុរសផង ស្ត្រីផង ហើយអ្នកឆ្លើយតបនឹងការអង្កេតម្នាក់ (២%) ចូលចិត្តរួមភេទជាមួយអ្នកបំលែងភេទ។ អ្នកឆ្លើយតបនឹងការសម្ភាសន៍នៅក្នុងការសិក្សាទាំងនេះ បាននិយាយថា ពួកគេមានការខ្មាស់គេចំពោះការងារដែលពួកគេកំពុងធ្វើ ហើយមិនចង់ប្រាប់អ្នកដទៃទៀតអំពីការងារនេះទេ។ ទោះបីជាពួកគេអាចរកប្រាក់បានច្រើននៅក្នុងគ្រឹះស្ថានទាំងនេះ ជាងតាមរយៈការងារផ្សេងទៀតក្តី ការងារប្រកបរបរផ្លូវភេទ និងការងារនៅក្នុងហាងម៉ាស្សា ត្រូវបានសង្គមមើលងាយ។

ការសិក្សាដើមគ្រាអំពីមនុស្សស្រីប្តូរភេទ នៅក្នុងឧស្សាហកម្មផ្លូវភេទនៅក្នុងរាជធានីភ្នំពេញ[33] បានបង្ហាញពីអំពើហិង្សានិងការរំលោភបំពានយ៉ាងច្រើន ជាពិសេសពីសំណាក់នគរបាល និងបានរៀបរាប់ផងដែរអំពីបញ្ហាសុខភាពនានា ដូចជាជំងឺកាមរោគដែលមានអត្រាដ៏ខ្ពស់ ការប្រើថ្នាំអំហ្វេតាមីន និង គ្រឿងស្រវឹង ក៏ដូចជាផលវិបាកនៃការចាក់ថ្នាំដោយគ្មានការត្រួតពិនិត្យដើម្បីផ្លាស់ប្តូរមុខមាត់របស់ពួកគេ។ មនុស្សស្រីប្តូរភេទដែលលក់សេវាភេទ ត្រូវទទួលរងការរើសអើងនិងអំពើហិង្សាកាន់តែច្រើនឡើងៗ។ ពួកគេប្រឈមមុខនឹងការមាក់ងាយទ្វេដង ដោយសារតែអត្តសញ្ញាណរបស់ពួកគេ និងដោយសារតែការងាររបស់ពួកគេ។ ប្រសិនបើពួកគេមានផ្ទុកមេរោគអេដស៍ វារឹងតែបន្ថែមការមាក់ងាយកាន់តែខ្លាំងថែមទៀត។

## *មោទនភាពរបស់មនុស្ស LGBT កាន់តែច្រើនឡើង និងការតស៊ូមតិទាមទារសិទ្ធិ*

នៅក្នុងប្រទេសកម្ពុជា ចលនាទាមទារសិទ្ធិរបស់មនុស្ស LGBT ថ្មីមួយ ត្រូវបានធ្វើឡើងដោយផ្អែកលើព្រះរាជបន្ទូលគាំទ្ររបស់ព្រះមហាក្សត្រ។ នៅក្នុងឆ្នាំ២០០៤ ព្រះសង្ឃថាដែលថ្លែងឡើងដោយព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ព្រះរាជបិតាជាតិ នរោត្តមសីហនុ បានអំពាវនាវឲ្យមានការអត់ឱន និងការទទួលយកទំនាក់ទំនងភេទដូចគ្នា។ នៅក្នុងការឆ្លើយតបទៅនឹងការសំដែងតាមទូរទស្សន៍មួយដែលបង្ហាញពីការរៀបការភេទដូចគ្នានៅក្នុងសហរដ្ឋអាមេរិក ព្រះអង្គបានចេញព្រះរាជសារមួយនៅលើគេហទំព័ររបស់ព្រះអង្គ ជា

[32] Davies and Miles, (2012) "ក្មេងប្រុសលិង្គនៃខេត្តសៀមរាប" (The Lingha boys of Siem Reap) - ការសិក្សាដើមគ្រានៃបុរសវ័យក្មេងដែលត្រូវបានគេធ្វើអាជីវកម្មផ្លូវភេទក្នុងខេត្តសៀមរាប", អង្គការLove 146, ការរួមគ្នាចាប់ដៃ, ជំហានទីមួយ, ទីសហគមន៍ដ៏លំបាកលំបិន, ទំព័រ 31

[33]Miles & Davies (n.d.). "លើសពីយេនឌ័រ" - ការសិក្សាដើមគ្រាលើបុរសប្តូរភេទនៅក្នុងឧស្សាហកម្មផ្លូវភេទនៅក្នុងទីក្រុងភ្នំពេញ។ បទបង្ហាញ Powerpoint ដោយអង្គការ Love 146

ការគាំទ្រដល់ការរៀបការភេទដូចគ្នា ដោយព្រះអង្គឆ្លេងយល់ថា *"ក្នុងនាមជាប្រទេសប្រជាធិបតេយ្យសេរីមួយ ព្រះរាជណាចក្រកម្ពុជា គួរតែអនុញ្ញាតឲ្យមាន "ការរៀបការរវាងបុរសនិងបុរស... ឬរវាងស្ត្រីនិងស្ត្រី"។* ព្រះអង្គមានព្រះបន្ទូលថា ព្រះអង្គគោរពអ្នកស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ហើយថា ពួកគេមានស្ថានភាពបែបនេះ ក៏ព្រោះតែ *"ព្រះ សព្វព្រះទ័យសេជាតិចម្រុះ"*[34]។

នេះគឺជាសេចក្តីថ្លែងការណ៍ជាសាធារណៈលើកដំបូងបំផុត ដែលធ្វើឡើងដោយព្រះមហាវីរក្សត្រ អំពីបញ្ហាមនុស្ស LGBT។ សកម្មជនមួយចំនួនតូចដែលធ្វើការផ្តែកការពារសិទ្ធិរបស់មនុស្សLGBT នៅក្នុងប្រទេសកម្ពុជា បានចាត់ទុកថាសេចក្តីថ្លែងការណ៍នេះគឺជាការញ៉ាំងទឹកចិត្តមួយសម្រាប់រៀបចំព្រឹត្តិការណ៍ដើម្បីលើកកម្ពស់មោទនភាពរបស់មនុស្ស LGBT ហើយសេចក្តីថ្លែងការណ៍នេះបានក្លាយទៅជាមួយមូលដ្ឋានមួយសម្រាប់ការងារតស៊ូមតិ និងការទទួលស្គាល់បុគ្គល LGBT។ ទោះបីជាយ៉ាងណាក្តី អាជ្ញាធររដ្ឋាភិបាលនិងអ្នកតាក់តែងគោលនយោបាយមិនបានចាត់វិធានការទូលំទូលាយលើសេចក្តីថ្លែងការណ៍របស់ព្រះមហាក្សត្រនេះឡើយ។ នាពេលថ្មីៗនេះ សេចក្តីប្រកាសនិងសេចក្តីថ្លែងការណ៍អន្តរជាតិជាសាធារណៈ ពីសហរដ្ឋអាមេរិក និង អង្គការសហប្រជាជាតិដែលថា "សិទ្ធិមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា (សិទ្ធិបុគ្គល LGBT) គឺជាសិទ្ធិមនុស្ស ហើយសិទ្ធិមនុស្សគឺជាសិទ្ធិមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា (ឬ LGBT)" បាននិងកំពុងមានប្រជាប្រិយយ៉ាងខ្លាំងក្នុងចំណោមបុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា។

ការប្រារព្ធពិធីមោទនភាពមនុស្សប្រុសស្រឡាញ់ភេទដូចគ្នាលើកដំបូងរបស់កម្ពុជា ដែលបានធ្វើឡើងក្នុងឆ្នាំ២០០៣[35] គឺជាព្រឹត្តិការណ៍រយៈពេលមួយថ្ងៃ ដែលមានកម្មវិធីតន្ត្រីនិងច្រៀងរាំកម្សាន្ត ការបង្ហាញម៉ូដ និងការជួបជុំជាលក្ខណៈសង្គម។ ព្រឹត្តិការណ៍មោទនភាពនេះគឺជាគំនិតផ្តួចផ្តើមរបស់សហគមន៍ដោយស្ម័គ្រចិត្តមួយ ដែលត្រូវបានផ្តល់មូលនិធិតាមរយៈអំណោយឯកជននិងជារឿយៗអំណោយពីបុគ្គលផ្ទាល់ ព្រមទាំងដឹកនាំដោយសិល្បករខ្មែរអាមេរិក ឆាត់ ពាសាត (Chath Piersath)។ ពីឆ្នាំ២០០៥ ដល់ ២០០៨ ពុំមានការរៀបចំព្រឹត្តិការណ៍មោទនភាពឡើយ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ២០០៩ មក សហគមន៍ឥន្ទធនូកម្ពុជា (RoCK) បានដឹកនាំការប្រារព្ធពិធីមោទនភាព LGBT នេះកាន់តែអធឹកអធម[36] សកម្មភាពរយៈពេលមួយសប្តាហ៍ បានពង្រីកដល់ខេត្តដទៃទៀត ដូចជាបាត់ដំបង និង

---

[34] .http://news.bbc.co.uk/2/hi/asia-pacific/3505915.stm, ២០ កុម្ភៈ ២០០៤។ ទាញចេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៤។

[35] របាយការណ៍ខ្លះដាក់ការប្រារព្ធពិធីមោទនភាពលើកដំបូងក្នុងឆ្នាំ២០០៣ (www.utopia.asia.org) និង http://en.wikipedia.org/wiki/LGBT_rights_in_Cambodia

[36] Mullen, D. "មនុស្សគ្រប់រូបត្រូវការមានមោទនភាព", ភ្នំពេញប៉ុស្តិ៍ ៧ថ្ងៃ ១៤-២០ ឆ្នាំ ២០១០, លេខ ៤១, ទំព័រ១៨-១៩; "កម្មវិធីមោទនភាពឆ្នាំ២០០៩", ជីវិតអាស៊ីនៅភ្នំពេញ លេខ ២៩ ខែ ឧសភា ឆ្នាំ២០០៩; "ត្រូវចេះស្រឡាញ់ខ្លួនឯង ", កម្មវិធីមោទនភាពឆ្នាំ២០១០; "ខ្ញុំមានមោទនភាពចំពោះខ្លួនខ្ញុំ" កម្មវិធីមោទនភាពឆ្នាំ២០១១នៅកម្ពុជា; "ខុសគ្នា ប៉ុន្តែដូចគ្នា" កម្មវិធីមោទនភាព ឆ្នាំ២០១២នៅកម្ពុជា - ទាំងអស់ត្រូវបានរៀបចំ និងបោះពុម្ពផ្សាយដោយអង្គការសហគមន៍ឥន្ទធនូ កម្ពុជា (RoCK) ២០១០, ២០១១ និង ២០១២)

សៀមរាប។ បច្ចុប្បន្នេះ ការប្រារព្ធពិធីនេះរួមមានការសំដែងសិល្បៈ ព្រឹត្តិការណ៍រឿងផ្សេងៗ សិក្ខាសាលា ការសំដែងរបស់មនុស្សប្លូរភេទ ការប្រកួតកីឡា ការប្រណាំងរ៉ឺម៉កកង់បី ការផ្សព្វផ្សាយសៀវភៅ និងការបញ្ចាំងភាពយន្ត។ ទិវាគ្រួសារ និងការសូត្រមន្តលើករាសីពីព្រះសង្ឃនៅក្នុងវត្ត ក៏សំខាន់ខ្លាំងណាស់ដែរចំពោះការចូលរួមរបស់បុគ្គល LGBT នៅមូលដ្ឋាន ក៏ដូចជាដៃគូ និងគ្រួសាររបស់ពួកគេ។ សប្តាហ៍មោទនភាពត្រូវបានរៀបចំឡើងនៅពាក់កណ្តាលខែឧសភា ដើម្បីឲ្យចំពេលជាមួយការប្រារព្ធទិវា IDAHOT (ទិវាអន្តរជាតិប្រឆាំងការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា និងការស្អប់មនុស្សប្លូរភេទ) ដែលកើតឡើងនៅថ្ងៃទី១៧ ខែឧសភា និងជាទិវាដែលអង្គការសុខភាពពិភពលោក (WHO) បានដកការស្រឡាញ់មនុស្សភេទដូចគ្នា ចេញពីបញ្ជីឈ្មោះជំងឺរបស់ខ្លួន។ អង្គការក្រៅរដ្ឋាភិបាលដទៃទៀត ដូចជា CCHR ក៏បានរៀបចំសកម្មភាព កម្មវិធីសម្ភាសន៍តាមវិទ្យុ និងព្រឹត្តិការណ៍ផ្សេងៗទៀតក្នុងអំឡុងទិវាមោទនភាព។ ពុំមានប្រតិកម្មតបណាមួយពីខាងរដ្ឋាភិបាល ចំពោះព្រឹត្តិការណ៍ទាំងនេះឡើយ។

ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិនៅក្នុងប្រទេសប្រទេសកម្ពុជា ក៏ជាឱកាសមួយផងដែរសម្រាប់តស៊ូមតិអំពីសិទ្ធិរបស់បុគ្គល LGBT។ នៅក្នុងឆ្នាំ២០១៣ ការប្រារព្ធពិធី ដែលមានចំណងជើងថា "សម្លេងរបស់ខ្ញុំសំខាន់ណាស់" បានបង្ហាញពីជីវិតរបស់គូស្រករ LGBT និងគ្រួសាររបស់ពួកគេ។ អាជ្ញាធរមូលដ្ឋាន មេឃុំ (ដែលជាអង្គភាពតូចបំផុតរបស់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន) មានការគាំទ្រ ហើយសកម្មជន LGBT របស់អង្គការRoCK បានចែករំលែកបទពិសោធន៍របស់ពួកគេអំពីការមានគូស្រករភេទដូចគ្នារស់នៅក្នុងភូមិរបស់ពួកគេ។

នៅក្នុងឆ្នាំ២០១០, អង្គការ CCHR បាធ្វើការបកប្រែ និងចែកចាយគោលការណ៍យ៉កយ៉ាក៍តា នៅក្នុងប្រទេសកម្ពុជា។ "គោលការណ៍យ៉ូយ៉ាក៍តា គឺជាឯកសារលេចធ្លោមួយដែលវិភាគពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការអនុវត្តច្បាប់នេះចំពោះទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ (SOGI) ដែលបានបង្កើតឡើងដោយអ្នកជំនាញមួយក្រុមនៅក្នុងប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ២០០៦ [37] ។ គោលការណ៍ទាំងនេះបញ្ជាក់ពីកាតព្វកិច្ចចម្បងរបស់រដ្ឋដើម្បីអនុវត្តសិទ្ធិមនុស្ស; គោលការណ៍នីមួយៗមានអមដោយអនុសាសន៍លម្អិតមួយចំនួនសម្រាប់រដ្ឋ និងភាគីដទៃទៀត ដូចជា អង្គការសហប្រជាជាតិ ស្ថាប័នសិទ្ធិមនុស្សជាតិ ប្រព័ន្ធផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ថវិកា។

នៅក្នុងឆ្នាំ២០១២ នៅពេលកម្ពុជាធ្វើជាប្រធានអាស៊ាន កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដោយក្រុម LGBT ផ្សេងៗនៅក្នុងប្រទេសជាសមាជិកអាស៊ាន (ក្រុម អាស៊ានLGBTQ Caucus) ដើម្បីដាក់បញ្ចូលបញ្ហានិងកង្វល់របស់ LGBT ទៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះមិនបានទទួលជោគជ័យនោះទេ ទោះបីជា

[37]គណៈកម្មការអ្នកច្បាប់អន្តរជាតិ និងសេវាកម្មអន្តរជាតិសម្រាប់សិទ្ធិមនុស្ស (២០០៧)។ គោលការណ៍យ៉កយ៉ាក៍តា: ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ទាក់ទងនឹងទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

មានប្រទេសមួយចំនួនបានខិតខំបញ្ចុះបញ្ចូលឲ្យដាក់បញ្ចូល SOGI នៅក្នុងខចែងស្តីពីការមិនរើសអើងក៏ដោយ។[38] សភាប្រជាជននៅមូលដ្ឋាននៃអាស៊ាន ដែលជាក្រុមមិនមែនរដ្ឋាភិបាលក្រៅផ្លូវការមួយ បានចេញសេចក្តីថ្លែងការណ៍មួយដែលបានដាក់បញ្ចូលការទាមទារឲ្យលុបចោលច្បាប់នានា ដែលឧក្រិដ្ឋនីយកម្ម SOGI, ការទទួលស្គាល់សិទ្ធិរបស់មនុស្ស LGBT ជាសិទ្ធិមនុស្ស ការការពារសិទ្ធិរបស់អ្នកប្រកបមុខរបរផ្លូវភេទ ហើយថា គោលការណ៍យ៉ូកយ៉ាកាតា ត្រូវតែសុខដុមនីយកម្មទៅក្នុងច្បាប់ និងគោលនយោបាយជាតិ។[39]

នៅក្នុងឆ្នាំ២០១៣ សម្ព័ន្ធកម្ពុជាក្នុងស្រុកមួយដែលរួមមានទាំងសមាគមដែលបានចុះបញ្ជី និងមិនបានចុះបញ្ជី - ដឹកនាំដោយ RoCK បណ្តាញស្ត្រីដើម្បីរួបរួម (WNU) សេវាច្បាប់សហគមន៍ (CLS), បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា (CPN+) និង CamASEAN - បានរៀបចំសំណើរួមគ្នាមួយស្តីពីសិទ្ធិរបស់មនុស្ស LGBT ដាក់ជូនទៅកិច្ចប្រជុំត្រួតពិនិត្យតាមពេលកំណត់ជាសកល (UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (HRC)។ អង្គការ CCHR រួមជាមួយដៃគូដទៃទៀតក្នុងតំបន់ ដូចជាបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍អាស៊ីប៉ាស៊ីហ្វិក (APN+) និងគំនិតផ្តួចផ្តើមស្តីពីសិទ្ធិផ្លូវភេទ ក៏បានរៀបចំសំណើពាក់ព័ន្ធមួយដែរ ដែលផ្តោតលើ SOGI សិទ្ធិផ្លូវភេទ និងមេរោគអេដស៍។[40] ដូចជាសំណើជាច្រើនដទៃទៀតដែរ សំណើនេះមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ ទោះបីជាយ៉ាងណាក្តី ការដែលអង្គការសង្គមស៊ីវិលអាចជួបជុំគ្នា និងដាក់សំណើទាំងនេះ មានន័យថា ជាជំហានដ៏សំខាន់មួយនៅក្នុងការតស៊ូមតិគាំទ្រសិទ្ធិរបស់មនុស្ស LGBT ផងដែរ។

គំនិតផ្តួចផ្តើមជាច្រើនដើម្បីគាំទ្រដល់ការយល់ដឹងអំពីសិទ្ធិរបស់មនុស្ស LGBT ត្រូវបានបង្កើតឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ សាស្ត្រាចារ្យសកលវិទ្យាល័យកម្ពុជាមួយចំនួន បានរៀបចំសិក្ខាសាលាស្តីពី LGBT និងបញ្ហា SOGI នៅក្នុងវគ្គសិក្សាស្តីពីយេនឌ័ររបស់ពួកគេ។ គំនិតផ្តួចផ្តើមជួយខ្លួនឯងជាច្រើន គាំទ្រដោយផ្ទាល់ដល់មនុស្សស្រឡាញ់ប្រុសដូចគ្នា និងមនុស្សប្តូរភេទនៅក្នុងស្ថានភាពលំបាកនានា ដូចជា "Cindy Donation" (ដាក់ឈ្មោះតាមអ្នកប្តូរភេទដ៏មានប្រជាប្រិយម្នាក់) និងមូលនិធិសង្គ្រោះបន្ទាន់សម្រាប់បុរសដែលរួមភេទជាមួយបុរសដែលផ្ទុកមេរោគអេដស៍ (គាំទ្រដោយសប្បុរសជនឯកជនមកពីប្រទេសហូឡង់ដ៍)។ នេះគឺជាអំណោយសប្បុរសដែលត្រូវបានធ្វើឡើងដោយបុគ្គលទាំងឡាយដែលឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរកជំនួយ ពីបុរសដែលរួមភេទជាមួយបុរសដែលផ្ទុកមេរោគអេដស៍ ឬស្ត្រីរកស៊ីផ្លូវភេទដែលជាមនុស្សប្តូរភេទដែលស្ថិតក្នុងស្ថាន

[38]CCHR (2012) "ឥន្ទធនូខ្មែរ: ពីបុរេនិច្ឆ័យទៅជាមោទនភាព", ទំព័រ ១០.

[39]សេចក្តីថ្លែងការណ៍របស់សភាប្រជាជននៅថ្នាក់មូលដ្ឋាននៃអាស៊ាន (AGPA), ២០១២។ ទាញចេញពី៖ http://iglhrc.org/content/asean-grassroots-people's-assembly-people's-statement

[40]CCHR, បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍អាស៊ីប៉ាស៊ីហ្វិក និងគំនិតផ្តួចផ្តើមស្តីពីសិទ្ធិផ្លូវភេទ ។ (២០១៣)។ ការដាក់បញ្ជូនសេចក្តីថ្លែងការណ៍ទៅកាន់កិច្ចប្រជុំត្រួតពិនិត្យតាមពេលកំណត់សកលលើកទី១៨ (18th UPR)- កម្ពុជា

ភាពក្រីក្រធ្ងន់ធ្ងរ និងសុខភាពមិនល្អ រស់នៅតែម្នាក់ឯង និងឯកោ គ្មានការគាំទ្រពីគ្រួសាររបស់ពួកគេ។ពុំមានគំនិតផ្តួចផ្តើមសប្បុរសដែលមានគោលដៅស្រដៀងគ្នាសម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រុសប្តូរភេទនោះឡើយ លើកលែងតែសម្រាប់ការគាំទ្រតាមធម្មតាពីមិត្តភក្តិ និងគ្រួសារនៅពេលត្រូវការ។

## *ការវិវត្តន៍ថ្មីៗ៖ ប្រព័ន្ធផ្សព្វផ្សាយ នគរូបនីយកម្ម និងបច្ចេកវិទ្យាថ្មីៗ*

ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាថ្មីៗ កំពុងត្រូវបានប្រើប្រាស់សម្រាប់តស៊ូមតិគាំទ្រមនុស្ស LGBT។ ជាផ្នែកមួយនៃគម្រោង SOGI អង្គការ CCHR ប្រើប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកសម្រាប់តស៊ូមតិ។ អង្គការនេះបានរៀបចំ "Rainbow Portal" អនឡាញ ដែលដាក់បញ្ចូលបង្ហាញព័ត៌មាននិងឯកសារនានាអំពីបញ្ហាសិទ្ធិមនុស្សរបស់បុគ្គល LGBT ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត។ ការចូលទស្សនាគេហទំព័រនេះហាក់ដូចជានៅមានកម្រិតទាបនៅឡើយ[41]។ ឧបករណ៍និងសៀវភៅណែនាំជាច្រើនសម្រាប់ការតស៊ូមតិ និងការកាត់បន្ថយការមាក់ងាយនៅក្នុងចំពោះ MSM និងមនុស្សប្តូរភេទ ត្រូវបានបង្កើតឡើងដូចជា ការសម្របតាមបរិបទកម្ពុជាឆ្នាំ២០១០ នៃការយល់ដឹង និងការជំនះការមាក់ងាយចំពោះបុរសដែលរួមភេទជាមួយបុរស និង និងទម្រង់ជាភាសាខ្មែរនិងអង់គ្លេសដែលនឹងចេញផ្សាយក្នុងពេលខាងមុខនៃ ការនិយាយចេញមក - ឯកសារជំនួយស្មារតីសម្រាប់ (ឯកសារសម្របតាមបរិបទកម្ពុជា) ។[42] ខណៈពេលដែលការតស៊ូមតិនេះភាគច្រើនធ្វើឡើងនៅក្នុងវិស័យមេរោគអេដស៍និងសេវាសុខភាព ការងារនៅក្នុងវិស័យផ្សេងៗទៀតក៏បានចាប់ផ្តើមផងដែរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ជាមួយនឹងការកើនឡើងនូវនគរូបនីយកម្ម សកលភាវូបនីយកម្ម ឱកាសក្នុងការប្រើអ៊ិនធើណិត និងបណ្តាញសង្គម, យុវជនកម្ពុជានៅក្នុងទីក្រុងនានាកំពុងតែយល់ដឹងនិងមានទំនុកចិត្តកាន់តែច្រើនអំពីបញ្ហាផ្លូវភេទនិងការសំដែងពីភេទរបស់ពួកគេ។ បច្ចុប្បន្ននេះ យុវជនខ្មែរកាន់តែច្រើនថែមទៀត[43] បង្ហាញអត្តសញ្ញាណខ្លួនឯងជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ឬមនុស្សស្រីស្រឡាញ់ភេទដូចគ្នា។ ភ្នំពេញ និងសៀមរាប ត្រូវបានគេចាត់ទុកថាជាទី

---

[41] Khmer Rainbow portal: http://sogi.sithi.org

[42]USAID, PACT & មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវអំពីស្ត្រី (ICRW). (2010). ការយល់ដឹងនិងការជំនះការមាក់ងាយចំពោះបុរសដែលរួមភេទជាមួយបុរស៖ ឯកសារជំនួយស្មារតីសម្រាប់សកម្មភាព (ការសម្របតាមបរិបទកម្ពុជា), ទំព័រ ៣២៥ មានទម្រង់ជាភាសាអង់គ្លេសនិងខ្មែរ។ ការបោះពុម្ពផ្សាយក្នុងពេលខាងមុខ ក្នុងឆ្នាំ២០១៤ គឺ៖ ពី Salas, Vicente. (2014) ការនិយាយចេញ - ឯកសារជំនួយស្មារតី សម្រាប់ការតស៊ូមតិដែលដឹកនាំដោយ MSM និងមនុស្សប្តូរភេទ" (ទម្រង់ជាភាសាខ្មែរនិងអង់គ្លេសសម្របសម្រាប់បរិបទកម្ពុជា)។ វេទិកាសកលស្តីពី MSM និង HIV (MSMGF)

43 "យុវជនខ្មែរ" សំដៅលើយុវជនកម្ពុជា ដែលស្ថិតនៅក្នុងក្រុមជនជាតិភាគតិច ដែលភាគច្រើនមិនបានទទួលការអប់រំក្នុងប្រព័ន្ធ។

កន្លែងដែលមានសុវត្ថិភាពជាងគេសម្រាប់មនុស្សម្នាធ្វើការជួបជុំនិងរាប់អានគ្នា[44] ទោះបីជាទស្សនៈនេះចេញពីក្រុមមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីប្តូរភេទភាគច្រើនលើសលុបក្តី។ ភ្នំពេញនិងសៀមរាប មានមជ្ឈមណ្ឌលអប់រំរបស់អង្គការក្រៅរដ្ឋាភិបាលកម្មវិធីចុះអប់រំដោយមិត្តភក្តិ និងគ្លីនិកសុខភាពផ្លូវភេទ។[45] បារ ក្លឹប តន្ត្រីឌីស្កូសម្រាប់មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា, សូណា សម្រាប់តែបុរស, ស្ប៉ា និងហាងម៉ាស្សា, ផ្ទះសំណាក់ សណ្ឋាគារ និងមណ្ឌលកម្សាន្ត បាននិងកំពុងរីកដុះដាលយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

បច្ចុប្បន្ននេះ សិល្បៈ ភាពយន្ត និងការសំដែងរឿងដែលទាក់ទងនឹងមនុស្ស LGBT មានកាន់តែច្រើន។ ការសំដែងសិល្បៈដោយមនុស្សប្តូរភេទ គឺជាឈុតឆាកមួយរបស់មនុស្សប្រុសស្រឡាញ់ភេទដូចគ្នាទាំងនៅខេត្តសៀមរាប និងភ្នំពេញ។ ការតាំងពិព័រណ៌សិល្បៈនិងរូបថតជាច្រើនដែលផ្តោតលើប្រធានបទ LGBT ត្រូវបានរៀបចំឡើង។[46] ភាពយន្តក្នុងស្រុកអំពីមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និង មនុស្សស្រីស្រឡាញ់ភេទដូចគ្នាផលិតមកសម្រាប់រោងភាពយន្ត ឬឯករាជ្យ ត្រូវបានដាក់បញ្ចាំងនៅតាមទីកន្លែងផ្សេងៗក្នុងរាជធានីភ្នំពេញ ដោយទទួលបានទស្សនៈជាវិជ្ជមានពីសាធារណជនទូទៅ។ ព័ត៌មានអំពីបុគ្គល LGBT មាននៅតាមប្រព័ន្ធផ្សព្វផ្សាយទូទៅផងដែរ ប៉ុន្តែច្រើនតែមានលក្ខណៈអវិជ្ជមានលំអៀង និងផ្ទុត់គំនិតអវិជ្ជមាន ជាពិសេសនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក (ជាភាសាខ្មែរ)។ ឧទាហរណ៍ មនុស្សប្តូរភេទ ត្រូវបានគេយល់ទូទៅថាជា ចោរ។[47]

ពាក្យក្នុងស្រុកជាច្រើនថែមទៀតកំពុងតែលេចចេញឡើង។ ពាក្យ*ស៊ីមពីរ* សំដៅលើការមានកាតម៉ូឌុលដែលមានអត្តសញ្ញាណអ្នកជាវពីរនៅក្នុងទូរស័ព្ទតែមួយ ហើយត្រូវបានប្រើប្រាស់ដោយមនុស្សប្រុសស្រឡាញ់ភេទដូចគ្នាវ័យក្មេង និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នាជាច្រើន ដែលមានន័យថា មនុស្សម្នាក់ចូលចិត្តរួមភេទជាមួយប្រុសផង ជាមួយស្រីផង។[48] ពាក្យ*ស៊ីមបី* សំដៅលើមនុស្សដែលអាចស្រឡាញ់ប្រុស ស្រី និងមនុស្សប្តូរភេទ/ខ្ទើ

---

[44] Lindstrom, N. "Drag Queen Divas" ជីវិតអាស៊ី ភ្នំពេញ, ចេញផ្សាយលេខ ២៩ (លេខ ២៩), ខែឧសភា ឆ្នាំ២០០៩ ទំព័រ ២៥-២៦; Gharbi, S., "Gay Scene និង Grindr on KohPich" ៧ ថ្ងៃ, ភ្នំពេញប៉ុស្តិ៍, ថ្ងៃ ១៤-២០ ខែ ធ្នូ ឆ្នាំ ២០១២. លេខ ១៧៣, ទំព័រ ៨

[45] Lindstrom, N. "M Style" ជីវិតអាស៊ី ភ្នំពេញ,លេខ ២៩, ខែឧសភា ឆ្នាំ ២០០៩, ទំព័រ ២៧; អង្គការក្រៅរដ្ឋាភិបាល និង អង្គការនៅសហគមន៍មួយចំនួន ដូចជា MHC, MHSS, CSSD, KDFO, និង KHEMARA គឺជាផ្នែកមួយនៃកម្មវិធី M-style. RHAC និង MEC មានគ្លីនិកពិសេសសម្រាប់ MSM និងមនុស្សប្តូរភេទដើម្បីបង្ការមេរោគអេដស៍។ បណ្តាញជាតិនៃអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា, មានគម្រោងសម្រាប់ MSM និងមនុស្សប្តូរភេទដែលផ្ទុកមេរោគអេដស៍។

[46] ក្នុងអំឡុងពេលប្រារព្ធទិវាមោទនភាព, ការតាំងពិព័រណ៌នេះរួមបញ្ចូលការតាំងពិព័រណ៌សិល្បៈយេនឌ័រនិងផ្លូវភេទ (២០០៩), Thoamada I & II, 2012 និង 2013, និងការតាំងពិព័រណ៌រូបថតដែលទទួលបានពានរង្វាន់ "ការជ្រើសរើសពណ៌ផ្កាឈូក" (រូបថត ភ្នំពេញ ២០១៣)

[47]MacIsaac, V, "៧ សំណួរ" ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២។ សកម្មជនសិទ្ធិ LGBT ម្នាក់ ត្រូវបានគេដកស្រង់សំដីនៅក្នុងអត្ថបទនេះ។

[48] ពាក្យដែលគេប្រើក្នុងស្រុកសម្រាប់បុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា ត្រូវបានពិណ៌នាលើក្រដាសដោយ Tan; Catalla et al; Earth; Salas V et al; និងនៅក្នុងឯកសារ "និយាយចេញមកក្រៅ": ឯកសារជំនួយស្មារតីសម្រាប់ការតស៊ូមតិដែលដឹកនាំ

យ។ មនុស្សស្រីស្រឡាញ់ភេទដូចគ្នាវ័យក្មេង បានបង្កើតពាក្យផ្ទាល់ខ្លួនរបស់គេ និងប្រភេទនៃមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ដូចជា‘WLW’, ‘LB’, ‘LG’ និង ‘LT’។[49] ពាក្យទាំងនេះគឺជាផលិតផលនៃការប៉ះប្រសព្វគ្នារវាងបច្ចេកវិទ្យាថ្មី និងតម្រូវការឲ្យមានភាពសម្ងាត់ សូម្បីតែនៅពេលដែលមនុស្ស LGBT ខំតស៊ូឲ្យមានការទទួលស្គាល់កាន់តែច្រើនផងដែរ (សូមមើលឧបសម្ព័ន្ធទី២៖ សន្ទានុក្រមនៃពាក្យដែលគេប្រើទូទៅ)។ ថ្មីៗនេះ ឃ្លាថា *ភេទទីបី* ហាក់ដូចជាកំពុងតែទទួលបានការពេញនិយមច្រើន ដើម្បីរៀបរាប់អំពីបុគ្គល LGBT នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ហើយបច្ចុប្បន្ននេះ ត្រូវបានគេចាត់ទុកថាជាពាក្យដែលគេអាចទទួលយកបានច្រើនជាងពាក្យផ្សេងៗទៀត។[50]

## *ការវិវត្តន៍ថ្មីៗ៖ អ្នកគាំទ្រថ្នាក់ជាតិ តំបន់ និងអន្តរជាតិ*

ចាប់តាំងពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ចេញសេចក្តីថ្លែងការណ៍គាំទ្រមនុស្ស LGBT កាលពីខែធ្នូ ឆ្នាំ២០១២ មក ក្រសួងកិច្ចការនារី ទទួលស្គាល់កាន់តែច្រើននូវសារៈសំខាន់នៃបញ្ហា LGBT។ នៅក្នុងឆ្នាំ២០១៤ ក្រសួងកិច្ចការី នឹងអនុវត្តការប៉ាន់ប្រមាណយេនឌ័រសម្រាប់កម្ពុជាដែលរួមបញ្ចូលទាំងក្រុមភាគតិចផ្លូវភេទ ។ ផែនការសកម្មភាពជាតិទីពីរដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) មានបញ្ជាក់ពីអំពើហិង្សាលើ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ(LBT)។ តំណាងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទ បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងការរៀបចំ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ។[51]

ដៃគូអភិវឌ្ឍន៍របស់កម្ពុជា បានគាំទ្រគំនិតផ្តួចផ្តើមផ្សេងៗទៀត។ OHCHR បានផ្តល់យោបល់ផ្នែកច្បាប់ក្នុងករណីមនុស្សស្រីស្រឡាញ់ភេទដូចគ្នាម្នាក់ ដែលត្រូវបានគេបំបែកពីដៃគូដោយបង្ខំ ឬចោទប្រកាន់មិនពិតអំពីការជួញដូរមនុស្ស និងការចាប់ជំរិត។ គ្រូសារអង្គការសហប្រជាជាតិបានផ្តល់សារគាំទ្រដល់សកម្មភាពមោទនភាព ក្នុងប្រទេសកម្ពុជា ។[52] ការិយាល័យអង្គការសហប្រជាជាតិជាច្រើន បានដាក់បង្ហាញទង់ឥន្ទធនូ LGBT យ៉ាងច្បាស់ នៅក្នុងអំឡុងសប្តាហ៍មោទនភាព ។

---

ដោយ MSM និងមនុស្សប្តូរភេទ” (ការសម្របសម្រាប់បរិបទកម្ពុជា)។ វេទិកាសកលស្តីពី MSM និងមនុស្សប្តូរភេទ និងមេរោគអេដស៍ (នឹងមកដល់ក្នុងពេលឆាប់ៗ ឆ្នាំ២០១៤)

[49] “WLW” - ស្រីស្រឡាញ់ស្រី; LG – “ស្រីស្រឡាញ់ភេទដូចគ្នាដែលមានចរិតជាមនុស្សស្រី”; LB – “ស្រីស្រឡាញ់ភេទដូចគ្នាដែលមានចរិតជាមនុស្សប្រុស” ; LT - “ស្រីតែងខ្លួនជាប្រុស ឬមនុស្សប្រុសប្តូរភេទ”

[50] ការប្រាស្រ័យទាក់ទងបុគ្គល៖ Chanthorn Phorng, Cindy, Bunthorn, Hong Reaksmey, Meas Chanthan, និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀតជាច្រើន

[51] ការប្រាស្រ័យទាក់ទងបុគ្គល, RC (ទីប្រឹក្សាយេនឌ័រនិងប្រាស្រ័យទាក់ទងអមក្រសួងកិច្ចការនារី) ខែកុម្ភៈ ឆ្នាំ២០១៤

[52] http://www.un.org.kh/index.php/newsroom/speach-and-statement/629-2013-prideweek, និង http://asiapacific.unwomen.org/en/news-and-events/stories/2012/6/op-ed-cambodia-pride-week-12-to-20-may2012

ស្ថានទូតចក្រភពអង់គ្លេស ស៊ុយអែត និងសហរដ្ឋអាមេរិកបានគាំទ្រដល់សហគមន៍មនុស្សLGBT នៅកម្ពុជា រួមទាំងសកម្មភាពមោទនភាព LGBT ផងដែរ។ គំនិតផ្តួចផ្តើមថ្នាក់តំបន់អាស៊ាននិងថ្នាក់សកលដទៃទៀត រួមមាន យុទ្ធនាការ "សេរីភាព និងសមភាព" របស់ OHCHR[53] និងគំនិតផ្តួចផ្តើម 'Being LGBT in Asia' របស់USAID/UNDP។[54] ការគាំទ្រផ្នែកថវិកាសម្រាប់បញ្ហា LGBT និងសិទ្ធិមនុស្ស កំពុងតែកើនឡើង។ ការប្រកាសរកសំណើរបស់សភាពអឺរ៉ុប គម្រោងអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស (EIDHR, ២០១៣)នាពេលថ្មីៗនេះលើកទឹកចិត្តដល់ការតស៊ូមតិតាមប្រព័ន្ធផ្សព្វផ្សាយសម្រាប់សិទ្ធិរបស់ក្រុមឯកោ រួមទាំងបុគ្គល LGBT។

នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ការបោះពុម្ពឯកសារនាពេលថ្មីៗរបស់ UNDP និងសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកស្តីពីសុខភាពផ្លូវភេទបុរស (APCOM) ផ្តោតលើមេរោគអេដស៍និងសុខភាពសម្រាប់ MSM។ ឯកសារទាំងនេះក៏និយាយផងដែរអំពីសុខភាព សិទ្ធិមនុស្ស និងបញ្ហាដែលត្រូវយកចិត្តទុកដាក់សម្រាប់មនុស្សប្តូរភេទ រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ[55]។ ថ្មីៗនេះ ជនជាតិកម្ពុជាដែលជាមនុស្សប្តូរភេទ បានចូលរួមក្នុងបណ្តាញថ្នាក់តំបន់នៃមនុស្សប្តូរភេទដែលទើបបង្កើតថ្មីឈ្មោះថាបណ្តាញមនុស្សប្តូរភេទអាស៊ីប៉ាស៊ីហ្វិ(APTN)។

បច្ចុប្បន្នេះ សកម្មជន LGBT នៅកម្ពុជា ត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ស៊ូ សុធាវី បានទទួលពានរង្វាន់ ដេវីដកាតូ វីសិន អេន វ៉យ (David Kato Vision and Voice)។[56] ផ្តល់ជូនជារៀងរាល់ឆ្នាំ រង្វាន់នេះត្រូវបានផ្តល់ជូនបុគ្គលដែលបង្ហាញពីសេចក្តីក្លាហាននិងភាពជាអ្នកដឹកនាំដ៏ឆ្នើមនៅក្នុងការតស៊ូមតិគាំទ្រសិទ្ធិរបស់បុគ្គលLGBT ជាពិសេស នៅក្នុងកាលៈទេសៈលំបាកៗ និងបរិយាកាសគោលនយោបាយដែលមិនអំណោយផល។

---

[53]OHCHR. (2012) កើតមកមានសេរីភាព និងសមភាព - ទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

[54]USAID RDMA & UNDP APRC, (2012). "សេចក្តីសង្ខេប Being LGBT in Asia - ការពិនិត្យឡើងវិញនិងការវិភាគតាមបែបចូលរួមនៃបរិយាកាសច្បាប់និងសង្គមសម្រាប់បុគ្គល LGBT និងសង្គមស៊ីវិល"

[55]UNDP និងបណ្តាញមនុស្សប្តូរភេទអាស៊ីប៉ាស៊ីហ្វិក (APTN), (២០១២)។ "បាត់បង់ក្នុងពេលអន្តរកាលៈ មនុស្សប្តូរភេទ សិទ្ធិ និងភាពងាយរងគ្រោះដោយមេរោគអេដស៍នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក"។ APCOM & APTN, (2013) "មើលរំលង មិនយកចិត្តទុកដាក់ បំភ្លេច - មេរោគអេដស៍ និងសិទ្ធិជាមូលដ្ឋានរបស់មនុស្សប្តូរភេទនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក - សេចក្តីសង្ខេបគោលនយោបាយ

[56]http://www.prnewswire.com/news-releases/cambodian-transgender-activist-sou-sotheavy-wins-2014-david-kato-vision--voice-award-244929501.html.ពានតរង្វាន់ ដេវីដកាតូ វីសិន អេណ វ៉យ (DKVVA) ទទួលស្គាល់ និងគាំទ្រដល់ការងាររបស់មេដឹកនាំដែលខិតខំថែរក្សាសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ (LGBTI) ជុំវិញពិភពលោក។ ព័ត៌មានបន្ថែមអំពី DKVVA អាចមើលតាម http://www.visionandvoiceaward.com.

## កិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហគមន៍ LGBT

កិច្ចពិភាក្សាថ្នាក់ជាតិនៅកម្ពុជាស្តីពីសហគមន៍មនុស្ស LGBT ត្រូវបានធ្វើឡើងនៅក្នុងរាជធានីភ្នំពេញពីថ្ងៃទី២០ ដល់ ២១ ខែមករា ឆ្នាំ២០១៤ ជាសកម្មភាពគន្លឹះមួយនៃសមាសភាគរបស់គំនិតផ្តួចផ្តើម "Being LGBT in Asia" សម្រាប់កម្ពុជា។ កិច្ចសន្ទនាថ្នាក់ជាតិនេះ ត្រូវបានរៀបចំឡើងជាសហប្រតិបត្តិការមួយក្នុងចំណោមអង្គការសហប្រជាជាតិ រដ្ឋាភិបាលសហរដ្ឋអាមេរិក និងទីប្រឹក្សាបច្ចេកទេសឯករាជ្យ និងត្រូវបានចែកចេញជាពីរថ្ងៃ។

ថ្ងៃទីមួយនៃកិច្ចពិភាក្សាថ្នាក់ជាតិនេះ មានគោលបំណងផ្តល់ឱកាសសុវត្ថិភាពសម្រាប់តំណាងសហគមន៍ LGBT ដើម្បីពិនិត្យមើលបញ្ហា និងក្តីកង្វល់សំខាន់ៗរបស់បុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា។អ្នកចូលរួមអាចនិយាយដោយសេរីនិងយ៉ាងច្រើនអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ក៏ដូចជា បញ្ហានិងក្តីកង្វល់នានា ដោយផ្តោតលើប្រធានបទប្រាំមួយ៖ ជីវិតបុគ្គលនិងគ្រួសារ សហគមន៍ និងសង្គម ការអប់រំ សុខភាព ការងារ និងប្រព័ន្ធផ្សព្វផ្សាយ។ អ្នកចូលរួមចំនួន ៥១នាក់ ចំណោម ៥៩នាក់ គឺជាសមាជិកសហគមន៍ ហើយអ្នកចូលរួមចំនួន៨នាក់ មកពីទីភ្នាក់ងារអង្គការសហប្រជាជាតិ និង USAID ដើម្បីផ្តល់ការគាំទ្រសម្រាប់ដំណើរការប្រជុំ។ អ្នកចូលរួមទាំង ៥៩នាក់ មកពី ១៨ខេត្ត ក្នុងចំណោមខេត្ត និងក្រុងទាំង ២៤ នៅក្នុងប្រទេសកម្ពុជា។ តំណាងអង្គការចំនួន ៦ ដែលធ្វើការជាមួយ ឬគាំទ្របុគ្គល LGBT ក៏បានចូលរួមក្នុងកិច្ចពិភាក្សានេះដែរ។ អ្នកតំណាងចំនួន ២៥នាក់ មកពីរាជធានីភ្នំពេញ ហើយ ៣៤នាក់មកពីខាងក្រៅរាជធានីភ្នំពេញ។ ក្រុមនីមួយៗមានលក្ខណៈចម្រុះ ដោយក្នុងនោះរួមមាន មនុស្សស្រីស្រឡាញ់ភេទដូចគ្នា ៣នាក់ មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ៩នាក់ មនុស្សស្រីស្រឡាញ់ភេទទាំងពីរចំនួន ៥នាក់ មនុស្សប្រុសស្រឡាញ់ភេទទាំងពីរ ១នាក់ មនុស្សស្រីប្តូរភេទ ៦នាក់ មនុស្សប្រុសប្តូរភេទ ១៦នាក់ បុរសដែលរួមភេទជាមួយបុរស ១នាក់ មិនស្គាល់អត្តសញ្ញាណភេទ ១នាក់ និង អ្នកគាំទ្រមនុស្សស្រលាញ់ភេទដូចគ្នា ១៧នាក់ ដែលសន្មត់ថា ជាមនុស្សស្រឡាញ់ភេទផ្ទុយគ្នា។

កិច្ចប្រជុំចាប់ផ្តើមដោយមានការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន។ អ្នកចូលរួមបានប្រើវិធីសាស្ត្រតាមបែបចូល ហៅថា "លំហាត់ខ្សែជីវិត" ដើម្បីរំលឹកឡើងវិញពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជីវិតបុគ្គល ជាមនុស្សLGBT។ បន្ទាប់មក ពួកគេបានគូសផែនទីអំពីបទពិសោធន៍ទាំងនេះនៅលើក្រដាសមួយសន្លឹក ដោយបង្ហាញពីអាយុ និងពេលវេលាដែលព្រឹត្តិការណ៍ទាំងនេះបានកើតឡើង ដោយប្រើរូបសញ្ញា និងពណ៌ផ្សេងៗដែលប្រើដើម្បីសម្គាល់ពីផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមានមកលើបុគ្គលនោះ។ បន្ទាប់មក មានការពិភាក្សាគ្នាយោងទៅតាមប្រធានបទ រួមទាំងដំណោះស្រាយនិងអនុសាសន៍ដែលអាចមាន។ អ្នកចូលរួមពីរបីនាក់ ត្រូវបានជ្រើសរើសឲ្យធ្វើបទបង្ហាញដល់ភាគីពាក់ព័ន្ធនៅថ្ងៃទីពីរ។

គោលបំណងនៃថ្ងៃទីពីរនៃកិច្ចពិភាក្សាថ្នាក់ជាតិនេះ គឺដើម្បីបង្ហាញពីលទ្ធផលដែលបានមកពីការពិភាក្សាក្នុងថ្ងៃទីមួយ ដល់ក្រុមធំមកពីខាងក្រៅសហគមន៍ LGBT បន្ទាប់មកមាន

ការពិភាក្សាតាមដានបន្ត។ នៅចុងបញ្ចប់នៃកិច្ចពិភាក្សា មានសេចក្តីថ្លែងការណ៍ពីមន្ត្រីរបស់ UNDP APRC, OHCHCR Cambodia, USAID/Cambodia, USAID/RDMA, និង UNAIDS កម្ពុជា។ របកគំហើញពីការសិក្សាស្រាវជ្រាវមួយ[57] អំពីការផាត់ចេញពីសង្គមនូវបុគ្គល LGBT ពីយន្តការគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា ("របាយការណ៍ស្តីពីការផាត់ចេញពីសង្គម") ត្រូវបានបង្ហាញជូនអ្នកចូលរួមផងដែរ។

មានអ្នកចូលរួមប្រមាណ ៩៩នាក់ នៅថ្ងៃទី២ មកពីអង្គការក្រៅរដ្ឋាភិបាលចំនួន១១ ដែលធ្វើការលើបញ្ហា LGBT ទីភ្នាក់ងារអង្គការសហប្រជាជាតិទាំងអស់ (UNDP, OHCHCR, UN Women, UNV, ILO, WHO, UNAIDS និង UNESCO) និងដៃគូអភិវឌ្ឍន៍ទ្វេភាគី ដូចជាស្ថានទូតអាមេរិក និងស្ថានទូតស៊ុយអែត។ តំណាងប្រព័ន្ធផ្សព្វផ្សាយ គ្រូនៅតាមសកលវិទ្យាល័យ និស្សិតដែលកំពុងសិក្សាផ្នែកយេនឌ័រ អ្នកស្រាវជ្រាវឯករាជ្យ និងមន្ត្រីឃុំនៅមូលដ្ឋាន ក៏បានចូលរួមនៅក្នុងកិច្ចពិភាក្សានេះដែរ។

## ក្នុងនាមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទនៅអាស៊ី (Being LGBT in Asia)

គំនិតផ្តួចផ្តើម 'Being LGBT in Asia: ការពិនិត្យឡើងវិញនិងការវិភាគតាមបែបចូលរួមនៃបរិយាកាសច្បាប់និងសង្គមសម្រាប់សង្គមស៊ីវិល LGBT' ក្រោមកិច្ចសហប្រតិបត្តិការមួយរវាង UNDP និង USAID មានគោលបំណងស្វែងយល់ គូសផែនទី និងវិភាគពីស្ថានភាពនៃសិទ្ធិរបស់បុគ្គលLGBT នៅក្នុងសហគមន៍និងប្រទេសនានា ដោយធ្វើការវិភាគនិងពិនិត្យឡើងវិញលើស្ថានភាពរបស់សហគមន៍ LGBT និងសិទ្ធិមនុស្សរបស់ពួកគេនៅក្នុងប្រទេសទាំងឡាយក្នុងអាស៊ី។គំនិតផ្តួចផ្តើមនេះ កើតឡើងចំពេលដែលមានបញ្ហាប្រឈមផ្នែកសិទ្ធិមនុស្សរបស់បុគ្គលLGBT ទូទាំងពិភពលោកប៉ុន្តែដោយមានការបង្កើនការចូលរួមរបស់អន្តរជាតិជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ប្រធានាធិបតីសហរដ្ឋអាមេរិក និងរដ្ឋមន្ត្រីក្រសួងការបរទេស ដែលបានសំដែងពីការព្រួយបារម្ភ។

តាមរយៈការអភិវឌ្ឍចំណេះដឹងថ្មី និងទំនាក់ទំនង, គំនិតផ្តួចផ្តើម'Being LGBT in Asia' ព្យាយាមធ្វើឲ្យប្រសើរឡើងនូវបណ្តាញអង្គការLGBT នៅក្នុងតំបន់អាស៊ីភាគខាងត្បូង ខាងកើត និងអាស៊ីអាគ្នេយ៍ និង ផ្តល់ជាមូលដ្ឋានសម្រាប់ការតាក់តែងគោលនយោបាយ និងកម្មវិធីនៅក្នុងបរិបទនៃការអភិវឌ្ឍតាមរយៈដំណើរការតាមបែបចូលរួម ដែលសង្កត់ធ្ងន់លើ

[57] Salas V & Srun S. (2013). "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទនៅក្នុងគ្រួសារនិងសហគមន៍ និងវិធីដោះស្រាយរបស់ពួកគេ។" របាយការណ៍ស្រាវជ្រាវ។ ផ្នែកសម្របសម្រួលការគាំពារសង្គម ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មជនបទ (SPCU-CARD) ភ្នំពេញ។

អភិក្រមថ្មីៗ រួមទាំងការប្រើវីដេអូ អ៊ីធើណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។គំនិតផ្តួចផ្តើមនេះមានគោលដៅសម្រេចឲ្យបានការសិក្សាទ្វេទិស បង្កើតទិន្នន័យគោល ធៀបនឹងបញ្ហាច្បាប់ និងសិទ្ធិមនុស្ស និងផ្តល់សិទ្ធិអំណាចដល់អ្នកចូលរួមដែលជាមនុស្ស LGBT។ វានឹងជួយផងដែរដល់ការបង្កើតឧបករណ៍ពហុបច្ចេកវិទ្យា និងប្រព័ន្ធសង្គម និងធនធាន ជំរុញការចូលរួមពីមេដឹកនាំយុវជន ដើម្បីគាំទ្រសង្គមស៊ីវិលនៃ LGBT និងដើម្បីលើកកម្ពស់សមត្ថភាពរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក និងគ្រួសារអង្គការសហប្រជាជាតិ ដើម្បីធ្វើការជាមួយអង្គការសង្គមស៊ីវិល LGBT នៅទូទាំងអាស៊ី។

គោលដៅសំខាន់មួយរបស់គំនិតផ្តួចផ្តើម ‘Being LGBT in Asia’ គឺប្រមូលផ្តុំសហាគមន៍បុគ្គល និងអង្គការនានាដែលធ្វើការលើបញ្ហា LGBT នៅទូទាំងតំបន់ ជាពិសេសនៅក្នុងប្រទេសគោលដៅទាំង៨ រួមទាំងដៃគូអភិវឌ្ឍន៍ រដ្ឋាភិបាល អង្គការសង្គមស៊ីវិល LGBT និងអង្គការសាសនា។ តាមរយៈការវិនិយោគលើការបង្កើតបណ្តាញអន្តរកម្មប្រកបដោយភាពច្នៃប្រឌិតក្នុងចំណោមស្ថាប័ន និងដៃគូអភិវឌ្ឍន៍នៅមូលដ្ឋាន ភាគីពាក់ព័ន្ធទាំងអស់នឹងមានសមត្ថភាពកាន់តែប្រសើរក្នុងពេលអនាគតដើម្បីសម្រេចបាននូវអភិក្រមនិងកម្មវិធីអភិវឌ្ឍន៍ដែលរួមបញ្ចូលមនុស្សLGBT ។ នៅក្នុងប្រទេសនីមួយៗ "កិច្ចពិភាក្សាសហគមន៍ថ្នាក់ជាតិ" គឺជាសកម្មភាពគន្លឹះដំបូងបំផុត។

# ទិដ្ឋភាពរួមនៃសិទ្ធិមនុស្សរបស់បុគ្គលLGBT នៅក្នុងប្រទេសកម្ពុជា

## បរិយាកាសច្បាប់និងគោលនយោបាយ

ប្រព័ន្ធច្បាប់របស់កម្ពុជា មានលក្ខណៈអព្យាក្រឹតគួរសមសម្រាប់បុគ្គល LGBT បើប្រៀបធៀបជាមួយប្រទេសដទៃទៀត។ បើពិនិត្យមើលមួយផ្នែក សកម្មភាពភេទដូចគ្នា (ទាំងទំនាក់ទំនង ឬសកម្មភាពផ្លូវភេទ) មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ប៉ុន្តែបើពិនិត្យមើលមួយផ្នែកទៀត ច្បាប់មិនទទួលស្គាល់បុគ្គល LGBT ហើយមិនបញ្ជាក់អំពីការរើសអើងប្រឆាំងនឹងបុគ្គល LGBT ឡើយ។ ពុំមានការគាំពារផ្នែកច្បាប់សម្រាប់បុគ្គល LGBT ទេ។ ពុំមានការហាមឃាត់ការរើសអើង ដែលទាក់ទងនឹងទំនោរផ្លូវភេទ និង/ឬ អត្តសញ្ញាណយេនឌ័រឡើយ ហើយក៏គ្មានទណ្ឌកម្មសម្រាប់អ្នកដែលរំលោភសិទ្ធិមនុស្សរបស់បុគ្គល LGBT ដែរ។ បន្ថែមពីលើនេះ ពុំមានការទទួលស្គាល់ផ្នែកច្បាប់នៃដៃគូភេទដូចគ្នាឡើយ[58] ប៉ុន្តែដៃគូភេទដូចគ្នាមិនត្រូវបានហាមឃាត់ពីការសុំកូនចិញ្ចឹមនោះទេ។ អាយុសម្រាប់ការរួមភេទដោយមានការយល់ព្រមតាមច្បាប់ គឺដូចគ្នាសម្រាប់គ្រប់ភេទ និងយេនឌ័រទាំងអស់ ប៉ុន្តែច្បាប់នានាដែលទាក់ទងទៅនឹងមនុស្សប្តូរភេទ គឺមិនមានភាពច្បាស់លាស់។ ជារឿយៗមនុស្សប្តូរភេទមិនត្រូវបានគេនិយាយដល់នោះទេ។ មានព័ត៌មានតិចតួចអំពីការវះកាត់បញ្ជាក់ភេទ ដែលគេស្គាល់ផងដែរថាជាការកំណត់អត្តសញ្ញាណភេទឡើងវិញ ការវះកាត់បញ្ជាក់ភេទ និងការវះកាត់កំណត់អត្តសញ្ញាណយេនឌ័រឡើងវិញ ។[59]

## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាតិ

ស្ថានភាពច្បាប់និងគោលនយោបាយរបស់កម្ពុជាអាចមានភាពច្របូកច្របល់។មានឋានានុក្រមនៃច្បាប់និងគោលនយោបាយ ដោយក្នុងនោះរដ្ឋធម្មនុញ្ញកម្ពុជា និងការសន្យារបស់អន្តរជាតិ និងអនុសញ្ញាអង្គការសហប្រជាជាតិ គឺជាច្បាប់និងលិខិតូបករណ៍កំពូល។ បន្ទាប់មកមាន ក្រម ក្រឹត្យ (ព្រះរាជក្រឹត្យ) អនុក្រឹត្យ ប្រកាស (សេចក្តីសម្រេច) និងសារាចរ។[60] សម្រាប់គោលបំណងជាក់ស្តែង និងអនុវត្តន៍ផ្ទាល់ ប្រកាសគឺជាបទបញ្ជា ប៉ុន្តែមិនមែនជាច្បាប់ទេ។ វាមានលក្ខណៈជាក់លាក់ជាង ហើយត្រូវបានគេចាត់ទុកថាជាគោលការណ៍ណែនាំ។ បន្ថែមពីលើនេះ ក្រសួងរបស់រដ្ឋាភិបាលអាចចេញគោលនយោបាយនានាដែល

---

58 Caceres, C and Pecheny, M et al. (2009). "ការពិនិត្យឡើងវិញលើក្របខ័ណ្ឌច្បាប់និងស្ថានភាពសិទ្ធិមនុស្សដែលទាក់ទងនឹងភាពចម្រុះនៃផ្លូវភេទនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបនិងមធ្យម" UNAIDS។ http://data.unaids.org/pub/Report/2009/20091215_legalframeworks_sexualdiversity_en.pdf

59 Baird, Vanessa. (2001). '*The No-Nonsense Guide to Sexual Diversity.*' New Internationalist Publications. ទំព័រ ១៣៣

60 កូនសៀវភៅតស៊ូមតិ, សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA), 2011, ទំព័រ៥

ត្រូវបានអនុវត្តដោយយោងតាមអំណាចនិងធនធានរបស់ក្រសួងនោះ។ ផ្អែកលើច្បាប់ទាំងអស់នេះ ក្រឹត្យនិងគោលនយោបាយ គឺជាបទដ្ឋានវប្បធម៌និងយេនឌ័រផ្សេងៗដែលមានឥទ្ធិពលលើរបៀបអនុវត្តច្បាប់។

ច្បាប់កំពូលនៃដែនដី គឺរដ្ឋធម្មនុញ្ញ សង្កត់ធ្ងន់លើសមភាពនិងការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋធម្មនុញ្ញអាចត្រូវបានបកស្រាយថាមិនហាមឃាត់អាពាហ៍ពិពាហ៍ភេទដូចគ្នា។ មាត្រា៤៥ ចែងថា "អាពាហ៍ពិពាហ៍ទាំងអស់ត្រូវធ្វើឡើងយោងតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ ដោយផ្អែកលើគោលការណ៍យល់ព្រមទៅវិញទៅមករវាងប្ដីមួយនិងប្រពន្ធមួយ"[61] ។ រដ្ឋធម្មនុញ្ញមិនបានបញ្ជាក់ថា ប្ដីគួរតែជាប្រុស ឬប្រពន្ធគួរតែជាស្រីនោះទេ។ នៅក្នុងអត្ថបទមួយក្នុងកាសែតភ្នំពេញប៉ុស្ដិ៍ សកម្មជន LGBT ស្រ៊ិន ស្រ៊ុន បានអះអាងថាបានដឹងយ៉ាងតិច ១៥គូស្រករ ដែលបានទទួលលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ដែលក្នុងនោះម្នាក់ត្រូវបានកំណត់ថាជា "ប្ដី" ហើយ ម្នាក់ទៀត ជា "ប្រពន្ធ"។[62]

ច្បាប់កម្ពុជាឆ្នាំ១៩៨៩ ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ ជារឿយៗត្រូវបានគេលើកឡើងថាជាឧបសគ្គដ៏ធំមួយចំពោះសមភាពនៃការរៀបការភេទដូចគ្នា។ មាត្រា ៦ មានចំណុចហាមឃាត់មួយចំនួនលើការរៀបការ រួមទាំងបុគ្គលដែលមានភេទដូចគ្នា។[63] ការហាមឃាត់ផ្សេងៗទៀតចំពោះការរៀបការនៅក្នុងមាត្រា ៦ រួមមាន អសត្ថភាពផ្លូវភេទ ការមានជំងឺ ដូចជាមហារីក របេង ឃ្លង់ និងជំងឺកាមរោគ ពិការភាពផ្លូវចិត្ត ហើយដៃគូម្ខាងបានរៀបការរួចទៅហើយ។ ច្បាប់ឆ្នាំ២០១១នាពេលថ្មីនេះ ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី មោឃៈភាព ឬលុបចោល ខ្លឹមសារភាគច្រើននៃច្បាប់ឆ្នាំ១៩៨៩ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ រួមទាំង បទប្បញ្ញត្តិនៃមាត្រា ៦ ផងដែរ ដែលហាមឃាត់អាពាហ៍ពិពាហ៍ភេទដូចគ្នា។ ទោះបីជាយ៉ាងណាក្ដី វានៅតែមិនច្បាស់ថាតើបច្ចុប្បន្ននេះ ការរៀបការភេទដូចគ្នាមានភាពស្របច្បាប់ ឬថា វាមិនខុសច្បាប់ឬយ៉ាងណា។

មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សប្លែងភេទ រស់នៅដោយចំហជាមួយដៃគូភេទដូចគ្នា និងបានរៀបចំពិធីអាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីមន្ត្រីមូលដ្ឋានផងដែរ។ ពិធីរៀបពាហ៍ពិពាហ៍ទាំងនេះគឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ខ្មែរ និងជីវិតសហគមន៍ និងបង្ហាញដល់សហគមន៍ថា មនុស្សពីរនាក់ពាក់ព័ន្ធនឹង

---

[61] គេសន្មត (ប៉ុន្តែមិនបញ្ជាក់ច្បាស់) ថាប្ដីត្រូវតែជាប្រុស ឬប្រពន្ធត្រូវតែជាស្រី

[62] Kunthear, M និង Drennan, J. "ច្បាប់មិនអាចបញ្ឈប់គូស្នេហ៍មិនឲ្យរៀបការបានទេ", ភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៣

[63] Articles III, V, VI, VII & VIIIច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសាររបស់កម្ពុជា(១៩៨៩ ការបកជាភាសាអង់គ្លេសក្រៅផ្លូវការ) http://www.gocambodia.com/laws/data%20pdf/Law%20on%20Marriage%20and%20Family/Law%20on%20the%20marriage%20and%20family(EN).pdf(ទាញចេញថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤); ច្បាប់អាពាហ៍ពិពាហ៍ក៏ហាមឃាត់អាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ (មាត្រា III), និងចែងពីអាយុអប្បបរមារបស់មនុស្សប្រុសនិងស្រី; ច្បាប់ហាមឃាត់ការរៀបការរវាងសាច់ញាតិរហូតដល់កម្រិតទីបីនៃទំនាក់ទំនងសាច់ឈាម។

ស្នេហាជាមួយគ្នា ហើយមានបំណងចែករំលែកអនាគតរបស់ពួកគេជាមួយគ្នា។ ទោះបីជាពិធីទាំងនេះអាចត្រូវបានអនុញ្ញាត និងមានការចូលរួមពីមនុស្សម្នាជាច្រើនពីសហគមន៍ក្តីក៏នៅក្នុងករណីភាគច្រើន លិខិតបញ្ជាក់អាពាហ៍ពិពាហ៍មិនត្រូវបានគេចេញជូនឡើយ។

មន្ត្រីក្រសួងមហាផ្ទៃម្នាក់ បាននិយាយថា មិនចាំបាច់កែច្បាប់អាពាហ៍ពិពាហ៍ទេ ដោយលោកបញ្ជាក់ "*យើងមិនបានហាមឃាត់ពួកគេមិនឲ្យរៀបការនោះទេ - នៅពេលមានការរៀបអាពាហ៍ពិពាហ៍រវាងស្រីនិងស្រី អ្នកអាចចុះបញ្ជីម្នាក់ជាប្រុស ហើយម្នាក់ទៀតជាស្រី*" ។[64] មន្ត្រីនៅមូលដ្ឋានខ្លះបានបង្កើតវិធីដើម្បីអនុញ្ញាតឲ្យមនុស្សរស់នៅជាមួយគ្នា និងមានទ្រព្យសម្បត្តិរួមគ្នា និងចិញ្ចឹមបីចាច់កូនតាមរយៈការចុះឈ្មោះជាគូស្រករភេទដូចគ្នា ជា "បងប្អូនស្រី" ឬ "ដៃគូ" នៅក្នុងឯកសារច្បាប់ ដូចជាសៀវភៅគ្រួសារជាដើម។ គ្រួសារនីមួយៗរក្សាកំណត់ត្រានៃកូននិងទ្រព្យសម្បត្តិរបស់ពួកគេ។ ទោះបីជាយ៉ាណាក្តី វិធានការទាំងនេះគឺទាក់ទងតែទៅនឹងទ្រព្យសម្បត្តិនិងការថែរក្សាប៉ុណ្ណោះ មិនទាក់ទងនឹងសិទ្ធិគ្រួសារផ្សេងទៀត ដូចជា មរតក ពន្ធ និងសិទ្ធិចូលសួរសុខទុក្ខក្នុងមន្ទីរពេទ្យសម្រាប់ដៃគូភេទដូចគ្នា។

នៅក្នុងរបាយការណ៍ឆ្នាំ២០១២[65], អង្គការ CCHR បានវិភាគទិដ្ឋភាពច្បាប់ជារួមនៅក្នុងប្រទេសកម្ពុជា ទាក់ទងទៅនឹងកិច្ចការពារផ្នែកច្បាប់ដែលមានស្រាប់សម្រាប់បុគ្គល LGBT ដោយបានពិនិត្យមើលទិដ្ឋភាពនានានៃជីវិតរបស់ពួកគេ (គ្រួសារ សហគមន៍ សុខភាព ការអប់រំ) និងផ្តល់អនុសាសន៍ផ្នែកច្បាប់និងក្រៅពីច្បាប់ ដោយលើកឡើងពីច្បាប់និងគំនិតផ្តួចផ្តើមនានាដែលអាចអនុវត្តបាននៅក្នុងប្រទេសពាក់ព័ន្ធដទៃទៀត។ អនុសាសន៍ជាច្រើនក្នុងចំណោមអនុសាសន៍ទាំងនេះ អាចមានសារៈប្រយោជន៍សម្រាប់កិច្ចខិតខំប្រឹងប្រែងតស៊ូមតិទាមទារសិទ្ធិមនុស្សនិងច្បាប់ក្នុងពេលអនាគត ដូចជាការកាត់បន្ថយការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នាក្នុងសាលារៀន ការបណ្តុះបណ្តាលដើម្បីបង្កើនការយល់ដឹងអំពីបុគ្គល LGBT និងបញ្ហា SOGI; និងការលើកកម្ពស់ការមិនរើសអើងក្នុងចំណោមនគរបាល មន្ត្រីអនុវត្តច្បាប់ និងអ្នកផ្តល់សេវាសុខភាព។

ជាទូទៅ ការស្រាវជ្រាវទៅក្នុងវិធីដែលច្បាប់និងគោលនយោបាយប៉ះពាល់បុគ្គល LGBT គឺមិនទាន់មាននៅឡើយ។ ពុំមានព័ត៌មានអំពីផលប៉ះពាល់នៃមរតក ពន្ធដារ សិទ្ធិគ្រួសារ និងសិទ្ធិទៅសួរសុខទុក្ខដៃគូភេទដូចគ្នានៅមន្ទីរពេទ្យប្រសិនបើពួកគេទទួលរងគ្រោះថ្នាក់របួសធ្ងន់ធ្ងរ ឬត្រូវទទួលការថែទាំរយៈពេលវែងសម្រាប់ជំងឺណាមួយ ចំពោះគ្រួសារភេទដូចគ្នា។

---

[64] Kunthear M and Drennan, J. "ច្បាប់មិនអាចបញ្ឈប់គូស្នេហ៍មិនឲ្យរៀបការបានទេ" ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៣ ទំព័រ៤

[65] CCHR (2012). ឥន្ទធនូខ្មែរ: ពីបុរេនិច្ច័យទៅមោនទភាព

## ក្រមរដ្ឋប្បវេណីកម្ពុជាថ្មី៖ ការទទួលស្គាល់មិនច្បាស់លាស់នៃការរៀបការភេទដូចគ្នា?

ការវិភាគនាពេលថ្មីៗទៅលើច្បាប់និងគោលនយោបាយពាក់ព័ន្ធ បង្ហាញថា ភាគច្រើននៃច្បាប់ អាពាហ៍ពិពាហ៍ឆ្នាំ១៩៨៩ គឺលែងមានសុពលភាពទៀតហើយ។ នៅឯសន្និសីទស្តីពីច្បាប់ទាក់ទងនឹង LGBT នៅកម្ពុជា ដែលផ្តល់មូលនិធិដោយ USAID/Cambodia កាលពីថ្ងៃទី៥-៦ ខែមីនា ឆ្នាំ២០១៤ សកម្មភាពក្រោមកម្មវិធីស្តីពីសិទ្ធិនិងយុត្តិធម៌ទី២ និងជាលើកដំបូងបំផុត អ្នកជំនាញផ្នែកច្បាប់មកពីវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចឹម បានកត់សម្គាល់ថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៨[66] គ្រប់គ្រងការហាមឃាត់លើភាគីដែលរៀបអាពាហ៍ពិពាហ៍ និងប្រើពាក្យ "សហព័ទ្ធ" ដើម្បីរៀបរាប់ពីគូស្រករ ខណៈពេលជាមួយគ្នា កត់សម្គាល់ថា អាពាហ៍ពិពាហ៍មានពីរប្រភេទ គឺរវាងភេទផ្ទុយគ្នា និងភេទដូចគ្នា (ដូចបានពិពណ៌នានៅក្នុងផ្នែកស្តីពីច្បាប់ស្នុំកូន[67])។ នៅក្នុងសៀវភៅទី៧, ជំពូក ៣ នៃក្រមរដ្ឋប្បវេណី អាពាហ៍ពិពាហ៍ភេទដូចគ្នា មិនត្រូវបានហាមឃាត់ត្រង់ថា វាមិនបានបញ្ជាក់ថា អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងរវាងបុរសម្នាក់ និងស្ត្រីម្នាក់នោះទេ។[68] អង្គការក្រៅរដ្ឋាភិបាល និងក្រុមសិទ្ធិមនុស្សដែលធ្វើការលើបញ្ហា LGBT មិនបានដឹងពីទិដ្ឋភាពត្រង់នេះនៅក្នុងក្រមរដ្ឋប្បវេណីទេ រហូតដល់ពេលមានសន្និសីទនេះ។ សម្រាប់អ្នកខ្លះ នេះគឺជាលើកទីមួយដែលពួកគេបានឮអំពីក្រមរដ្ឋប្បវេណីនេះ។

បន្ថែមពីលើនេះ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែលទើបបង្កើតថ្មីៗនេះ (ឆ្នាំ២០១១) ចែងនៅក្នុងមាត្រា ៧៨ ថា "ច្បាប់ស្តីពីគ្រួសារនិងអាពាហ៍ពិពាហ៍ នឹងក្លាយជាមោឃៈចាប់ពីថ្ងៃអនុវត្ត [ក្រមរដ្ឋប្បវេណីឆ្នាំ២០១១] តទៅ, លើកលែងតែសម្រាប់បទប្បញ្ញត្តិនៃមាត្រា ៧៦ និង ៧៧ និងមាត្រា ៧៩ និង ៨១"។[69] ដូចច្នេះ ច្បាប់នេះនិរាករ ឬលុបចោលបទប្បញ្ញត្តិភាគច្រើននៃច្បាប់ស្តីពីគ្រួសារនិងអាពាហ៍ពិពាហ៍ ឆ្នាំ១៩៨៩ រួមទាំងមាត្រា ៦ ដែលហាមឃាត់ អាពាហ៍ពិពាហ៍ភេទដូចគ្នាផងដែរ។

ទោះបីជាយ៉ាងណាក្តី ការផ្លាស់ប្តូរនៅក្នុងច្បាប់របស់ប្រទេសតាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ២០០៨ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ និងនិរាករណ៍ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ឆ្នាំ១៩៨៩ មិនទាន់ត្រូវបានគេផ្សព្វផ្សាយឲ្យបានទូលំទូលាយ ហួសពីស្ថាប័

---

[66] Crothers, Lauren. "ការពិភាក្សាផ្តោតលើសមភាពនីយកម្មសិទ្ធិ LGBT នៅកម្ពុជា". ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៤ ទាញចេញពី http://www.cambodiadaily.com/news/discussions-center-on-equalizing-cambodias-lgbt-rights-53529

[67] ក្រមរដ្ឋប្បវេណី, ការបកប្រែអង់គ្លេសក្រៅផ្លូវការ។ សៀវភៅទី ២, ជំពូកទី ២, ផ្នែកទី៥, មាត្រា១០២៣, បទបញ្ញាតិ ២ (ទំព័រ ២៣៧)

[68] ក្រមរដ្ឋប្បវេណីនៃកម្ពុជា ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ ឆ្នាំ២០០៨, សៀវភៅទី៧, ជំពូកទី៣, ទំព័រ ២២១-២២៤.

[69] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១ និងអនុម័តដោយព្រឹទ្ធសភា នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១។ តាមរយៈបំណកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ ទំព័រទី១ និង មាត្រា ៧៨ ទំព័រ ២៨។

នច្បាប់នៅឡើយទេ។ អ្នកចូលរួមនៅក្នុងសន្និសីទស្តីពីច្បាប់ LGBT នៅកម្ពុជា បានប្រាប់ឲ្យដឹងថា ព័ត៌មាននេះគឺថ្មីសម្រាប់ពួកគេ ដូចជាព័ត៌មានអំពីនិរាករណ៍នៃច្បាប់អាពាហ៍ពិពាហ៍ ឆ្នាំ១៩៨៩ ដែរ។

ទាំងមន្ត្រីនៅថ្នាក់មូលដ្ឋានដែលចេញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ទាំងអង្គការក្រៅរដ្ឋាភិបាល ក្រុមសិទ្ធិមនុស្ស ក្រុមLGBT និងបុគ្គល LGBT ដែលមានបំណងចង់រៀបការ មិនបានដឹងអំពីការផ្លាស់ប្តូរនៅក្នុងច្បាប់របស់កម្ពុជាឡើយ។ ការតស៊ូមតិបន្ថែមទៀតសម្រាប់សមភាពអាពាហ៍ពិពាហ៍ ត្រូវតែផ្អែកលើច្បាប់ជាភាសាខ្មែរផ្លូវការនិងសំណៅដើម។ សំណៅបកប្រែជាភាសាអង់គ្លេស មិនអាចយកមកប្រើតាមច្បាប់បានទេ ដោយសារតែវាមានឃ្លាព្រមានជាក់លាក់មួយថា "បកប្រែក្រៅផ្លូវការ"។ [70]

វាប្រហែលជាករណីសាកល្បងមួយនៅក្នុងតុលាការ ដើម្បីបំភ្លឺអំពីបញ្ហានេះ ហើយថាតើអាពាហ៍ពិពាហ៍ភេទដូចគ្នាត្រូវបានអនុញ្ញាតឬទេ ដើម្បីធានាថា បទប្បញ្ញត្តិទាំងនេះត្រូវបានគេយល់ និងអាចត្រូវអនុវត្ត។ សម្រាប់ពេលនេះ ការហាមឃាត់អាពាហ៍ពិពាហ៍ភេទដូចគ្នា នៅតែជាជាករណីយុត្តិសាស្ត្រ (ទម្លាប់ពីមុន) និងខ្វះខាតភាពច្បាស់លាស់ពីច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។ នៅក្នុងសហរដ្ឋអាមេរិក នៅក្នុងរដ្ឋនានាដែលការរៀបការភេទដូចគ្នាមិន "ខុសច្បាប់" អាចមិនទាន់ស្របច្បាប់ វាលែងតែច្បាប់ជាក់លាក់មួយត្រូវបានគេអនុម័តដើម្បីអនុញ្ញាតឲ្យមានការរៀបការបែបនេះ។ ដូច្នេះ ស្ថានភាពនេះអាចដូចគ្នានៅក្នុងប្រទេសកម្ពុជា។ បញ្ហានេះនឹងត្រូវបានគេបន្តតាមដានមើលតទៅទៀត។

សន្និសីទស្តីពីច្បាប់សម្រាប់ LGBT នៅកម្ពុជា ដែលផ្តល់មូលនិធិដោយ USAID/Cambodia ដែលបានរៀបរាប់ខាងលើនេះ គឺជាជំហានតូចមួយឆ្ពោះទៅរកការបង្កើតច្បាប់គាំទ្រ LGBT នៅក្នុងប្រទេសកម្ពុជា។ មេធាវី និស្សិតច្បាប់ ជំនួយការមេធាវី និងមន្ត្រីក្រសួងយុត្តិធម៌ បានពិភាក្សាគ្នាអំពីបញ្ហាច្បាប់ដែលសហគមន៍ LGBT កំពុងជួបប្រទះ និងដំណោះស្រាយដែលអាចមានសម្រាប់បញ្ហាទាំងនេះ ដូចជាសមភាពនៅក្នុងអាពាហ៍ពិពាហ៍ និងការដាក់បញ្ចូលបញ្ហា SOGI ទៅក្នុងច្បាប់ និងគោលនយោបាយ។ វាគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយដែលផ្តល់ព័ត៌មានដល់ភាគីពាក់ព័ន្ធអំពីបញ្ហានានា ទោះបីជាទទួលស្គាល់ថា ការផ្លាស់ប្តូរច្បាប់អាចត្រូវការរយៈពេលជាច្រើនទសវត្សរ៍ក៏ដោយ។

[70] ច្បាប់នេះជាភាសាខ្មែរគឺឯកសារផ្លូវការ រីឯបំណងប្រែវិញមានឃ្លាព្រមានមួយ៖ "នេះគឺជាការបកប្រែក្រៅផ្លូវការ។ បំណកប្រែនេះមានកំហុសក្នុងការបកប្រែ និងការប្រើពាក្យពេចន៍មិនស្របគ្នា ហើយអាចខ្វះខាតព័ត៌មានខ្លះ។ បំណងប្រែនេះគឺសម្រាប់តែជាព័ត៌មានប៉ុណ្ណោះ ហើយយើងមិនទទួលខុសត្រូវលើកំហុស ឬភាពស្រពិចស្រពិលណាមួយឡើយ។ គេអាចផ្អែកលើសំណៅជាភាសាខ្មែរផ្លូវការតែមួយគត់"។

## អាជ្ញាធរមូលដ្ឋាន និងនគរបាល៖ បំណាកស្រាយផ្សេងៗគ្នាចំពោះច្បាប់ផ្សេងៗគ្នា

របាយការណ៍ សំណុំរឿងរបស់អង្គការ RoCK បង្ហាញថាបុគ្គលLGBT ត្រូវបានគេបំបែកចេញពីដៃគូរបស់ពួកគេដោយបង្ខំនិងស្របតាមច្បាប់។ ជារឿយៗ អាជ្ញាធរ ដោយឃុបឃិតជាមួយឪពុកម្តាយ បានប្រើច្បាប់នានាដូចជាច្បាប់ប្រឆាំងការចាប់ជំរិត ដើម្បីបំបែកដៃគូភេទដូចគ្នា។ នៅក្នុងរបាយការណ៍ករណីមួយ ឪពុកម្តាយរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នាម្នាក់ បានចោទនាងថាចាប់ជំរិតកូនស្រីរបស់ពួកគាត់។ ដើម្បីបំបែកពួកគេចេញពីគ្នា គ្រួសារដាក់សម្ពាធលើកូនស្រីឲ្យឈប់ធ្វើការក្នុងរោងចក្រកាត់ដេរនិងរៀបការជាមួយបុរសម្នាក់ដែលពួកគេជាអ្នកជ្រើសរើសឲ្យ។

មានភាពមិនច្បាស់លាស់នៅក្នុងសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី។ ក្នុងសុន្ទរកថាមួយនៅឆ្នាំ២០០៧ លោកបានកាត់កាលកូនស្រីដែលស្រឡាញ់ស្រីដូចគ្នាម្នាក់របស់គាត់ ខណៈពេលដែលក្នុងពេលជាមួយគ្នានោះ អំពាវនាវឲ្យមានការមិនរើសអើង។ នៅក្នុងសុន្ទរកថាមួយ បន្ទាប់ពីទិវាសិទ្ធិមនុស្សក្នុងឆ្នាំ២០១២ លោកបានអំពាវនាវដល់សាធារណជនឲ្យអត់ឱនបន្ថែមទៀតដល់សហគមន៍ LGBT។[71]

មន្ត្រីមកពីនគរបាល និងក្រសួងមហាផ្ទៃ បដិសេធថា មានការរើសអើងជាលក្ខណៈប្រព័ន្ធប្រឆាំងបុគ្គល LGBT ឬថា ការរើសអើងគឺជាបញ្ហាមួយ ដូច្នេះត្រូវការកិច្ចការពារពិសេស។ ពួកគេបានអះអាងថា អង្គការក្រៅរដ្ឋាភិបាលសិទ្ធិមនុស្សទទួលខុសត្រូវក្នុងការ "ធ្វើឲ្យបញ្ហានេះមើលទៅដូចជាបញ្ហាធំ ប៉ុន្តែតាមពិតវាមិនដូច្នោះនោះទេ"។[72]

ទោះបីជាយ៉ាងណាក្តី មានការរើសអើងយ៉ាងច្បាស់នៅក្នុងផ្នែកខ្លះនៃសង្គម។ ការស្រាវជ្រាវដែលបានធ្វើឡើងក្នុងឆ្នាំ២០០៩ ទៅលើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានបង្ហាញថា ខណៈពេលដែលចំនួននៃការចាប់ខ្លួននារីបម្រើសេវាកម្មផ្លូវភេទបានធ្លាក់ចុះយ៉ាងខ្លាំងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ ការចាប់ខ្លួនបុរសដែលរួមភេទជាមួយបុរស (MSM) និងមនុស្សប្តូរភេទដែលជាអ្នកបម្រើសេវាកម្មផ្លូវភេទ បានកើនឡើងដល់

---

[71] Ip, Stephanie. "សហគមន៍ LGBT ដែលត្រូវគោរព-PM", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២; Knox, Claire, "ក្មេងស្រីនឹងធ្វើជាក្មេងប្រុស ហើយក្មេងប្រុសនឹងធ្វើជានារី: "សិល្បៈស្លៀកពាក់ប្តូរភេទ" ភ្នំពេញប៉ុស្តិ៍, ៧ថ្ងៃ, លេខផ្សាយ ១៧៣, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២, ទំព័រទី៨; Kunthear, M &Drennan, J. "ច្បាប់មិនអាចបញ្ឈប់គូស្នេហ៍មិនឲ្យរៀបការបានទេ" ភ្នំពេញប៉ុស្តិ៍ , ២០ ឧសភា ២០១៣, ទំព័រទី៤

[72] Drennan, J. and Chanyda, "ការផ្លាស់ប្តូរនៅក្នុងគោលនយោបាយ LGBT ភ្នំពេញប៉ុស្តិ៍, ២ មករា ២០១៣; Baron, Laignee. "ក្រុមទទូចឲ្យមានសិទ្ធិស្មើគ្នា"), ភ្នំពេញប៉ុស្តិ៍, ១១ ធ្នូ ២០១៣

ទៅបីដង។[73] នៅក្នុងតំបន់ទេសចរណ៍ធំៗក្នុងខេត្តសៀមរាប មនុស្សស្រីប្លែងភេទត្រូវបានគេហាមមិនឲ្យចូល ឬជាគោលដៅនៃការចាប់ខ្លួន ដោយសង្ស័យថាជាចោរ។[74]

យោងតាមរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល គោលនយោបាយមួយទៀតដែលគេច្រើនប្រើញឹកញាប់ដើម្បីធ្វើការចាប់ខ្លួន និងរំខានដល់បុគ្គល LGBT (ក៏ដូចជាអ្នកដែលលក់សេវាភេទ) គឺគោលនយោបាយភូមិឃុំមានសុវត្ថិភាព (VCSP), ដែលត្រូវបានតាក់តែងឡើងក្នុងឆ្នាំ២០១១។ គោលនយោបាយភូមិឃុំមានសុវត្ថិភាពផ្តោតលើសន្តិសុខនិងសណ្តាប់ ធ្នាប់សាធារណៈ។ គោលនយោបាយនេះអំពាវនាវឲ្យអាជ្ញាធរមូលដ្ឋានធ្វើការលុបបំបាត់បទឧក្រិដ្ឋគ្រប់ប្រទេសនៅថ្នាក់ភូមិដោយផ្តោតជាពិសេសលើគ្រឿងញៀនខុសច្បាប់ អំពើពេស្យាចារ អំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ សកម្មភាពក្មេងទំនើង ល្បែងស៊ីសង និងអាវុធខុសច្បាប់។ ទោះបីជាយ៉ាងណាក្តី យោងតាមរបាយការណ៍របស់ CCHR គោលនយោបាយនេះត្រូវបានគេប្រើជាមធ្យោបាយមួយដើម្បីបង្ក្រាប និងគ្រប់គ្រងប្រជាពលរដ្ឋ។ គោលនយោបាយនេះផ្តល់សិទ្ធិឲ្យនគរបាលតាមដានមើលប្រជាពលរដ្ឋកម្ពុជារបស់ខ្លួន និងចាប់ខ្លួនមនុស្សមុនពេលប្រព្រឹត្តបទល្មើស។ សកម្មភាពនេះរួមមាន បុគ្គល LGBT ដែលអង្គុយសៀមស្ងាត់ក្នុងសួនច្បារសាធារណៈ និងអ្នកដែលនគរបាលគិតថា ជាសមាជិកក្រុមទំនើង និងអ្នកប្រកបរបរផ្លូវភេទ។[75] ក្រុមសិទ្ធិមនុស្សបានការព្រួយបារម្ភយ៉ាងខ្លាំង អំពីគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលថាវាមិនមែនជាច្បាប់ផ្លូវការមួយដែលត្រូវបានជជែក និងអនុម័តដោយរដ្ឋសភានោះទេ។ ផ្ទុយទៅវិញ វាគឺជាបទបញ្ជាមួយដែលចេញពីក្រសួងមហាផ្ទៃ។

របាយការណ៍របស់ កិច្ចប្រជុំពិសេសនៃមហាសន្និបាតអង្គការសហប្រជាជាតិ (UNGASS) ឆ្នាំ២០១០-២០១១ បានលើកឡើងពីបញ្ហាប្រឈមជាមួយច្បាប់និងគោលនយោបាយ ដោយបញ្ជាក់ថា គោលនយោបាយនិងច្បាប់ខ្លះបានរារាំងដល់វឌ្ឍនភាពនៅក្នុងការបង្ការមេរោគអេដស៍ ការថែទាំ និងការគាំទ្រ។[76] អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ យោងលើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលបាន *"ធ្វើឲ្យឱកាសរបស់អ្នកប្រើគ្រឿងញៀន និងការទទួលបានសេវា កាន់តែពិបាក ដោយសារការយល់ច្រឡំរបស់មន្ត្រីអនុវត្តច្បាប់ ជាពិសេសនៅថ្នាក់ឃុំ"*។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មិនបានបញ្ជាក់ចំៗពី MSM និងមនុស្សប្លែងភេទនោះទេ ប៉ុន្តែមនុស្សប្លែងភេទជាច្រើនដែលលក់សេវាភេទ ប៉ុន្តែបដិសេធថាមិនមានគ្រឿងញៀនជាប់ខ្លួន ត្រូវបានគេចាប់ខ្លួន។ ភាគ

---

[73] CACHA & អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (២០០៩)។ របាយការណ៍ស្រាវជ្រាវ, "បរិយាកាសគោលនយោបាយទាក់ទងនឹងការទទួលបានសេវាជាសកល និងសិទ្ធិរបស់អ្នកបម្រើសេវាកម្សាន្តនៅក្នុងប្រទេសកម្ពុជា" ទំព័រ ៦៥-៦៧.

[74] ការប្រាស្រ័យទាក់ទងផ្ទាល់ពី បណ្តាញអ្នកស្ម័គ្រចិត្ត MSM និងមនុស្សប្លែងភេទ និងអ្នកអប់រំ (២០១៣ & ២០១៤)

[75] របាយការណ៍ CCHR, (2012). Ibid. ទំព័រ ១៦

[76] អាជ្ញធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA). (2012). របាយការណ៍វឌ្ឍនភាពរបស់ប្រទេសនៃ UNGASS, ២០១០-២០១១. ទំព័រ១៥

ច្រើននៃពួកគេ ឲ្យលុយ ឬរបស់មានតម្លៃដល់នគរបាល ជាថ្នូរនឹងការដោះលែងពីពន្ធនាគារ ហើយជឿថា នគរបាលចាប់ខ្លួនពួកគេដើម្បីគ្រាន់តែជំរិតយកលុយតែប៉ុណ្ណោះ។

## អាកប្បកិរិយាវប្បធម៌និងសង្គមនិងទស្សនៈចំពោះបុគ្គល LGBTនៅក្នុងប្រទេសកម្ពុជា

ដូចបានរៀបរាប់ពីខាងលើមកហើយ ទស្សនទាននៃ "ការស្រឡាញ់ភេទដូចគ្នា" តាមអ្វីដែលគេយល់នៅប្រទេសលោកខាងលិច គឺមិនសុទ្ធតែមានការយល់ដូចគ្នានៅក្នុងប្រទេសកម្ពុជានោះទេ។ ភាសាខ្មែរ មិនអាចពិពណ៌នាច្បាស់លាស់អំពីពាក្យ ឥរិយាបថមនុស្សស្រឡាញ់ភេទដូចគ្នា, មនុស្សស្រឡាញ់ភេទផ្ទុយគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ឬ មនុស្សស្រីស្រឡាញ់ភេទដូចគ្នានោះទេ។ យោងតាម ផុង តាន់ ជនជាតិកម្ពុជាយល់ពាក្យ យេនឌ័រនិង សកម្មភាពផ្លូវភេទ ក្នុងន័យស្រាលជាងចំណាត់ថ្នាក់របស់បស្ចឹមប្រទេសថា "ប្រុស" និង "ស្រី" ។[77] យេនឌ័រ ជាទូទៅ ត្រូវបានគេរៀបរាប់ដោយប្រើពាក្យ *ស្រី* និង *ប្រុស* ដែលមានន័យថា "មនុស្សជាតិម្នាក់ដែលមានភេទជាស្រី" និង "មនុស្សជាតិម្នាក់ដែលមានភេទជាប្រុស"។ និយាយម្យ៉ាងទៀត ពុំមានការបែងចែកច្បាស់លាស់រវាងទស្សនទាន យេនឌ័រ និង ភេទ ឡើយ។ ពាក្យថា *ញី* និង *ឈ្មោល* សម្គាល់យេនឌ័រ ប៉ុន្តែអនុវត្តជាទូទៅចំពោះសត្វ និងរុក្ខជាតិ។ នៅក្នុងភាសាខ្មែរ អត្តសញ្ញាណរបស់បុគ្គលម្នាក់ មិនផ្អែកលើចំណង់ផ្លូវភេទ ដៃគូ ឬអត្តសញ្ញាណរបស់ពួកគេនោះទេ ប៉ុន្តែផ្អែកលើចរិតលក្ខណៈនិងបុគ្គលិកលក្ខណៈ លក្ខណៈសម្បត្តិ ដែលគេជឿថាមានមកតាំងពីកំណើត។ មនុស្សដែលមានភេទប្រុសអាចមានពីរប្រភេទ៖ ស្រីភេទ (សុភាពស្លូត) និង ប្រុសភេទ (រឹងមាំ ស្វិតស្វាញ)។[78] គេមិនដឹងថាតើប្រភេទនេះ អនុវត្តចំពោះមនុស្សស្រីដែរ ឬយ៉ាងណា។

ពាក្យមួយដែលគេច្រើនប្រើដើម្បីរៀបរាប់ភេទទីពីរ គឺ *ខ្ទើយ (kteuy)* ដែលមានបំណកស្រាយផ្សេងៗគ្នាមួយចំនួន។ វចនានុក្រមរបស់វិទ្យាស្ថានព្រះពុទ្ធសាសនា ដែលបានបោះពុម្ពដោយ សម្តេចសង្ឃ ជួន ណាត (ដូចដែលលើកឡើងនៅក្នុងឯកសារនេះដោយ ផុង តាន់) កំណត់និយមន័យ ខ្ទើយ ជា "បុគ្គលម្នាក់ដែលមានចរិតពីរ និងមានប្រដាប់ភេទប្រុសផងស្រីផង..."។ គេប្រើពាក្យនេះដើម្បីពិពណ៌នាអំពីអ្នកដែលអាចជាបុរសតាមធម្មជាតិ ឬស្ត្រី ប៉ុន្តែបង្ហាញពីបុគ្គលិកលក្ខណៈ ឬឥរិយាបថរបស់ភេទផ្ទុយទៅវិញ។ *ខ្ទើយ* ត្រូវបានគេ

[77] Earth, Barbara. (2006). ពិពិធកម្មយេនឌ័រ៖ អត្តសញ្ញាណមនុស្សក្លែងភេទពីប្រុសទៅស្រី និងកម្មវិធីមេរោគអេដស៍ក្នុងរាជធានីភ្នំពេញ កម្ពុជា។ យេនឌ័រ និងការអភិវឌ្ឍ ១៤:២,ទំព័រ ២៦០

[78] Tan, Phong. (2008). ជាតិពិន្ទុសាស្ត្រនៃសកម្មភាពផ្លូវភេទបុរសនិងបុរសនៅក្នុងប្រទេសកម្ពុជា ។ កម្មវិធីបង្ការមេរោគអេដស៍/ជំងឺអេដស៍ យូនេស្កូ, ភ្នំពេញ។

គិតថាមានប្រភពដើមរបស់វានៅក្នុងភាសាខ្មែរបុរាណ។ [79] នៅក្នុងប្រទេសកម្ពុជា *ខ្ទើយ* បង្កប់នូវន័យប្រមាថ ហើយត្រូវបានគេចាត់ទុកថាជាការមើលងាយ ជាពិសេសនៅពេលប្រើដោយអ្នកខាងក្រៅ ដើម្បីពិពណ៌នាអំពីមនុស្សដែលចាត់ទុកខ្លួនឯងថាជាមនុស្សប្ដូរភេទ។

ការផ្ដោតទៅលើចរិតដែលមើលឃើញពីខាងក្រៅ និងចរិតលក្ខណៈពីធម្មជាតិ ជាជាងទំនោរផ្លូវភេទ មានន័យថា ប្រជាពលរដ្ឋកម្ពុជាជាច្រើនដែលស្រឡាញ់ភេទដូចគ្នា មិនកំណត់អត្តសញ្ញាណខ្លួនពួកគេបែបនេះទេ។ នៅពេលពាក្យថា "មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា" ត្រូវគេប្រើប្រាស់ ជាទូទៅគេសំដៅទៅលើមនុស្សប្រុសដែលមានចរិតខាងក្រៅ និយាយនិងស្លៀកពាក់ដូចស្រី។[80] ជារឿយៗ គេប្រើវាជាពាក្យដូចគ្នានឹងពាក្យ ខ្ទើយ ។ ដូចគ្នានេះដែរ បុគ្គលនានាអាចពិពណ៌នាខ្លួនឯងថា "មនុស្សស្រឡាញ់ភេទផ្ទុយគ្នា" ទោះបីជាពួកគេមានសកម្មភាពស្រឡាញ់ភេទដូចគ្នាក្ដី។ ដូចដែលជនជាតិកម្ពុជាម្នាក់បានបញ្ជាក់ "ខ្ញុំមិនមែនមនុស្សប្រុសស្រលាញ់ភេទដូចគ្នាទេ ខ្ញុំគ្រាន់តែចូលចិត្តរួមភេទជាមួយបុរស។[81]

បទដ្ឋានវប្បធម៌ដែលចាក់យ៉ាងជ្រៅ បង្ហាញពីឥរិយាបថរបស់បុរសនិងស្ត្រី និងត្រូវបានគេចាត់បញ្ចូលក្នុង*ច្បាប់ស្រី* និង *ច្បាប់ប្រុស*។ នេះគឺជាច្បាប់ប្រពៃណីជាលាយលក្ខណ៍អក្សរដែលមានមករាប់សតវត្សរ៍មកហើយ។ ទោះបីជាមិនមែនជាច្បាប់ឬលក្ខន្តិកៈផ្លូវការក្ដី ក៏ច្បាប់ប្រពៃណីទាំងនេះមានឥទ្ធិពលយ៉ាងជ្រៅមកលើសង្គមខ្មែរ។

នៅក្នុងគម្រោងស្រាវជ្រាវ "នៅក្រៅស្រមោល" (២០០៣), អ្នកឆ្លើយតបនឹងសម្ភាសន៍ បាននិយាយថា ពួកគេចូលចិត្តអនុវត្តតាមច្បាប់ស្រី ដោយបានដកស្រង់ឃ្លាមួយចេញពីច្បាប់ស្រី៖ *"ស្រីត្រូវដើរដោយយឺតៗនិងដោយទន់ភ្លន់ ត្រូវមានចលនាដោយស្ងៀមស្ងាត់មិនឲ្យគេឮសម្លេងសំពត់រលាស់ឡើយ..... "*[82] ខណៈដែលច្បាប់ប្រុស និងច្បាប់ស្រី លែងត្រូវបានគេបង្រៀននៅតាមសាលារៀនទៀតហើយនោះ (នៅពេលម្ដងនោះ កុមារត្រូវសូត្រច្បាប់នេះឲ្យឮខ្លាំងៗ) ច្បាប់ទាំងនេះនៅតែមានឥទ្ធិពល។ ដូចវប្បធម៌ជាច្រើនផ្សេងទៀតដែរ សុភាសិតកម្ពុជា និងពាក្យចាស់ ឆ្លុះបញ្ចាំងពីបទដ្ឋានយេនឌ័រដែលគេទទួលយក។ ឧទាហរណ៍ "មនុស្សប្រុសគឺដូចមាស មនុស្សស្រីគឺដូចក្រណាត់ស" បង្ហាញពីតម្លៃប្រៀប

[79] Beyrer, C. (1998) សង្គ្រាមនៅក្នុងឈាម: ភេទ, នយោបាយ និងជំងឺអេដស៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ Palgrave and Macmillan: "ពាក្យថា *ខ្ទើយ* ត្រូវបានគេគិតថាចេញមកពីខ្មែរបុរាណ។ "ក" ចេញពីមកពីពាក្យតំណាងឲ្យមនុស្ស, *"ទើយ"* ចេញមកពីពាក្យដែលមានន័យថា "ដទៃទៀត" ឬ "ជនចម្លែក" ន័យចំ, មនុស្សមួយប្រភេទផ្សេងទៀត"។ ទំព័រ១៦៥

[80] Tan, Phong, Ibid. ទំព័រ២៤–២៦.

[81] CCHR. (2010) ការបើកចំហរពីភេទរបស់ខ្លួននៅព្រះរាជាណាចក្រ : មនុស្សស្រីស្រឡាញ់ភេទដូចគ្នា, មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា, មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្ដូរភេទ នៅក្នុងប្រទេសកម្ពុជា។ ទំព័រ ១១

[82] CatallaTAP et al., ទំព័រ ១៦–១៧.

ធៀបដែលសង្គមកម្ពុជាផ្តល់ដល់មនុស្សប្រុស និងមនុស្សស្រី។[83] តើពាក្យទាំងនេះអាចអនុវត្តចំពោះបុគ្គល LGBT ដូចម្តេចនោះ គឺមិនទាន់មានគេធ្វើការសិក្សានៅឡើយទេ។

សង្គមកម្ពុជាអាចអត់ឱនឲ្យឥរិយាបថស្រឡាញ់ភេទប្រុសដូចគ្នាដរាបណាវាធ្វើឡើងដោយសម្ងាត់ និងមិនប៉ះពាល់ដល់រចនាសម្ព័ន្ធគ្រួសារតាមទំនៀមទម្លាប់។ មនុស្សប្រុសត្រូវគេរំពឹងថារៀបការ និងមានកូន។ ការធ្វើដូច្នេះ ទំនាក់ទំនងផ្លូវភេទជាមួយមនុស្សប្រុសដទៃទៀត អាចបន្តទៅដោយគ្មាននរណាចាប់អារម្មណ៍ឬយកចិត្តទុកដាក់។[84] ដូចនៅក្នុងសង្គមដទៃទៀតជាច្រើនដែរ បុគ្គលស្រឡាញ់ប្រុសដូចគ្នា រៀបការជាមួយភេទផ្ទុយគ្នា បើទោះបីជាពួកគេមិនចង់ធ្វើដូច្នោះក៏ដោយ ដើម្បីជៀសវាងការសង្ស័យ ឬដើម្បីធ្វើតាមបទដ្ឋានវប្បធម៌។ នៅក្នុងការសិក្សាភាគច្រើនទៅលើ MSM និងមនុស្សប្តូរភេទ ដែលរស់នៅជាមួយមេរោគអេដស៍មួយចំនួនតូចស្ថិតនៅក្នុងចំណាងអាពាហ៍ពិពាហ៍ជាមួយភេទផ្ទុយគ្នា។

របាយការណ៍ផាត់ចេញពីសង្គម[85] កត់សម្គាល់ពីយោបល់អំពីបុគ្គល LGBT ដែលឆ្លុះបញ្ចាំងពីបទដ្ឋានយេនឌ័រយ៉ាងជ្រៅ។ អាជ្ញាធរមូលដ្ឋានខ្លះ (មកពីឃុំមួយ) បានបញ្ជាក់ថា គាត់គ្មានជំនឿថា មនុស្សពីរនាក់ដែលមានភេទដូចគ្នាអាចរស់នៅជាមួយគ្នាបានទេ ព្រោះថា *"វាខុសពីធម្មជាតិ"*; *"ភាគច្រើននៃស្រ្តីទាំងនោះដែលស្រឡាញ់ស្រីដូចគ្នា គ្មានការងារធ្វើ និងមិនអាចរកស៊ីបានទេ ប៉ុន្តែ បុរស ប្រសិនបើពួកគេចង់រស់នៅជាមួយគ្នា ពួកគេអាចធ្វើទៅបាន ពីព្រោះពួកគេខ្លាំង"* *"ប្រសិនបើមានមនុស្សស្រីស្រឡាញ់ភេទដូចគ្នានិងមនុស្សស្រឡាញ់ភេទដូចគ្នាកាន់តែច្រើន ប្រទេសរបស់យើងនឹងមានការរីកចម្រើនយឺត នឹងមានកូនតិចជាងមុន ហើយនេះគឺមិនមែនកម្ពុជាទេ"*។ ទោះបីជាយ៉ាងណាក្តី នៅក្នុងការសិក្សាដដែលនេះ មានភូមិខ្លះដែលមានការទទួលស្គាល់គូស្រករស្រីដូចគ្នារស់នៅជាមួយគ្នា ជាពិសេសគឺដោយសារតែពួកគេបានរស់នៅជាមួយគ្នាជាយូរមកហើយ និងចិញ្ចឹមកូន កូនសុំគេ ឬកូនតាមធម្មជាតិពីការរៀបការលើកមុន។ សកម្មជន RoCK ប៉ាន់ស្មានថា មានគូស្រករ LGBTយ៉ាងហោចណាស់ចំនួនមួយពាន់គូ នៅក្នុងប្រទេសកម្ពុជា។ ក្នុងអំឡុងទិវាមោទនភាព ឆ្នាំ២០១៣, គូស្រករស្រីស្រឡាញ់ភេទដូចគ្នាចំនួន ៧៦ គូ និងប្រុសស្រឡាញ់ភេទដូចគ្នាចំនួន ៥គូ បានចូលរួមសិក្ខាសាលាមួយរបស់ RoCK ក្នុងរាជធានីភ្នំពេញ។[86]

---

[83] ចូរមើលផងដែរនៅគេហទំព័រ http://sochua.wordpress.com/2010/12/02/from-white-cloth-to-precious-gems-cambodian-women-challenge-gender-stereotypes-and-defend-against-hiv/

[84] CCHR. (2010) "ចេញជាជំហានៅព្រះរាជាណាចក្រ" ទំព័រ ១៩

[85] Salas V & Srun S. (2013). "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទនៅក្នុងគ្រួសារ និងសហគមន៍ និងវិធីដោះស្រាយរបស់ពួកគេ"។ របាយការណ៍ស្រាវជ្រាវ។ ផ្នែកសម្របសម្រួលការគាំពារសង្គម ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មជនបទ (SPCU-CARD) ភ្នំពេញ

[86]Kunthear M and Drennan, J. "ច្បាប់មិនអាចបញ្ឈប់គូស្នេហ៍មិនឲ្យរៀបការបានទេ", ភ្នំពេញប៉ុស្តិ៍។ ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៣

## អាកប្បកិរិយារបស់បុរសចំពោះការស្រឡាញ់ភេទដូចគ្នា៖ ជាការអាម៉ាស់ ប៉ុន្តែច្បាប់គួរការពារពួកគេ ពីការរើសអើង

ដើម្បីស្វាបស្ទង់ពីទស្សនៈរបស់បុរសអំពីការស្រឡាញ់ភេទដូចគ្នា ការអង្កេតទូទាំងប្រទេសមួយក្នុងឆ្នាំ២០១២[87], ជាផ្នែកមួយនៃយុទ្ធនាការផ្សព្វផ្សាយប្រឆាំងអំពើហិង្សាលើស្ត្រី, បានសួរសំណួរពីរអំពីការស្រឡាញ់ភេទដូចគ្នា។ ស្ត្រីមិនត្រូវបានគេដាក់បញ្ចូលនៅក្នុងការអង្កេតនេះទេ។ ក្នុងចំណោមអ្នកឆ្លើយតបការសម្ភាសន៍ជាបុរសចំនួន ១៥១៩នាក់ ៦៣% បានឯកភាពថា "ខ្ញុំនឹងមានការអាម៉ាស់ ប្រសិនបើមានកូនប្រុសដែលស្រឡាញ់ប្រុសដូចគ្នា"។ អ្នកឆ្លើយតបនឹងការសម្ភាសន៍ក្នុងចំណោមច្រើនជាងនេះបន្តិច (៦៥%) បានយល់ស្របថា "គួរតែមានច្បាប់ដែលការពារមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងអ្នកស្រឡាញ់ភេទដូចគ្នាពីការរើសអើង"។[88] ការអង្កេតពុំមានសំណួរទាក់ទងនឹងស្រីស្រឡាញ់ស្រីដូចគ្នាទេ។

## ទស្សនៈរបស់ព្រះពុទ្ធចំពោះឥរិយាបថផ្លូវភេទ

ថេរវាទគឺជាទម្រង់លេចធ្លោបំផុតនៃសាសនាព្រះពុទ្ធនៅក្នុងប្រទេសកម្ពុជា។ ប្រជាពលរដ្ឋកម្ពុជាយ៉ាងតិច ៩៦ភាគរយ គោរពសាសនាព្រះពុទ្ធ។[89] Pali Canon មិនហាមឃាត់ចំពោះការស្រឡាញ់ភេទដូចគ្នានោះទេ។ ធម៌វិន័យព្រះពុទ្ធ មិនមានការស្អប់មនុស្សស្រី ការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា និងការស្អប់មនុស្សប្តូរភេទទេ។[90] ជំហាននៃមាគ៌ាដែលមានប្រាំបីវគ្គ ផ្តោះទៅរកការត្រាស់ និយាយពីសកម្មភាពផ្លូវភេទ។ ជំហានទីពីរបញ្ជាក់ថា "អ្នកត្រូវតែលះបង់ចោលការសប្បាយត្រេកត្រអាលនឹងវិញ្ញាណទាំងអស់"។ នេះត្រូវបានគេគិតថាចង់និយាយអំពីសកម្មភាពផ្លូវភេទគ្រប់ប្រទេស និងចង់និយាយអំពីការតមមិនរួមភេទទាំងស្រុងតែម្តង។ ជំហានទីបួន ហាមឃាត់ "អំពើរួមភេទដែលមិនស្របច្បាប់"។ អ្នកអត្ថាធិប្បាយព្រះពុទ្ធតែងបកស្រាយអំពើបែបនេះថា សំដៅទៅលើ "ការរំលោភសេពសន្ថវៈ ការរុកកួនផ្លូវភេទ ការរុកកួនផ្លូវភេទកុមារ និងការក្បត់ប្តីប្រពន្ធខ្លួនឯង"។

ពុំមានការបែងចែកភាពខុសគ្នារវាងឥរិយាបថស្រឡាញ់ភេទដូចគ្នា និងស្រឡាញ់ភេទផ្ទុយគ្នាឡើយ - ទាំងពីរត្រូវតែគ្មានគ្រោះថ្នាក់ ដោយមានការយល់ព្រមគ្នាទៅវិញទៅមក ការបំបែកការប្តេជ្ញាចិត្តចំពោះបុគ្គលម្នាក់ទៀតគឺមិនពាក់ព័ន្ធ ហើយឥរិយាបថផ្លូវភេទត្រូវតែអនុវត្តដោយមានបំណងសំដែងនូវក្តីស្រឡាញ់ដោយការគោរព និងផ្តល់សេចក្តីសប្បាយ

[87] Domrei Research & Consulting. (2012) ការអង្កេតដើមគ្រាស្តីពីយុទ្ធនាការផ្សព្វផ្សាយរួមគ្នាស្តីពីអំពើហិង្សាលើស្ត្រី។ របាការណ៍រៀបចំសម្រាប់ សន្តិភាព និងការអភិវឌ្ឍ (Paz Y Desarollo)

[88] Domrei Research and Consulting. (2012). Ibid. ទំព័រ ២៧–២៨ និង ទំព័រ ៣៩

[89] http://en.wikipedia.org/wiki/Religion_in_Cambodia, ទាញចេញថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤។

[90] http://www.religioustolerance.org/hom_budd0.htm. ទាញចេញថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤

រីករាយដល់គ្នាទៅវិញទៅមក។ ធម៌វិន័យទាំងនេះអនុវត្តដោយមិនគិតពីភេទ ឬទំនោរផ្លូវភេទរបស់នរណាម្នាក់ឡើយ។ គោលការណ៍ដូចគ្នាត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃទំនាក់ទំនងទាំងអស់ និងឥរិយាបថផ្លូវភេទ ទាំងការស្រឡាញ់ភេទផ្ទុយគ្នា ឬភេទដូចគ្នា។[91] ថ្មីៗបំផុតនេះ ដាឡៃឡាម៉ា បានសំដែងការគាំទ្រចំពោះការរៀបការភេទដូចគ្នា ហើយព្រះអង្គបានកត់សម្គាល់ថានីត្យានុកូលកម្មនៃការចងសម្ព័ន្ធមេត្រីបែបនេះ គឺជាបញ្ហាសម្រាប់ប្រទេសនីមួយៗជាអ្នកសម្រេច។[92]

ក្នុងអំឡុងពេលប្រារព្ធពិធីមោទនភាពLGBT ឆ្នាំ២០១២ សកម្មភាពអធិកអធមទាំងនេះបានបញ្ចប់ទៅជាមួយនឹងការជូនពរជ័យនៅឯវត្តមួយ។[93] ចៅអធិការវត្តទួលដំបងខ្ពស់ បានមានសង្ឃដីកាថា "...ព្រះពុទ្ធមិនដែលមានទំនាស់ជាមួយបញ្ហាកាមគុណ ឬអត្តសញ្ញាណទេ... ឡើយ ព្រះសម្មាសម្ពុធរបស់យើងបានបង្រៀនយើងឲ្យចេះស្រឡាញ់គ្នា ចេះជួយគ្នា និងមិនរើសអើងនឹងគ្នា..."

## វិមជ្ឈការ និងភាពខុសគ្នានៅទូទាំងប្រទេសកម្ពុជា៖ ទំនាក់ទំនង និងភាពជាដៃគូរបស់ LGBT

ការទទួលយកបុគ្គល LGBT មិនត្រូវបានគេធ្វើការសិក្សាជាលក្ខណៈប្រព័ន្ធនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ ទោះបីជាយ៉ាងណាក្តី ដូចជានៅក្នុងប្រទេសដទៃទៀតក្នុងពិភពលោកដែរ ទីក្រុងធំៗ និងទីរួមខេត្ត ច្រើនតែជាកន្លែងដែលមនុស្សប្រុសស្រឡាញ់ប្រុស និង MSM និងមនុស្សប្តូរភេទដទៃទៀត ប្រមូលផ្តុំ។ នេះមិនមែនជារឿងភ្ញាក់ផ្អើលនោះទេ ដោយសារតែមានបណ្តាញសង្គមដែលអាចពឹងពាក់បាន ឱកាសការងារនិងរាប់អានគ្នាកាន់តែច្រើនថែមទៀត ហើយទីកន្លែងទាំងនោះមានលក្ខណៈជាឯកជនច្រើនទៀតផង។ សេវា LGBT ជាច្រើន ដូចជាមណ្ឌលអប់រំដែលចាត់ចែងដោយអង្គការក្រៅរដ្ឋាភិបាល និងគ្លីនិក ជាពិសេសសម្រាប់ MSM និងមនុស្សស្រីប្តូរភេទ ស្ថិតនៅក្នុងទីក្រុង។ ក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះ ទាំងនៅរាជធានីភ្នំពេញ ទាំងនៅសៀមរាប គ្រឹះស្ថានសម្រាប់មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នាដូចជា បារ ឌីស្កូ ផ្ទះសំណាក់ និងសូណាសម្រាប់តែបុរស និងទីកន្លែងម៉ាស្សា បានចាប់ផ្តើមបើកឡើង។

ភ័ស្តុតាងតាមការនិយាយតៗគ្នា បង្ហាញថាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទពីស្រីទៅប្រុស ចូលចិត្តរស់នៅតាមខេត្ត ជាពិសេសប្រសិនបើពួកគេមានដៃគូ និងបាន

[91] Trembath. Kerry. "សាសនាព្រះពុទ្ធ និងការស្រឡាញ់ភេទដូចគ្នា" http://www.enabling.org/ia/vipassana/Archive/T/Trembath/buddhismAndHomosexualityTrembath.html ទាញចេញថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៤

[92] http://abcnews.go.com/blogs/politics/2014/03/dalai-lama-says-he-supports-gay-marriage/ ២៨ មីនា ២០១៤

[93] Roth Meas, "ទិវាមោទនភាពត្រូវបានបញ្ចប់ដោយការសូត្រមន្ត". ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ទាញយកពី http://www.phnompenhpost.com/lifestyle/pride-closes-buddhist-blessing

កំពុងរស់នៅជាមួយគ្នារួចហើយនោះ។ មេភូមិម្នាក់ដែលគាំទ្រចំពោះសកម្មភាពនេះ បានប្រាប់រឿងរ៉ាវអំពីគ្រួសារដែលមានមនុស្សស្រីពីរនាក់ជាមេគ្រួសារ នៅក្នុងការប្រជុំនៅថ្នាក់ឃុំនិងស្រុក, "*...ហាក់ដូចជាមានច្រើនដែរ (មនុស្សស្រីដែលមានទំនាក់ទំនងភេទដូចគ្នា, រស់នៅជាមួយគ្នា) នៅក្នុងភូមិនេះ... ប៉ុន្តែហាក់ដូចជាមិនមានមនុស្សប្រុសស្រឡាញ់ភេទដូចគ្នានិងមនុស្សប្តូរភេទ (មនុស្សប្រុសស្លៀកពាក់ជាស្រី) ដោយសារពួកគេទាំងអស់គ្នាទៅរស់នៅក្នុងទីក្រុង ។*"[94]

## ស្ថាប័នសំខាន់ៗសម្រាប់ការពារសិទ្ធិរបស់ LGBT

ពុំមានស្ថាប័នរដ្ឋាភិបាលដែលធ្វើការជាក់លាក់ទៅលើសិទ្ធិរបស់ LGBT ឡើយ។ ជាគោលការណ៍ ប្រជាពលរដ្ឋកម្ពុជាទាំងអស់ត្រូវទទួលបានការយកចិត្តទុកដាក់ដូចៗគ្នាផ្អែកតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស ដោយមិនគិតពីភេទ អាយុ ជាតិសាសន៍ ឬជំនឿសាសនា។ គណៈកម្មការសិទ្ធិមនុស្សជាតិកម្ពុជា មិនបានពាក់ព័ន្ធនៅក្នុងបញ្ហារបស់មនុស្សLGBT ទេ ហើយក៏មិនបានផ្តល់យោបល់អំពីបញ្ហាសិទ្ធិរបស់មនុស្ស LGBT ដែលបានលើកឡើងក្នុងរបាយការណ៍ផ្ញើជូនគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHRC) សម្រាប់របាយការណ៍ត្រួតពិនិត្យតាមពេលកំណត់ជាសកលឆ្នាំ២០១៣ នោះដែរ។

ក្រសួងរដ្ឋាភិបាលមិនមានកម្មវិធីឬគម្រោងជាក់លាក់សម្រាប់បុគ្គល LGBT ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងសុខាភិបាល, (តាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) បានបង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ឆ្លើយតបនឹងមេរោគអេដស៍ក្នុងចំណោម MSM និងមនុស្សស្រីប្តូរភេទ។ ផ្អែកលើអេពីដេមសាស្ត្រមេរោគអេដស៍ ក្របខ័ណ្ឌនេះមិនបាននិយាយអំពី មនុស្សស្រីស្រឡាញ់ភេទដូចគ្នា ឬមនុស្សប្រុសប្តូរភេទ។

ថ្មីៗនេះ ក្រសួងកិច្ចការនារីបានបានចាប់ផ្តើមដាក់បញ្ចូល មនុស្សស្រីស្រឡាញ់ភេទទាំងពីរ មនុស្សស្រីប្តូរភេទ និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ទៅក្នុងសេចក្តីព្រាងផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី ។ នេះគឺជាជំហានវិជ្ជមានមួយ។ បច្ចុប្បន្នេះ គេនៅមិនទាន់ច្បាស់ថាតើក្រុមគោលដៅទាំងនេះនឹងត្រូវបានរក្សាទុកដដែលនៅក្នុងឯកសារចុងក្រោយ ឬយ៉ាងណានៅឡើយទេ។

អង្គការក្រៅរដ្ឋាភិបាលជាច្រើនផ្តោតការយកចិត្តទុកដាក់លើមេរោគអេដស៍ និងធ្វើការជាមួយ MSM និងស្ត្រីប្តូរភេទ។ ពួកគេមានសេវាប្រឹក្សាជំងឺកាមរោគនិងមេរោគអេដស៍ ប៉ុន្តែសេវាទាំងនេះមានត្រឹមតែការពិនិត្យរោគសញ្ញាគ្លីនិក ការព្យាបាល និងការប្រើស្រោមអនា

[94] Salas V & Srun, S. (2013) ទំព័រ ១៦ និង ១៨

ម័យ។ បញ្ហា SOGI មិនត្រូវបានគេពិភាក្សាឡើយ ហើយក៏ពុំមានការបណ្តុះបណ្តាលសម្រាប់អ្នកផ្តល់ប្រឹក្សាក្នុងផ្នែកទាំងនេះដែរ។ ប្រសិនបើមានការរំលោភសិទ្ធិដែលមិនទាក់ទងនឹងសុខភាព ដូចជាការចាប់ខ្លួន និងការឃុំខ្លួនដោយមិនរើសមុខ អង្គការក្រៅរដ្ឋាភិបាលទាំងនេះបញ្ជូនអ្នកដែលប៉ះពាល់ទៅរកអង្គការសិទ្ធិមនុស្ស និងអង្គការដែលតស៊ូមតិផ្នែកច្បាប់។

អង្គការក្រៅរដ្ឋាភិបាលសិទ្ធិមនុស្ស CCHR បានអនុវត្តគម្រោង SOGI និងសិទ្ធិ LGBT តាំងពីឆ្នាំ២០១០។ អង្គការក្រៅរដ្ឋាភិបាលដទៃទៀតដែលធ្វើការលើសិទ្ធិមនុស្ស រួមមាន សម្ព័ន្ធកម្ពុជាដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស (LICADHO)។ យូរៗម្តង ពួកគេផ្តល់សេវាផ្នែកច្បាប់ដល់បុគ្គល LGBT ផងដែរ បើទោះបីបញ្ហាជាអាទិភាពរបស់ពួកគេ គឺភាពគ្មានដីធ្លី និងអំពើហិង្សាពីសំណាក់នគរបាលក៏ដោយ។ អង្គការនានាដែលធ្វើការលើសិទ្ធិរបស់ស្ត្រី (រួមទាំងសិទ្ធិផ្នែកផ្លូវភេទនិងបន្តពូជ) ឬធ្វើការទប់ស្កាត់អំពីហិង្សាក្នុងគ្រួសារ និងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ មិនបានផ្តោតលើមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ឬមនុស្សប្តូរភេទឡើយ។

បុគ្គល LGBT ប្រហែលជាមានការយល់ដឹងមិនគ្រប់គ្រាន់នោះទេអំពីច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនានា។ របាយការណ៍ស្តីពីការផាត់ចេញពីសង្គម បានសួរអ្នកឆ្លើយតបនឹងសម្ភាសន៍ដែលជាមនុស្ស LGBT ថាតើពួកគេធ្លាប់ឮពីច្បាប់និងគោលនយោបាយជាតិខ្លះដែលឬទេ។ ៧២%នៃអ្នកឆ្លើយតបនឹងសម្ភាសន៍បានដឹងពីច្បាប់ស្តីពីសិទ្ធិកុមារ បន្ទាប់មកច្បាប់ការងារ ៦២% ច្បាប់ស្តីពីការលែងលះ ៥៩% ច្បាប់ប្រឆាំងការជួញដូរមនុស្ស ៥៧% និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ៤៧%។[95]

ច្បាប់ជាច្រើន ដូចជាច្បាប់ប្រឆាំងការចាប់ជំរិត ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ត្រូវបានគេប្រើជាមូលដ្ឋានមួយសម្រាប់បំបែកដៃគូ។[96] ករណីពិសេសមួយបានទាក់ទាញការយកចិត្តទុកដាក់ពី OHCHR នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០១២។ មានការចោទប្រកាន់ថា គ្រួសារមួយបានសូកប៉ាន់មន្ត្រីសមត្ថកិច្ចឲ្យប្តូរអាយុរបស់កូនស្រីពួកគេនៅក្នុងឯកសារ ដើម្បីចាត់វិធានការតាមច្បាប់ប្រឆាំងនឹងដៃគូស្រីរបស់នាង។[97]

នៅថ្នាក់ឃុំ សកម្មជននៅមូលដ្ឋានបានកត់សម្គាល់ថា ពាក្យបណ្តឹងអំពីការវាយ និងអំពើហិង្សា ត្រូវបានបញ្ជូនមកមន្ត្រីសមត្ថកិច្ច និងនគរបាលមូលដ្ឋាន ប៉ុន្តែជារឿយៗ ត្រូវបានគេ

---

[95] Salas V & Srun, (2013). ទំព័រ ១៤

[96] របាយការណ៍ CCHR ឆ្នាំ២០១២, ទំព័រ១៦; ការប្រាស្រ័យទាក់ទងផ្ទាល់ពីសកម្មជនLGBT នៅអង្គការ RoCK

[97]Lewis, M. "ចេញជាជំហានៅក្នុងប្រទេសកម្ពុជា: ស្ត្រីក្នុងទំនាក់ទំនងភេទដូចគ្នា ក្រោកឈរដើម្បីសិទ្ធិមនុស្ស"។ http://www.theguardian.com/journalismcompetition/professional-longlist-20121

មិនយកចិត្តទុកដាក់។ ជនរងគ្រោះត្រូវបានគេប្រាប់ថា "នេះគឺជាបញ្ហាផ្ទាល់ខ្លួន" ឬ "គ្រាន់តែធ្វើតាមឪពុកម្ដាយរបស់អ្នកទៅ"។"[98]

នៅក្នុងឆ្នាំ២០០៨ មានការស្នើឡើងថា សាលាក្ដីខ្មែរក្រហមគួរដាក់បញ្ចូលបញ្ហារៀបការដោយបង្ខំជាបទឧក្រិដ្ឋមួយដែលគួរជំនុំជម្រះផងដែរ។ នេះគឺជាគោលនយោបាយរបស់របបនោះដែលតម្រូវឲ្យសមាជិកក្រុមរៀបការជាមួយគ្នា ទោះជាពួកគេស្គាល់គ្នាឬមិនស្គាល់ក៏ដោយ។ ស្ត្រីប្លូរភេទម្នាក់ គឺជាបុគ្គលដំបូងបំផុតម្នាក់ដែលបាននិយាយចេញមកអំពីបញ្ហានេះ។[99] ទោះបីជាយ៉ាងណាក្ដី គេនៅមានមន្ទិលសង្ស័យថាតើសំណុំរឿងទាំងនេះនឹងត្រូវបានគេបើកសវនាការឬទេ។ មានតែពីរករណីប៉ុណ្ណោះក្នុងចំណោមរាប់រយរាប់ពាន់សំណុំរឿង ត្រូវបានគេសម្រេចក្នុងរយៈពេល៦ឆ្នាំចុងក្រោយនេះ ហើយសាលាក្ដីនេះលែងមានធនធានដើម្បីបន្តការងារនេះទៀតហើយ ។

[98] ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន, ស្រិន ស្រ៊ុន (២០១៤)

[99] Freeman, J. and Chanida, C. "ភាគីរដ្ឋប្បវេណីលើកឡើងនូវអាពាហ៍ពិពាហ៍ដោយបង្ខំជាសាធារណៈម្ដងទៀត", ភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ទាញយកពី http://www.phnompenhpost.com/national/civil-parties-put-forced-marriage-back-spotlight

## ការការពារសិទ្ធិរបស់បុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា

ផ្នែកនេះមើលលើការការពារសិទ្ធិរបស់បុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា ក្រោមប្រធានបទដូចជា៖កិច្ចការគ្រួសារការអប់រំ និងសាលារៀនមុខរបរ និងការងារ សហគមន៍ និងសង្គមសុខភាពប្រព័ន្ធផ្សព្វផ្សាយបញ្ហា និងក្ដីកង្វល់ដទៃទៀត។

ផ្នែកនីមួយៗរួមមានការពិពណ៌នាអំពីបញ្ហានិងក្ដីកង្វល់ និងអនុសាសន៍សម្រាប់សហគមន៍ LGBT, និងសម្រាប់ភាគីពាក់ព័ន្ធដទៃទៀត ដូចជា អង្គការសង្គមស៊ីវិល ក្រសួងរដ្ឋាភិបាល អ្នកតាក់តែងគោលនយោបាយ អ្នកអនុវត្តន៍ ដៃគូអភិវឌ្ឍន៍ និងភាគីដទៃទៀត។

### កិច្ចការគ្រួសារ

អ្នកចូលរួមដែលជា LGBT បានលើកឡើងនូវបញ្ហាយ៉ាងច្រើនដែលពួកគេមាននៅក្នុងគ្រួសារ រួមទាំងការមិនទទួលស្គាល់ ការយកចិត្តទុកដាក់ខុសគ្នាធៀបនឹងបងប្អូនបង្កើតដទៃទៀត និងការបដិសេធ។ ឪពុកម្ដាយខ្លះជឿថា ការធ្វើជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នាគឺជាជំងឺផ្លូវចិត្តមួយ ហើយចាត់ទុកកូនរបស់ពួកគេ ឆ្កួត។ ពួកគេទៅរកគ្រូពេទ្យផ្នែកចិត្តសាស្ត្រ វិកលវិទូ និងគ្រូខ្មែរ ឬស្រោចទឹក ដើម្បី "ព្យាបាល"ពួកគេ។ គ្រួសារខ្លះយល់ថា កូនរបស់ពួកគេដែលជា LGBT ធ្វើឲ្យគ្រួសារមានការអាម៉ាស់ និងអាប់ឱនកិត្តិយស។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិ បានលើកឡើងអំពីការមាក់ងាយ ការវាយធ្វើបាប ការជេរ ការស្ដីបន្ទោស និងការដកហូតយករបស់របរផ្ទាល់ខ្លួននានា ដូចជាទូរស័ព្ទ និងម៉ូតូ ជាដើម។ ពួកគេបានលើកឡើងអំពីការគំរាមកំហែងចង់កាត់កាលពួកគេ ដោយសារតែពួកគេមានចរិតខុសគេ ឬដោយសារប្រុសធ្វើចរិតស្រី ព្រោះពួកគេពាក់សក់វែង។ ពួកគេបានប្រាប់ផងដែរថា ឪពុកម្ដាយមិនអនុញ្ញាតឲ្យពួកគេជួបមិត្តភក្តិ ឬជ្រើសរើសដៃគូដែលពួកគេចង់បានឡើយ។ អ្នកចូលរួមដែលជាមនុស្សប្ដូរភេទ បានលើកឡើងថា គ្រួសាររបស់ពួកគេមិនអនុញ្ញាតឲ្យពួកគេប្ដូរភេទនៅលើឯកសារផ្លូវការឡើយ ទោះបីជាគេមិនច្បាប់ថាតើគ្រួសារមានសិទ្ធិផ្លាស់ប្ដូរភេទនៅក្នុងឯកសារផ្លូវការឬយ៉ាងណាក្ដី។ ពួកគេក៏បញ្ជូនកូនឲ្យទៅរស់នៅផ្ទះរបស់បងប្អូន ដើម្បីព្យាយាមផ្លាស់ប្ដូរពួកគេ និងឲ្យឆ្ងាយពីឥទ្ធិពល "អាក្រក់"។ អ្នកចូលរួមជាច្រើនបានលើកឡើងថា ពួកគេត្រូវបានបង្ខំឲ្យបែកចេញពីដៃគូដែលពួកគេស្រឡាញ់ និងបង្ខំឲ្យពួកគេរៀបការជាមួយមនុស្សដែលមានភេទផ្ទុយគ្នា។

ជាផលវិបាក អ្នកចូលរួមជាច្រើនបានប្រាប់ថា ពួកគេបានរត់ចេញពីផ្ទះ ទៅរស់នៅជាមួយមិត្តភក្តិ ឬ "អ្នកដែលដូចខ្ញុំ"។ អ្នកខ្លះទៀតបាននិយាយថា បាក់ទឹកចិត្ត និងចង់ធ្វើអត្តឃាត។ អ្នកខ្លះមានការឈឺចាប់យ៉ាងខ្លាំង ព្រោះតែកង្វះខាតក្ដីស្រឡាញ់ និងភាពស្និទ្ធស្នាលនៅក្នុងគ្រួសារ ដោយសារតែខុសគេ។ ពួកគេមានការអាក់អន់ចិត្ត និងមានកំហឹងយ៉ាងខ្លាំងដែលសារតែមិនអាចផ្លាស់ប្ដូរអត្តសញ្ញាណរបស់ខ្លួនបាន។ នេះគឺជាការបដិសេធពីគ្រួសារ

ដែលតាមពិតត្រូវតែផ្តល់ការការពារមុនគេ មានផលប៉ះពាល់យ៉ាងខ្លាំងមកលើជីវិតរបស់បុគ្គល LGBT ដូចមានបញ្ជាក់នៅក្នុងការសិក្សាករណីខាងក្រោម។

### ករណីសិក្សាទី១

"នៅពេលខ្ញុំកើតមក ឪពុកម្តាយរបស់ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដោយសារខ្ញុំគឺជាកូនប្រុសម្នាក់ ហើយគ្រូទាយបានប្រាប់ថា សំណាងណាស់ព្រោះខ្ញុំកើតក្នុងឆ្នាំល្អ ហើយថាខ្ញុំនឹងនាំនូវភ័ព្វសំណាង និងជោគជ័យដល់គ្រួសារ... ក្រោយមកទៀត ឪពុកខ្ញុំមានការខកចិត្តយ៉ាងខ្លាំង...

នៅក្នុងសាលារៀន ទោះបីជាខ្ញុំនៅតូចក្តី មានបញ្ហាជាច្រើន ហើយមិត្តរួមថ្នាក់មើលងាយខ្ញុំ លេងសើចដាក់ខ្ញុំ និងគប់ដីសដាក់ខ្ញុំ។ គ្រូខ្ញុំមិនបានឃាត់ពួកគេឡើយ ហើយពួកគេមិនចូលចិត្តវិធីស្លៀកពាក់របស់ខ្ញុំ ដំណើរខ្ញុំ និងពេលខ្ញុំនិយាយស្តី។ ខ្ញុំបានរៀនចប់ត្រឹមថ្នាក់ទី៩ប៉ុណ្ណោះ។

គ្រួសារខ្ញុំធ្លាប់ស្តីបន្ទោសខ្ញុំ ដោយសារតែខ្ញុំអញ្ចឹង ពួកគេមាក់ងាយខ្ញុំ និងមិនចូលចិត្តខ្ញុំ បងប្អូនខ្ញុំក៏អញ្ចឹងដែរ... ហើយពួកគេដេញខ្ញុំចេញពីផ្ទះអស់បីខែ នៅពេលពួកគេឃើញខ្ញុំពាក់សំលៀកបំពាក់ស្រី។ ខ្ញុំមានអាយុប្រហែល១៥ឆ្នាំនៅពេលនោះ។ បន្ទាប់ពីពួកគេទាត់ខ្ញុំចោលពីផ្ទះ ខ្ញុំរស់នៅជាមួយមិត្តភក្តិខ្ញុំ... ខ្ញុំមានការលំបាកច្រើន ដោយសារខ្ញុំមិនដឹងថាតើត្រូវចិញ្ចឹមខ្លួនឯងដូចម្តេច... ខ្ញុំមិនបានចូលសាលារៀនទេ ហើយត្រូវលក់ខ្លួនដើម្បីរស់ ទោះបីជាខ្ញុំមិនចង់ធ្វើដូច្នេះក្តី។

ខ្ញុំធ្លាប់ប៉ូលីសចាប់ម្តង។ គ្រួសារខ្ញុំបានព្យាយាមធ្វើឲ្យខ្ញុំផ្លាស់ប្តូរ។ ខ្ញុំប្រាប់ពួកគេថា "ទោះបីជាខ្ញុំដូច្នេះមែន ប៉ុន្តែខ្ញុំមិនដែលធ្វើបាបអ្នកណាទេ... ខ្ញុំមិនធ្វើអ្វីខុសច្បាស់ ឬជាឧក្រិដ្ឋជនទេ..."

ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះឪពុកខ្ញុំ។ គាត់ស្លាប់ទៅហើយ ព្រោះខ្ញុំមិនដែលមានឱកាសធ្វើឲ្យគាត់ទទួលស្គាល់ខ្ញុំសោះ ដើម្បីកែលម្អទំនាក់ទំនងរបស់យើង និងដើម្បីឲ្យគាត់ស្រឡាញ់ខ្ញុំ។ យើងមានកង្វះខាតនេះ យើងមិនដែលនិយាយគ្នាទេ ខ្ញុំមិនដែលហៅគាត់ថា "ប៉ា"ទេ ហើយគាត់កាត់កាលខ្ញុំចោល និងមិនចង់ឲ្យខ្ញុំហៅគាត់ថា "ប៉ា"ទេ។"

សិលា (ឈ្មោះដាក់ឲ្យក្រៅ), ស្ត្រីប្តូរភេទ

### *អនុសាសន៍ដែលផ្តល់ដោយសមាជិកនៃកិច្ចពិភាក្សាថ្នាក់ជាតិស្តីពីសហគមន៍ LGBT នៅកម្ពុជាដល់សមាជិកសហគមន៍ LGBT៖*

- អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិជាច្រើន បានកត់សម្គាល់ថា នៅពេលពួកគេបានចាប់ផ្តើមរកប្រាក់បានខ្លះ និងជួយគ្រួសារ សហគមន៍ និងសង្គមផ្នែកហិរញ្ញវត្ថុ មានការទទួលស្គាល់កាន់តែច្រើន។ បន្ទាប់មក ពួកគេអាចមានឥទ្ធិពលនិងអំណាចកាន់តែច្រើនក្នុងគ្រួសារ។
- រិះរកវិធីផ្សេងៗដើម្បីពន្យល់ដោយខ្លួនឯង ដល់គ្រួសាររបស់អ្នក - ឧទាហរណ៍ អង្គការឥន្ទធនូកម្ពុជា (RoCK) បានផលិតកូនសៀវភៅព័ត៌មានអំពី "ការបើកចំហពីភេទ

របស់ខ្លួន" និង "សំណួរដែលគេច្រើនសួរញឹកញាប់អំពីបុគ្គលLGBT"។ "នេះគឺជាឯកសារណែនាំដើម្បីស្វែងយល់ដោយខ្លួនឯង ក្នុងនាមជាមនុស្ស LGBT ។

- ចូលរួមជាមួយក្រុមគាំទ្រ - ជាពិសេស នៅពេលបុគ្គល LGBT ជួបប្រទះបញ្ហា។ វាជាការសំខាន់ណាស់ដែលត្រូវស្វែងរកជំនួយខាងក្រៅ និងនិយាយអំពីបញ្ហាជាមួយអ្នកដទៃ។ ជួយគ្នាក្នុងគ្រាមានវិបត្តិ។
- គេគួរផ្តល់ដំបូន្មានដល់សមាជិកគ្រួសារ អំពីបញ្ហានិងផលប៉ះពាល់នៃការរើសអើងប្រឆាំងកូនរបស់ពួកគេដែលជា LGBT ។

## *អនុសាសន៍សម្រាប់រដ្ឋាភិបាលថ្នាក់ជាតិ អ្នកតាក់តែងគោលនយោបាយ អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល៖*

- រដ្ឋាភិបាលគួរពិនិត្យឡើងវិញ ឬកែសម្រួលច្បាប់ សារាចរ និងគោលនយោបាយរបស់ស្ថាប័នដើម្បីការពារបុគ្គល LGBT និងសិទ្ធិរបស់ពួកគេ។ នេះអាចត្រូវបានធ្វើឡើងដោយមានការគាំទ្រពីក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងរដ្ឋសភាជាតិ។ អនុសាសន៍ជាក់លាក់រួមមាន៖
  - បន្ថែម SOGI ជាក់លាក់ទៅលើបទប្បញ្ញត្តិ "ស្ថានភាពដទៃទៀត" ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ទាក់ទងទៅនឹងការមិនរើសអើង។ SOGI គួរត្រូវបានចែងជាក់លាក់ថាជា ស្ថានភាពមួយដែលមិនអាចប្រឈមនឹងការរើសអើង។
  - បង្កើតច្បាប់ប្រឆាំងការរើសអើងដែលផ្តោតជាក់លាក់ទៅលើបុគ្គល LGBT ។
  - ធ្វើវិសោធនកម្មច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ដើម្បីអនុញ្ញាតដល់ការរៀបការភេទដូចគ្នា។ជាជម្រើសផ្សេងមួយទៀត គឺផ្សព្វផ្សាយនៅគ្រប់កម្រិតថ្នាក់នូវនិរាករណ៍ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ដែលលុបចោលបទប្បញ្ញត្តិឆ្នាំ១៩៨៩ ដែលហាមឃាត់អាពាហ៍ពិពាហ៍ភេទដូចគ្នា។
- ក្រសួងរបស់រដ្ឋាភិបាល និងស្ថាប័នរដ្ឋទាំងអស់ គួរពិចារណាបញ្ហាដែលបុគ្គល LGBT កំពុងជួបប្រទះ ក៏ដូចជាដំណោះស្រាយ និងដាក់បញ្ចូលកិច្ចការទាំងនេះទៅក្នុងកម្មវិធីការងារនិងឯកសារគោលនយោបាយរបស់ពួកគេ។ ឧទាហរណ៍ ក្រសួងកិច្ចការនារី គួរដាក់បញ្ចូលបញ្ហា LGBT ទៅក្នុងផែនការសកម្មភាពជាតិរយៈពេល៥ឆ្នាំរបស់ខ្លួនស្តីពីការទប់ស្កាត់អំពើហិង្សា ទាក់ទងនឹងយេនឌ័រ (២០១៣-២០១៧)។
- អាជ្ញាធរមូលដ្ឋាន គួរត្រូវបានជម្រាបប្រាប់អំពីបញ្ហា ឬផលប៉ះពាល់នៃការរើសអើងមកលើបុគ្គល LGBT ពីសំណាក់គ្រួសាររបស់ពួកគេ។ ពួកគេគួរសម្រុះសម្រួល និងណែនាំឪពុកម្តាយ កុំឲ្យប្រើអំពើហិង្សាមកលើកូនរបស់ពួកគេដែលជា LGBT ព្រមទាំងផ្តល់យន្តការនានាដើម្បីការពារ ឬ បញ្ឈប់អំពើហិង្សាក្នុងគ្រួសារដែលទាក់ទងនឹង SOGI។ ពួកគេគួរអន្តរាគមន៍ នៅពេលមានអំពើហិង្សាក្នុងគ្រួសារ - ទាំងផ្លូវ

កាយទាំងផ្លូវចិត្ត - ឬនៅពេលឪពុកម្តាយ និងសាច់ញាតិបង្ខំកូនឬសាច់ញាតិរបស់ខ្លួនដែលជា LGBT ឲ្យរៀបការ។ មេឃុំមិនគួរចេញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ដល់គ្រួសារណាដែលបង្ខំកូនរបស់ពួកគេដែលជា LGBT ឲ្យរៀបការនោះឡើយ។

- សង្គមស៊ីវិលគួរមានយន្តការដើម្បីផ្តល់ការអប់រំជាសាធារណៈ អំពីផលប៉ះពាល់នៃអំពើហិង្សាដែលទាក់ទងនឹង SOGI បង្កឡើងដោយគ្រួសារប្រឆាំងនឹងសមាជិកគ្រួសាររបស់ខ្លួនដែលជា LGBT។ ពួកគេគួរពិចារណារៀបចំក្រុមពិភាក្សាអំពីការទទួលស្គាល់របស់គ្រួសារ និងរៀបចំផែនការអនុវត្តគម្រោងនានាដែលស្រដៀងគ្នានឹង អង្គការ ឪពុកម្តាយគ្រួសារ និង មិត្តភក្តិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា នៅក្នុងប្រទេសដទៃទៀតក្នុងតំបន់ ដូចជា ចិន និង វៀតណាម។
- អង្គកាសង្គមស៊ីវិល គួរប្រើវិធីនិងមធ្យោបាយថ្មីៗ ដូចជាសិល្បៈ ភាពយន្ត និងតន្ត្រីដើម្បីផ្សព្វផ្សាយអំពីសិទ្ធិ LGBT។ ឧទាហរណ៍រួមមាន ចម្រៀង *"កំហុសអ្នកណា?"* ដោយ ណយ ស៊ីថា ដោយមានទំនុកចំរៀង នៅក្នុងប្រអប់ខាងក្រោម ឬគម្រោង *"ក្រម៉ាឥន្ទធនូ"* នៃអង្គការCCHR ដែលលក់ក្រម៉ាឥន្ទធនូ ដើម្បីទ្រទ្រង់សកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតរបស់ស្ត្រីក្រីក្រ ខណៈពេលផ្សព្វផ្សាយអំពីនិម្មិតសញ្ញា LGBT ។
- ឯកសារច្បាប់នានាដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ឯកសារធ្វើដំណើរ និងប័ណ្ណអ្នកក្រីក្រ[100] ដែលចេញដោយមន្ត្រីនៅមូលដ្ឋាន អាចបង្កជាឧបសគ្គដល់បុគ្គល LGBT ជាពិសេស នៅពេលឯកសារទាំងនេះមិនឆ្លុះបញ្ចាំងពីភេទ (យេនឌ័រ) របស់បុគ្គលដែលបានជ្រើសរើសយកភេទនោះ។ ភាគីពាក់ព័ន្ធទាំងអស់ គួររំលេច និងចែករំលែកជាមួយមន្ត្រីមូលដ្ឋានដទៃទៀតនៅថ្នាក់ឃុំ ស្រុក និងខេត្ត នូវការអនុវត្តដែលពាក់ព័ន្ធនានាទាក់ទងទៅនឹងឯកសារច្បាប់ដែលលើកកម្ពស់ការដាក់បញ្ចូលក្នុងសង្គម ។[101]

---

[100] IDPoor គឺជាអក្សរកាត់សម្រាប់ "កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" ដែលជាកម្មវិធីគាំពារសង្គមរបស់រដ្ឋាភិបាលមួយដែលធ្វើចំណាត់ថ្នាក់គ្រួសារយោងទៅតាមកម្រិតនៃប្រាក់ចំណូល និងភាពក្រីក្រ។ អ្នកដែលស្ថិតនៅក្នុងក្រុមដែលមានប្រាក់ចំណូលទាប ត្រូវបានចាត់ទុកថា មានអាទិភាពសម្រាប់ទទួលការគាំទ្រ ឬជំនួយសង្គ្រោះបន្ទាន់ សេវាសង្គមនិងសុខភាព។ (កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ)

[101]Salas V & Srun S., "ការសិក្សាស្វែងយល់នៃការផាត់ចេញពីសង្គមនូវ LGBT ពីយន្តការគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា, SPCU-CARD & RoCK, 2014. (មិនទាន់ផ្សព្វផ្សាយជាផ្លូវការ) រូបទី ២, និងតារាងទី III, ទំព័រ ៧ & ១០

តើវាជាកំហុសអ្នកណា? (កំណាព្យដោយ ណាយស៊ីថា)

*គ្រួសាររបស់យើង មិនចូលចិត្តយើងទេ*
*ពួកគេនិយាយថា វាផ្ទុយនឹងច្បាប់ធម្មជាតិ...*
*ខ្លួនយើងគឺជាប្រុស ប៉ុន្តែចិត្តយើងគឺជាស្រី*
*តើវាជាកំហុសអ្នកណា?*
*ហេតុអ្វីព្រហ្មលិខិតមិនអត់ឱនឲ្យយើង?*
*កុំបំបែកយើង សូមពុកម៉ែលើកលែងទោសឲ្យយើងផង...*
*កុំបំបែកយើង សូមពុកម៉ែលើកលែងទោសឲ្យយើងផង...*
*សូមមនុស្សទាំងអស់កុំរើសអើងនឹងយើង ឬព្រហ្មលិខិតរបស់យើង...*
*សូមផ្តល់សិទ្ធិមកយើង ដើម្បីជ្រើសរើសគូស្រករ*
*ដូចមនុស្សធម្មតាក្នុងពិភពលោកដែរ...*

*(បកប្រែដោយ៖ គង់ ប៊ុនថន និង យ៉ាង ម៉ាណា)*

## ការអប់រំ និង សាលារៀន

### *បញ្ហា និងក្តីកង្វល់*

ការទទួលបានការអប់រំក្នុងប្រព័ន្ធ គឺជាគន្លឹះចំពោះការអភិវឌ្ឍធនធានមនុស្ស ប្រាក់ចំណូលកាន់តែខ្ពស់ និងគុណភាពជីវិតកាន់តែប្រសើរ។ កម្ពុជាទទួលបានផលចំណេញយ៉ាងច្រើននៅក្នុងការអប់រំ និងអត្រាអក្ខរកម្មក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ។ គម្លាតយេនឌ័រនៅក្នុងការអប់រំកំពុងតែរួមតូច ជាពិសេសនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។ ការប្រៀបធៀបទិន្នន័យពីការអង្កេតប្រជាសាស្ត្រនិងសុខភាព ឆ្នាំ២០០៥ និង ២០១០ (CDHS) បង្ហាញថាភាគរយនៃស្ត្រីដែលគ្មានការអប់រំ បានធ្លាក់ចុះពី ២៥ មក ១៦% (សម្រាប់បុរស ពី ១៣ មក ៨%)។ សមាមាត្រស្ត្រីដែលមានយ៉ាងហោចណាស់ការអប់រំថ្នាក់មធ្យមសិក្សាខ្លះ បានកើនឡើងពី ១៦ ដល់ ៣៥% ពីឆ្នាំ២០០៥ និង ២០១០ សម្រាប់បុរស បានកើនឡើងពី ៣១ ដល់ ៥១%។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់ឆ្នាំ២០០៩-២០១៣ ធានាផងដែរថា កុមារនិងយុវជនកម្ពុជាទាំងអស់ មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំកម្រិតមូលដ្ឋាន ទាំងក្នុងប្រព័ន្ធ ទាំងក្រៅប្រព័ន្ធ ដោយគ្មានការរើសអើង ដោយឈរលើមូលដ្ឋានជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទំនាក់ទំនងនយោបាយរបស់ឪពុកម្តាយ ទីកន្លែងកំណើត ឬ

ស្ថានភាពសង្គមឡើយ។ ប៉ុន្តែផែនការនេះមិនបានបញ្ជាក់ពីស្ថានភាព SOGI នោះឡើយ។[102]

ទូទាំងប្រទេស មានតែសិស្សម្នាក់ក្នុងចំណោម៥នាក់ បានបោះបង់ចោលការសិក្សាក្នុងអំឡុងឆ្នាំសិក្សា ២០១០-២០១១ នៅថ្នាក់បឋមសិក្សាបឋមភូមិ។[103] ភ័ស្តុតាងដែលនិយាយតៗគ្នាពី CCHR បង្ហាញថាអត្រានេះអាចខ្ពស់ជាងនេះនៅក្នុងចំណោមយុវជន LGBT។ មូលហេតុនៃបញ្ហារួមមានបញ្ហាផ្នែកសេដ្ឋកិច្ចដែលកើតឡើងតាំងពីគ្រួសារមិនទទួលស្គាល់ រហូតដល់ការប្រើភាសាមិនគប្បី និងការបន្លាចពីសំណាក់មិត្តរួមថ្នាក់ដោយសារតែបញ្ហាផ្លូវភេទរបស់ពួកគេ។[104] របាយការណ៍ផាត់ចេញពីសង្គម បានបង្ហាញពីកម្រិតនៃការអប់រំខ្ពស់ជាងមធ្យមសិក្សា ដោយក្នុងនោះ ២០ភាគរយនៃបុរសស្រឡាញ់ភេទដូចគ្នាបានចូលសកលវិទ្យាល័យ (ប្រៀបធៀបនឹង ២៣.២% នៃបុរសរស់នៅក្នុងទីក្រុងភ្នំពេញនៅក្នុងការអង្កេត CDHS ២០១០) និង ១៧ភាគរយនៃអ្នកឆ្លើយតបនឹងសម្ភាស៍ដែលជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា បានចូលសកលវិទ្យាល័យ (១១.៦%នៃស្ត្រីរស់នៅក្នុងទីក្រុងភ្នំពេញមានការសិក្សាលើសថ្នាក់មធ្យមសិក្សា)។ មានតែ ៦ភាគរយប៉ុណ្ណោះនៃស្ត្រីប្តូរភេទដែលមានការអប់រំលើមធ្យមសិក្សា។ សម្រាប់ស្ត្រីប្តូរភេទ សម្ពាធគ្រួសារដើម្បីបញ្ឈប់ការសិក្សាគឺជាមូលហេតុចម្បង។ ៣០គាគរយ បានរាយការណ៍ថា គ្រួសារ "ព្យាយាមបញ្ឈប់ (ពួកគេ) ពីការសិក្សា ឬការងារ" ខណៈដែល ៨ភាគរយនៃមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា បានរាយការណ៍ឲ្យដឹងអំពីបញ្ហាដូចគ្នានេះដែរ។[105]

អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិ បានរាយការណ៍ឲ្យដឹងថា គ្រួសារដាក់សម្ពាធមកលើកូនឲ្យធ្វើចរិតតាមភេទពីធម្មជាតិរបស់ពួកគេ និងបញ្ជាវិធីស្លៀកពាក់ និងតុបតែងខ្លួនពួកគេ។ នៅក្នុងបរិបទសាលារៀន សិស្ស LGBT ទទួលរងការបន្លាច និងការសើចចំអកពីសិស្សដទៃ។ បទបញ្ជាផ្ទៃក្នុងសាលារៀនសម្រាប់ឯកសណ្ឋាន មិនមានលក្ខណៈបត់បែននោះទេ៖ សិស្សប្រុសត្រូវស្លៀកខោខៀវ សិស្សស្រីសំពត់ខៀវ។ ប្រសិនបើស្លៀកពាក់ ឬប្រព្រឹត្តផ្ទុយពីនេះនៅក្នុងសាលារៀន គ្រូឲ្យពួកគេឈរ ហាមពួកគេមិនឲ្យអង្គុយ និងធ្វើឲ្យពួកគេខ្មាស់គេក្នុងថ្នាក់។ ជាលទ្ធផលបុគ្គល LGBT ជាច្រើនបានប្រាប់ថាពួកគេឈប់រៀន។ នេះគឺជាកត្តាមួយដែលអាចរារាំងដល់ការទទួលបានឱកាសការងារ និងជំនាញ។ ស្ត្រីប្តូរភេទជាច្រើន ងាកទៅរកមុខរបរផ្លូវភេទដើម្បីរស់រាន។ កង្វះខាតឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់បុគ្គល ក៏ត្រូវ បានគេលើកឡើងផងដែរ។

---

102 របាយការណ៍ CCHR, 2012, ទំព័រ ១៩

103 កម្មវិធីទប់ស្កាត់ការបោះបង់ចោលការសិក្សា - ការវិភាគទំនោរនៃការបោះចោលការសិក្សា: កម្ពុជា. USAID, សីហា ២០១១, ទំព័រ ៥១

104 របាយការណ៍ CCHR, ២០១២, ទំព័រ ១៩

105 Salas V. & Srun S, ទំព័រ ២១

អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិខ្លះ ដែលជាគ្រូ បាននិយាយថា ពួកគេក៏ជួបប្រទះបញ្ហា និងការរើសអើងផងដែរ នៅពេលចាប់ផ្តើមបង្រៀន ប៉ុន្តែការទទួលយកមានការកើនឡើង នៅពេលដែលពួកគេបង្ហាញពីសមត្ថភាពជំនាញជាគ្រូ និងជាអ្នកគ្រប់គ្រងសាលា។

គំនិតផ្តួចផ្តើមដើម្បីផ្សព្វផ្សាយអំពីបញ្ហា LGBT ចាប់ផ្តើមនៅក្នុងសកលវិទ្យាល័យមួយចំនួនតូចក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប ដូចជា សកលវិទ្យាល័យបញ្ញាសាស្ត្រ សកលវិទ្យាល័យភូមិន្ទភ្នំពេញ និង សកលវិទ្យាល័យបៀលប្រាយ។ អង្គការក្រៅរដ្ឋាភិបាលនានា ដូចជា RoCK និង CCHR ត្រូវបានអញ្ជើញជាបុគ្គលធនធាន និងបង្ហាញភាពយន្ត ចែករំលែកបទពិសោធន៍ រៀបចំសិក្ខាសាលា និងបង្កើតក្រុមពិភាក្សា LGBT។ និស្សិតក៏ត្រូវបានស្នើឲ្យសរសេរឯកសារមួយដែលឆ្លើយតបនឹងវគ្គនោះ។ អ្នកចូលរួមជាច្រើន បានឲ្យដឹងពីការផ្លាស់ប្តូរនៅក្នុងអាកប្បកិរិយារបស់ពួកគេ និងទទួលបានការយល់ដឹងកាន់តែច្រើនអំពីបញ្ហាប្រចាំថ្ងៃដែលបុគ្គល LGBT ជួបប្រទះ។[106] សាស្ត្រាចារ្យសកលវិទ្យាល័យខ្លះព្យាយាមដាក់បញ្ចូលវគ្គទាំងនេះជាមួយជំពូកសិក្សានៅថ្នាក់បរិញ្ញាបត្រអំពីយេនឌ័រ។ គំនិតផ្តួចផ្តើមមួយឈ្មោះថា CamASEAN ដែលបានចាប់ផ្តើមឡើងដោយក្រុមនិស្សិតស្ម័គ្រចិត្ត កំពុងតែវិភាគច្បាប់និងគោលនយោបាយរបស់កម្ពុជា និងផ្តល់ព័ត៌មានដល់បុគ្គល LGBT តាមរយៈខ្សែទូរស័ព្ទពិសេស និងបណ្តាញសង្គម ដូចជា ហ្វេសប៊ុក ជាដើម។

## *អនុសាសន៍*

សមាជិកនៃកិច្ចពិភាក្សាថ្នាក់ជាតិស្តីពី LGBT នៅកម្ពុជា ផ្តល់អនុសាសន៍ឲ្យសមាជិកសហគមន៍ LGBT ព្យាយាមបើកចំហបន្ថែមទៀតអំពីអត្តសញ្ញាណពិតប្រាកដរបស់ខ្លួន និងនិយាយអំពីអារម្មណ៍តាមធម្មជាតិផ្ទាល់ខ្លួនអំពីការស្រឡាញ់ភេទដូចគ្នា។ សកម្មភាពទាំងនេះគួរធ្វើឡើងនៅពេលពួកគេមានទំនុកចិត្ត និងគិតថា វាមានសុវត្ថិភាពក្នុងការធ្វើដូច្នោះ។

### *អនុសាសន៍សម្រាប់រដ្ឋាភិបាល សាលារៀន អង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល*

- ក្រសួងអប់រំ យុវជន និងកីឡា គួរដាក់បញ្ចូលសិទ្ធិមនុស្ស និងបញ្ហា SOGI ទៅក្នុងកម្មវិធីសិក្សា។ សិទ្ធិមនុស្ស និងបញ្ហា SOGI គួរដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយក្នុងពេលអនាគត។ ក្រសួងអប់រំ យុវជន និងកីឡា គួរចាត់វិធានការលុបបំបាត់ការរើសអើងនៅក្នុងថ្នាក់រៀន និងដាក់ទណ្ឌកម្មអ្នកដែលរើសអើងប្រឆាំងបុគ្គល LGBT ឬចូលរួមនៅក្នុងការបន្លាចស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា។
- ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើការជាមួយអង្គការ UNESCO និង អង្គការសង្គមស៊ីវិល ដើម្បីបង្កើតយុទ្ធនាការប្រឆាំងការបន្លាចដែលទាក់ទងនឹង SOGI ជា

[106] របាយការណ៍ CCHR (2012). ទំព័រ ២០

ពិសេស នៅថ្នាក់មធ្យមសិក្សា។[107] អង្គការ UNESCO មានឯកសារមួយដែលផ្តល់ការឆ្លើយតបទៅនឹងការបន្លាចដោយស្អប់មនុស្សស្រឡាញ់ភេទដូចគ្នានៅក្នុងសាលារៀន និងបង្ហាញពីគំរូនៃការអនុវត្តល្អនៅក្នុងប្រទេសដទៃទៀតដើម្បីកាត់បន្ថយការបន្លាច។[108]

- ក្រសួងអប់រំ យុវជន និងកីឡា គួរផ្តល់អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់សិស្ស LGBT ។
- សាលារៀន និងសកលវិទ្យាល័យ គួរមានភាពទន់ភ្លន់បន្ថែមទៀតនៅក្នុងការអនុវត្តគោលនយោបាយ "ឯកសណ្ឋានសាលា" និងគួរអនុញ្ញាតឲ្យសិស្សពាក់សំលៀកបំពាក់ដែលពួកគេចង់ស្លៀក នៅពេលចូលរៀន។
- កម្មវិធីសិក្សា គួរដាក់បញ្ចូលការអប់រំអំពីសិទ្ធិមនុស្សនិងការយល់ដឹងអំពីស្ថានភាព និងបញ្ហាប្រឈមរបស់បុគ្គល LGBT ព្រមទាំងពិចារណាអំពីជីវិតរបស់បុគ្គល LGBT ។
- រដ្ឋាភិបាល និងសង្គមស៊ីវិល គួរធ្វើការអង្កេតមួយដើម្បីកំណត់ពីវិសាលភាពនៃការបោះបង់ចោលការសិក្សារបស់យុវជន LGBT ។
- សាលារៀនរដ្ឋ និងឯកជន មិនគួររើសអើងនៅក្នុងការជួលបុគ្គល LGBT ជាគ្រូបង្រៀន ហើយនៅពេលណាសមស្រប គួរប្រើពួកគេជាជនគំរូសម្រាប់សិស្ស។
- អង្គការសហប្រជាជាតិ គួរលើកទឹកចិត្តឲ្យក្រសួងអប់រំ យុវជន និងកីឡា ដាក់បញ្ចូលសិទ្ធិមនុស្ស និងបញ្ហា SOGI ទៅក្នុងប្រព័ន្ធអប់រំរបស់កម្ពុជា ដើម្បីទប់ស្កាត់ការរើសអើងដែលទាក់ទងនឹង SOGI។ បន្ថែមពីលើនេះ ក្រសួងអប់រំ យុវជន និងកីឡា គួរអភិវឌ្ឍធនធានសម្រាប់គ្រូប្រើនៅក្នុងថ្នាក់រៀន ទាក់ទងនឹងបញ្ហា SOGI ។

---

[107] CCHR 2012, ទំព័រ២១

[108] អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ។ (UNESCO)(2012). ការអនុវត្តល្អនៅក្នុងការអប់រំអំពីមេរោគអេដស៍ និងសុខភាព, សៀវភៅទី ៨ ។ "ការឆ្លើយតបរបស់វិស័យអប់រំទៅនឹងការបន្លាចដោយការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា", ទំព័រ ៦០

### ករណីសិក្សាទី២៖ ការបញ្ចុះបញ្ចូលសម្រាប់ការផ្លាស់ប្តូរនៅក្នុងបទបញ្ជាផ្ទៃក្នុងស្តីពីឯកសណ្ឋានដើម្បីអនុញ្ញាតឲ្យសិស្សចូលរៀនដោយប្រើសំលៀកបំពាក់ដែលពួកគេចូលចិត្ត

វ៉ាន់ ដែលជាអ្នកចូលរួមម្នាក់នៅក្នុងកិច្ចសន្ទនាគឺជាគ្រូបង្រៀននិងជាអ្នកគ្រប់គ្រងសាលាម្នាក់អស់រយៈពេលជាង២០ឆ្នាំមកហើយ។ គាត់បានធ្វើការជាមួយមន្ទីរអប់រំខេត្តកំពង់ឆ្នាំង។ ក្នុងនាមជាគ្រូបង្វឹក "ក្រុមកីឡាបាល់ទាត់នារី" កីឡាករខ្លះរបស់គាត់គឺជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងចូលចិត្តទៅរៀនដោយស្លៀកខោវែង និងខោខ្លីដូចក្មេងប្រុសដែរ។ គ្រូខ្លះនៅក្នុងសាលារដ្ឋ មិនអនុញ្ញាតឲ្យពួកគេចូលថ្នាក់រៀនទេ ដោយនិយាយថាពួកគេស្លៀកពាក់មិនបានត្រឹមត្រូវ។ វ៉ាន់ បានជួបជាមួយនាយកសាលានោះ ដោយបានពន្យល់អំពីបញ្ហានេះ។ គាត់បានសរសេរលិខិតមួយទៅនាយកសាលានោះដើម្បីសុំការអនុញ្ញាតឲ្យសិស្សស្លៀកពាក់តាមអ្វីដែលពួកគេគិតថាសមស្រប។ ហេតុផលចម្បងរបស់គាត់គឺថា "ប្រសិនបើយើងមិនអនុញ្ញាតឲ្យសិស្សទាំងនេះចូលសាលា យើងនឹងមិនអាចបំពេញគោលដៅរបស់ប្រទេសសម្រាប់ការអប់រំបានទេ"។ នាយកសាលា និងគ្រូនៅទីនោះ ក៏បានលើកលែង។ ចាប់ពីថ្ងៃនោះមក កីឡាករអាចទៅរៀនក្នុងសំលៀកបំពាក់ដែលពួកគេគិតថាសមស្របសម្រាប់គេ។

នៅក្នុងសកលវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ និស្សិតត្រូវបានតម្រូវឲ្យគោរពតាមបទបញ្ជាស្តីពីការស្លៀកពាក់ដ៏តឹងរឹងមួយ។និស្សិតប្រុសត្រូវតែស្លៀកខោខៀវចាស់ ហើយនិស្សិតស្រីត្រូវតែស្លៀកសំពត់ត្រឹមកជើងពណ៌ខៀវ។ ភីភី (ឈ្មោះក្រៅ) តែងតែស្លៀកខោ ហើយធ្លាប់តែយកសំពត់របស់នាងដាក់ក្នុងថង់មួយនិងប្តូរវាមុនពេលចូលថ្នាក់រៀន។បន្ទាប់ពីការចូលរួមវគ្គផ្សព្វផ្សាយជាមួយក្រុមសិទ្ធិមនុស្ស LGBT និងធ្វើការជាអ្នកប្រមូលទិន្នន័យឲ្យគម្រោងស្រាវជ្រាវអំពី LGBT មួយមក ភីភីបានសម្រេចចិត្តធ្វើជាអ្នកក្លាហានបន្តិច ហើយមករៀនដោយស្លៀកខោ។ ដូចការរំពឹងទុក គ្រូរបស់នាងបានហៅនាងមកជួប ហើយសួរហេតុអ្វីបានជានាងមិនស្លៀកឯកសណ្ឋាន។ គាត់ក៏បានសួរបន្ថែម "តើនេះគឺជាអ្វីដែលអ្នកពិតជាចង់ពាក់ក្នុងថ្នាក់រៀនមែនទេ?"ភីភីបានពន្យល់ពីមូលហេតុរបស់នាងប្រកបដោយភាពអត់ធ្មត់។ គ្រូរបស់នាងក៏បានអនុញ្ញាតឲ្យនាងស្លៀកពាក់តាមចិត្តនាងនៅក្នុងថ្នាក់ក្រោយមកទៀត។

ជាកំណត់សម្គាល់បន្ថែមមួយ អ្នកចូលរួមនៅឯសន្និសីទស្តីមួយពីច្បាប់ដែលទាក់ទងនឹង LGBT នៅកម្ពុជា ក្នុងពេលថ្មីៗនេះ បានបង្កើតសេចក្តីព្រាងសម្រាប់ប្រកាសមួយ (គោលនយោបាយសម្រាប់អនុវត្ត) ដើម្បីស្នើទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុញ្ញាតឲ្យមានភាពទន់ភ្លន់ថែមទៀតនៅក្នុងការប្រើឯកសណ្ឋានសាលា។

## ការងារ និងមុខរបរ

### *បញ្ហា និងក្តីកង្វល់*

បុគ្គល LGBT ទទួលរងនូវការរើសអើងនិងផ្នត់គំនិតអវិជ្ជមានពីអ្នកដទៃយ៉ាងច្បាស់នៅកន្លែងធ្វើការ ចាប់តាំពីការដាក់ពាក្យសុំ រហូតដល់ការសម្ភាសន៍ តាមរយៈការជួលឲ្យបម្រើការ និងការបំពេញការងាររបស់ពួកគេ។ អ្នកខ្លះបានរាយការណ៍ឲ្យដឹងបានធ្វើតេស្តសរសេរជាប់ និងត្រូវបានគេហៅឲ្យធ្វើសម្ភាសន៍ ប៉ុន្តែការសម្ភាសន៍ត្រូវបានលុបចោលបន្ទាប់ពីពួកគេបានបង្ហាញខ្លួន ឬពួកគេត្រូវបានគេប្រាប់ដោយត្រង់ៗថា ពួកគេមិនស័ក្តិសមនឹងការងារនោះទេ។ ជារឿយៗ បុគ្គល LGBT ត្រូវតែលាក់ទំនោរផ្លូវភេទនិងអត្តសញ្ញាណយេន

ឪរបស់ពួកគេនៅកន្លែងធ្វើការ។ បើទោះបីជាដូច្នោះក៏ដោយ ក៏ពួកគេនៅតែអាចទទួលរងនូវពាក្យសំដីយ៉ាងគ្រោតគ្រាតពីអតិថិជន និងសហការី ដូចជា *"ហេតុអ្វីបានជាកន្លែងនេះជួលមនុស្សខ្ទើយមកធ្វើការ?"* ឬពាក្យសំដីមើលស្រាលពីសហការី ថា ពួកគេមិនអាចធ្វើការដូចមនុស្ស "ធម្មតា" តាមទេ។

មានឱកាសតិចតួចសម្រាប់បុគ្គលLGBT ខ្លះ ដែលមានកម្រិតវប្បធម៌និងជំនាញទាប។ មានកង្វះខាតឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈ។ជូនកាល ពួកគេវិលទៅលក់សេវាភេទដោយសារតែគ្មានជម្រើស និងខ្វះខាតការងារ។ ស្រ្តីប្តូរភេទអាចមានឱកាសការងារបន្តិចបន្តួចត្រឹមតែជាអ្នកតុបតែងមុខ និងអ៊ុតសក់។ មានអ្នកសិល្បៈជាមនុស្សប្តូរភេទមួយចំនួនតូចនៅក្នុងឧស្សាហកម្មកម្សាន្តក្នុងស្រុក។[109] ក្នុងនាមជាអ្នកសិល្បៈកម្សាន្ត ពួកគេត្រូវបានគេប្រគល់តួនាទីជាអ្នកកំប្លែងដដែលៗដែលជាញឹកញាប់ពួកគេតែងតែជាប្រធានបទនៃការកំប្លែងដែលមានលក្ខណៈបន្ទាបបន្ថោក។ ជាទូទៅ អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិ បាននិយាយថាពួកគេមិនអាចសំដែងឫកពារពិតប្រាកដរបស់ពួកគេបានទេនៅកន្លែងធ្វើការ។ ពួកគេអាចទទួលរងការរើសអើង និងការរុកគួន និងក្លាយជាវត្ថុលេងសើច និងកំប្លែងអវិជ្ជមានពីសំណាក់សហការីដទៃទៀត។

មានសកម្មភាពតិចតួចបំផុតដែលគេបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីបញ្ហា SOGI ជាមួយនិយោជក - រួមទាំងស្ថាប័នរដ្ឋនានា ដូចជា យោធា នគរបាល នីតិបញ្ញត្តិ និងតុលាការ ឬសមាគមនិយោជក និងសហជីព។ កង្វះខាតសកម្មភាពបែបនេះ បើយោងតាមរបាយការណ៍ឆ្នាំ២០១២របស់CCHR គឺដោយសារតែបញ្ហាការងារជាអាទិភាពដទៃទៀត ដូចជាការតស៊ូមតិសម្រាប់ ការរស់នៅ ប្រាក់ឈ្នួលសមរម្យឬអប្បបរមា។ កំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងនៅក្នុងប្រទេសត្រូវបានគេគិតថា ជាមធ្យោបាយមួយសម្រាប់ពង្រីកឱកាសការងារ។ ក្រុមហ៊ុនអន្តរជាតិច្រើនតែផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅការទទួលខុសត្រូវក្នុងសង្គមរបស់សាជីវកម្ម សិទ្ធិការងារ និងសិទ្ធិមនុស្សទូទៅ រួមទាំងការផ្តោតគោលដៅលើការរើសអើងដែលទាក់ទងនឹង SOGI នៅកន្លែងធ្វើការ។[110]

ការអនុវត្តច្បាប់ ដូចជា ច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានផលប៉ះពាល់អវិជ្ជមានដោយមិនសមាមាត្រមកលើបុគ្គលLGBT ជាពិសេស អ្នករកស៊ីផ្លូវភេទដែលជាមនុស្សប្តូរភេទ។ ច្បាប់នេះធ្វើឲ្យការចាប់ខ្លួនកើតឡើង ធ្វើឲ្យប្រាក់ចំណូលថយចុះ និងកាត់បន្ថយការទទួលបានសេវាសុខភាពនិងសង្គមផងដែរ។ ការស្រាវជ្រាវឆ្នាំ២០០៩ទៅលើច្បាប់នេះ បានបង្ហាញថា ខណៈដែលចំនួននៃការចាប់ខ្លួននារីបម្រើសេវាកម្សាន្ត

[109]Sreynang C. and MacIsaac, V, "តារាប្តូរភេទទីមួយនៅកម្ពុជាជ្រើសរើសមុខមាត់ធម្មជាតិ" ភ្នំពេញប៉ុស្ត៍ ៧ថ្ងៃ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១២,ទំព័រ ១២; Knox, C, "ស្រីនឹងក្លាយជាប្រុស ប្រុសនឹងក្លាយជាស្ត្រី: សិល្បៈនៃសំដែងដោយមនុស្សប្តូរភេទ" ភ្នំពេញប៉ុស្ត៍ ៧ថ្ងៃ, លេខ ១៧៣, ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១២, ទំព័រ ៨

[110] CCHR. (2012). "ពីបុរេនិច្ឆ័យទៅមោទនភាព, ទំព័រ ២២

បានធ្លាក់ចុះយ៉ាងខ្លាំងពីឆ្នាំ២០០៧ ដល់ ២០០៨ ការចាប់ខ្លួន MSM និងអ្នកធ្វើការក្នុងសេវាកម្សាន្តដែលជាមនុស្សប្តូរភេទ មានការកើនឡើងដល់ទៅ ៣ដង។ ៥៥ភាគរយនៃ MSM និងស្ត្រីប្តូរភេទ ត្រូវបានដោះលែង ដោយបង់ប្រាក់ ឬផ្តល់សម្ភារៈមានតម្លៃដល់នគរបាល បើប្រៀបធៀបនឹង ៣៩ភាគរយនៃនារីបម្រើសេវាកម្សាន្ត។[111] បច្ចុប្បន្ននេះ នៅក្នុងខេត្តសៀមរាប អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា ស្ត្រីប្តូរភេទមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងតំបន់ទេសចរណ៍សំខាន់ៗទេ (ផ្លូវលក់ចំណីអាហារនិងភេសជ្ជៈនៅក្នុងផ្សារចាស់) ដោយសារតែពួកគេត្រូវបានគេគិតថាជាចោរ។ មានការចាប់ខ្លួនដោយចៃដន្យផងដែរដែលធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន។[112]ផ្ទុយទៅវិញ នៅខេត្តសៀមរាប មានការសំដែងសិល្បៈខាបារ៉ែតមួយដែលបង្ហាញពីអ្នកក្លែងខ្លួនជាស្ត្រី ហើយភាគច្រើនគឺជាអ្នកប្តូរភេទជនជាតិកម្ពុជា។ ពួកគេអាចជាតារាងសំដែង ដោយនាំមកនូវប្រាក់ និងភ្ញៀវទេសចរដល់រដ្ឋាភិបាល ប៉ុន្តែផ្ទុយទៅវិញ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យដើរចូលក្នុងតំបន់ទេសចរណ៍នៃទីក្រុងនោះ។

សូម្បីតែនៅក្នុងវិស័យមេរោគអេដស៍ ដែលអង្គការក្រៅរដ្ឋាភិបាលត្រូវរំពឹងថានឹងធ្វើការជាមួយ MSM និង TG នោះ ក៏អាចនៅតែមានការរើសអើងដែរ។ ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ ២០១២ បណ្តាញជាតិនៃ MSM និងមនុស្សប្តូរភេទ មិនមានបុគ្គលិកដែលមានបៀវត្សរ៍ណាម្នាក់ដែលបានកំណត់អត្តសញ្ញាណខ្លួនឯងថាជា MSM ឬមនុស្សប្តូរភេទនោះឡើយ។[113] អង្គការក្រៅរដ្ឋាភិបាលនិងអង្គការនៅសហគមន៍មួយចំនួនតូច ដែលធ្វើការជាមួយ MSM និងមនុស្សប្តូរភេទ មានដោយចំហានូវបុគ្គលិកដែលជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នាឬមនុស្សប្តូរភេទនៅក្នុងមុខតំណែងគ្រប់គ្រងនិងត្រួតពិនិត្យ។ MSM និងមនុស្សប្តូរភេទភាគច្រើន ធ្វើការនៅកម្រិតទាបបំផុតនៃឋានានុក្រមរបស់អង្គការ ជាអ្នកស្ម័គ្រចិត្ត ឬអ្នកអប់រំមិត្តនិងអ្នកសម្របសម្រួល។ការប្រកាសជ្រើសរើសបុគ្គលិកដោយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើបញ្ហាទាំងនេះ អាចបញ្ជាក់ថា "MSM និងមនុស្សប្តូរភេទ ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យ"។ ប៉ុន្តែ ពុំមានវិធីតាមដានមើលការដាក់ពាក្យសុំរហូតដល់ដំណើរការជ្រើសរើស ឬថាតើការពិចារណាទាំងនេះត្រូវបានគេធ្វើតាមឬយ៉ាងណា។ មូលហេតុមួយដែលគេតែងផ្តល់ចំពោះការមិនជួល MSM និងមនុស្សប្តូរភេទ គឺថា "ពួកគេ (MSM និងមនុស្សប្តូរភេទ) នៅតែមានខ្វះខាតសមត្ថភាព"។

---

[111] សម្ព័ន្ធភាពកម្ពុជាដើម្បីប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ (CACHA) និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, (២០០៩) របាយការណ៍ស្រាវជ្រាវ, "បរិយាកាសគោលនយោបាយទាក់ទងនឹងការទទួលបានជាសកល និងសិទ្ធិទទួលបានការងាររបស់អ្នកបម្រើសេវាកម្សាន្តនៅក្នុងប្រទេសកម្ពុជា"។ ទំព័រ ៦៥–៦៧.

[112] ការប្រាស្រ័យទាក់ទងបុគ្គលពីបណ្តាញអ្នកស្ម័គ្រចិត្ត MSM និងមនុស្សប្តូរ ភេទ និងអ្នកអប់រំមិត្តមនុស្សប្តូរភេទនៃអង្គការក្រៅរដ្ឋាភិបាល

[113] Salas V. (2012) របាយការណ៍ស្តីពីការវាយតម្លៃបណ្តាញ MSM និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា (ធ្វើឡើងសម្រាប់បណ្តាញចតុមុខ និង UNAIDS Cambodia), ឯកសារផ្ទៃក្នុង

### ករណីសិក្សាទី ៣៖ គ្មានការងារសម្រាប់អ្នក

"នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ខ្ញុំបានដាក់ពាក្យធ្វើការជាគ្រូបង្រៀនភាសាថៃនិងអង់គ្លេស ជាគ្រូបង្រៀនឯកជននៅផ្ទះសិស្ស។ ខ្ញុំបានចាប់ផ្តើមបង្រៀននៅកម្រិត "អ្នកចាប់ផ្តើមដំបូង" ដោយមានប្រាក់ខែ ៨០ដុល្លារក្នុងមួយខែ បង្រៀនមួយថ្ងៃមួយម៉ោង ប្រាំថ្ងៃក្នុងមួយសប្តាហ៍។ ក្នុងអំឡុងពេលជ្រើសរើស អ្នកទទួលបន្ទុកមានលក្ខណៈបើកចំហនៅពេលគាត់និយាយជាមួយខ្ញុំ ហើយសុំទោសជាមុន ដោយនិយាយថា សិស្សមានសិទ្ធិបដិសេធគ្រូ ប្រសិនបើពួកគេមិនចូលចិត្តចរិតស្រីរបស់ខ្ញុំ។ ខ្ញុំបានបង្រៀនពីរបីដងដែរ ប៉ុន្តែមួយសប្តាហ៍ក្រោយមក អ្នកជ្រើសរើសខ្ញុំ បានប្រាប់ខ្ញុំថា៖ "ខ្ញុំសុំទោស វិទ្យាស្ថានរបស់យើងខ្វះគ្រូ ហើយយើងត្រូវការមនុស្សដែលមានជំនាញដូចអ្នក ប៉ុន្តែនៅផ្ទះសិស្សនោះ គាត់និយាយថាគាត់មិនចង់បានបុរសដែលធ្វើដូចស្រីជាគ្រូរបស់គាត់ទេ"។ អ្នកជ្រើសរើសបានទូរស័ព្ទហៅខ្ញុំ ដើម្បីសុំទោស ហើយនិយាយថា ពួកគេនឹងប្រាប់ខ្ញុំប្រសិនបើមានថ្នាក់ផ្សេងទៀតដែលត្រូវការគ្រូ ប៉ុន្តែពួកគេមិនដែលហៅខ្ញុំម្តងទៀតឡើយ។ បន្ទាប់ពីបទពិសោធន៍នេះមក ខ្ញុំបានដាក់ប្រវត្តិរូបរបស់ខ្ញុំទៅកន្លែងផ្សេងៗទៀតជាច្រើន ប៉ុន្តែមានតែពីរកន្លែងទេដែលហៅខ្ញុំ។ កន្លែងមួយបានបដិសេធមិនទទួលខ្ញុំភ្លាមៗ បន្ទាប់ពីសម្ភាសន៍តាមទូរស័ព្ទ ហើយកន្លែងមួយទៀតបានជ្រើសរើសខ្ញុំជាគ្រូបង្រៀនអង់គ្លេសសម្រាប់ថ្នាក់ដំបូងនៅសាលាភាសាជិនហ្វាអន្តរជាតិ ប៉ុន្តែខ្ញុំបានបង្រៀនទីនោះបានតែមួយសប្តាហ៍ ដោយសារមានសិស្សតែពីរបីនាក់។ អ្នកទទួលភ្ញៀវប្រាប់ខ្ញុំថា "លោកគ្រូ យើងមានសិស្សតែបីនាក់ក្នុងថ្នាក់ ដូច្នេះយើងសូមផ្ទេរសិស្សទាំងនេះទៅថ្នាក់មួយទៀត ហើយយើងនឹងព្យាយាមរកថ្នាក់របស់លោកគ្រូពេលក្រោយ"។ ខ្ញុំមានការខកចិត្ត ហើយនៅតែសង្ឃឹមនឹងពួកគេនឹងហៅខ្ញុំ ប៉ុន្តែរហូតមកដល់ពេលនេះ ពួកគេមិនបានហៅទេ។

សេនេលីន បូរដឹម (ឈ្មោះសិប្បនិម្មិត)

### *មុខរបរ និងការងារ*

សម្រាប់សហគមន៍ LGBT កម្ពុជា អ្នកចូលរួមក្នុងកិច្ចពិភាក្សាជាតិ បានផ្តល់អនុសាសន៍ថា គេគួរខិតខំអភិវឌ្ឍសមត្ថភាពបុគ្គលនិងសហគមន៍ - ជាលក្ខណៈបុគ្គលម្នាក់ៗ ឬរួមគ្នា - តាមរយៈការសិក្សាជាកូនជាង និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ ការបណ្តុះបណ្តាលគួររួមបញ្ចូលជំនាញវិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ សិទ្ធិមនុស្ស និងទំនាក់ទំនង។

អនុសាសន៍សម្រាប់រដ្ឋាភិបាល ក្រសួង អង្គការនៅសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល៖

- រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល គួរបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ថែមទៀត ដែលបើកចំហសម្រាប់ទាំងអស់គ្នា រួមទាំងបុគ្គល LGBT និងផ្តល់ជំនួយដល់បុគ្គល LGBT ដើម្បីស្វែងរកការងារ។
- ក្រសួងពាក់ព័ន្ធ និងស្ថាប័នច្បាប់ ដូចជាក្រសួងការងារ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋសភាជាតិ និងព្រឹទ្ធសភា គួរបង្កើតគោលនយោបាយប្រឆាំងការរើសអើងនៅកន្លែងធ្វើការ និងកែទម្រង់ច្បាប់ការងារ ដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិការងារពីការរើសអើងដែលទាក់ទងនឹង SOGI។

- ក្រសួងការងារគួរពន្យល់អំពីសិទ្ធិរបស់ LGBT នៅកន្លែងធ្វើការ អប់រំអ្នកគ្រប់គ្រង និងបុគ្គលិកថ្នាក់ខ្ពស់ នៅតាមអង្គការក្រៅរដ្ឋាភិបាល គ្រឹះស្ថានសាធារណៈ និងឯកជន។ល។ ដើម្បីឲ្យដល់ពីសិទ្ធិស្មើគ្នាចំពោះការងារ និងបញ្ហា SOGI បញ្ឈប់ការរើសអើងនៅកន្លែងធ្វើការ និងបង្កើតគោលនយោបាយប្រឆាំងការរើសអើង ដែលមានលក្ខណៈស្រដៀងគ្នានឹងគោលនយោបាយដែលបានបង្កើតឡើងក្រោមច្បាប់ជំងឺអេដស៍ ដូច្នោះដែរ។
- អង្គការនៅសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើបញ្ហា LGBT គួរផ្តល់អាទិភាពដល់ការជ្រើសរើសបុគ្គល LGBT ជាបុគ្គលិក។
- អង្គការនៅសហគមន៍គួរអំពាវនាវដល់និយាយជក ឲ្យគោរពសិទ្ធិរបស់ក្រុមភាគចិត្តផ្នែកផ្លូវភេទ ដោយប្រកាន់ខ្ជាប់ទៅនឹងច្បាប់ការងារ និងច្បាប់ពាក់ព័ន្ធដទៃទៀត ដែលការពារ និងលើកកម្ពស់សិទ្ធិរបស់បុគ្គល LGBT ចំពោះការងារ បង្កើតគោលការណ៍ SOGI នៅក្នុងសកម្មភាពកាន់តែទូលំទូលាយ និងសមាគមនិយាយជកនិងនិយោជិត ដោយរួមបញ្ចូលទាំងសកម្មភាពអាជីវកម្ម និងអំពាវនាវដល់សហជីពទាំងអស់ ឲ្យការពារសិទ្ធិរបស់កម្មករដែលជា LGBT ។

## សហគមន៍ និងសង្គម

### *បញ្ហា និងក្តីកង្វល់*

បុគ្គលLGBT ជាពិសេស យុវជន គឺងាយរងគ្រោះចំពោះការវាយប្រហារដោយសារការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា និងការរំលោភបំពាននៅក្នុងសហគមន៍ដែលពួកគេរស់នៅក្នុងនោះ ជារឿយៗពីសំណាក់គ្រួសារ សាច់ញាតិ និងអ្នកជិតខាង។ កង្វះខាតការយល់ដឹងពីគ្រួសារនិងសហគមន៍ ត្រូវបានរៀបរាប់ពីខាងលើរួចមកហើយ។ សម្ពាធវប្បធម៌ សង្គម និងសេដ្ឋកិច្ច និងការរំពឹងទុក មានឥទ្ធិពលទៅលើបទដ្ឋានសហគមន៍។ កូនប្រុស និងកូនស្រី ត្រូវបានគេបង្ខំឲ្យរៀបការ និងមានកូន។[114] របាយការណ៍ឆ្នាំ២០១២របស់ CCHR កត់សម្គាល់ថា "ឧក្រិដ្ឋកម្មដោយការស្អប់" ដែលជំរុញដោយសារតែជនរងគ្រោះជា SOGI គឺកើតឡើងជាទូទៅ។ ភាគច្រើននៃករណីទាំងនេះអាចមិនមានការរាយការណ៍ដល់អាជ្ញាធរ។ ជនរងគ្រោះដឹងថា ពាក្យបណ្តឹងរបស់ពួកគេនឹងមិនត្រូវបានគេយកចិត្តទុកដាក់ ហើយនគរបាលអាចត្រូវបានគេសូកប៉ាន់ដោយងាយ។

ពុំមានព័ត៌មានបែបបរិមាណអំពីបទឧក្រិដ្ឋប្រភេទទាំងនេះនោះទេ។ មានរបាយការណ៍អំពីជនទំនើង និងនគរបាល វាយប្រហារលើបុគ្គលLGBT ដែលជួបជុំគ្នានៅតាមសួនឧទ្យាន ក៏

---

[114]CCHR. (2010) "ចេញជាជំហានៅក្នុងព្រះរាជាណាចក្រ៖ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា ប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ : CCHR, ទំព័រ ១៤-១៥.

ដូចជារបាយការណ៍អំពីការរួមភេទដោយបង្ខំ។[115] នៅក្នុងទីកន្លែងសាធារណៈ (សួនឧទ្យាន ទីផ្សារ ក្លឹប និងកន្លែងកម្សាន្ត) បុគ្គលLGBT បានរាយការណ៍អំពីការរើសអើងនិងការបដិសេធមិនទទួលស្គាល់។ សកម្មភាពទាំងនេះត្រូវបានស្តែងចេញជាការមើលងាយ ការប្រើភាសាមិនគប្បី មិនផ្តល់សេវាជូន និងធ្វើព្រងើយកន្តើយ មិនអនុញ្ញាតឲ្យចូលគ្រឹះស្ថាន ឬការសំឡឹងមើល ដោយការមើលងាយមើលថោកដោយអ្នកដទៃ។ ក្នុងចំណោមអ្នកឆ្លើយតបនឹងសម្ភាស៍ដែលជា LGBT ចំនួន ១៥៩នាក់ នៅក្នុងរបាយការណ៍ស្តីពីការផាត់ចេញពីសង្គម ៥៦ភាគរយបានរាយការណ៍ថាបានជួបប្រទះឧប្បត្តិហេតុបែបនេះ[116] បុគ្គល LGBT បានរាយការណ៍ថា ពួកគេត្រូវបានគេទម្លាក់កំហុសដាក់ និងបន្ទោសថាជាអ្នកដែលធ្វើឲ្យមានសកម្មភាពឧក្រដ្ឋកាន់តែច្រើន និងជាប្រភពនៃលុយដែលងាយស្រួលសម្រាប់មន្ត្រីនិងអាជ្ញាធរមូលដ្ឋានដែលពុករលួយ ផងដែរ។

នៅក្នុងអំឡុងពេលកិច្ចពិភាក្សាថ្នាក់ជាតិក្នុងរាជធានីភ្នំពេញ អ្នកចូលរួមត្រូវបានស្នើឲ្យបង្ហាញឬបង្កើតសារមួយដែលពួកគេចង់ចែងរំលែកជាមួយអ្នកដទៃទៀត។ សារទាំងនោះរួមមានការអំពាវនាវឲ្យបញ្ឈប់ការរើសអើង ស្វែងយល់ឲ្យកាន់តែច្បាស់ ផ្តល់សិទ្ធិស្មើភាពដូចអ្នកដទៃដែរ និងអនុញ្ញាតឲ្យរៀបការ ក៏ដូចជា ការសំដែងនូវបំណងឲ្យគេស្រឡាញ់ និងស្រឡាញ់គេ និងសង្ឃឹមទទួលបានអនាគតកាន់តែភ្លឺថ្លា។ សារខ្លះបានសំដែងពីក្តីសង្ឃឹមថានឹងមានការរើសអើងតិចជាងមុននៅក្នុងចំណោមបុគ្គលLGBTខ្លួនឯង និងសាមគ្គីជាមួយសមាជិកដទៃទៀតនៃសហគមន៍ LGBT ។

នៅក្នុងបរិបទនេះ និយមន័យនៃ "សហគមន៍" ពីរបាយការណ៍របស់គណៈកម្មការអេដស៍ក្នុងអាស៊ី មានសារៈប្រយោជន៍ដែលត្រូវចងចាំទុកក្នុងចិត្តៈ

នៅក្នុងប្រទេសកម្ពុជា គេច្រើនតែសំដៅលើទីកន្លែងជារូបវ័ន្ត ពោលគឺ តំបន់ជិតខាង ឬភូមិ នៅពេលនិយាយអំពីទស្សនទាននៃសហគមន៍។ ទោះបីជាយ៉ាងណាក្តី សម្រាប់បុគ្គល LGBT ជាច្រើន (ដែលបានចាកចេញពីផ្ទះ ដោយបង្ខំ ឬតាមការយល់ព្រមដោយខ្លួនឯង) សហគមន៍គឺជាលើសពីទីកន្លែងមួយទៅទៀត។វាមានន័យថាជាការស្ថិតនៅជាមួយមនុស្សដទៃទៀតដូចខ្លួនពួកគេដែរ ដែលមានបំណងប្រាថ្នា និងចំណូលចិត្តដូចគ្នា រួមទាំងចំណូលចិត្តដល់បានសេចក្តីស្រឡាញ់ ភាពស្និទ្ធស្នាល ការថ្នាក់ថ្នម និងសាមគ្គីភាពជាមួយអ្នកដទៃទៀត ដែលអាចជាមនុស្សភេទឬយេនឌ័រដូចគ្នានឹងខ្លួនពួកគេដែរ។ នៅក្នុងពិភពអនឡាញនេះអាចសំដៅលើ "សហគមន៍អ៊ីធើណិត" និងបណ្តាញសង្គមផ្សេងៗ ដែលមនុស្សនានាអាចជាធ្វើសមាជិកក្នុងនោះ។

---

[115] របាយការណ៍ CCHR, (ឆ្នាំ២០១២). "ពីបុរេនិច្ឆ័យទៅមោទនភាព", ទំព័រ១៥

[116] Salas V & Srun S., Ibid. ទំព័រ ១៧ -១៨

### អត្ថន័យនៃ "សហគមន៍"

ដូចជាកោសិកាសង្គមជាច្រើនដែរ ពាក្យថា "សហគមន៍" មិនមានលក្ខណៈថេរតែមួយនោះទេ។ យ៉ាងតិចមាននិយមន័យពីរ នៅក្នុងបរិបទនៃការរីករាលដាលមេរោគអេដស៍។

### សហគមន៍ក្នុងន័យជាទីកន្លែងមួយ

សញ្ញាណនេះគឺជាការបកស្រាយកម្រិតមូលដ្ឋានបំផុតនៃសហគមន៍។ នៅក្នុងករណីនេះ សហគមន៍សំដៅលើក្រុមមនុស្សដែលផ្សារភ្ជាប់គ្នានៅក្នុងទីកន្លែងតែមួយ។ ទោះបីជាកាលៈទេសៈនិងតម្រូវការផ្ទាល់របស់ពួកគេអាចខុសគ្នា សមាជិកសហគមន៍មានចរិតលក្ខណៈខ្លះដូចគ្នា ដូចជាទំនៀមទម្លាប់ និងគុណតម្លៃដូចគ្នា ជាដើម។ ជាធម្មតា ពួកគេមានភាសាតែមួយ ឬជំនឿសាសនាដូចគ្នា។ សមាជិកភាពគឺអាចផ្តល់និយមន័យដោយងាយស្រួល ដោយសារវាផ្អែកលើទីតាំងរូបវន្តជាក់ស្តែង។

### សហគមន៍ក្នុងនាមជាទម្រង់មួយនៃអត្តសញ្ញាណ និងសមាជិកភាព

នៅទីនេះ សញ្ញាណនៃសហគមន៍សំដៅលើមនុស្សមួយក្រុម ដែលផ្សារភ្ជាប់គ្នាតាមរយៈកាលៈទេសៈ និងបទពិសោធន៍រួមគ្នា - ដូចជាអ្នករស់នៅជាមួយមេរោគអេដស៍ ឬអ្នកដែលមានចរិយាសម្បត្តិពីធម្មជាតិដូចគ្នាខ្លះ។ ន័យរបស់សហគមន៍ត្រូវបានពង្រឹងដោយការយល់ដឹងពីបទពិសោធន៍រួម ជារឿយៗអត្ថន័យនេះកើតឡើងបន្តិចម្តងៗ ប៉ុន្តែអាចត្រូវបានជំរុញ និងគាំទ្រដោយកត្តាខាងក្រៅ។ សញ្ញាណនៃសហគមន៍នេះគឺផ្អែកលើវិញ្ញាណអត្តនោម័ត នៃអត្តសញ្ញាណ។ គេផ្តល់និយមន័យខ្លាំងទៅតាមការយល់អំពីអ្នកដែលមិនមែនជាកម្មសិទ្ធ ជាការយល់អំពីអ្នកដែលជាកម្មសិទ្ធិ។

*ដកស្រង់ចេញពី៖ គណៈកម្មការស្តីពីជំងឺអេដស៍ក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ឆ្នាំ២០០៨) កំណត់និយមន័យឡើងវិញនៃជំងឺអេដស៍នៅក្នុងតំបន់អាស៊ី៖ ការបង្កើតការឆ្លើយតបប្រកបដោយប្រសិទ្ធភាព, ទំព័រ១៥៣–១៥៤*

សហគមន៍ នៅក្នុងវិញ្ញាណទាំងពីរនៃពិភពលោក គឺជាប្រភពនៃការចិញ្ចឹមបីបាច់ និងកម្មសិទ្ធិ។ នៅក្នុងអំឡុងពេលកិច្ចពិភាក្សាថ្នាក់ជាតិស្តីពីសហគមន៍ LGBT ក្រុមពិភាក្សាមួយដែលភាគច្រើនមានសមាជិកជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងបុគ្គលប្តូរភេទពីស្រីធ្វើជាប្រុស ដែលបានរស់នៅក្នុងតំបន់ជនបទជាច្រើនឆ្នាំ បាននិយាយថា៖

*"ក្រុមរបស់យើងមិនបានកត់សម្គាល់ឃើញបញ្ហាអ្វីធំដុំទេ - យើងរីករាយគាំទ្រសហគមន៍កាកបាទក្រហម... យើងមានការគាំទ្រផ្នែកជម្រកស្នាក់នៅក្នុងភូមិ។ គ្រប់គ្នាហាក់ដូចជាគាំទ្រ។ បើសិនអ្នកចង់រៀបការ ពួកគេអាចជួយសម្រួល ចេញឲ្យអ្នកនូវប័ណ្ណក្រីក្រ និងសៀវភៅគ្រួសារ។ សាររបស់យើងគឺចង់បានសិទ្ធិជ្រើសរើសអ្នកដែលពួកគេចូលចិត្ត ឬស្រឡាញ់... នេះគឺជាអ្វីដែលយើងមានពីកំណើត ហើយនេះគឺជារឿងធម្មជាតិសម្រាប់យើង។"*

ការបង្ហាញខុសពីធម្មតាអំពីការទទួលយករបស់សហគមន៍នៅក្នុងភូមិមួយក្នុងខេត្តកំពង់ធំ អាចដោយសារតែគូស្រករបានរស់នៅជាមួយគ្នាក្នុងឃុំនោះអស់រយៈពេលជាយូរមកហើយ និងត្រូវបានគេទទួលស្គាល់ក្នុងសង្គមថាជាប្តីប្រពន្ធ តាមរយៈពិធីមង្គលការ។ ទោះបីជាយ៉ាងណាក្តី ដូចដែលបានកត់សម្គាល់ក្នុងអំឡុងកិច្ចពិភាក្សាថ្នាក់ជាតិ ក៏ដូចជានៅក្នុង

របាយការណ៍ដទៃទៀតដែរ [117] ,  នេះគឺមិនសុទ្ធតែកើតឡើងសម្រាប់ដៃគូភេទដូចគ្នាដែលអាចមិនត្រូវបានគេចាត់ទុកថាជា "គ្រួសារ" នោះឡើយ។ អ្នកដែលគ្មានផ្ទះសម្បែង រស់នៅក្នុងបន្ទប់មួយជាមួយឪពុកម្តាយ និងបងប្អូន ធ្វើដំណើរមកកាន់ទីក្រុងដើម្បីដើម្បីរកការងារធ្វើ និងរក្សាភាពអនាមិក។ មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងស្ត្រីប្តូរភេទជាច្រើនក្នុងចំណោមអ្នកទាំងនេះ ធ្លាក់ខ្លួនមករស់នៅក្នុងតំបន់ភាគតិចក្រីក្រក្នុងទីក្រុង ដែលនៅទីនោះ អ្នកជិតខាង - ពោលគឺ "សហគមន៍" - មានការភ័យខ្លាច និងមានអារម្មណ៍មិនស្រួលចំពោះវត្តមានរបស់ពួកគេ។ [118]

នៅក្នុងរបាយការណ៍ស្តីពីការផាត់ចេញពីសង្គម [119] , នៅពេលអ្នកឆ្លើយតបនឹងសម្ភាសន៍ដែលជា LGBT ត្រូវសួរអំពីអ្នកដែលពួកគេអាចពឹងផ្អែកដើម្បីគាំទ្រនៅពេលមានបញ្ហាធ្ងន់ធ្ងរ, ៦៥ភាគរយបាននិយាយថា "មិត្តភក្តិជិតស្និទ្ធ" បន្ទាប់មក មាន ឪពុកម្តាយ (៥៨ភាគរយ) បងប្អូនបង្កើត និងសាច់ញាតិដទៃទៀត។ អង្គការក្រៅរដ្ឋាភិបាលត្រូវបាន មាន ៣១ភាគរយ ហើយ ស្ថាប័នរដ្ឋាភិបាលមាន ១២ភាគរយ។

### *អនុសាសន៍សម្រាប់រដ្ឋាភិបាលកម្ពុជា៖ កំណែទម្រង់ច្បាប់និងគោលនយោបាយ*

- រដ្ឋាភិបាលគួរតែបង្កើតច្បាប់ដើម្បីការពារបុគ្គល LGBT ពីការរើសអើង ឬអំពើហិង្សា ទាំងផ្លូវកាយ ទាំងផ្លូវអារម្មណ៍ យកចិត្តទុកដាក់ដល់មនុស្សគ្រប់រូបស្មើគ្នាចំពោះមុខច្បាប់ និងដាក់ឲ្យអនុវត្តច្បាប់ប្រឆាំងឧក្រិដ្ឋកម្មដោយស្អប់ ។
- រដ្ឋាភិបាលគួរតែធ្វើការពិនិត្យឡើងវិញជាលក្ខណៈប្រព័ន្ធ លើគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងវិធីដែលគោលនយោបាយនេះត្រូវបានគេប្រើប្រាស់កន្លងមកដើម្បីរុកគួនបុគ្គល LGBT ដោយសំអាងលើហេតុផលបង្ក្រាបបទឧក្រិដ្ឋ។ គោលនយោបាយនេះមិនគួរស្ថិតនៅជាច្បាប់ក្រៅផ្លូវការមួយនោះឡើយ ប៉ុន្តែត្រូវតែធ្វើការពិនិត្យឡើងវិញ ដើម្បីកុំឲ្យគេប្រើដើម្បីរំលោភសិទ្ធិរបស់LGBT - ហើយបន្ទាប់មកទៀត អនុម័តជាច្បាប់ពិតប្រាកដ ដោយមានការណែនាំដល់មន្ត្រីអនុម័តច្បាប់ និងសាធារណជន អំពីការប្រើច្បាប់នេះឲ្យបានត្រឹមត្រូវ។
- ក្រសួងផែនការ និងអាជ្ញាធរមូលដ្ឋាន គួរតែពិនិត្យមើលការចេញប័ណ្ណក្រីក្រ និងអត្តសញ្ញាណប័ណ្ណ ដោយសារវាទាក់ទៅនឹងបុគ្គល LGBT៖

---

[117] Salas & Srun, p.16. ការគាំទ្រស្រដៀងគ្នាពីមន្ត្រីមូលដ្ឋានក្នុងខេត្តតាកែវ ស្វាយរៀង និងព្រៃវែង ត្រូវបានចែករំលែកដោយសកម្មជន RoCK

[118] http://sunnarin.wordpress.com/2010/11/13/cambodias-first-gay-town/ ទីក្រុងមនុស្សប្រុសស្រលាញ់ភេទដូចគ្នាទីមួយនៅកម្ពុជា, ប្លូបលប៉ុស្ត៍, ទាញយក ថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៤

[119] Salas & Srun, ibid.

    - ក្រសួងផែនការគួរធានាថា បុគ្គល LGBT មិនត្រូវបានផាត់ចេញពីការទទួលបានប័ណ្ណក្រីក្រ ដោយសារតែការរើសអើង ឬការមិនទទួលស្គាល់ភាពជាដៃគូភេទដូចគ្នា។[120]
    - អាជ្ញាធរមូលដ្ឋាន គួរផ្តល់អត្តសញ្ញាណប័ណ្ណដោយមានភេទ (យេនឌ័រ) របស់បុគ្គលដែលបុគ្គលនោះចង់បាន មិនសុទ្ធតែយេនឌ័រ ដែលបានកំណត់ពីកំណើតនោះឡើយ។ គួរមានការស៊ើបអង្កេតបន្ថែមទៀតដើម្បីឲ្យដឹងថាតើនរណាមានសិទ្ធិចេញ និងផ្លាស់ប្តូរអត្តសញ្ញាណប័ណ្ណ។
- ក្រសួងសង្គមកិច្ចគួរអនុញ្ញាតឲ្យបុគ្គល LGBT សុំកូនចិញ្ចឹម។

*អនុសាសន៍សម្រាប់សហគមន៍ទូទៅ៖ ផ្សព្វផ្សាយជាសាធារណៈអំពីការមាក់ងាយនិងការរើសអើង និងការគាំទ្រសម្រាប់អង្គការនៅសហគមន៍*

- ភាគីពាក់ព័ន្ធទាំងអស់ គួរធ្វើការផ្សព្វផ្សាយដល់គ្រួសារ សាលារៀន មន្ទីរពេទ្យ និងទីកន្លែងសាធារណៈអំពីសិទ្ធិមនុស្ស ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ កម្មវិធីសម្ភាសន៍តាមទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព/ឌីជីថល) សិល្បៈ និងសកម្មភាពវប្បធម៌ ដើម្បីលុបបំបាត់ការរើសអើង។
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ គួរបណ្តុះបណ្តាលសកម្មជនអំពីសិទ្ធិរបស់ LGBT បញ្ហា SOGI និងអំពីការតស៊ូមតិនិងការគាំទ្រផ្នែកច្បាប់ ក៏ដូចជាផ្តល់សេវាច្បាប់និងដំបូន្មានដែលសមស្របចំពោះស្ថានភាពរបស់បុគ្គល LGBT ។
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការនៅសហគមន៍ គួរប្រើនិងផ្សព្វផ្សាយបន្ថែមទៀតនូវធនធានដែលមានស្រាប់អំពីការប្រឆាំងការមាក់ងាយដូចជាឯកសារជំនួយស្មារតីប្រឆាំងការមាក់ងាយជាភាសាខ្មែរសម្រាប់ MSM និងមនុស្សប្តូរភេទ ដោយអង្គការ PACT និងក្រុមប្រឹក្សាអន្តរជាតិស្តីពីការស្រាវជ្រាវសម្រាប់ស្ត្រី (ICFRW); គោលការណ៍យ៉កយ៉ាក៏តា; គម្រោង "ក្រមាឥន្ទធនូ"; កូនសៀវភៅព័ត៌មានស្តីពី "ការបើកជាចំហពីភេទរបស់ខ្លួន" និង "សំណួរដែលគេតែងសួរញឹកញាប់អំពីបុគ្គល LGBT" ផលិតដោយ RoCK និងឯកសារសង្ខេបអំពី SOGI និងសិទ្ធិមនុស្ស ដែលផលិតឡើងដោយ OHCHR។
- រដ្ឋាភិបាល និងសង្គម គួរគាំទ្រអង្គការនៅសហគមន៍ដែលផ្តោតជាក់លាក់លើ LGBT ក្រុមគាំទ្រក្រៅផ្លូវការនានា ដូចជាសមាគមមិត្តភក្តិ ឪពុកម្តាយ វត្តអារ៉ាមនិងព្រះសង្ឃ។ ក្រុមជួយខ្លួនឯង គួរត្រូវបានលើកទឹកចិត្តផងដែរ។

---

[120] Salas V & Srun S. (2013). "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទនៅក្នុងគ្រួសារនិងសហគមន៍ និងវិធីដោះស្រាយរបស់ពួកគេ"។ "របាយការណ៍ស្រាវជ្រាវ។ ផ្នែកសម្របសម្រួលការគាំពារសង្គម ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មជនបទ (SPCU-CARD) ភ្នំពេញ ទំព័រ ១៥–១៦

- យន្តការគាំទ្រសហគមន៍មូលដ្ឋាន - ឧទាហរណ៍សមាគមសន្សំប្រាក់ ជំនួយបុណ្យសព បុណ្យសហគមន៍ និងការប្រារព្ធពិធីអបអរសាទរបុណ្យជាតិនានា យន្តការសម្រេចចិត្តថ្នាក់ភូមិ - គួរដាក់បញ្ចូល និងទទួលយកបុគ្គល LGBT ឲ្យបានកាន់តែច្រើនថែមទៀត។

## សុខភាព រួមបញ្ចូលទាំងមេរោគអេដស៍

### *បញ្ហា និងក្ដីកង្វល់*

សូចនាករសុខភាពទូទៅ ដូចជាអាយុកាលជាមធ្យម និងអត្រាមរណភាពកុមារក្រោមមួយឆ្នាំ មានភាពប្រសើរនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅតែមានគម្លាតធំជាច្រើននៅឡើយនៅក្នុងគុណភាព ភាពគ្រប់ជ្រុងជ្រោយ និងការទទួលបានសេវាសុខភាព។ ការចំណាយលើសេវាថែទាំសុខភាពត្រូវបានគេចាត់ទុកថា ជាឧបសគ្គដ៏ធំសម្រាប់អ្នកក្រីក្របំផុត។ លទ្ធភាពចូលទៅរកសេវា រួមទាំងចម្ងាយនិងមធ្យោបាយដឹកជញ្ជូន ចំណេះដឹងអំពីគម្រោងជំនួយ ជំនឿង និងការប្រតិបត្តិសង្គម-វប្បធម៌ និងកង្វះខាតទំនុកចិត្តនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ ក៏កាត់បន្ថយផងដែរលទ្ធភាពទទួលបានសេវាផងដែរ។[121]

កម្ពុជាត្រូវបានគេលើកឡើងជាឧទាហរណ៍ចំពោះជោគជ័យរបស់ខ្លួននៅក្នុងការកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍នៅក្នុងចំណោមប្រជាជនទូទៅនិងនៅក្នុងការបង្កើនការទទួលបានការព្យាបាលដោយឱសថប្រឆាំងវីរុស (ART)។ វឌ្ឍនភាពជាច្រើនត្រូវបានធ្វើឡើងនៅក្នុងការកាត់បន្ថយប្រេវ៉ាឡង់មេរោគអេដស៍ពី៣ភាគរយក្នុងឆ្នាំ១៩៩៧ មកត្រឹម ១,៩ភាគរយក្នុងឆ្នាំ២០០៣ និង មកដល់ ០,៧ភាគរយក្នុងឆ្នាំ២០១០ (របាយការណ៍ UNGASS)។ កម្ពុជាក៏ត្រូវបានគេលើកឡើងជាវិជ្ជមានផងដែរ ចំពោះការផ្ដល់ការទទួលបានស្ទើរតែជាសកលនូវការព្យាបាលដោយឱសថប្រឆាំងវីរុស តាមរយៈកម្មវិធីមេរោគអេដស៍ដែលគាំទ្រដោយម្ចាស់ជំនួយ។

បច្ចុប្បន្ននេះ ការរីករាលដាលនៃមេរោគអេដស៍នៅកម្ពុជា ហាក់ដូចជាប្រមូលផ្ដុំក្នុងចំណោមក្រុមប្រឈមមុខបំផុត (MARPs)។ នៅក្នុងប្រទេសកម្ពុជា, ក្រុមប្រឈមមុខបំផុតគឺជា MSM និងមនុស្សប្ដូរភេទ អ្នកចាក់គ្រឿងញៀន និងអ្នកធ្វើការក្នុងសេវាកម្សាន្ត ដែលជានារីបម្រើការក្នុងហាងម៉ាស្សា នារីស្ទូរស្រាបៀរ និងខារ៉ាអូខេ ដែលអាចលក់សេវាភេទម្ដងម្កាលឬជាប្រចាំ។

ការសិក្សាតាមដានមេរោគអេដស៍និងការប្រព្រឹត្តិក្នុងចំណោម MSM និងមនុស្សប្ដូរភេទ មិនមានលក្ខណៈទៀងទាត់។ ការសិក្សាលើកទីមួយត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០០ ដែលមាន

[121] WHO និង MoH កម្ពុជា។ (២០១៣) ការផ្ដល់សេវាសុខភាព កម្ពុជា ២០១២. ទំព័រ ៥

វិសាលភាពមានកម្រិត (ចេញផ្សាយក្នុងចុងឆ្នាំ២០០២) បន្ទាប់មកក្នុងឆ្នាំ២០០៥ ហើយចុងក្រោយគឺក្នុងឆ្នាំ២០១០។ ការសិក្សាមិនទៀងទាត់បែបនេះ ទំនងជាអាចនឹងបាត់បង់ទំនោរដែលផ្លាស់ប្តូរនៅក្នុងការចម្លង។ នៅក្នុងការសិក្សាចុងក្រោយបំផុតពីឆ្នាំ២០១០ អត្រាមេរោគអេដស៍ក្នុងចំណោម MSM ក្នុងរាជធានីភ្នំពេញគឺ ៣,៤ភាគរយ ដែលជាកម្រិតមួយខ្ពស់ជាងបុរសដទៃទៀតដល់ទៅពីរដង និងជិតប្រាំដងនៃប្រជាពលរដ្ឋទូទៅ (0,៧%)។ ភាពខុសគ្នាគឺឃើញមានកាន់តែច្បាស់នៅក្នុងខេត្តសៀមរាប ដែលក្នុងនោះ ៤,៩ភាគរយនៃ MSM មានផ្ទុកមេរោគអេដស៍។ នៅក្នុង MSM អាយុ ៣៥-៤៤ឆ្នាំ អត្រាមេរោគអេដស៍មាន ១៤ភាគរយ ឬប្រមាណ ១នាក់ ក្នុងចំណោម ៧នាក់។ នៅក្នុងក្រុមវ័យក្មេងជាងនេះ អត្រាមេរោគអេដស៍គឺ 0,៨-១,៥ភាគរយ។ MSM សក់វែង ដែលបានកំណត់អត្តសញ្ញាណខ្លួនឯងមានអត្រាមេរោគអេដស៍ខ្ពស់ជាង MSM សក់ខ្លី (៣.៦% ធៀបនឹង ៣.១%)។ ជិត ៣៣ភាគរយនៃ MSM និងមនុស្សប្លូរភេទ នៅក្នុងការសិក្សានេះ បានរាយការណ៍ថាបានប្រើគ្រឿងញៀន ដែល ប្រសិនបើប្រើដោយចាក់ នឹងបង្កើតជាកត្តាប្រឈមបន្ថែមមួយទៀតសម្រាប់ការឆ្លងមេរោគអេដស៍។[122]

តម្រូវការបង្ការមេរោគអេដស៍របស់ក្រុមគោលដៅផ្សេងៗ ត្រូវតែដោះស្រាយឲ្យបានគ្រប់ជ្រុងជ្រោយ បន្ថែមពីលើការធ្វើតេស្តមេរោគអេដស៍ និងការប្រើស្រោមអនាម័យ។ ការមាននិងការទទួលបានសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ គឺនៅតែមានកង្វះខាតជាច្រើននៅឡើយ ក៏ដូចជានៅក្នុងសេវាទូទៅនិងសុខភាពបឋមដែរ។ គេចាំបាច់ត្រូវតែដឹងពីភាពខុសគ្នានៅក្នុងចំណោមអនុក្រុមនៃ MSM និងមនុស្សប្លូរភេទ ទាក់ទងទៅនឹងអាយុ ការអប់រំ ការប្រព្រឹត្តិផ្លូវភេទ និងក្រុមមិត្តភក្តិ។

## *ការបែងចែកភាពខុសគ្នារវាង MSM និងមនុស្សប្លូរ ភេទ នៅក្នុងកម្មវិធីមេរោគអេដស៍ និងសុខភាព*

កិច្ចខិតខំប្រឹងប្រែងប្រកបដោយមនសិកាមួយត្រូវបានធ្វើឡើងក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះ ដើម្បីទទួលស្គាល់ និងបែងចែកភាពខុសគ្នារវាង MSM និងមនុស្សប្លូរភេទនៅក្នុងកម្មវិធីបង្ការមេរោគអេដស៍។ បច្ចុប្បន្ននេះ MSM និងមនុស្សប្លូរភេទ ត្រូវបានគេទទួលស្គាល់នៅក្នុងវិស័យមេរោគអេដស៍ ថាជាក្រុមដោយឡែកដែលមានតម្រូវការនិងបញ្ហាដោយឡែក។ ផែនការយុទ្ធសាស្រ្តជាតិសម្រាប់ជំងឺអេដស៍ (២០១១-២០១៥) កំណត់ពីសូចនាករគោលដៅផ្សេងៗគ្នាសម្រាប់ MSM និងមនុស្សប្លូរភេទ។[123] នីតិវិធីប្រតិបត្តិស្តង់ដារត្រូវបានធ្វើបច្ចុប្បន្នកម្មនិងកែសម្រួល។[124] ទោះបីជាយ៉ាងណាក្តីកិច្ចខិតខំប្រឹងប្រែងទាំងនេះហាក់ដូចជាគ្រាន់តែជាការសន្យានិងសើរៗតែប៉ុណ្ណោះ ដោយក្នុងនោះពាក្យ "មនុស្សប្លូរភេទ" ត្រូវបានគេបន្ថែមទៅលើ MSM តាមក្រោយតែប៉ណ្ណោះ។ បញ្ហាសុខភាពដែលជាក់លាក់ទៅនឹងមនុស្សប្លូរភេទ - ដូចជាការប្រើអ័រម៉ូន ការដាំបញ្ចូលសរីរាង្គ និងការវះកាត់ - មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ មនុស្សប្លូរភេទត្រូវបានគេរាយការណ៍មកថាបានទទួលរកផលវិបាក

---

[122]Liu, Kai-Li និង Chorvann, C. (2010), "ការអង្កេតការប្រព្រឹត្តិប្រកបដោយការប្រឈមក្នុងចំណោមបុរសក្នុងទីក្រុងដែលប្រឈមមុខនៅក្នុងប្រទេសកម្ពុជា (ការសិក្សាអំពីប្រុសខ្មែរ)" FHI 360. pp. 46-48

[123] អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, (NAA). (២០១០). ផែនការយុទ្ធសាស្រ្តជាតិសម្រាប់ឆ្លើយតបគ្រប់ជ្រុងជ្រោយនិងពហុវិស័យចំពោះជំងឺអេដស៍សម្រាប់ឆ្នាំ២០១១-២០១៥. ទំព័រ ២៩

[124] ក្រសួងសុខាភិបាល និង NCHADS, មេសា ២០១៣។ "នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់យុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថៃទាំ និងព្យាបាល (CoCPT) សម្រាប់ក្រុមប្រឈមមុខខ្ពស់បំផុត (MARPs) នៅក្នុងប្រទេសកម្ពុជា". ទំព័រ ២–៣.

ឬស្លាប់ទៀតផងដែរ ពីការប្រើថ្នាំចាក់និងប្រេងលាបដែលគ្មានការត្រួតពិនិត្យនិងគ្មានព័ត៌មានគ្រប់គ្រាន់ ជាផ្នែកមួយនៃការផ្លាស់ប្តូរភេទ។[125]

នៅក្នុងសេចក្តីសង្ខេបគោលនយោបាយមួយស្តីពីការរើសអើងនឹងខ្លួនឯងក្នុងចំណោម MSM និងស្ត្រីប្តូរភេទវ័យក្មេង អ្នកចូលរួមមកពីកម្ពុជាម្នាក់នៅក្នុងការពិភាក្សាក្រុមគោលដៅមួយ បានកត់សម្គាល់ថា អន្តរាគមន៍ផ្តោតលើមេរោគអេដស៍មិនសុទ្ធតែពាក់ព័ន្ធ ឬសមស្របនោះឡើយ។ នាងបានបញ្ជាក់ថា៖ *"អ្នកចុះអប់រំនៅមូលដ្ឋានតែងតែនាំខ្ញុំទៅ VCT ដើម្បីពិនិត្យជំងឺកាមរោគ (STI) ប៉ុន្តែពួកគេមិនបានយល់អំពីបញ្ហាពិតរបស់យើងឡើយ - ជួនកាល ខ្ញុំឈឺមុខរបស់ខ្ញុំដោយសារតែការវះកាត់ដាក់ស៊ីលីកូន ខ្ញុំមានផលរំខានពីការចាក់អ័រម៉ូន... យើងពិតជាត្រូវការការប្រឹក្សា ប៉ុន្តែគ្មាននរណាអាចជួយយើងបានទេ។"*[126]

"ប័ណ្ណរបាយការណ៍ស្តីពីការបង្ការមេរោគអេដស៍ក្នុងចំណោម MSM និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា" (២០១២) មានអនុសាសន៍សម្រាប់កែសម្រួលច្បាប់និងគោលនយោបាយ ការបង្កើនលទ្ធភាពទទួលបាន និងការមានសេវា និងការបង្កើនការចូលរួមរបស់ MSM និងមនុស្សប្តូរភេទ។[127]

MSM និងមនុស្សប្តូរភេទ បានរាយការណ៍ឲ្យដឹងអំពីការមាក់ងាយនិងការរើសអើងពីបុគ្គលិកសុខាភិបាល និងបុគ្គលមូលដ្ឋានសុខាភិបាលដទៃទៀត។ នៅក្នុងរបាយការណ៍ស្តីពីការផាត់ចេញពីសង្គម [128]៧ភាគរយនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ (ប៉ុន្តែ ១៨%នៃស្ត្រីបំលែងភេទ) បានរាយការណ៍ឲ្យដឹងពីការរើសអើងតាមទម្រង់ផ្សេងៗនៅក្នុងមូលដ្ឋានសុខាភិបាល។ វាមិនច្បាស់ថាតើបញ្ហានេះកើតឡើងដោយសារតែពួកគេគ្មានសមត្ថភាពបង់ប្រាក់ ឬដោយសារតែការស្តែងចេញនូវភេទ របស់ពួកគេ។ លទ្ធភាពនៃការរើសអើងនឹងខ្លួនឯង និងការផាត់ចេញខ្លួនឯងពីសេវា មិនត្រូវបានគេសិក្សានៅឡើយទេ។ អ្នកផ្តល់សេវាសុខភាពខ្លះ យល់ថា ការរើសអើងកើតចេញពីខាងក្នុង។ ពួកគេនិយាយថា *"...អ្នកផ្តល់សេវាសុខភាពមិនរើសអើងទេ ប៉ុន្តែពួកគេ (MSM និងមនុស្សប្តូរភេទ) គេចចេញពីសេវាសុខភាពដោយខ្លួនឯង។"* [129] បុគ្គលដែលមិនមែនជាមនុស្សLGBT ដោយចំហ អាចមិនយល់ពីប្រភេទការផាត់ចេញដោយខ្លួនឯងប្រភេទនេះទេ។ ពួកគេអាចមិនបានដឹងថា អាកប្ប

---

[125] ប៊ុនថន គង់ និងបណ្តាញថ្នាក់ជាតិនៃ MSM និងមនុស្សប្តូរភេទ, ការប្រាស្រ័យទាក់ទងបុគ្គល ២០១៣។

[126]Youth Voices Count (YVC). (2013). "ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំមិនសមនឹងទទួលបានការសប្បាយចិត្តសោះឡើយ" ។ សេចក្តីសង្ខេបគោលនយោបាយ៖ ការរើសអើងនឹងខ្លួនឯងក្នុងចំណោម MSM និងស្ត្រីប្តូរភេទវ័យក្មេង និងទំនាក់ទំនងជាមួយមេរោគអេដស៍ក្នុងទ្វីបអាស៊ី)។

[127]IPPF, MSMGF, UNFPA & RHAC, (2011). ប័ណ្ណរបាយការណ៍អំពីការបង្ការមេរោគអេដស៍សម្រាប់ MSM និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា។ ឯកសារព័ត៌មាននេះណែនាំឲ្យមានសកម្មភាពកម្មវិធី គោលនយោបាយនិងថវិកា ដើម្បីលើកកម្ពស់ការបង្ការមេរោគអេដស៍សម្រាប់ MSM និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា។

[128] Salas, V & Srorn, S. ibid.

[129]Salas V & Srorn S. (2013). Ibid,ទំព័រ. ៩, ១៧-១៨; ការប្រាស្រ័យទាក់ទងបុគ្គលជាមួយ VS

កិរិយារើសអើង គឺត្រូវបានស្តែងចេញមិនត្រឹមតែជាពាក្យសំដីប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈឥរិយាបថជាកាយវិការនិងការសំដែងទឹកមុខផងដែរ។

រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ផ្តល់រោគវិនិច្ឆ័យជំងឺកាមរោគនិងមេរោគអេដស៍ និងការព្យាបាលជំងឺអេដស៍។ គ្លីនិកសុខភាពគ្រួសារបានចាប់ផ្តើមដាក់បញ្ចូលគ្នានូវសេវាជំងឺកាមរោគនិងមេរោគអេដស៍។អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលផ្តល់សេវាសុខភាពមាតា និងកុមារ និងគ្លីនិកផ្តល់សេវាផែនការគ្រួសារនិងសុខភាពផ្លូវភេទនិងបន្តពូជ គាំទ្រការផ្តល់សេវាសម្រាប់ MSM និងមនុស្សប្តូរភេទដោយឡែក ឬដាក់បញ្ចូលសេវាទាំងនេះទៅក្នុងសេវាគ្លីនិកដែលមានស្រាប់របស់ពួកគេ។ អង្គការរ៉ាក់ (RHAC) បានទាក់ទង MSM និងមនុស្សប្តូរភេទឲ្យចូលរួមក្នុងការវាយតម្លៃគុណភាពរបស់សេវាគ្លីនិក តាមរយៈការប្រើវិធីសាស្រ្តថ្មីៗដូចជា"អតិថិជនអាថ៌កំបាំង"។[130] អ្នកផ្តល់សេវាសុខភាពរបស់អង្គការក្រៅរដ្ឋាភិបាលខ្លះ ដូចជា គ្លីនិករបស់អង្គការម៉ារីស្តូប អន្តរជាតិ (MSI) ប្រើ សារ និងអ៊ីនធើណិត ដើម្បីផ្តល់ព័ត៌មានអំពីសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជដោយអនាមិក។ ពួកគេក៏លើកទឹកចិត្តឲ្យអតិថិជនធ្វើការតាមដានបន្តផងដែរ។

នៅក្នុងអំឡុងកិច្ចពិភាក្សាថ្នាក់ជាតិ បញ្ហាសុខភាពដែលបានកំណត់ដោយអ្នកចូលរួមដែលជាមនុស្សLGBT រួមមាន ភាពមិនគ្រប់គ្រាន់និងកង្វះខាតភាពគ្រប់ជ្រុងជ្រោយនៃសេវា។ បញ្ហាសុខភាពដែលជាក់លាក់សម្រាប់មនុស្ស LGBT ដែលមិនទាន់បានបំពេញ រួមមានបញ្ហាដែលទាក់ទងនឹងការប្រើអ័រម៉ូន ថ្នាំគ្រាប់ការពារកំណើត ដូចជា ថ្នាំគ្រាប់ "OK" និងថ្នាំធ្វើឲ្យស្បែកស - ក៏ដូចជា ទម្រង់ការវេជ្ជសាស្រ្តដើម្បីឲ្យកាន់តែមានលក្ខណៈជាស្រី ឬជាប្រុសច្រើនថែមទៀត ដូចជាការវះកាត់កែសម្ផស្ស រួមទាំងការដាក់បញ្ចូលសុដន់ និងធ្វើចង្កា រ និងការចាក់ផលិតផលប្រេងរុក្ខជាតិ ដូចជាប្រេងចាន់ និងការប្រើឱសថបុរាណ។

## *កង្វះព័ត៌មានដែលជាក់លាក់ និងសេវាសម្រាប់ មនុស្សLGBT*

គេគិតថា គ្រូពេទ្យខ្លះនៅក្នុងប្រទេសកម្ពុជា មានបទពិសោធន៍ទូលំទូលាយនិងគ្រប់ជ្រុងជ្រោយអំពីបញ្ហាសុខភាពរបស់មនុស្ស LGBT។ មនុស្សជាច្រើន ពឹងផ្អែកលើមិត្តភក្តិក្នុងការទទួលព័ត៌មានអំពីទម្រង់ការបញ្ជាក់យេនឌ័រ។ អ្នកខ្លះប្រើការថែទាំវេជ្ជសាស្រ្តដោយខ្លួនឯង ។ ជាលទ្ធផល មានការរាយការណ៍ថា មានផលវិបាកនិងផលរំខានយ៉ាងធ្ងន់ធ្ងរ។[131] ការវះកាត់បញ្ជាក់ភេទ មិនមាននៅក្នុងប្រទេសកម្ពុជាទេ។ គេអាចធ្វើនៅក្នុងប្រទេសថៃ ដែលមនុស្សប្តូរភេទខ្លះមានលទ្ធភាពផ្អែកហិរញ្ញវត្ថុ ធ្វើដំណើរទៅរកសេវាវះកាត់បែបនេះ អម

[130]Salas, V. របាយការណ៍វាយតម្លៃ, (2013). "ការលើកកម្ពស់សុខភាពផ្លូវភេទនិងសុខភាពបន្តពូជរបស់ MSM ក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ចាម និងកំពង់ស្ពឺ"។ សមាគមសុខភាពគ្រួសារនៃកម្ពុជា (RHAC), ឯកសារផ្ទៃក្នុង។
[131] ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនពីមន្ត្រីសម្របសម្រួលបណ្តាញចតុមុខ (២០១៤)

ដំណើរដោយឈ្នួញកណ្ដាល ឬជនដទៃទៀត។[132] មនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្ដូរភេទពីស្រីទៅប្រុស បានរាយការណ៍ប្រាប់អំពីបញ្ហាសុខភាពនានា ដូចជា ការឈឺខ្លួនដោយសារការប្រើឧបករណ៍ចងទ្រូងដើម្បីបង្រួមទំហំសុដន់ ជាដើម។

អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិ ក៏បានកត់សម្គាល់ផងដែរអំពីកង្វះខាតការប្រឹក្សា និងសេវាសុខភាពផ្លូវចិត្តសម្រាប់បុគ្គល LGBT ។ អ្នកខ្លះត្រូវបានបង្ខំឲ្យព្យាបាលជំងឺវិបត្តិផ្លូវចិត្ត ដែលគេចាត់ទុកថាឆ្កួត និងត្រូវបានគេបង្ខំឲ្យទៅរកគ្រូខ្មែរ ដើម្បី "ព្យាបាល" ជំងឺស្រឡាញ់ភេទដូចគ្នា។ អ្នកខ្លះបានប៉ុនប៉ងធ្វើអត្តឃាត។ ជារឿយៗ អ្នកផ្ដល់សេវាប្រឹក្សាពុំមានការបណ្ដុះបណ្ដាល ឬជំនាញនៅក្នុងបញ្ហា LGBT និង SOGI។ ដំបូន្មានទូទៅមួយ យោងតាមអ្នកដែលបានទទួលប្រឹក្សាកន្លងមក (ដោយស្ម័គ្រចិត្ត ឬបង្ខំដោយឪពុកម្ដាយ)[133] គឺ "គ្រាន់តែព្យាយាមផ្លាស់ប្ដូរ និងធ្វើតាមបំណងរបស់ឪពុកម្ដាយរបស់អ្នកទៅ"។

នៅឯកិច្ចពិភាក្សាថ្នាក់ជាតិ អ្នកចូលរួមបានរាយការណ៍ថា ពុំមានសេវាសុខភាពដែលមានស្រាប់សម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នាទេ៖ "សម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា គ្មានអ្វីទាំងអស់... បើទោះបីជាពួកគេនិយាយថា សេវាសុខភាពគឺសម្រាប់ទាំងអស់គ្នាក៏ដោយ ប៉ុន្តែនៅពេលមនុស្សស្រីស្រឡាញ់ភេទដូចគ្នាខ្លះទៅ ពួកគេពិបាករកសេវាណាស់... អ្នកផ្ដល់សេវាសុខភាពព្យាបាលពួកគេមិនស្មើគ្នា ជាពិសេស ស្ត្រីប្ដូរភេទ - នេះគឺអាចដោយសារតែឥរិយាបថរបស់មនុស្សប្ដូរភេទខ្លួនផ្ទាល់, ឬ អាចថា អ្នកផ្ដល់សេវាមិនចូលចិត្តពួកគេ..."[134]

## *អនុសាសន៍អំពីសុខភាព រួមទាំងមេរោគអេដស៍*

- ចាំបាច់ត្រូវធ្វើការវាយតម្លៃសុខភាពរបស់ LGBT រួមទាំងឥរិយាបថ និងទម្លាប់ស្វែងរកការថែទាំសុខភាពផងដែរ។
- ក្រសួងសុខាភិបាល អង្គការក្រៅរដ្ឋាភិបាល LGBT និងអ្នកផ្ដល់សេវា (រួមទាំងអ្នកដែលធ្វើការជាមួយមេរោគអេដស៍) គួរផ្ដល់ព័ត៌មាន និងការបណ្ដុះបណ្ដាលដល់អ្នកផ្ដល់សេវាអំពីបញ្ហា LGBT, SOGI និងការយល់ដឹងអំពីយេនឌ័រ ។
- អ្នកមានវិជ្ជាជីវៈផ្នែកចិត្តសាស្ត្រ ត្រូវការការបណ្ដុះបណ្ដាល និងជំនាញជាក់លាក់ដើម្បីផ្ដល់សេវាផ្ដល់ប្រឹក្សាសមស្របដល់បុគ្គល LGBT ។
- ការផ្ដល់ប្រឹក្សាគួរផ្ដល់ដល់បុគ្គល LGBT ដែលមានបញ្ហាចិត្តសាស្ត្រឬផ្លូវចិត្ត ក៏ដូចជាសម្រាប់សមាជិកគ្រួសាររបស់ពួកគេ។

[132] ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន, តាន់ អឹងស៊ី (២០១២)

[133] ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនពីអ្នកសម្របសម្រួល RoCK និងសកម្មជនសហគមន៍

[134] ចំណាប់អារម្មណ៍ពីការពិភាក្សាក្រុមតូចក្នុងអំឡុងពេលកិច្ចពិភាក្សាថ្នាក់ជាតិ

- អ្នកផ្តល់ប្រឹក្សាសម្រាប់សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងអ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត គួរតែផ្តល់ព័ត៌មានដែលមានតុល្យភាពនិងល្អិតល្អន់អំពីបញ្ហានិងក្តីកង្វល់របស់ LGBT។ ពួកគេមិនគួរគ្រាន់តែផ្តល់ដំបូន្មាន "ធ្វើតាមឪពុកម្តាយរបស់អ្នក" ប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់ជម្រើសជាច្រើនសមស្របដល់អតិថិជន។
- ត្រូវជំរុញការប្រើកាន់តែច្រើនថែមទៀតនូវប្រព័ន្ធផ្សព្វផ្សាយសង្គម និងសេវាផ្តល់ប្រឹក្សាតាមអនឡាញ និងពង្រីកទំហំនិងវិសាលភាពនៃគំនិតផ្តួចផ្តើមទាំងនេះ។
- អ្នកផ្តល់សេវាថែទាំសុខភាពត្រូវពិភាក្សាក្នុងចំណោមសហការីរបស់ខ្លួន និងជាមួយមនុស្សប្តូរភេទអំពីបញ្ហា និងផលវិបាកនៃការប្រើឱសថដែលទាក់ទងនឹងការប្តូរភេទផ្សេងៗ។ ឱសថទាំងនេះរួមមាន ថ្នាំគ្រាប់ការពារកំណើត និងសារធាតុបំប៉ននិងឱសថផ្សេងទៀត សារធាតុធ្វើឲ្យស និងការចាក់ស៊ីលីកូន និងសារធាតុដទៃទៀតដូចជាអ័រម៉ូនដែលប្រើសម្រាប់ឲ្យក្លាយជាស្រី និង/ឬប្រុសកាន់តែច្រើន។ ការយល់ដឹងអំពីផលវិបាកនៃការព្យាបាលទាំងនេះ គួរផ្សព្វផ្សាយផ្ទាល់ក្នុងចំណោមបុគ្គលដែលប្រើការព្យាបាលទាំងនេះ។
- អ្នកផ្តល់សេវាសុខភាពនិងសេវាមេរោគអេដស៍ គួរពិចារណាអនុសាសន៍បន្ថែមខាងក្រោមនេះ ពីប័ណ្ណរបាយការណ៍បង្ការមេរោគអេដស៍សម្រាប់ MSM និងមនុស្សប្តូរភេទនៅក្នុងប្រទេសកម្ពុជា៖
  - ស្វែងរកវិធីបង្កើនសេវាកាន់តែច្រើននៅតាមគ្លីនិកសុខភាពផ្លូវភេទ និងសុខភាពគ្រួសារ ដើម្បីដាក់បញ្ចូលការពិនិត្យរោគស្ត្រីនិងរន្ធគូថ ការចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ សេវាកាត់បន្ថយគ្រោះថ្នាក់ និងបញ្ហាសុខភាពដទៃទៀតរបស់បុគ្គល LGBT។
  - ពង្រីកការផ្តល់សេវាសុខភាព រួមទាំងគ្លីនិកសម្រាប់ LGBT ការបង្ការវិជ្ជមានសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍, គ្លីនិកចល័ត, ការផ្តល់ប្រឹក្សាអំពីក្តីកង្វល់ទាក់ទងនឹង SOGI, និងការដាក់បញ្ចូលជាមួយសេវាដែលមានស្រាប់។
  - បណ្តុះបណ្តាលបុគ្គលិកគ្លីនិកទាំងអស់ (អ្នកផ្តល់សេវា អ្នកទទួលភ្ញៀវ អ្នកយាមបុគ្គលិកមន្ទីរពិសោធន៍) អំពីយេនឌ័រ ការមិនរើសអើងជាមួយ LGBT និងទំនាក់ទំនងអតិថិជន។
  - បណ្តុះបណ្តាលអ្នកផ្តល់សេវាថែទាំសុខភាព (វេជ្ជបណ្ឌិត គិលានុបដ្ឋាក/យិកា គ្រូពេទ្យមធ្យម) អំពីបញ្ហាសុខភាពរបស់ LGBT បង្កើតភាពស្និតស្នាល ការពិនិត្យសុដន់ជាប្រចាំ ការពិនិត្យប្រដាប់ភេទនិងរន្ធគូថ និងការពិនិត្យសុខភាពទាំងមូល ។
  - ធានារៀបចំម៉ោងធ្វើការគ្លីនិកដែលងាយស្រួលសម្រាប់បុគ្គល LGBT ដើម្បីបង្កើនលទ្ធផលទទួលសេវាសម្រាប់អ្នកដែលធ្វើការពេលយប់នៅក្នុងឧស្សាហកម្មផ្លូវភេទ។
  - ដាក់បញ្ចូលបុគ្គល LGBT ជាបុគ្គលធនធាននៅពេលបណ្តុះបណ្តាលអ្នកផ្តល់សេវាថែទាំសុខភាព។

- ដាក់បញ្ចូល MSM និងមនុស្សប្ដូរភេទ នៅក្នុងការតាមដាន HIV ជាប្រចាំ និងបញ្ចេញលទ្ធផលទាន់ពេលវេលាដើម្បីប្រើសម្រាប់គាត់តែងកម្មវិធី និងអន្តរាគមន៍។
- បុគ្គល LGBT គួរពាក់ព័ន្ធនៅក្នុងការវាយតម្លៃសេវាសុខភាព និងនៅក្នុងការបណ្ដុះបណ្ដាលបុគ្គលិកសុខាភិបាល ដោយអនុវត្តតាមគំរូគ្លីនិកនានា ដូចជាគ្លីនិករបស់អង្គការរ៉ាក់ (RHAC)។

## ប្រព័ន្ធផ្សព្វផ្សាយ រួមទាំង បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង

### *បញ្ហា និងក្ដីកង្វល់*

អ្នកចូលរួមក្នុងកិច្ចពិភាក្សាថ្នាក់ជាតិ បានកត់សម្គាល់ថា ប្រព័ន្ធផ្សព្វផ្សាយអាចប្រឌិតព័ត៌មាន ប្រើពាក្យក្នុងន័យរើសអើង ហើយថា អ្នករាយការណ៍មិនយល់ពីបញ្ហាសិទ្ធិមនុស្ស និង SOGI។ ប្រព័ន្ធជាភាសាខ្មែរក្នុងស្រុក ត្រូវបានសកម្មជន LGBT ក្នុងស្រុកភាគច្រើនចាត់ទុកថាមានលក្ខណៈអវិជ្ជមានហួសហេតុចំពោះការផ្សាយព័ត៌មានអំពីបុគ្គលLGBT។ ព័ត៌មានលំអៀងនិងការសន្និដ្ឋានជាទូទៅអំពីបុគ្គលLGBT លេចឡើងជារឿយៗនៅក្នុងសារព័ត៌មានក្នុងស្រុក។ ឧទាហរណ៍ នៅពេលស្ត្រីប្ដូរភេទម្នាក់ត្រូវបានគេតាមទាន់កំពុងលួចគេ កាសែតខ្មែរក្នុងស្រុកផ្សាយព័ត៌មានដោយសន្និដ្ឋានជាទូទៅអំពីស្ត្រីប្ដូរភេទទាំងអស់ ថាប្រើគ្រឿងញៀន ឬធ្វើជាចោរ។ ទស្សនាវដ្ដីក្នុងស្រុកមួយបានបង្ហាញរូបថតមួយអំពីសមាជិករបស់ បណ្ដាញចតុមុខ(បណ្ដាញជាតិនៃ MSM និងមនុស្សប្ដូរភេទ) ដែលយកពីអត្ថបទដំណឹងមិនពាក់ព័ន្ធគ្នាមួយហើយប្រើពាក្យមិនសមរម្យនិងមើលងាយ។[135] ប្រព័ន្ធផ្សព្វផ្សាយជាភាសាអង់គ្លេសក្នុងស្រុក និងទីភ្នាក់ងារសារព័ត៌មាន មានលក្ខណៈវិជ្ជមាន និងមានតុល្យភាពជាងនៅក្នុងការផ្សាយដំណឹងអំពីបុគ្គល LGBT និងបញ្ហារបស់ពួកគេ។[136]

ជារឿយៗ មនុស្សប្ដូរភេទត្រូវបានគេបង្ហាញថា ឆ្កួត ខ្សោយ និងល្ងង់។ ករណីភាគច្រើនបំផុត ពួកគេត្រូវបានគេប្រគល់តួនាទីកម្រិតទាប ជាតួចិត្តអាក្រក់ និងបិសាច នៅពេលសំដែងភាពយន្តក្នុងស្រុក។ ការផ្សាយពាណិជ្ជកម្មទូរទស្សន៍នាពេលថ្មីៗមួយសម្រាប់ក្រុមហ៊ុនទូរស័ព្ទចល័តមួយ សើចចំអកឲ្យមនុស្សប្ដូរភេទ។ វាបង្ហាញពីក្រុមហ៊ុនទូរស័ព្ទគូប្រជែងដែលមានសេវាមិនល្អរអាក់រអួល ខ្សែទូរស័ព្ទមាន "ភាពច្របូកច្របល់" និងភ្ជាប់អ្នកហៅទៅនឹងបុគ្គលប្ដូរភេទ ជាជាងស្រីស្អាត។ អង្គការ CCHR និងសកម្មជន LGBT ក្នុងស្រុក បាន

---

[135] ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន, គង់ ប៊ុនថន និង អុង សារ៉េន

[136] Sreyneang C. and McIsaac V. , "តារាប្ដូរភេទលើកដំបូងបំផុតរបស់កម្ពុជា សុខចិត្តជ្រើសរើសយកសម្រស់តាមធម្មជាតិ" ៧ ថ្ងៃ, ភ្នំពេញប៉ុស្តិ៍, ថ្ងៃ១៣-១៩ ខែតុលា ឆ្នាំ ២០១២, ទំព័រ១២; Knox, C., "ស្រីនឹងក្លាយជាប្រុស ប្រុសនឹងក្លាយជាស្រី: "សិល្បៈតែងខ្លួនប្ដូរភេទ" ភ្នំពេញប៉ុស្តិ៍, ៧ ថ្ងៃ, ថ្ងៃទី១៤-២០ ខែធ្នូ ឆ្នាំ ២០១២, ទំព័រ ៧

តវ៉ានៅក្នុងកាសែត។ [137] ការផ្សាយពាណិជ្ជកម្មនេះហាក់ដូចជាត្រូវបានគេផ្អាកហើយ។ ប្រធានក្រុមហ៊ុននេះបានបញ្ជាក់ថា ពួកគេ "មិនបានរំពឹងទុកថាមានប្រតិកម្មបែបនេះទេ"។ ភ្នាក់ងារផ្សាយពាណិជ្ជកម្មដែលបានផលិតស្ប៉ត់នេះ មិនបានឆ្លើយតបនឹងអត្ថបទកាសែតនោះទេ។[138]

ទោះបីជាយ៉ាងណាក្តី មានការវិវត្តន៍ជាវិជ្ជមាននៅក្នុងវិស័យភាពយន្តនិងបោះពុម្ពផ្សាយ។ ភាពយន្តមួយអំពីគូស្នេហ៍ស្រីភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា គឺទាក់ទាញទស្សនិកជនយ៉ាងច្រើនកុះករនៅក្នុងឆ្នាំ២០០៩ *"តើខ្ញុំជានរណា?"*[139] ភាពយន្តឆ្នាំ២០១០ រឿង *"ស្នេហានៅវិទ្យាល័យ"* ដែលផ្តោតលើប្រធានបទមេរោគអេដស៍ ការរើសអើង និង "ការរួមភេទរបស់មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា"។ [140] រឿងប្រលោមលោកដំបូងបំផុតអំពីបុរសស្រលាញ់ភេទដូចគញនា ជាភាសាខ្មែរ *"មិត្តប្រុស"* ត្រូវបានចេញផ្សាយក្នុងឆ្នាំ២០១០។[141] ភាពយន្តឯករាជ្យជាច្រើនអំពីជីវិតរបស់មនុស្សប្តូរភេទ មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ត្រូវបានផលិតដោយមានការគាំទ្រពី RoCK។ ភាពយន្តពីរក្នុងចំណោមភាពយន្តទាំងនេះ គឺ *"ស្រីពីរនាក់ប្រឆាំងនឹងភ្លៀង"* និង *"កូនស្រីនិងផ្កាត្នោត"*, ត្រូវបានគេទទួលយកមកបញ្ចាំងនៅឯមហោស្រពភាពយន្តក្រៅប្រទេស។[142] អង្គការ RoCK ក៏បានបោះពុម្ពសៀវភៅរូបថតមួយអំពីជីវិត LGBT ដែរ ដោយវិចិត្រករ វុធ លីណូ នៅក្នុងឆ្នាំ២០១៣។[143]

ប្រជាពលរដ្ឋកម្ពុជាវ័យក្មេងពឹងផ្អែកលើអ៊ីធើណិត, ការសរសេរលើគេហទំព័រផ្ទាល់ខ្លួន, បណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា ហ្វេសប៊ុក, និងសារតាមទូរស័ព្ទ សម្រាប់ ព័ត៌មានអំពីបញ្ហាប្រចាំថ្ងៃ ដោយសារពួកគេមើលឃើញសារព័ត៌មានថាជាមានឥទ្ធិពលផ្នែកនយោបាយ។ ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពជាភាសាខ្មែរក្នុងស្រុក ត្រូវបានគេមើលឃើញថាមិនឯករាជ្យពិតប្រាកដ និងស្ថិតក្រោមឥទ្ធិលរបស់គណបក្សនយោបាយដែលកាន់អំណាច។ ប្រព័ន្ធផ្សព្វផ្សាយដែលហៅថា "ឯករាជ្យ" មួយចំនួនតូច ត្រូវបានគេមើលឃើញថាលំអៀងទៅនឹងគណបក្សប្រឆាំង។ ទំព័របណ្តាញសង្គមដ៏មានប្រជាប្រិយសម្រាប់យុវជនកម្ពុជា រួមមាន ក្រុមហ្វេសប៊ុក ដូចជា RoCK, CamASEAN ប្រឹក្សាច្បាប់ និង LGBT, និងគេហទំព័រ Rainbow Portal ដែលប្រតិបត្តិការដោយអង្គការ CCHR។ ក្រុមធំជាងគេបំផុតបច្ចុប្បន្ន មាន

[137] Kasztelan, Marta. ថ្ងៃទី ៣ មិនា ឆ្នាំ ២០១៤ ទាញយកពី http://asiancorrespondent.com/120120/rights-group-cambodia-cellcard-ad-discriminatory-against-lgbt-people/

[138] Morton, Eddie. "ការផ្សាយពាណិជ្ជកម្មរបស់ សេលខាត ត្រូវបានគេសួរ" ភ្នំពេញប៉ុស្ត៍, ថ្ងៃទី ៤ មិនា ឆ្នាំ ២០១៤

[139] http://archive.indianexpress.com/news/first-cambodian-lesbian-film-is-a-hit/444976. Viewed 22 June 2014

[140] http://www.phnompenhpost.com/lifestyle/new-film-raise-hivaids-awareness. មើលថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៤

[141] http://khmerbird.com/writing/boyfriend-first-gay-novel-in-khmer-language.html. មើល ខែមិនា ឆ្នាំ២០១៤

[142] Thiemann, J. , "ប្រាំពីរសំណួរជាមួយ សៅ សុភ័ក្រ", ភ្នំពេញប៉ុស្ត៍ ៧ ថ្ងៃ, ថ្ងៃទី ១៥ ខែកុម្ភះ ឆ្នាំ ២០១៣ ទាយយកពី http://www.phnompenhpost.com/7days/7-questions-sao-sopheak

[143] Knox, C. "សិល្បៈការចេញជាចំហនៅកម្ពុជាបង្ហាញពីការមាក់ងាយ". ភ្នំពេញប៉ុស្ត៍. ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៣ ទាញយកពី http://www.phnompenhpost.com/lifestyle/coming-out-cambodia-art-series-captures-stigma

សមាជិកពី ៧០០ ទៅ ៨០០នាក់ ដែលគេគិតថាជាភាគរយតូចមួយនៃសហគមន៍ខ្មែរអនឡាញ។

*អនុសាសន៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ រួមទាំង បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង*

- ក្រសួងព័ត៌មានគួរអនុម័តបទបញ្ញាដើម្បីការពារបុគ្គល LGBT ពីការរើសអើង និងផ្ទត់គំនិតបុរេនិច្ឆ័យនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។
- ប្រព័ន្ធផ្សព្វផ្សាយគួរគោរពតាមក្រមសីលធម៌ផ្ទាល់របស់ខ្លួន និងត្រូវមានលក្ខណៈសត្យានុម័ត និងតុល្យភាពនៅក្នុងការផ្សាយពីបុគ្គល LGBT។
- ចាំបាច់ត្រូវមានវគ្គផ្សព្វផ្សាយជាមួយប្រព័ន្ធផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស, SOGI និង LGBT ជាពិសេស សម្រាប់អ្នកសារព័ត៌មានខ្មែរក្នុងស្រុក។
- បុគ្គល LGBT គួរចូលរួមបន្ថែមទៀតនៅក្នុងសកម្មភាពប្រព័ន្ធផ្សព្វផ្សាយ ដើម្បីចែករំលែកបទពិសោធន៍ក្នុងជីវិត និងជោគជ័យរបស់ពួកគេ។ បុគ្គល LGBT គួរបង្ហាញខ្លួនជាមនុស្សសមរម្យ ដើម្បីឲ្យសង្គមមានទស្សនៈវិជ្ជមានអំពីពួកគេ LGBT។
- ការបណ្តុះបណ្តាលគួរត្រូវបានផ្តល់ដល់បុគ្គល LGBT និងអង្គការក្រៅរដ្ឋាភិបាលអំពីរបៀបដោះស្រាយការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយដែលអវិជ្ជមាន និងមិនពិតអំពីបុគ្គល LGBT នៅកម្ពុជា (ពោលគឺ តាមរយៈលិខិតផ្ញើជូនអ្នករៀបរៀង ឯកសារគោលជំហរ ឬអត្ថបទគោលរឿង)។
- អង្គការក្រៅរដ្ឋាភិបាល អង្គការនៅសហគមន៍ និងបុគ្គល LGBT គួរបង្កើតគេហទំព័រ និងចូលរួមជាមួយក្រុមបណ្តាញសង្គម ដែលផ្តល់ព័ត៌មានគួរឲ្យចាប់អារម្មណ៍ មានសារៈប្រយោជន៍ និងមានតុល្យភាពអំពីសកម្មភាពផ្លូវភេទ បំណិតជីវិត និងជីវិតពិតរបស់ LGBT ។
- គម្រោងផ្តល់រង្វាន់ និងការទទួលស្គាល់ គួរត្រូវបានផ្តល់ដល់អង្គការប្រព័ន្ធផ្សព្វផ្សាយ និងបុគ្គលជាអ្នកសារព័ត៌មាន ចំពោះការងារល្អក្នុងការផ្សព្វផ្សាយអំពីបុគ្គល LGBT ជាមនុស្សជាតិ ឬនៅក្នុងការកាត់បន្ថយការរើសអើងនៅក្នុងអង្គការ និងការបោះពុម្ពផ្សាយរបស់ពួកគេ។

## បញ្ហា និងក្តីកង្វល់ដទៃទៀត

ផ្នែកដទៃទៀតជាច្រើននៃក្តីកង្វល់សម្រាប់បុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា ត្រូវបានលើកឡើងនៅឯកិច្ចពិភាក្សាថ្នាក់ជាតិឬត្រូវបានពិភាក្សានៅក្នុងការពិនិត្យលើឯកសារដែលមានស្រាប់ខាងក្រៅផ្នែកទាំងប្រាំមួយខាងលើ។ ផ្នែកទាំងនេះរួមមានអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ការមាក់ងាយខ្លួនឯង ការពង្រឹងអង្គការសង្គមស៊ីវិល និងការស្រាវជ្រាវលើបញ្ហា។

### *អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ*

បញ្ហាធំមួយសម្រាប់បុគ្គល LGBT គឺអំពើហិង្សាក្នុងគ្រួសារ ដូចដែលបានកត់សម្គាល់ដោយអ្នកចូលរួមខ្លះនៅក្នុងកិច្ចពិភាក្សាថ្នាក់ជាតិនៅក្នុងវគ្គពិភាក្សាក្រុមតូចរបស់ពួកគេ។ របាយការណ៍ស្តីពីការផាត់ចេញពីសង្គមបានសួរជាក់លាក់អំពីទម្រង់នៃអំពើហិង្សាដែលសមាជិកគ្រួសារ និង/ដៃគូ បានជួបប្រទះ។ ភាគច្រើននៃអ្នកឆ្លើយតបនឹងការសម្ភាស៍ដែលជាមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា (៥៧ភាគរយ) បានរាយការណ៍ឲ្យដឹងថាបានទទួលរងអំពើហិង្សាក្នុងគ្រួសារ។ អត្រានេះគឺខ្ពស់ក្នុងចំណោមស្ត្រីប្តូរភេទ (៦៦ភាគរយ)។ ប្រភេទផ្សេងនៃអំពើហិង្សាក្នុងគ្រួសារ (ផ្លូវកាយ ផ្លូវអារម្មណ៍ ផ្លូវភេទ) និងអ្នកប្រព្រឹត្តផ្សេងៗនៅក្នុងគ្រួសារ ត្រូវបានគេលើកឡើង - ឪពុកម្តាយ សាច់ញាតិ ឪពុកមា ម្តាយមីង ជីដូនជីតា និងដៃគូ។[144]

សមាមាត្រនៃ LGBT នៅក្នុងរបាយការណ៍ស្តីពីការផាត់ចេញពីសង្គម ការរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារគឺពី ៣ ទៅ ១០ដងខ្ពស់ជាងអត្រាដែលបានរាយការណ៍ដោយប្រជាពលរដ្ឋជាស្ត្រីទូទៅនៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងការសិក្សាដែលមានចុងក្រោយបំផុត ដែលរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារ ពោលគឺការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០០៥។ ការសិក្សាឆ្នាំ២០០៥ គឺជាសំណាកកម្រងដែលជ្រើសរើសដោយចៃដន្យពីជំរឿនជាតិមួយ លើស្ត្រីចំនួន ២០៣៧នាក់។

គេសង្កេតឃើញភាពខុសគ្នាយ៉ាងច្បាស់ ពីសូចនាករផ្សេងៗនៃអំពើហិង្សាក្នុងគ្រួសារនិងផ្លូវភេទដែលបានយកចេញពី CDHS ឆ្នាំ២០០៥ និងរបាយការណ៍ស្តីពីការផាត់ចេញពីសង្គម ឆ្នាំ២០១២ (តារាងខាងក្រោមនេះត្រូវបានដកស្រង់ចេញពីតារាងទី៦, ទំព័រ ១២នៃរបាយការណ៍ស្តីពីការផាត់ចេញពីសង្គម)៖

| ការប្រៀបធៀបករណីអំពើហិង្សាក្នុងគ្រួសារនិងអំពើហិង្សាផ្លូវភេទប្រភេទខ្លះ<br>*(មាត្រានៃប្រភេទជម្លោះកែតម្រូវ ដែលប្រើសម្រាប់ការអង្កេតទាំងពីរ)* | CDHS ២០០៥ (ស្ត្រី ២០៣៥ នាក់ ) | ២០១២ (LGBT ១៩៩ នាក់) |
|---|---|---|
| បង្ខំឲ្យប្រព្រឹត្តអំពើផ្លូវភេទ ដែលខ្ញុំមិនចង់ធ្វើ (លើកលែងតែការរួមភេទ) | ០,៥% | ១៩% |
| បង្ខំឲ្យរួមភេទ ទោះបីជាខ្ញុំមិនចង់ | ២,៥% | ១២% |
| រុញ គ្រវី ឬគ្រវែងអ្វីមួយដាក់ខ្ញុំ | ៧.៨% | ៣២% |
| ទះខ្ញុំ ឬ មួលដៃខ្ញុំ | ៩.៥% | ២៦% |

[144] Salas V. and Srorn, S. (2014). ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃបុគ្គល LGBT នៅក្នុងប្រទេសកម្ពុជា និងវិធីដោះស្រាយរបស់ពួកគេ។ SPCU-CARD, ទំព័រ ១១–១២

| | | |
|---|---|---|
| វាយខ្ញុំជាមួយអាវុធ (កាំបិត កាំភ្លើង ឬវត្ថុដទៃទៀត) | ១% | ៩% |

ខណៈពេលដែលអាចមានភាពខុសគ្នានៅក្នុងការពិពណ៌នាអំពី "អំពើផ្លូវភេទ" រវាងការសិក្សាទាំងពីរ អត្រាដ៏ខ្ពស់នៃអំពើហិង្សាផ្លូវភេទដែលបានរាយការណ៍ឲ្យដឹង[145] ដែលទទួលរងដោយអ្នកឆ្លើយនឹងសម្ភាសន៍ដែលជា មនុស្សLGBT គឺមានលក្ខណៈគួរឲ្យព្រួយបារម្ភ។ បុគ្គល LGBT ម្នាក់ ក្នុងចំណោម៥នាក់ បានរាយការណ៍ថាត្រូវគេបង្ខំឲ្យប្រព្រឹត្តអំពើផ្លូវភេទនានា ក្រៅពីការរួមភេទ ប្រៀបធៀបនឹងស្ត្រីរៀបការម្នាក់ក្នុងចំណោម ២០០នាក់។

ការសិក្សានៅក្នុងប្រទេសជាច្រើនក្នុងពេលតែមួយនាពេលថ្មីៗនេះ ពីអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើស្ត្រី (ឆ្នាំ២០១៣) បានដាក់បញ្ចូលសំណួរអំពីអំពើហិង្សាផ្លូវភេទដាក់ស៊ិកបញ្ចូលរបស់បុរស ក៏ដូចជាបទពិសោធន៍របស់បុរសដែលត្រូវបានរំលោភសេពសន្ថវៈដោយបុរសផ្សេងទៀត។[146] ក្នុងចំណោមប្រទេសចំនួន៦នៅក្នុងការសិក្សានេះ មានតែកម្ពុជាទេដែលមានសំណាកតំណាងទូទាំងប្រទេសដែលអាចជឿទុកចិត្តបាន។ ក្នុងចំណោមអ្នកឆ្លើយនឹងសម្ភាសន៍ចំនួនប្រមាណ ១៨០០នាក់ ៣,៣ភាគរយបានរាយការណ៍ប្រាប់ថាបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើបុរសដទៃទៀត ឬក្មេងប្រុស។ នៅក្នុងការសិក្សាដដែល ៣,៧ភាគរយនៃបុរសកម្ពុជាបានរាយការណ៍ថាបានទទួលរងអំពើហិង្សាផ្លូវភេទ រួមទាំងការរំលោភសេពសន្ថវៈដោយបុរសដទៃទៀត។ ការវិភាគលើរបកគំហើញដំបូងដោយអ្នកនិពន្ធ បង្ហាញថា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា ឬមនុស្សប្រុសចរិកស្រីទំនងជាក្លាយជាជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ។ កត្តាខ្លះដែលពាក់ព័ន្ធនឹងការរំលោភបុរសដទៃទៀត រួមមានការសេពគ្រឿងស្រវឹង ការប្រើគ្រឿងញៀន និងសមាជិកក្រុមទំនើង។

ការសិក្សារបស់អង្គការសហប្រជាជាតិនេះ កត់សម្គាល់ពីភាពស្មុគស្មាញ និងភាពពាក់ព័ន្ធគ្នានៃកត្តាជាច្រើនដែលរួមចំណែកដល់អំពើហិង្សាក្នុងគ្រួសារនិងផ្លូវភេទ។ ការសិក្សានេះបានសន្និដ្ឋានថា អំពើហិង្សាក្នុងគ្រួសារនិងការរំលោភសេពសន្ថវៈ គឺទាក់ទងយ៉ាងសំខាន់ទៅនឹងបទដ្ឋានយេនឌ័រមិនស្មើភាព វិសមភាពអំណាច និងឧត្តមគតិគ្របដណ្តប់នៃភាពជាបុរស ដែលគាំទ្រអំពើហិង្សានិងការត្រួតត្រាលើស្ត្រី។

[145] Salas, V & Srorn, S. ibid.

[146] Fulu E, Warner X, Miedma S, Jewkes R, Roselli T and Lang, J. (2013). ហេតុអ្វីបុរសខ្លះប្រើអំពើហិង្សាប្រឆាំងស្ត្រី ហើយតើយើងអាចទប់ស្កាត់វាដោយរបៀបណា? របកគំហើញបែបបរិមាណវិស័យពីការសិក្សាក្នុងប្រទេសជាច្រើនរបស់អង្គការសហប្រជាជាតិទៅលើបុរស និងអំពើហិង្សានៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ បាងកក៖ UNDP, UNFPA, UN Women និង UNV. (ទំព័រ ១៧, ៤៧, ៤៩, ៨៣–៨៤)

### *ការមាក់ងាយខ្លួនឯងក្នុងចំណោម MSM និងមនុស្សស្រីប្លូរភេទវ័យក្មេង*

ការមាក់ងាយខ្លួនឯងគឺជាចំណុចផ្តោតសំខាន់នៃសេចក្តីសង្ខេបគោលនយោបាយមួយដែលបានបោះពុម្ពដោយអង្គការសម្លេងយុវជនសំខាន់ក្នុងឆ្នាំ២០១៣។ [147] សេចក្តីសង្ខេបគោលនយោបាយនេះកំណត់ពីបញ្ហារបស់ខ្លួនឯង ថាជាចង្កោមនៃក្តីកង្វល់ដែលមានផលប៉ះពាល់ជាវិជ្ជមាន ឬអវិជ្ជមានមកលើការទទួលយកខ្លួនឯង, ការយល់ឃើញអំពីខ្លួនឯង, ប្រសិទ្ធភាពខ្លួនឯង, ការផ្តល់តម្លៃដល់ខ្លួនឯង, និងទំនុកចិត្តលើខ្លួនឯង។ ការមាក់ងាយខ្លួនឯងកើតឡើង នៅពេលបញ្ហារបស់ខ្លួនឯង មានអន្តរកម្មជាមួយកត្តាខាងក្រៅនានា ដូចជាការរើសអើង និងអំពើហិង្សានៅក្នុងសាលា នៅផ្ទះ និងសហគមន៍ ដែលធ្វើឲ្យមានការបាក់ទឹកចិត្ត ការមិនផ្តល់តម្លៃដល់ខ្លួនឯង និងការធ្វើឲ្យឈឺចាប់ដល់ខ្លួនឯង។ របាយការណ៍នេះដាក់បញ្ចូលសក្ខីកម្មពី MSM និងមនុស្សស្រីប្លូរភេទវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ដូចជា៖

*"ដៃគូខ្លះបានបង្ខំខ្ញុំឲ្យប្រើគ្រឿងញៀន និងគ្រឿងស្រវឹង មុននឹងរួមភេទ ហើយខ្ញុំមិនមានទំនុកចិត្តលើខ្លួនឯងដើម្បីបដិសេធទេ... ខ្ញុំបានទទួលរងអំពើហិង្សានិងការរំលោភបំពានពី MSM ដទៃទៀត និងរឹតតែធ្វើឲ្យអារម្មណ៍ខ្ញុំអវិជ្ជមានអំពីខ្លួនឯង។"*

### *ផ្នែកដែលត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀត និងកត់ត្រាទុកជាឯកសារ*

របាយការណ៍ស្តីពីការផាត់ចេញពីសង្គម (២០១៣) ផ្តល់អនុសាសន៍ឲ្យធ្វើការស្រាវជ្រាវជាច្រើនផ្នែកទៀត ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការបង្កើតគោលនយោបាយនាពេលខាងមុខ។ គេត្រូវការព័ត៌មានបន្ថែមទៀតអំពីបុគ្គល LGBT វ័យក្មេង (១២-១៨ឆ្នាំ) ដោយហេតុថានេះគឺជាជាពេលដែលទំនោរផ្លូវភេទនិងការសំដែងផ្លូវភេទចាប់ផ្តើមលេចចេញមកក្រៅឲ្យគេស្គាល់។ នៅអាយុទាំងនេះ មនុស្សវ័យក្មេងៗងាយរងគ្រោះខ្លាំងបំផុតទៅនឹងបញ្ហានានាដូចជាអំពើហិង្សា ការបន្លាច និងការបណ្តេញចេញពីផ្ទះ ឬសាលារៀន។ អនុក្រុមមួយទៀតនៃក្រុម LGBT ដែលត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែមពីបុគ្គលLGBT វ័យចំណាស់ (អាយុ៥០ឆ្នាំ ឡើងទៅ) ដែលអាចគ្មានគ្រួសារ ឬកូន រស់នៅឯកោ និងមិនទទួលបានការគាំទ្រពីរដ្ឋាភិបាល តាមរយៈយន្តការគាំពារសង្គម។

គេគួរធ្វើការកត់ត្រាទុកជាឯកសារផងដែរនូវជីវិតរបស់ LGBT និងយន្តការដោះស្រាយ រួមទាំងការគាំទ្រពីក្រុមសហគមន៍ផ្សេងៗ រដ្ឋាភិបាល មន្ត្រីមូលដ្ឋាន និងអ្នកដទៃទៀត។

---

[147] "ខ្ញុំមានអារម្មណ៍ថាខ្ញុំមិនសមនឹងទទួលបានសុភមង្គលទាល់តែសោះ!". គោលនយោបាយខ្លីៗ: ការស្អប់ខ្ពើមខ្លួនឯង ក្នុងចំនោម MSM វ័យក្មេង និងមនុស្សស្រីប្លូរភេទ និងការពាក់ព័ន្ធនិងជំងឺអេដស៍នៅប្រទេសអាស៊ី. Youth Voices Count (YVC), 2013

# សមត្ថភាពរបស់អង្គការ LGBT នៅក្នុងប្រទេសកម្ពុជា

## សាវតារ

ប្រទេសកម្ពុជាក្នុងសម័យទំនើប ក្រោយឆ្នាំ១៩៧០ បានឆ្លងកាត់ប្រវត្តិសោកនាដកម្ម ចលាចលអស់រយៈពេលជាងពីរទសវត្សរ៍នៃសង្គ្រាមស៊ីវិល អំពើប្រល័យពូជសាសន៍ ការផ្លាស់ប្តូរទីលំនៅក្នុងទ្រង់ទ្រាយធំ គ្រោះទុរ្ភិក្ស និងការបំផ្លាញទាំងស្រុងនូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ សង្គម គ្រួសារ និងសហគមន៍ និងស្ថាប័នរដ្ឋ។ ប្រជាជនកម្ពុជាម្នាក់ក្នុងចំណោមបួននាក់បានស្លាប់នៅក្នុងអំឡុងឆ្នាំទាំងនេះ។ អស់រយៈពេលទើបតែជាង ៣០ឆ្នាំប៉ុណ្ណោះដែលអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដំបូងបំផុត បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជានៅក្នុងបរិបទនៃរយៈពេលក្រោយជម្លោះ វិបត្តិមនុស្សធម៌ និងជនភៀសខ្លួន។ អង្គការក្រៅរដ្ឋាភិបាលក្នុងដំបូងបំផុត ត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលទើបតែក្នុងទសវត្សរ៍១៩៩០ ប៉ុណ្ណោះ។[148]

ប្រទេសនេះមានស្ថិរភាពល្អគួរសមចាប់តាំងពីឆ្នាំ១៩៩៨មក។ មានកំណើនម៉ាក្រូសេដ្ឋកិច្ចដ៏ខ្ពស់ (ជាធម្យម ៦-៧ភាគរយក្នុងមួយឆ្នាំ ពីឆ្នាំ២០១០ ដល់ ២០១១)។ ផលទុនជាតិក្នុងស្រុកសរុប (ផសស) ក្នុងមនុស្សម្នាក់ បានកើនឡើងចាប់តាំងពីឆ្នាំ២០០៥មក ពី ៤៧១ ដុល្លារអាមេរិក ដល់ ៨៩៧ដុល្លារអាមេរិក ក្នុងឆ្នាំ២០១១។[149] ភាគរយនៃអ្នករស់នៅក្រោមបន្ទាត់ភាពក្រីក្រ បានធ្លាក់ចុះជិតដល់ ៥០ភាគរយក្នុងរយៈពេលបីឆ្នាំ។ នៅក្នុងឆ្នាំ២០០៨ អត្រាអ្នករស់នៅក្រោមបន្ទាត់ភាពក្រីក្រគឺ ៣៨,៨ភាគរយ។ អត្រានេះបានធ្លាក់ចុះមកដល់ ២០,៥ភាគរយក្នុងឆ្នាំ២០១១ ដែលជាឆ្នាំចុងក្រោយដែលមានតួលេខនេះ។ [150] នៅក្នុងឆ្នាំ ២០១៣ គណបក្សកាន់អំណាចបានបាត់បង់អសនៈយ៉ាងគំហុកដែលមិនធ្លាប់មានពីមុនមក ហើយគណបក្សប្រឆាំងបានទទួលការគាំទ្រពីប្រជាពលរដ្ឋយ៉ាងច្រើន ជាពិសេសក្នុងចំណោមមនុស្សវ័យក្មេង។ ចាប់តាំងពីពេលនោះមក មានឱកាសកាន់តែច្រើនសម្រាប់អង្គការសង្គមស៊ីវិលប៉ុន្តែក៏មានការរឹតបន្តឹងធំៗផងដែរដែលធ្វើឡើងដោយគណបក្សកាន់អំណាច មកលើបាតុកម្ម និងការប្រមូលផ្តុំ ដែលរឹតត្បិតសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ និងការសំដែងមតិដោយសន្តិវិធី។

ផ្នែកនានាដែលត្រូវបានរដ្ឋាភិបាលចាត់ទុកថា "មានលក្ខណៈរសើបខ្លាំង" គឺសិទ្ធិមនុស្ស សិទ្ធិដីធ្លី សម្បទានសេដ្ឋកិច្ច ការប្រឆាំងអំពើពុករលួយ និងភាពវិចវិលនៃបរិស្ថាន។ អង្គការសង្គមស៊ីវិល ក៏ប្រឈមមុខនឹងការគំរាមកំហែងពីនិយ័តកម្មរបស់រដ្ឋាភិបាលកាន់តែច្រើន

---

[148] Bennet, Jon and Benson, Charlotte. (1995). "កម្ពុជា៖ សហប្រតិបត្តិការអង្គការក្រៅរដ្ឋាភិបាលនៅក្នុងបរិបទជំនួយដែលមានការផ្លាស់ប្តូរ, ១៩៧៩-១៩៩៤។' នៅក្នុង 'ការអនុវត្តន៍រៀបចំអង្គការក្រៅរដ្ឋាភិបាល ទីក្រុងឡុង, Earthscan publications.

[149] http://data.un.org/CountryProfile.aspx?crName=Cambodia ទាញយកថ្ងៃទី ២ មេសា ឆ្នាំ២០១៤

[150] http://data.worldbank.org/country/cambodia rទាញយកថ្ងៃទី ២ មេសា ឆ្នាំ២០១៤

ឡើង តាមរយៈ "ច្បាប់អង្គការក្រៅរដ្ឋាភិបាល" ដែលបានឆ្លងកាត់ការកែសម្រួលជាច្រើនលើកច្រើនសារក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ។ ទោះបីជាយ៉ាងណាក្តី ទម្រង់ចុងក្រោយនៃច្បាប់នេះមិនទាន់ត្រូវបានគេបញ្ចេញ ឬពិភាក្សាជាមួយតំណាងអង្គការសង្គមស៊ីវិលនៅឡើយទេ។

ជាទូទៅ ការងារទាក់ទងនឹងសិទ្ធរបស់ LGBT មិនប្រឈមមុខនឹងការត្រួតពិនិត្យតឹងរឹងពីអាជ្ញាធរតាមរូបភាពដូចគ្នានេះទេ ប៉ុន្តែក៏គេពុំឃើញមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដទៃទៀតដែរ។ នេះប្រហែលជាដោយសារតែការពិតដែលថា វាគឺជាប្រធានបទថ្មីមួយដែរនៅក្នុងប្រទេសនេះ ហើយថា បរិយាកាសគោលនយោបាយជាតិស្តីពីក្រុមភាគតិចផ្លូវភេទមិនសូវតឹងរឹងដូចនៅក្នុងប្រទេសដទៃទៀតទេ។ដូចបានពិពណ៌នានៅក្នុងផ្នែកមុនស្តីពីគោលនយោបាយមកហើយអង្គការ RoCK គឺជាអង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីជាផ្លូវការដំបូងបំផុត (ក្នុងខែកុម្ភៈ ឆ្នាំ២០១៤) ដែលបានដាក់បញ្ចូលសិទ្ធិ និងបញ្ហារបស់ LGBT យ៉ាងច្បាស់នៅក្នុងធម្មនុញ្ញរបស់ខ្លួន។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូច បានចាប់ផ្តើមធ្វើការជាមួយអ្នកទទួលផលដែលជា MSM និងស្ត្រីប្តូរភេទក្នុងឆ្នាំ១៩៩៩។ អង្គការខ្លះនៅតែសកម្មភាពនៅឡើយក្នុងឆ្នាំ២០១៤។

## ការអង្កេតទៅលើអង្គការក្រៅរដ្ឋាភិបាល

ក្នុងអំឡុងពេលកិច្ចពិភាក្សាថ្នាក់ជាតិ តំណាងរបស់អង្គការនានាត្រូវបានស្នើឲ្យឆ្លើយនឹងសំណួរស្តីពី "ធនធាននិងសមត្ថភាពរបស់អង្គការ LGBT"។ សំណួរអង្កេតត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកនៃ UNDP និងចែកចាយដល់អ្នកចូលរួមក្នុងអំឡុងសិក្ខាសាលា។ អង្គការក្រៅរដ្ឋាភិបាលខ្លះ ត្រូវបានផ្តល់ជូននូវការអង្កេតបន្ទាប់ពីកិច្ចពិភាក្សាថ្នាក់ជាតិ។ ក្រុមខ្លះបានបញ្ជូនចម្លើយរបស់ខ្លួនពីរបីថ្ងៃក្រោយមក។

នៅក្នុងកម្រងសំណួរ មានផ្នែកដែលត្រូវយកចិត្តទុកដាក់ចំនួនបួនធំៗ៖ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សមត្ថភាពអង្គការ និងសហប្រតិបត្តិការនិងសម្ព័ន្ធភាព។ ផ្នែកនីមួយៗមានសំណួរពាក់ព័ន្ធ ដូចមានរៀបរាប់ខាងក្រោម៖

- **ធនធានហិរញ្ញវត្ថុ៖** ចំនួនថវិកា ប្រភពថវិកា (រដ្ឋាភិបាល អាជីវកម្ម អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងអង្គការសហប្រជាជាតិ) សមត្ថភាពរកប្រាក់ចំណូលផ្ទៃក្នុង ការមានប្រភពថវិការយៈពេលវែងនិងអាចជឿទុកចិត្តបាន យន្តការផ្តល់ថវិកា និង កំហិតថវិកាទាក់ទងនឹងការតស៊ូមតិ។
- **ធនធានមនុស្ស៖** ការទាក់ទាញ និងការថែរក្សាប្រធាន រដ្ឋបាការី និងមន្ត្រីហិរញ្ញវត្ថុ ការថែទាំរក្សាបុគ្គលកម្មវិធីដែលមានគុណភាពខ្ពស់ ដែលមានជំនាញខាងនយោបាយ អភិបាលកិច្ច និងគោលនយោបាយសាធារណៈ ចំណេះដឹងអំពីស្តង់

ដារនិងកម្មវិធីអន្តរជាតិ និងបទប្បញ្ញត្តិសម្រាប់ការកសាងសមត្ថភាពជាលក្ខណៈប្រព័ន្ធ។

- **សមត្ថភាពអង្គការៈ** វត្តមានរបស់ថ្នាក់ដឹកនាំដែលខ្លាំង និងប្រកបដោយចក្ខុវិស័យ, យុទ្ធសាស្ត្រច្បាស់លាស់និងសមស្រប, ប្រព័ន្ធគ្រប់គ្រងខ្លាំង និងរចនាសម្ព័ន្ធគ្រប់គ្រង និងសមត្ថភាពក្នុងការសិក្សា និងអនុវត្តមេរៀនដែលបានទទួល។
- **សហប្រតិបត្តិការ និងសម្ព័ន្ធភាពៈ** ការធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយភ្នាក់ងារផ្លាស់ប្តូរដទៃទៀត, ការធ្វើការជាបណ្តាញប្រកបដោយប្រសិទ្ធភាព, យន្តការសម្របសម្រួលថ្នាក់ជាតិនិងថ្នាក់តំបន់, ភាពងាយស្រួលនៃការធ្វើការជាបណ្តាញនិងការកសាងសម្ព័ន្ធភាព ជាមួយភ្នាក់ងារផ្លាស់ប្តូរដទៃទៀត ដើម្បីដោះស្រាយបញ្ហារួម ប្រសិទ្ធភាពនៃការគ្របដណ្តប់របស់ប្រព័ន្ធផ្សព្វផ្សាយ, ប្រសិទ្ធភាពនៃអន្តរកម្មជាមួយរដ្ឋាភិបាលនិងអង្គនីតិបញ្ញត្តិ និងសមត្ថភាព ដើម្បីកៀងគរសហគមន៍ដោះស្រាយបញ្ហាជាអាទិភាព។

ដើម្បីបំពេញបន្ថែមលើការអង្កេតនេះ ការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ទៅលើគេហទំព័ររបស់អង្គការចំនួន១២ និងព័ត៌មានជាសាធារណៈ ត្រូវបានធ្វើឡើងដើម្បីប្រមូលព័ត៌មានអំពីចក្ខុវិស័យ គោលដៅរួម យុទ្ធសាស្ត្រ និងសកម្មភាពរបស់អង្គការ និងទីតាំងភូមិសាស្ត្រគោលដៅ។ ព័ត៌មាននេះត្រូវបានផ្តល់ដោយអង្គការនានា ហើយមិនបានធ្វើការផ្ទៀងផ្ទាត់ទេ។ គេសន្មតថាត្រឹមត្រូវនៅពេលសរសេររបាយការណ៍នេះ។

## របកគំហើញ

### *ការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់*

ការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ តាមរយៈគេហទំព័ររបស់អង្គការក្រៅរដ្ឋាភិបាលចំនួន១២ និងព័ត៌មានជាសាធារណៈដទៃទៀត បានបង្ហាញឲ្យឃើញពីអង្គការតែមួយគត់ដែលឆ្លុះបញ្ចាំងបញ្ហារបស់ LGBT នៅក្នុងចក្ខុវិស័យ និង/ឬបេសកកម្មរបស់ខ្លួន។ ក្រុមមួយទៀតផ្តោតលើ MSM និងមនុស្សប្តូរភេទ។ អង្គការមួយគឺជាអង្គការសិទ្ធិមនុស្សទូទៅដែលមានគម្រោង LGBT មួយ។ អង្គការមួយចំនួនទៀតបាននិងកំពុងធ្វើការលើបញ្ហា HIV រួមទាំងក្រុម MSM និងមនុស្សប្តូរភេទ, ក៏ដូចជា ក្រុមប្រឈមមុខដទៃទៀត រួមទាំងកម្មករកាត់ដេរ អ្នកធ្វើការក្នុងសេវាកម្សាន្ត និងនិស្សិតសកលវិទ្យាល័យ។ អង្គការដទៃទៀតធ្វើការជាចម្បងលើបញ្ហាប្រឆាំងការជួញដូរកុមារ កិច្ចការពារស្ត្រីនិងកុមារ ឬធ្វើការលើ "ការផ្តល់សិទ្ធិអំណាចដល់អង្គការប្រជាពលរដ្ឋ".

សកម្មភាព និងយុទ្ធសាស្ត្រគឺផ្តោតជាចម្បងលើការបង្ការមេរោគអេដស៍ ការផ្សព្វផ្សាយ ការអប់រំ ការបណ្តុះបណ្តាល សកម្មភាពនៅមូលដ្ឋាន និងការបញ្ជូន ការចាត់ចែងមណ្ឌលអប់រំ

ការផ្ដល់ប្រឹក្សា និងជំនួយផ្នែកច្បាប់។ អង្គការមួយចំនួនតូច បានលើកឡើងអំពីការងារសង្គម ការស្រាវជ្រាវ និងការតស៊ូមតិ។ អង្គការខ្លះបានធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ, ICT, និងសុខភាពបន្តពូជ។ អង្គការតែពីរប៉ុណ្ណោះ បានបញ្ជាក់ជាក់លាក់អំពីការចងក្រង LGBT និងការរៀបចំបណ្ដាញ LGBT ជាយុទ្ធសាស្ត្រ និងសកម្មភាពចម្បង។ អ្នកទទួលផលខ្លះរបស់អង្គការទាំងនេះ ត្រូវបានគេសន្មតថាជាបុគ្គល LGBT បើទោះបីជាមិនមានការបញ្ជាក់ច្បាស់ក្ដី។ អង្គការភាគច្រើនកំពុងតែធ្វើការជាមួយអនុក្រុមនៃ "សហគមន៍ LGBT" ជាពិសេស - MSM និងស្ត្រីប្ដូរភេទ - និងមិនមានយុទ្ធសាស្ត្រ ឬសកម្មភាពសម្រាប់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រុសប្ដូរភេទទេ។

អង្គការទាំងអស់មានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ។ អង្គការចំនួនប្រាំ បាននិយាយថា ពួកគេមានសកម្មភាពនៅក្នុងខេត្តកណ្ដាល តែពីរបីគីឡូម៉ែត្រក្រៅទីក្រុងភ្នំពេញ ប៉ុណ្ណោះ។ អង្គការខ្លះក៏មានសកម្មភាពនៅក្នុងខេត្តដទៃទៀតមួយចំនួនផងដែរ។

*ការអង្កេតដោយប្រើកម្រងសំណួរ*

អង្គការចំនួន១២ ដែលបានចូលរួមក្នុងកិច្ចពិភាក្សាជាតិ ត្រូវបានបញ្ជូនឲ្យនូវសំណួរអង្កេត ហើយ ៨អង្គការបានឆ្លើយតប។ អង្គការចំនួន ៧ បានឆ្លើយនឹងកម្រងសំណួរដោយផ្ទាល់ រីឯមួយទៀតបានឆ្លើយតាមរយៈការសម្ភាសន៍តាមទូរស័ព្ទ។ ជាការគួរឲ្យស្ដាយ ភាគច្រើននៃអង្គការទាំងនេះមិនបានផ្ដល់ព័ត៌មានលម្អិតនៅក្នុងចម្លើយរបស់ពួកគេទេ ឬពួកគេអាចមិនយល់ច្បាស់ពីសំណួរ។ ភាគច្រើននៃសំណួរ មិនបានទទួលចម្លើយពេញលេញនោះទេ។

ចម្លើយចំពោះការអង្កេត មិនតំណាងឲ្យទស្សនៈគ្រប់ជ្រុងជ្រោយរបស់អង្គការក្រៅរដ្ឋាភិបាល LGBT នៅក្នុងប្រទេសទេ។ គេត្រូវតែប្រុងប្រយ័ត្ននៅក្នុងការសន្និដ្ឋាន ឬសន្និដ្ឋានជារួមអំពីសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាល LGBT ពីការអង្កេតនេះ។ វាគ្រាន់តែជាការពិនិត្យមើលដោយត្រួសៗមួយតែប៉ុណ្ណោះ។ នៅទីណាដែលមានការបញ្ជាក់ថា "អង្គការក្រៅរដ្ឋាភិបាល LGBT ឬអង្គការ LGBT" នេះគឺគ្រាន់តែជាការសំដៅទៅលើអង្គការក្រៅរដ្ឋាភិបាលដែលបានបញ្ជូនចម្លើយសម្រាប់ការអង្កេតនេះតែប៉ុណ្ណោះ។

## *ក. ធនធានហិរញ្ញវត្ថុ*

*គំហើញទី១៖ ធនធានហិរញ្ញវត្ថុសម្រាប់អង្គការ LGBT នៅក្នុងប្រទេសកម្ពុជាត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់។ ស្ទើរតែគ្មានការគាំទ្រសោះពីរដ្ឋាភិបាល មានការគាំទ្រខ្លះពីវិស័យឯកជន ម្ចាស់ជំនួយអន្តរជាតិ និងប្រព័ន្ធសហប្រជាជាតិ។*

ភាគច្រើននៃអង្គការទាំងនេះដែលបានធ្វើអង្កេត បានបញ្ជាក់ថា ពួកគេមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់សកម្មភាព LGBT ទេ។ បរិមាណថវិកាប្រចាំឆ្នាំដែលបានរាយការណ៍ឲ្យដឹង គឺចាប់ពី "គ្មានថវិកា រហូតដល់ ៥០.០០០ដុល្លារ"។ ថវិកាភាគច្រើនត្រូវកម្រិត

ត្រឹមតែសកម្មភាពមួយចំនួន ដូចជាការស្រាវជ្រាវជាដើម។ ក្រុមថ្មីមួយ គឺគំនិតផ្តួចផ្តើមស្ម័គ្រចិត្តសុទ្ធសាធមួយ ខ្នាតតូច ដែលមានអ្នកទទួលផលពីរឬបីនាក់។ ការស្វែងរកធនធានហិរញ្ញវត្ថុមិនមែនជាអាទិភាពមួយសម្រាប់ពួកគេនៅពេលនេះទេ។

*អ្នកឆ្លើយនឹងសម្ភាសន៍ទាំងអស់ បាននិយាយថា រដ្ឋាភិបាលមិនបានផ្តល់ថវិកាសម្រាប់អង្គការក្រៅរដ្ឋាភិបាល*LGBT *ទេ។ ក្រុមមួយបានឲ្យដឹងថា រដ្ឋាភិបាលទទួលថវិកាពីម្ចាស់ជំនួយ ប៉ុន្តែថវិកានេះត្រូវបានប្រើប្រាស់ដើម្បីរៀបចំកិច្ចប្រជុំផ្ទាល់របស់គេ ដើម្បីចែករំលែកព័ត៌មាន និងបញ្ហាប្រឈមដែលជួបប្រទះដោយ* MSM *និងមនុស្សប្តូរភេទ។ រដ្ឋាភិបាលបានព្យាយាមបង្ហាញពីអ្វីដែលកំពង់កើតឡើង ដល់ភាគីខាងក្រៅក្នុងនាមក្រុមនោះ។*

ជាទូទៅ វិស័យឯកជនមិនបានផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល LGBT ឡើយ។ អង្គការក្រៅរដ្ឋាភិបាលចំនួនពីរ បានផ្តល់ការប៉ាន់ស្មានថវិកាដែលត្រូវបានផ្តល់៖ "ពីរបីរយដុល្លារ" ហើយអង្គការមួយបានបញ្ជាក់ថា "តិចជាង ២០.០០០ដុល្លារ" ក្នុងមួយឆ្នាំ។ "បើពួកគេផ្តល់ គឺសម្រាប់តែព្រឹត្តិការណ៍ពិសេសម្តងៗប៉ុណ្ណោះ ជាពិសេសទាក់ទងនឹងការរៀបចំពិធីសប្តាហ៍មោទនភាព"។

អ្នកឆ្លើយតបនឹងការអង្កេតទាំងអស់ លើកលែងតែអង្គការមួយ ដែលបានឆ្លើយតបថា ម្ចាស់ជំនួយអន្តរជាតិ ឬសកម្មភាពអង្គការក្រៅរដ្ឋាភិបាល LGBT ដែលហិរញ្ញប្បទានដោយអង្គការសហប្រជាជាតិ។ ភាគច្រើននៃអង្គការដែលបានឆ្លើយតប បានបញ្ជាក់ថាថវិកាទាំងនេះគឺបានមកពីមូលនិធិសកលដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ (GFATM) ឬមូលនិធិសកល (Global Fund) និងសម្រាប់ការងារមេរោគអេដស៍។ ចំនួនថវិកាដែលបានរាយការណ៍ គឺពី ១០.០០០ដុល្លារ ដល់ ៩៥.០០០ដុល្លារក្នុងមួយឆ្នាំ។ ហាក់ដូចជាមានការសន្មត់មួយក្នុងចំណោមអង្គការទាំងនេះ (ក៏ដូចជា អាជ្ញាធរជាតិ) ថា ការងារមេរោគអេដស៍ជាមួយ MSM និងស្ត្រីប្តូរភេទ គឺស្មើនឹង ឬអាចរាយការណ៍ជាសកម្មភាព LGBT។ ទោះបីជាយ៉ាងណាក្តី នេះមិនមែនជាករណីនោះទេ។ ការងារមេរោគអេដស៍ដែលផ្តោតជាក់លាក់ទៅលើ MSM និងស្ត្រីប្តូរភេទ មិនដោះស្រាយតម្រូវការរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្រុសប្តូរភេទ ឬបុគ្គលអន្តរភេទ។

ជាមួយនឹងការថយចុះនូវធនធានសម្រាប់មេរោគអេស៍ អង្គការក្រៅរដ្ឋាភិបាជាច្រើនហាក់ដូចជាចង់ធ្វើការកាន់តែច្រើនលើបញ្ហា LGBT។ ពួកគេអាចធ្វើការទៅលើបញ្ហាមេរោគអេដស៍រួចទៅហើយសម្រាប់ MSM និងស្ត្រីប្តូរភេទ កន្លងមក ឬកំពុងធ្វើការលើបញ្ហាសិទ្ធិមនុស្សបញ្ហាស្ត្រី ឬបញ្ហាប្រជាធិបតេយ្យនិងអភិបាលកិច្ច។ អង្គការខ្លះអាចសំដែងការស្មោះត្រង់ រីឯអង្គការខ្លះទៀតកំពុងស្វែងរកធនធានបន្ថែមទៀតសម្រាប់សកម្មភាពរបស់ពួកគេប៉ុណ្ណោះ។

មូលនិធិសកល (GFATM) មានយុទ្ធសាស្ត្រ SOGI។ ប៉ុន្តែ ពុំមានថវិកានៅក្នុងប្រទេសកម្ពុជាសម្រាប់ការងារជាក់លាក់នៃ SOGI នោះទេ។ គេមិនច្បាស់ថាតើអង្គការក្រៅរដ្ឋាភិបាលដែលទទួលថវិកាពីមូលនិធិសកល ដឹងថាមានយុទ្ធសាស្ត្របែបនេះទេ។

*គំហើញទី២៖ អង្គការក្រៅរដ្ឋាភិបាល LGBT មានសមត្ថភាពរកចំណូលផ្ទៃក្នុងខ្លះ ដើម្បីគាំទ្រសកម្មភាព ប៉ុន្តែភាគច្រើនមិនមានប្រភពថវិការយៈពេលវែងដែលអាចជឿទុកចិត្តបានទេ។ ប្រភពនៃថវិកាសម្រាប់សកម្មភាពតស៊ូមតិ មានកម្រិត។*

អង្គការក្រៅរដ្ឋាភិបាលបីក្នុងចំណោមអង្គការ ៨ បានរាយការណ៍ថាមានសមត្ថភាពរកប្រាក់ចំណូលផ្ទៃក្នុងខ្លះ ដើម្បីសកម្មភាពរបស់ខ្លួន។ សកម្មភាពទាំងនេះរួមមាន ការលក់អាវយឺតនិងផលិតផលដទៃទៀត ការគាំទ្រផ្នែកអាជីវកម្មតូចៗ និងការប្រមូលវិភាគទានពីសមាជិកដើម្បីជួយសមាជិកដទៃទៀត នៅពេលពួកគេត្រូវការសម្រាកពេទ្យ។ ថវិកាទាំងនេះហាក់ដូចជាមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការចំណាយរបស់អង្គការនោះទេ។

មានតែអង្គការក្រៅរដ្ឋាភិបាលមួយប៉ុណ្ណោះក្នុងចំណោមអង្គការ៨ ដែលបានអង្កេត បានបញ្ជាក់ថា ពួកគេមានប្រភពថវិការយៈពេលវែងដែលអាចជឿទុកចិត្តបានពីម្ចាស់ជំនួយ។ អង្គការថ្មីមួយបាននិយាយថា "យើងមិនដែលដាក់ពាក្យសុំថវិកាទេ"។

ពាក់កណ្តាលនៃអ្នកឆ្លើយនឹងសម្ភាសន៍ បួនក្នុងចំណោម៨ គិតថា ថវិកាត្រូវបានកំណត់ត្រឹមផ្នែកក្រៅពីការតស៊ូមតិ។ ថវិកាភាគច្រើនត្រូវបានបែងចែកសម្រាប់សកម្មភាពបង្ការមេរោគអេដស៍និងសុខភាព។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ នៅពេលនិយាយអំពី "ការតស៊ូមតិ" នៅក្នុងបរិបទខ្មែរឬ មានទស្សនៈផ្សេងៗគ្នាអំពីប្រភេទនៃពាក្យដែលត្រូវប្រើប្រាស់ ហើយអង្គការក្រៅរដ្ឋាភិបាលហាក់ដូចជាមានការប្រុងប្រយ័ត្នអំពីការបកប្រែជាភាសាក្នុងស្រុក។[151] អ្នកឆ្លើយនឹងការអង្កេតមួយបានផ្តល់យោបល់ថា "ភាគច្រើននៃថវិកាគឺសម្រាប់សុខភាព *(សេវាសុខភាព)*។ រាល់ពេលដែលប្រធានបទ "តស៊ូមតិ" ត្រូវបានគេលើកឡើង គេមិនអនុញ្ញាតឲ្យនិយាយទេ ហើយប្រធានបទត្រូវបានផ្លាស់ប្តូរ។ ពាក្យជាភាសាខ្មែរក្នុងស្រុកដែលប្រើ ត្រូវបានផ្លាស់ប្តូរ ទៅជាជាពាក្យមួយដែលមានន័យថា "ស្វែងរកការគាំទ្រ" ។[152] អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីសុខភាព និយមប្រើពាក្យទីពីរនេះ ដោយសារវាហាក់ដូចជាមិនសូវទាមទារខ្លាំង ឬបង្កហេតុខ្លាំងពេក។ ទោះបីជាយ៉ាងណាក្តី បញ្ហានេះប៉ះពាល់ដល់អ្វីដែលអង្គការអាចធ្វើបាន លើការប្រឆាំងការរើសអើង"។

---

[151]Salas, V. "និយាយចេញមកក្រៅ" - ឯកសារជំនួយស្មារតីស្តីពីការតស៊ូមតិដែលដឹកនាំដោយ MSM និងមនុស្សប្តូរភេទ (ការសម្របតាមបរិបទកម្ពុជា)។ (2014). វេទិកាសកលស្តីពី MSM និងមេរោគអេដស៍ (MSMGF). ជិតចេញផ្សាយ. ប្រើដោយមានការអនុញ្ញាត

[152] Marston, J. មានគំហើញស្រដៀងគ្នាមួយអំពីការប្រើភាសាខ្មែរសមស្រប ដែលត្រូវបានគេប្រើជាញឹកញាប់សម្រាប់ "តស៊ូមតិ". មើល: Marston, J (2000).*' ផលប៉ះពាល់នៃការតស៊ូមតិអំពីសិទ្ធិមនុស្ស' (របាយការណ៍លេខ. 37, SIDA/Forum Syd, កញ្ញា ២០០០) -របាយការណ៍អំពីការវាយតម្លៃលើអង្គការសិទ្ធិមនុស្សប្រាំមួយក្នុងប្រទេសកម្ពុជា*

## *ធនធានមនុស្ស*

*គំហើញទី ៣៖ អង្គការក្រៅរដ្ឋាភិបាល LGBT មិនអាចទាក់ទាញ និងថែរក្សាប្រធាន/នាយក រដ្ឋបាលការី និងមន្ត្រីហិរញ្ញវត្ថុ ល្អៗ ក៏ដូចជាបុគ្គលិកកម្មវិធីគុណភាព ដែលមានជំនាញ ដែលត្រូវការផ្នែកអភិបាលកិច្ច គ្រប់គ្រង និងគោលនយោបាយសាធារណៈ។*

ពាក់កណ្តាលនៃអង្គការក្រៅរដ្ឋាភិបាលដែលបានឆ្លើយតបគិតថា ពួកគេអាចថែរក្សាប្រធាន/នាយក រដ្ឋបាលការី និងបុគ្គលិកហិរញ្ញវត្ថុល្អៗ។ អង្គការមួយបានបង្ហាញពីទំនុកចិត្តថា អង្គការរបស់ខ្លួនមានរចនាសម្ព័ន្ធរឹងមាំ។ អង្គការដទៃទៀតមិនសូវមានទំនុកចិត្តទេ ដោយពន្យល់ថា បុគ្គលិកត្រូវបានស្នើឲ្យឈប់ពីការងារ ដោយសារតែខ្វះខាតថវិកា ហើយអង្គការខ្លះទៀតត្រូវតែទទួលមុខងារគ្រប់គ្រងផ្សេងៗក្នុងពេលតែមួយ។ អង្គការមួយបានបញ្ជាក់ថា "យើងធ្លាប់មានបុគ្គលិក៧នាក់... ដោយសារតែខ្វះខាតថវិកា ឥឡូវនេះប្រធានអង្គការត្រូវធ្វើការរដ្ឋបាល និងហិរញ្ញវត្ថុផងដែរ"។ អង្គការដទៃទៀតរំពឹងថានឹងជួបប្រទះការលំបាកក្នុងការស្វែងរកបុគ្គលិកដែលមានជំនាញនិងអាកប្បកិរិយាត្រឹមត្រូវ។ អង្គការក្នុងចំនួនប្រហែលគ្នា (៥០%) ជឿថា ពួកគេអាចទាក់ទាញបុគ្គលិកដែលមានសមត្ថភាព ខណៈដែលអង្គការខ្លះទៀតមិនប្រាកដ។

*គំហើញទី៤៖ វាមិនច្បាស់ថាតើអង្គការក្រៅរដ្ឋាភិបាល LGBT នៅក្នុងប្រទេសកម្ពុជា មាន "ចំណេះដឹងអំពីស្តង់ដារនិងកម្មវិធីអន្តរជាតិ" ដែលពាក់ព័ន្ធនឹងវិស័យការងាររបស់ពួកគេឬទេ។*

មានចម្លើយចម្រុះចំពោះសំណួរនេះ។ ៥០ភាគរយ *(៤ ក្នុងចំណោម ៨)* នៃអ្នកឆ្លើយតបនឹងការអង្កេត យល់ថា ពួកគេមាន "ចំណេះដឹងអំពីស្តង់ដារនិងកម្មវិធីអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យការងាររបស់ពួកគេ"។ អង្គការមួយបញ្ជាក់ថា ពួកគេកំពុងបន្តខិតខំពង្រឹងសមត្ថភាពរបស់អង្គការរបស់ពួកគេតាមរយៈឱកាសសិក្សាសមស្រប និងទំនាក់ទំនងជាមួយគ្នា។

*គំហើញទី៥៖ អង្គការក្រៅរដ្ឋាភិបាល LGBT ភាគច្រើននៅក្នុងប្រទេសកម្ពុជា មានគោលការណ៍សម្រាប់កសាងសមត្ថភាពជាលក្ខណៈប្រព័ន្ធសម្រាប់បុគ្គលិករបស់ខ្លួន។*

អង្គការប្រាំមួយក្នុងចំនួន៨ បានគិតថា ពួកគេមានប្រព័ន្ធនៅនឹងកន្លែងសម្រាប់កសាងសមត្ថភាពបុគ្គលិក។ អង្គការមួយនិយាយថា ពួកគេមានគោលនយោបាយអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក ប៉ុន្តែថា ម្ចាស់ជំនួយមិនផ្តល់ការគាំទ្រដោយផ្ទាល់ទេ ប៉ុន្តែផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដោយផ្ទាល់ដោយខ្លួនឯង។ អង្គការមួយទៀតបានបញ្ជាក់ថា ការអភិវឌ្ឍសមត្ថភាពបុគ្គលិក ធ្វើឡើងម្តងម្កាល និងមិនមានលក្ខណៈជាប្រព័ន្ធទេ។

### *សមត្ថភាពអង្គការ*

*គំហើញទី៦៖ អង្គការក្រៅរដ្ឋាភិបាល LGBT ភាគច្រើនបំផុតនៅក្នុងប្រទេសកម្ពុជា អះអាងថាមាន "ផ្ទាក់ដឹងរឹងមាំនិងប្រកបដោយចក្ខុវិស័យ ដោយមានយុទ្ធសាស្ត្រច្បាស់លាស់និងសមស្រប"។*

អង្គការស្ទើរតែទាំងអស់ (៧ ក្នុងចំណោម ៨) បានឆ្លើយជាវិជ្ជមាន។ ពួកគេបញ្ជាក់ថា ពួកគេមានយុទ្ធសាស្ត្រច្បាស់លាស់និងសមស្រប។

*គំហើញទី ៧៖ អង្គការក្រៅរដ្ឋាភិបាល LGBT ភាគច្រើន ខ្វះខាតប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ។ ពួកគេក៏អះអាងផងដែរថា មានសមត្ថភាពតិចតួចក្នុងការសិក្សា និងអនុវត្តមេរៀនដែលទទួលបាន។*

ចម្លើយមានលក្ខណៈចម្រុះ៖ អង្គការប្រាំក្នុងចំណោមប្រាំបី យល់ថា អង្គការក្រៅរដ្ឋាភិបាលមិនមានប្រព័ន្ធនិងរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ។ ពាក់កណ្ដាលនៃអង្គការយល់ថា សមត្ថភាពរបស់ពួកគេក្នុងការសិក្សា និងអនុវត្តមេរៀនជាបទពិសោធន៍ គឺមានកម្រិត។ អង្គការមួយបានបញ្ជាក់ថា"*វាហាក់ដូចជាថា អង្គការក្រៅរដ្ឋាភិបាលភាគច្រើន ផ្ដល់អាទិភាពសកម្មភាពរបស់ខ្លួនទៅតាមម្ចាស់ជំនួយ ជាជាងមានសកម្មភាពនិងគុណតម្លៃច្បាស់លាស់ផ្ទាល់ខ្លួន។" អង្គការផ្សេងទៀត បានកត់សម្គាល់ថា ការគាំទ្របុគ្គលិក ឬសមាជិក ឲ្យសិក្សាប្រធានបទនានា ដូចជាភាសាអង់គ្លេស គណនេយ្យ កុំព្យូទ័រ នឹងធ្វើឲ្យពួកមានលទ្ធភាពធ្វើការតស៊ូមតិកាន់តែច្រើនថែមទៀតអំពីសិទ្ធិរបស់ LGBT"* ។

### *សហប្រតិបត្តិការ និងសម្ព័ន្ធភាព*

*គំហើញទី៨៖ អង្គការក្រៅរដ្ឋាភិបាល LGBT ភាគច្រើនបំផុតយល់ថា ពួកគេធ្វើការដោយប្រសិទ្ធភាពជាមួយភ្នាក់ងារផ្លាស់ប្តូរដទៃទៀត។ពួកគេអាចធ្វើការជាបណ្ដាញដោយប្រសិទ្ធភាព និងចូលជាសម្ព័ន្ធភាព។*

ភាគច្រើននៃអង្គការក្រៅរដ្ឋាភិបាលទាំងនេះ យល់ថា ពួកគេបានធ្វើការដោយប្រសិទ្ធភាពជាមួយភ្នាក់ងារផ្លាស់ប្តូរដទៃទៀតនិងបណ្ដាញនានា ដូចជាគណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍/ជំងឺអេដស៍ *(HACC)*។ អង្គការមួយបានសំដែងនូវមន្ទិលសង្ស័យដោយនិយាយថា៖

"*យើងមិនអាចផ្ដល់យោងល់ច្បាស់លាស់អំពីបញ្ហានេះបានទេ។ វាហាក់ដូចជាថា អង្គការក្រៅរដ្ឋាភិបាលធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកដទៃទៀត ដែលផ្ដល់អត្ថប្រយោជន៍ដល់ពួកគេ ទាក់ទងទៅនឹងការសម្រេចបានគោលដៅផ្ទាល់របស់ពួកគេ។ យើងមិនទាន់ឃើញវិធីធ្វើការរួមគ្នានៅឡើយទេ មិនត្រឹមតែនៅក្នុងអង្គការក្រៅរដ្ឋាភិបាល LGBT ប៉ុណ្ណោះទេ ប៉ុន្តែ*

*នៅក្នុងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតទាំងអស់។ វាហាក់ដូចជាថា អង្គការក្រៅរដ្ឋាភិបាលជាច្រើនកំពុងការពារ ស្ថានភាពនិងកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួនរបស់ពួកគេ ដូច្នេះវាមានដំណើរការប្រឆាំងនឹងវិធីសហប្រតិបត្តិការរួមគ្នាខ្លាំងក្លាក្នុងការធ្វើការងារ។ វានៅមិនច្បាស់នៅពេលអ្នកនិយាយថា អង្គការ LGBT - តើនេះគឺជាអ្វី? ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលធ្វើការតែលើបញ្ហា LGBT ប៉ុណ្ណោះឬ? អង្គការក្រៅរដ្ឋាភិបាលមួយដែលមានគម្រោងមួយអំពីបញ្ហារបស់ LGBT? ខ្ញុំគិតថា វាពិបាកស្វែងរកចំនួនអង្គការក្រៅរដ្ឋាភិបាល LGBT នៅក្នុងប្រទេសកម្ពុជា លើកលែងតែប្រភេទទីពីរ"*

អង្គការចំនួនបួនយល់ថា អង្គការក្រៅរដ្ឋាភិបាលរបស់ពួកគេមានដំណើរការទៅដោយប្រសិទ្ធភាព ដោយលើកឡើងពីបទពិសោធន៍របស់ពួកគេជាផ្នែកមួយនៃបណ្តាញមេរោគអេដស៍ថ្នាក់ជាតិ។ ពាក់កណ្តាលនៃអ្នកឆ្លើយតបនឹងការអង្កេត យល់ថា អង្គការក្រៅរដ្ឋាភិបាល LGBT អាចចូលក្នុងសម្ព័ន្ធភាព និងបណ្តាញនានាយ៉ាងងាយ។ អង្គការមួយបានបញ្ជាក់ថា ពួកគេធ្វើការជាបណ្តាញ ប្រសិនបើសម្ព័ន្ធភាពនេះទាក់ទងទៅនឹងការងាររបស់ LGBT។ អង្គការមួយឆ្លើយតបថា អង្គការក្រៅរដ្ឋាភិបាលជាច្រើនអះអាងថាធ្វើការជាបណ្តាញ ប៉ុន្តែពួកគេកម្រនឹងដោះស្រាយបញ្ហាដែលកើតឡើងជាទូទៅ ណាស់។

*គំហើញទី ៩៖ អង្គការក្រៅរដ្ឋាភិបាល LGBT មិនមានយន្តការសម្របសម្រួលថ្នាក់ជាតិ ឬថ្នាក់តំបន់។*

យន្តការសម្របសម្រួលបែបនេះសម្រាប់អង្គការក្រៅរដ្ឋាភិបាល *LGBT* មិនមានទេនៅក្នុងប្រទេសកម្ពុជា។ អង្គការមួយបានកត់សម្គាល់ថា សម្ព័ន្ធភាពខ្លះធ្វើការរួមគ្នាដើម្បីចែករំលែកព័ត៌មាន ប៉ុន្តែមិនសុទ្ធតែអំពីបញ្ហា *LGBT* ឡើយ។

*គំហើញទី ១០៖ អង្គការក្រៅរដ្ឋាភិបាល LGBT នៅក្នុងប្រទេសកម្ពុជា យល់ថា ពួកគេមានប្រសិទ្ធភាពនៅក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែពួកគេមិនមានទំនាក់ទំនងដោយប្រសិទ្ធភាពជាមួយរដ្ឋាភិបាល និងរដ្ឋសភាឡើយ។*

អង្គការភាគច្រើនយល់ថា ពួកគេមានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែអង្គការមួយបានផ្តល់យោបល់ថា "ប្រព័ន្ធផ្សព្វផ្សាយត្រូវតែទទួលការអប់រំបន្ថែមអំពីសិទ្ធិរបស់ LGBT"។ អង្គការក្រៅរដ្ឋាភិបាលភាគច្រើន យល់ថាពួកគេមិនបានប្រាស្រ័យទាក់ទងឲ្យមានប្រសិទ្ធភាពជាមួយរដ្ឋាភិបាល និងរដ្ឋសភាទេ។ មានតែអង្គការមួយប៉ុណ្ណោះដែលយល់ថា អង្គការក្រៅរដ្ឋាភិបាលរបស់ពួកគេ មានទំនាក់ទំនងល្អ ដោយលើកឡើងពីឧទាហរណ៍ជាមួយក្រសួងរដ្ឋចំនួនពីរដែលពួកគេធ្វើការជាមួយ។

*គំហើញទី ១១៖ អង្គការក្រៅរដ្ឋាភិបាល LGBT ភាគតិចយល់ថា ពួកគេអាចកៀងគរសហគមន៍ដើម្បីដោះស្រាយបញ្ហាជាអាទិភាពរបស់ពួកគេ។*

អង្គការក្រៅរដ្ឋាភិបាលបីដែលបានធ្វើអង្កេត យល់ថាពួកគេអាចកៀងគរសហគមន៍។ អង្គការមួយបានបញ្ជាក់ថា សម្រាប់អង្គការក្រៅរដ្ឋាភិបាលជាច្រើន មិនត្រឹមតែអង្គការដែលពាក់ព័ន្ធនឹង LGBT ប៉ុណ្ណោះទេ ការប្រើប្រាក់គឺជាវិធីធម្មតានៃការកៀងគរសហគមន៍។ វិធីនេះមិនមាននិរន្តរភាព និងមិនមានប្រសិទ្ធភាព។

*គំហើញទី ១២៖ ក្នុងចំណោមផ្នែកនៃសមត្ថភាពគន្លឹះបួន អ្នកឆ្លើយនឹងការអង្កេតដែលជាអង្គការក្រៅរដ្ឋាភិបាល LGBT ច្រើនតែមានទំនោរផ្តល់ចំណាត់ថ្នាក់ "សមត្ថភាពអង្គការ" ខ្ពស់បំផុត ហើយ "សម្ព័ន្ធភាពនិងសហប្រតិបត្តិការ" ទាបបំផុត។*

អង្គការត្រូវបានស្នើឲ្យផ្តល់ "ពិន្ទុមធ្យមភាគ" ពី ១ ដល់ ១០ នៅក្នុងផ្នែកដែលត្រូវផ្តោតការយកចិត្តទុកដាក់នីមួយៗ។ ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលទាំង៨ មានតែបីប៉ុណ្ណោះបានឆ្លើយនឹងសំណួរនេះ។នេះគឺធ្វើឲ្យការបកស្រាយមធ្យមភាគមានការលំបាក។
ទោះបីជាយ៉ាងនេះក្តី ក្នុងចំណោមអ្នកដែលបានឆ្លើយតប វាជាការគួរឲ្យចាប់អារម្មណ៍ដោយប្រៀបធៀបចំណាត់ថ្នាក់ទាំងនោះ៖ សមត្ថភាពអង្គការទទួលបានចំណាត់ថ្នាក់ខ្ពស់ជាងគេជារួម (៦,៦/១០) បន្ទាប់មកមានធនធានមនុស្ស (៥,៦/១០) និងធនធានហិរញ្ញវត្ថុ (៥/១០) ចំណែកឯសហប្រតិបត្តិការនិងសម្ព័ន្ធភាព បានទទួលចំណាក់ថ្នាក់ទាបជាងគេបំផុត ៣,៣/១០។

# ឯកសារយោង


AGPA (2012) ASEAN Grassroots Peoples Assembly (AGPA) Statement, 2012. Downloaded from: http://iglhrc.org/content/asean-grassroots-people's-assembly-people's-statement

Asia Life (2009) 'Pride 2009 Program'. Asia Life. Phnom Penh Issue 29 May 2009

Asia-Pacific Coalition On Male Sexual Health (APCOM) & Asia-Pacific Transgender Network (APTN) (2013). Policy Brief - 'Overlooked, Ignored, Forgotten – HIV and Basic Rights of Transgender People in Asia and the Pacific'

Baird, Vanessa (2001) '*The No-Nonsense Guide to Sexual Diversity*.' New Internationalist Publications.

Baron, Laignee (2013) 'Groups insist on Equal Rights', Phnom Penh Post, 11 Dec 2013.

BBC (2013) Q&A: Gay rights in Russia (13 August 2013). Retrieved 29 August 2013 from http://www.bbc.co.uk/news/ world-europe-23604142

BBC News (2004) 'Cambodia King Backs Gay Marriage'. 20 Feb 2004. Retrieved 15 Feb 2014 from http://news.bbc.co.uk/2/hi/asia-pacific/3505915.stm

Bennet, Jon and Benson, Charlotte. (1995). 'Cambodia: NGO Cooperation in a Changing Aid context, 1979–1994.' In '*NGO Coordination in Practice*' London, Earthscan publications.

Beyrer, C. (1998) 'War in the Blood: Sex, Politics and AIDS in South East Asia'. Palgrave and Macmillan.

Brown, R. (2012). Corrective Rape in South Africa: A Continuing Plight Despite an International Human Rights Response. 2012 Annual Survey of International & Comparative Law (Spring, 2012). Golden Gate University School of Law.

Burns, C. (2011). Fact Sheet: LGBT Discrimination in Higher Education Financial Aid. Center for American Progress. Retrieved 20 August 2013 from http://www.americanprogress.org/wp-content/uploads/issues/2011/08/pdf/ lgbt_factsheet.pdf.

Caceres C, Pecheny M et al. (2009). 'Review of Legal Frameworks and Situation of Human Rights related to Sexual Diversity in Low and Middle Income Countries'. http://data.unaids.org/pub/Report/2009/20091215_legalframeworks_sexualdiversity_en.pdf

Cambodia Center for Human Rights (CCHR). (2010) 'Coming Out in the Kingdom: Lesbian, Gay, Bisexual and Transgender People in Cambodia'

Cambodia Center for Human Rights (CCHR). (2012). 'Rainbow Khmer: From Prejudice to Pride'.

Cambodian Alliance for Combatting HIV/AIDS (CACHA)& National AIDS Authority (NAA). (2009).

Research Report, ‘Policies environment regarding universal access and the right to work of Entertainment Workers in Cambodia’.

Cambodian Independent Teachers Association (CITA). Advocacy Handbook, 2011.

Cambodian Law on Marriage and the Family (1989, unofficial English version), Articles III, V, VI, VII & VIII. Retrieved 30 January 2014 from: http://www.gocambodia.com/laws/data%20pdf/Law%20on%20Marriage%20and%20Family/Law%20on%20the%20marriage%20and%20family(EN).pdf

Catalla, TAP, Sovanara, K. & Van Mourik, G. (2003) Out of the Shadows – Male to Male Sexual Behavior in Cambodia. International HIV/AIDS Alliance & KHANA

CCHR, Asia-Pacific Network of People living with HIV (APN plus) and the Sexual Rights Initiative (SRI). (2013). Statement Submission to the 18th UPR-Cambodia

Civil Code of Cambodia, unofficial English translation, 2008, Book Seven, Chapter 3, pp. 221-224; Chapter 2, Module 2, sub-section V, Article 1023, provision 2. (p. 237).

Commission on AIDS in Asia and the Pacific. (2008) *‘Redefining AIDS in Asia-Crafting An Effective Response’*

Crothers, Lauren. ‘Discussions center on equalizing Cambodian LGBT rights’. 5 March 2014. http://www.cambodiadaily.com/news/discussions-center-on-equalizing-cambodias-lgbt-rights-53529

Daguan, Zhou (AKA Chou Ta-kuan), (1296) *The Customs of Cambodia*. Edited and newly translated from the French by Michael Smithies. The Siam Society, Bangkok, 2006.

Davies and Miles, (2012) ‘The Lingha boys of Siem Reap – A baseline study of sexually exploited young men in Siem Reap’, Love 146, Chab Dai Coalition, First Step, Hard Places Community, P. 31.

Domrei Research & Consulting. (2012) Baseline Survey on a Joint Communications Campaign on Violence against Women. Report prepared for PYD (Paz Y Desarollo)

Drennan, J. and Chanyda, (2013) ’Shift in LGBT policy urged’ Phnom Penh post, 2 January 2013

Earth, Barbara. (2006) ‘Diversifying Gender: Male to Female Transgender Identities and HIV Programming in Phnom Penh, Cambodia’. Gender & Development 14:2, pp. 259–271

Freeman, J. and Chanida, C. ‘Civil parties put forced marriage back into the spotlight’, Phnom Penh Post, 28 February 2013. Retrieved from http://www.phnompenhpost.com/national/civil-parties-put-forced-marriage-back-spotlight

Fulu E, Warner X, Miedma S, Jewkes R, Roselli T and Lang, J. (2013). Why do some men use Violence against Women and How can we Prevent it? Quantitative Findings from the United Nations Multi-country Study on Men and Violence in Asia and the Pacific. Bangkok: UNDP, UNFPA, UN Women and UNV.

Gharbi, S., 'Gay Scene and Grinder on KohPich' (2012) 7 Days, Phnom Penh Post, 14–20 December 2012. Issue 173, p. 8

Gharbi, Sylvain (2012) 'A Loveless life: A ladyboy in the Provinces'. 7 days, Phnom Penh post, 14–20 December 2012, p. 8

Girault, P. and Thaiy (1999) Unpublished. A Mapping of Men who have sex with Men. Phnom Penh, FHI

Girault, P. Saidel, T. Ngak, S.et al: (2002) 'Sexual Behaviors, STIs and HIV among men who have Sex with Men in Phnom Penh'. FHI

Glaziou, P. Bodet et al. (1999) 'Knowledge, attitudes and practices of University Students regarding HIV infection in Phnom Penh, Cambodia 1999. AIDS: Volume 13 (14), October 1999

Grant, J. M., Mottet, L. A., Tanis, J. et al. (2011) Injustice at Every Turn: A Report of the National Transgender Discrimination Survey. Washington: National Center for Transgender Equality and National Gay and Lesbian Task Force. Retrieved from www.thetaskforce.org/downloads/reports/reports/ntds_full.pdf

International Commission of Jurists, and the International Service for Human Rights, (2007). The Yogyakarta Principles: The Application of International Human Rights Law in relation to Sexual Orientation and Gender Identity.

International Lesbian, Gay, Bisexual, Trans and Intersex Association (ILGA) (2014) State-Sponsored Homophobia: A world survey of laws: Criminalisation, protection and recognition of same-sex love. Itaborahy and Zhu. May 2014, 9th Edition. Retrieved 18 July 2014 from http://old.ilga.org/Statehomophobia/ILGA_SSHR_2014_Eng.pdf

Ip, Stephanie (2012) 'LGBT Community to be respected-PM', Phnom Penh post, 12 December 2012

IPPF, MSMGF, UNFPA & RHAC, (2011) HIV Prevention Report Card for MSM and Transgender People in Cambodia.

Kasztelan, Marta (2014) 3 Mar 2014 http://asiancorrespondent.com/120120/rights-group-cambodia-cellcard-ad-discriminatory-against-lgbt-people/

Knox, C (2013) 'Coming Out Cambodia Art Series Captures Stigma'. Phnom Penh Post, 25 July 2013. http://www.phnompenhpost.com/lifestyle/coming-out-cambodia-art-series-captures-stigma

Knox, Claire (2012) 'Girls will be boys and boys will be ladies: the art of Drag' Phnom Penh Post, 7 Days, issue 173, 14 December 2012, p. 8;

Kunthear M and Drennan, J. (2013) 'Laws can't stop lovers Marrying', Phnom Penh Post, 20 May 2013.

Law on Implementation of the Civil Code of Cambodia. (2011) National Assembly and Senate of Cambodia. Unofficial English translation.

Lesley, E. and Rith, S. (2005) 'Stepping Out', Phnom Penh Post, 14 January 2005.

Lewis, M. 'Coming Out in Cambodia: Women in same-sex relationships stand up for human rights'. http://www.theguardian.com/journalismcompetition/professional-longlist-20121

LGBT Rights in Cambodia. Retrieved 6 Feb 2014 from http://en.wikipedia.org/wiki/LGBT_rights_by_country_or_territory#East_Asia

Liu, Kai-Li and Chorvann, C. (2010), 'Behavioral Risks On-Site Serosurvey among At-risk Urban Men in Cambodia (Bros Khmer study)' FHI 360, pp. 46–48.

Mac Isaac, V, (2012) 'Seven Questions' Phnom Penh Post, 20 April 2012.

Marston, J (2000).' Impact of Human Rights Advocacy' (Report No. 37, SIDA/Forum Syd, September 2000) – A report on the evaluation of six human rights NGOs in Cambodia

Menghourng, Ngo (2012) 'A voice for the vulnerable', 7 days, Phnom Penh Post, 14–20 May 2010. Issue 41, pp. 16–18

Miles & Davies (n.d.) 'More than Gender' – a baseline study of transgendered males in the sex industry in Phnom Penh. PowerPoint presentation by Love 146 (undated).

Ministry of Health & NCHADS (April 2013). 'Standard Operating Procedure (SoP) for the Boosted Continuum of Prevention, Care and Treatment (CoCPT) for Most At Risk Populations (MARPs) in Cambodia'.

Ministry of Planning. (2011). 'The Identification of Poor Households Programme – A key tool to support equitable Development'. Programme description and brochure.

Mullen, D. (2010) 'Everybody needs to have Pride', Phnom Penh Post 7 Days, 14–20 May 2010, Issue 41

National AIDS Authority (2009) National Guideline for STIs and HIV response among MSM and Transgender.

National AIDS Authority (NAA). (2012). UNGASS Country Progress Report, 2010–2011. P.15

National AIDS Authority, (NAA). (2010). National Strategic Plan for a Comprehensive and Multisectoral Response to AIDS for 2011–2015.

Office of the High Commissioner of Human Rights (OHCHR) (2011), "Discriminatory Laws and Practices and Acts of Violence against Individuals Based on their Sexual Orientation and Gender Identity", 17 November 2011 report submitted to the Human Rights Council. Retrieved 27 August 2013, from http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/ Session19/A-HRC-19-41_en.pdf.

Ogden, John (1994) 'Sex Survey Helps AIDS fight'. *Phnom Penh Post*, 26 August 1994. Retrieved from http://www.phnompenhpost.com/national/sex-survey-help-aids-fight

OHCHR. (2012) Born Free and Equal – Sexual Orientation and Gender Identity in International Human Rights Law

Personal communications (2013, 2014): Pal Sophat, August 2013; RC (Gender & Communications Advisor to the MoWA) Feb 2014; MSM and Transgender network volunteers and NGO transgender peer educators (2013 & 2014); Bunthorn Kong and the National MSM and Transgender network (2013).

Rainbow Community Kampuchea (RoCK) (2010, 2011 and 2012) 'Love who we are', LGBT Pride 2010 program; 'Proud to be Me' Cambodia LGBT Pride 2011 program; 'Different but the Same' Cambodia LGBT Pride Program 2012

RoCK, WNU, CPN+, CLS, and Cam ASEAN. (2013). Statement: LGBT Joint submission (Cambodia) for the Universal Periodic Review of the UN Human Rights Council.

Roth Meas (2012) 'Pride closes with a Buddhist Blessing'. *Phnom Penh Post*, 22 May 2012. http://www.phnompenhpost.com/lifestyle/pride-closes-buddhist-blessing

Salas V. (2009). Consultancy report for HACC & CAFOD for Bandanh Chatomuk (MSM and Transgender Network) - Annex 3, Bibliography of MSM and Transgender related publications .

Salas V. (2012)- Report on Assessment of the MSM and Transgender Network in Cambodia, (done for Bandanh Chatomuk and UNAIDS Cambodia)

Salas, V. (2013). Evaluation Report- 'Improving Sexual Reproductive Health of MSM in Phnom Penh, Kampong Cham and Kampong Speu provinces'. Reproductive Health Association of Cambodia (RHAC), internal document

Salas, V. and Srorn, S. (2013). 'An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping.' Research report. Social Protection Coordination Unit, Council for Agricultural Research and Development (SPCU-CARD)

Salas, Vicente. (2014, forthcoming) Speaking Out – A Toolkit for MSM and Transgender-led Advocacy (Khmer and English versions adapted for Cambodia). Global Forum on MSM and HIV (MSMGF)

Sears, B. & Mallory, C. (2011). Documented Evidence of Employment Discrimination and Its Effects on LGBT People. The Williams Institute. Retrieved 30 August 2013 from http://williamsinstitute.law.ucla.edu/wp-content/ uploads/Sears-Mallory-Discrimination-July-20111.pdf

Sreynang C. and MacIsaac, V (2012) 'Cambodia's first transgender star opts for natural look' Phnom Penh Post 7 Days, 13–19 July 2012

Tan, Phong. (2008) 'Ethnography of Male to Male Sexuality in Cambodia' UNESCO Phnom Penh

Tarr, Chou Meng and Aggleton, Peter. (1999) 'Young People and HIV in Cambodia-Meanings Contexts and Sexual Cultures'. Retrieved 14 Feb 2014 from http://www.racha.org.kh/rc2008/142/HAP-05F.pdf

Thiemann, J. (2013) "Seven Questions with Sao Sopheak", Phnom Penh Post 7 days, 15 February 2013. http://www.phnompenhpost.com/7days/7-questions-sao-sopheak

Trembath, Kerry. (n.d.) 'Buddhism and Homosexuality'. Retrieved 28 Mar 2014 from http://www.enabling.org/ia/vipassana/Archive/T/Trembath/buddhismAndHomosexualityTrembath.html

UNDP and the Asia-Pacific Transgender Network (APTN), (2012).'Lost in Transition: Transgender People, Rights and HIV Vulnerability in the Asia-Pacific Region.'

UNESCO (2012). Good Practices in HIV and Health Education, Booklet 8. 'Education Sector Responses to Homophobic Bullying'

United States Agency for International Development. (n.d.) LGBT Global Development Partnership: Promoting Lesbian, Gay, Bisexual, and Transgender Inclusive Development. Retrieved 20 August 2013 from http://www.usaid.gov/sites/default/files/documents/2496/USAID%20Fact%20Sheet%20LGBT%20Global%20Partnership.pdf

USAID RDMA & UNDP, (2012). 'Summary Brief, Being LGBT in Asia-A Participatory Review and Analysis of the Legal and Social Environment for LGBT persons and Civil Society'

USAID, PACT & International center for Research on Women (ICRW) (2010) Understanding and
Challenging Stigma toward Men who have sex with Men: A Toolkit for Action (Cambodia adaptation).

USAID (2011) 'School Dropout Prevention Pilot Program-Drop Out Trend Analysis: Cambodia' 51p.

WHO and MoH Cambodia (2013) Cambodia Health Service Delivery Profile 2012.

Winter, C. (2012) Responding to LGBT Health Disparities. Ryan Barker & Thomas McAuliffe (Eds.). Missouri Foundation for Health. Retrieved 23 August 2012 from http://www.mffh.org/mm/files/LGBTHealthEquityReport.pdf

Youth Voices Count (YVC) (2013) 'I feel like I do not deserve happiness at all'. Policy Brief: Self-Stigma among young MSM and Transgender women and linkages with HIV in Asia.

# គេហទំព័រដែលបានជ្រើសរើស

## ប្រភពព័ត៌មាន៖

http://data.un.org/CountryProfile.aspx?crName=Cambodia Retrieved 2 April 2014

http://data.worldbank.org/country/cambodia Retrieved 2 April 2014

http://en.wikipedia.org/wiki/Religion_in_Cambodia Retrieved 28 March 2014

http://www.religioustolerance.org/hom_budd0.htm Retrieved 28 March 2014

**LGBT News portal:**

Khmer Rainbow portal: http://sogi.sithi.org

## អត្ថបទកាសែត៖

http://sochua.wordpress.com/2010/12/02/from-white-cloth-to-precious-gems-cambodian-women-challenge-gender-stereotypes-and-defend-against-hiv/

http://abcnews.go.com/blogs/politics/2014/03/dalai-lama-says-he-supports-gay-marriage/ Retrieved 28 March 2014

http://sunnarin.wordpress.com/2010/11/13/cambodias-first-gay-town/ CAMBODIA'S FIRST GAY TOWN - Global Post, Retrieved 10 March 2014

http://www.un.org.kh/index.php/newsroom/speach-and-statement/629-2013-prideweek,

http://asiapacific.unwomen.org/en/news-and-events/stories/2012/6/op-ed-cambodia-pride-week-12-to-20-may2012

http://bluieladyblog.com/article/high-schools-love-story-cambodias-gay-film.html Retrieved March 2014

http://khmerbird.com/writing/boyfriend-first-gay-novel-in-khmer-language.htmlRetrieved March 2014.

http://www.prnewswire.com/news-releases/cambodian-transgender-activist-sou-sotheavy-wins-2014-david-kato-vision--voice-award-244929501.html & http://www.visionandvoiceaward.com.

# ឧបសម្ព័ន្ធទី១៖ បញ្ជីអង្គការដែលចូលរួម

| ឈ្មោះអង្គការ | ឈ្មោះបុគ្គលទំនាក់ទំនងពាក់ព័ន្ធ | លេខទូរស័ព្ទ | អ៊ីមែល | អាសយដ្ឋានការងារ |
|---|---|---|---|---|
| សហគមន៍ឥន្ទធនូកម្ពុជា (RoCK) | Collette O' Regan | (+855) 17 559-150 | colletteoregan@gmail.com | ផ្ទះលេខ 54i, ផ្លូវលេខ 103, សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ កម្ពុជា |
| មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR - SOGI project) | ស៊ីដារ៉ា នួន | (+855) 92 805-808 | sidara.nuon@cchrcambodia.org | ផ្ទះលេខ 798, ផ្លូវលេខ 99, សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ កម្ពុជា |
| បណ្តាញអភិវឌ្ឍន៍បុរសស្រ្តីកម្ពុជា (CNMWD) | សុធារី ស៊ូ | (+855) 11999-271 | cnmwd.khmer@gmail.com | N/A |
| បណ្តាញចតុមុខ (BC) - បណ្តាញជាតិនៃបុរសស្រឡាញ់បុរស និងមនុស្សប្លែកភេទ | ប៊ុនថន គង់ | (+855) 92 445-186 | bunthornkong@gmail.com | #33, St. 71, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, 12301 ភ្នំពេញ កម្ពុជា (KHANA) |
| បណ្តាញស្ត្រីដើម្បីរួបរួម (WNU) | ថា កែវ | (+855) 12 471-093 | wnu.cambodia@gmail.com | #3-4, St. 339, សង្កាត់បឹងកក់ 1 ខណ្ឌទួលគោក, PO Box 308, ភ្នំពេញ |
| ខេមអាស៊ាន (CamSEAN Youth's Future) | យ៉ារ៉ា គង់ | (+855) 70 740-185 | camasean@gmail.com | #228, St. 271, S/K ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា |
| បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍កម្ពុជា (CPN+) | ប៊ុនវីរៈ ហន | (+855) 89 685-686 | hornvirak@gmail.com | # 84, Street 606 សង្កាត់បឹងកក់ II , ខណ្ឌទួលគោក , ភ្នំពេញ កម្ពុជា |
| អង្គការសុខភាពបុរសកម្ពុជា (MHC) | គីមរុន ម៉ៅ | (+855) 12 404-669 | kimrunmao@hotmail.com | #28B5, St. 75, សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ |
| សហប្រតិបត្តិការសម្រាប់សេវាសង្គមនិងអភិវឌ្ឍន៍ (CSSD) | ចាន់ថន មាស | (+855) 17 373-986 | chanthanmeas@yahoo.com | #121, ផ្លូវ 32BT, សង្កាត់បឹងទំពន់ I, ខណ្ឌមានជ័យ ភ្នំពេញ |
| KANHNHA | វណ្ណារឿត ខា | (+855) 92 610-633 | khasovannaroeurt@yahoo.com | ផ្លូវជាតិលេខ 1, ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល |
| សហប្រតិបត្តិការស្ត្រីខ្មែរដើម្បីការអភិវឌ្ឍ (KWCD) | សាទុម ស៊ុម | (+855) 23 880-629 | info@kwcd.org | #68A, St.138, សង្កាត់ផ្សារដេប៉ូ II, ខណ្ឌទួលគោក ភ្នំពេញ |

## ឧបសម្ព័ន្ធទី ២៖ សន្ទានុក្រមនៃពាក្យដែលប្រើជាទូទៅ

ផ្នែកនេះនៃរបាយការណ៍ជាតិ ត្រូវដកស្រង់ចេញពី៖ Salas, V. (២០១៤) "និយាយចេញមកក្រៅ" - ឯកសារជំនួយស្មារតីស្ដីពីការតស៊ូមតិដែលដឹកនាំដោយ MSM និងមនុស្សប្តូរភេទ (ការសម្របតាមបរិបទកម្ពុជា)។ វេទិកាសកលស្តីពី MSM និងមេរោគអេដស៍ (MSMGF). ជិតចេញផ្សាយ

ឯកសារយោងសំខាន់ៗ សំរាប់ពាក្យជាភាសាអង់គ្លេស, លើកលែងតែត្រូវបានបញ្ជាក់៖

- អង្គការ PACT និង អង្គការ ICRW. (២០១០) ការយល់ដឹង និងភាពលំបាកនៃការស្អប់ខ្ពើមចំពោះ MSM: ឯកសារជំនួយស្មារតីស្តីពីសកម្មភាព. សម្របតាមបរិបទប្រទេសកម្ពុជា.
- International Commission of Jurists & International Service for Human Rights. (២០០៧). គោលការណ៍យ៉កយ៉ាកាតា – គោលការណ៍ក្នុងការប្រើប្រាស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពាក់ព័ន្ធនឹង ទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រ
- ទំព័រពិតនិយាយពី សិទ្ធិមនុស្សនៃLGBT៖សំណួរដែលគេសួរជាញឹកញាប់. ដក់ស្រង់ពី http://www.ohchr.org/EN/Issues/Discrimination/Pages/LGBTFactSheets.aspx and https://www.unfe.org/en/fact-sheets

| ពាក្យ ឬអក្សរកាត់ | ការពន្យល់ ឬនិយមន័យ |
|---|---|
| **មនុស្សស្រឡាញ់ភេទទាំងពីរ (Bisexual)** | បុគ្គលដែលស្រឡាញ់ប្រុសផង ស្រីផង ទាំងផ្លូវអារម្មណ៍ ទាំងផ្លូវភេទ |
| **មនុស្សប្រុសស្រឡាញ់ប្រុសដូចគ្នា (Gay)** | ប្រើដើម្បីពិពណ៌នាទាំងប្រុស ទាំងស្រី ដែលតម្រង់ផ្លូវអារម្មណ៍និងផ្លូវភេទទៅរកអ្នកដែលមានភេទដូចគ្នា។ ពាក្យ "Gay" ត្រូវបានគេនិយមជាង "ស្រឡាញ់ភេទដូចគ្នា" (homosexual) ដោយសារពាក្យចុងក្រោយនេះអាចមានន័យអវិជ្ជមាន និងផ្សារភ្ជាប់ទៅនឹងពេលវេលាដែលការស្រឡាញ់ភេទដូចគ្នា ត្រូវបានគេចាត់ទុកថាជាជំងឺ ឬជាវិបត្តិផ្លូវចិត្តមួយ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការប្រើពាក្យ "Gay" អនុវត្តភាគច្រើនចំពោះមនុស្សប្រុស ដោយសារមនុស្សស្រី គេចូលចិត្តប្រើពាក្យ "Lesbian" |

| | |
|---|---|
| **ការសំដែងយេនឌ័រ ឬ ការស្តែងចេញនូវភេទ** (Gender Expression) | វិធីដែលបុគ្គលម្នាក់បង្ហាញអត្តសញ្ញាណយេនឌ័រ ដូចដែលតាមធម្មតាស្តែងចេញតាមរយៈចរិតលក្ខណៈនានា ដូចជារូបរាង សំលៀកបំពាក់ ចលនាភាសាកាយវិការ វិធីនៃការនិយាយនិងសម្លេង ទាក់ទងទៅនឹងអ្វីដែលអាចទទួលយកបានផ្នែកវប្បធម៌ ជាបុរស ឬស្ត្រី |
| **អត្តសញ្ញាណយេនឌ័រ** (Gender Identity) | សំដៅលើបទពិសោធន៍ដែលជាអារម្មណ៍យ៉ាងជ្រៅ នៅខាងក្នុងនិងម្នាក់ៗរបស់បុគ្គលម្នាក់ៗចំពោះភេទ ដែលអាច ឬអាចមិនត្រូវគ្នាទៅនឹងភេទដែលផ្តល់ពីកំណើត រួមទាំងវិញ្ញាណផ្ទាល់ខ្លួននៃរាងកាយ (ដែលអាចពាក់ព័ន្ធប្រសិនបើត្រូវជ្រើសរើសដោយសេរី នូវការកែប្រែរូបរាងនៃរាងកាយ ឬមុខងារ ដោយមធ្យោបាយវេជ្ជសាស្រ្ត ឬវះកាត់ ឬវិធីផ្សេងទៀត) និងការសំដែងចេញនូវភេទ (យេនឌ័រ) រួមទាំងសំលៀកបំពាក់ ពាក្យសំដី និងអាការៈ។ |
| **ស្រឡាញ់ភេទផ្ទុយគ្នា** (Heterosexual) | បុគ្គលដែលស្រឡាញ់បុគ្គលម្នាក់ទៀតដែលមានភេទ ឬយេនឌ័រផ្ទុយពីគាត់ទាំងផ្នែកផ្លូវអារម្មណ៍និងផ្លូវភេទ |
| **ការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា** (Homophobia) **ការស្អប់មនុស្សប្លូរភេទ** (Transphobia) | ការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា គឺជាការខ្លាចដោយមិនសមហេតុផល ការស្អប់ ឬការមិនចូលចិត្តចំពោះមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ប្រុសស្រឡាញ់ភេទដូចគ្នា ឬមនុស្សស្រឡាញ់ភេទទាំងពីរ។ ការស្អប់មនុស្សប្លូរភេទ មានន័យថាជា ការខ្លាចដោយមិនសមហេតុផល ការស្អប់ ឬការមិនចូលចិត្តចំពោះមនុស្សប្លូរភេទ។ ដោយសារតែពាក្យថា ការស្អប់មនុស្សស្រឡាញ់ភេទដូចគ្នា ត្រូវបានគេយល់យ៉ាងទូលំទូលាយ ជារឿយៗគេប្រើនៅក្នុងន័យរួមបញ្ចូលទាំងអស់សំដៅលើការ ការខ្លាច ការស្អប់ ឬការមិនចូលចិត្តចំពោះមនុស្ស LGBT ជាទូទៅ។ |
| **មនុស្សស្រឡាញ់ភេទដូចគ្នា** (Homosexual) | បុគ្គលដែលស្រឡាញ់បុគ្គលម្នាក់ទៀតដែលមានភេទឬយេនឌ័រដូចគ្នាទាំងផ្លូវអារម្មណ៍ និងផ្លូវភេទ។ ជាពាក្យទូទៅមួយ បុគ្គលដែលស្រឡាញ់ភេទដូចគ្នា រួមបញ្ចូលទាំងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា។ |
| **មនុស្សភេទពីរឬមនុស្សអន្តរភេទ** (Intersex) | បុគ្គលដែលកើតមកមានល្បាយរួមគ្នានូវប្រដាប់ភេទប្រុសនិងស្រី ដែលអភិវឌ្ឍដោយពេញលេញឬដោយផ្នែក។ ពួកគេអាចមានសណ្ឋានក្រូម៉ូសូមដែលមិនត្រូវនឹងនិយមន័យធម្មតានៃ "ប្រុស" និង "ស្រី" ។ ជាធម្មតា មនុស្សដែលមានភេទពីរ ត្រូវបានគេកំណត់ភេទ(យេនឌ័រ)ពីកំណើត។ ជាញឹកញាប់ដំណើរការនេះមានលក្ខណៈផ្អែកលើបំណងផ្ទាល់ខ្លួន ហើយមនុស្សភេទពីរជាច្រើនជ្រើសរើសអត្តសញ្ញាណភេទផ្សេងៗមួយទៀតក្នុងជីវិតរបស់គេក្រោយមកទៀត ឬជ្រើសរើសយកអត្តសញ្ញាណភេទរបស់ខ្លួនជាបុគ្គលភេទពីរ ដែលជាប្រុសផងស្រីផង។ មនុស្សភេទពីរគឺជាកត្តបម្រែបម្រួលជីវសាស្រ្ត ហើយមិនមែនទំនោរផ្លូវភេទ ឬមិនសំដៅលើឥរិយាបថផ្លូវភេទ ទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ នោះទេ។ មនុស្សភេទពីរឆ្លងកាត់នូវទំនោរផ្លូវភេទ និងអត្តសញ្ញាណដូចគ្នានឹងបុគ្គលមិនមែនភេទពីរដែរ ។ |

| | |
|---|---|
| **មនុស្សស្រីស្រឡាញ់ភេទដូចគ្នា** (Lesbian) | ជាពាក្យដែលគេប្រើសម្រាប់មនុស្សស្រីដែលមានអត្តសញ្ញាណជាមនុស្សស្រឡាញ់ភេទដូចគ្នា។ ពាក្យ"Gay" ច្រើនប្រើជាមួយមនុស្សប្រុស ដូច្នេះមនុស្សស្រីជាច្រើនចូលចិត្តពាក្យដោយឡែកមួយដែលអនុវត្តជាក់លាក់ចំពោះទំនោរផ្លូវភេទរបស់មនុស្សស្រី។ |
| LGBT, or LGBTI | ជាអក្សរកាត់រួមបញ្ចូលគ្នាមួយដែលគេប្រើជាទូទៅដើម្បីនិយាយអំពីក្រុមមនុស្សទាំងមូលគឺមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ។ មនុស្សប្តូរភេទនិងមនុស្សភេទពីរ ជារឿយៗ មានទំនាក់ទំនងជាមួយ អត្តសញ្ញាណមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ ពីព្រោះពួកគេប្រឈមមុខនឹងការតស៊ូស្រដៀងគ្នានៅពេលមានការរុកកួន ឬការរើសអើង ដោយសារតែការសំដែងចេញនូវភេទ(យេនឌ័រ)របស់ខ្លួន។ ទោះបីជាយ៉ាងណាក្តី មនុស្សប្តូរភេទនិងមនុស្សភេទពីរ អាចជា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទផ្ទុយគ្នា ឬមនុស្សស្រឡាញ់ភេទទាំងពីរ ផងដែរ។ |
| **ក្រុមប្រឈមមុខបំផុត** (MARP) | អក្សរកាត់សម្រាប់ក្រុមមនុស្សដែលប្រឈមមុខបំផុត សម្រាប់មេរោគអេដស៍ គេប្រើនៅក្នុងវិស័យសុខាភិបាល។ នៅក្នុងប្រទេសកម្ពុជា ក្រុមមនុស្សទាំងនេះរួមមាន MSM និងមនុស្សស្រីប្តូរភេទដែលចាក់គ្រឿងញៀន និង "អ្នកធ្វើការក្នុងសេវាកម្សាន្ត"។ |
| **បុរសដែលរួមភេទជាមួយបុរស** (MSM) | ជាអក្សរកាត់មួយសម្រាប់ "បុរសដែលរួមភេទជាមួយបុរស"។ MSM គឺជាពាក្យឥរិយាបថមួយដែលគេប្រើដើម្បីសំដៅលើមនុស្សប្រុសតាមធម្មជាតិដែលរួមភេទជាមួយមនុស្សដទៃទៀត។ ពាក្យនេះមិនមានន័យថា MSM សុទ្ធតែមានអត្តសញ្ញាណផ្អែកលើនេះទេ ទោះបីជាពួកគេជាច្រើនមានអត្តសញ្ញាណបែបនេះក្តី។ MSM ជាច្រើនជាមនុស្សរៀបការរួច។ MSM ជាពាក្យមួយ មិនត្រូវបានគេប្រើទូលំទូលាយនៅខាងក្រៅមេរោគអេដស៍និងវិស័យសុខាភិបាលទេ។ នៅក្នុងប្រទេសកម្ពុជា អត្ថន័យនៃពាក្យ MSM ជារឿយៗ ត្រូវបានគេបកប្រែជា ប្រុសស្រឡាញ់ប្រុស។ |
| **ទំនោរផ្លូវភេទ ឬ ការប្រតិព័ទ្ធផ្លូវភេទ** (Sexual Orientation) | សំដៅលើសមត្ថភាពរបស់បុគ្គលម្នាក់ៗក្នុងការស្រឡាញ់ផ្អែកផ្លូវអារម្មណ៍ និងផ្លូវភេទយ៉ាងជ្រាលជ្រៅចំពោះ (និងទំនាក់ទំនងស្និទ្ធស្នាលគ្នានិងផ្លូវភេទជាមួយ) បុគ្គលដែលមានភេទផ្សេងមួយទៀត ឬភេទដូចគ្នា ឬភេទលើសពីមួយ។ គ្រប់គ្នាមានទំនោរផ្លូវភេទមួយ ដែលជាផ្អែកចាំបាច់ចំពោះអត្តសញ្ញាណរបស់បុគ្គលម្នាក់។ ទំនោរផ្លូវភេទបីត្រូវបានគេស្គាល់ជាទូទៅ៖ ស្រឡាញ់ភេទទាំងពីរ ស្រឡាញ់ភេទផ្ទុយគ្នា ឬស្រឡាញ់ភេទដូចគ្នា។ ទំនោរផ្លូវភេទ មិនទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ ទេ។ |
| **មនុស្សបំលែងភេទឬមនុស្សប្តូរភេទ** | គេប្រើដើម្បីពិពណ៌នាមនុស្សដែលកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួនផ្ទុយពីភេទតាមធម្មជាតិរបស់ពួកគេ ។ មនុស្សបំលែងភេទជារឿយៗមាន |

| | |
|---|---|
| (Transgender) | អារម្មណ៍ថា ពួកគេស្ថិតជាប់នៅក្នុងរាងកាយខុស។ មានមនុស្សប្តូរភេទទាំងពីប្រុសទៅស្រី ក៏ដូចជា ពីស្រីទៅប្រុស ។ |
| | វាគឺជាពាក្យរួមមួយសម្រាប់មនុស្សដែលអត្តសញ្ញាណនិងការសំដែងចេញនូវភេទរបស់ខ្លួនមិនអនុលោមតាមបទដ្ឋាន និងការរំពឹងទុក ដែលមានទំនាក់ទំនងពីបុរាណជាមួយភេទរបស់ពួកគេដែលកំណត់ពីកំណើត។ មនុស្សប្តូរភេទអាចកំណត់អត្តសញ្ញាណដោយខ្លួនឯង ជាភេទចម្រុះ, ប្រុស,ស្រី , ស្រីប្តូរភេទ, បុរសប្តូរភេទ, មនុស្សប្តូរភេទ, ខ្ទើយ, ‵waria′ ឬអត្តសញ្ញាណវប្បធម៌ជាក់លាក់ដទៃទៀត ហើយអាចសំដែងចេញភេទរបស់ខ្លួនតាមរូបភាពផ្សេងៗ ជាប្រុស, ស្រី, និង/ឬប្រុសផងស្រីផង ។ (មជ្ឈមណ្ឌលសម្រាប់ឧត្តមភាពមនុស្សប្តូរភេទ) |
| **មនុស្សប្តូរភេទ** (Transsexual) | មនុស្សដែលមានការកែឬប្តូរដោយវះកាត់ខ្លះទៅលើប្រដាប់ភេទរបស់ពួកគេ និង/ឬការព្យាបាលដោយអ័រម៉ូន ដើម្បីប្តូររូបរាងកាយរបស់ពួកគេដើម្បីឲ្យស្របតាមអត្តសញ្ញាណ យេនឌ័ររបស់ពួកគេ។ |

## ពាក្យក្នុងស្រុកខ្លះដែលគេប្រើបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា

### *កំណត់សម្គាល់របស់អំពីភាសា៖*

ភាសាតែងតែវិវត្តន៍ជានិច្ច។ ពាក្យថ្មីៗត្រូវបានគេបង្កើតឡើង និងចាប់ផ្តើមប្រើប្រាស់ដំបូង និងយល់នៅក្នុងក្រុមមិត្តភក្តិតូចមួយ មុននឹងត្រូវបានគេប្រើប្រាស់កាន់តែទូលំទូលាយ។ នៅក្នុងពេលនេះ អត្ថន័យអាចត្រូវបានគេរក្សាដដែល ឬអាចត្រូវបានគេផ្លាស់ប្តូរ។ ពាក្យខ្លះត្រូវយកដោយត្រង់ៗចេញពីប្រភពប្រទេស ពាក្យខ្លះទៀតត្រូវបានគេកែតម្រូវជាភាសាខ្មែរ ហើយពាក្យខ្លះទៀតត្រូវបានគេបង្កើតថ្មីសុទ្ធសាធ ដូចជា *ស៊ីមពីរ*។ [153] (ដែលសំដៅលើការមានស៊ីមកាតពីរនៅក្នុងទូរស័ព្ទតែមួយនិងត្រូវបានប្រើប្រាស់ដោយមនុស្សវ័យក្មេងជាច្រើន ដែលជាក្រុមមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា និងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា ដើម្បីមានន័យថា បុគ្គលម្នាក់ដែលចូលចិត្តរួមភេទជាមួយមនុស្សប្រុសផងស្រីផង។ នេះគឺជាពាក្យមួយដែលនឹងមិនត្រូវបានគេយកប្រើទេ ប្រសិនបើគ្មានទូរស័ព្ទស៊ីមពីរនោះ។

ពាក្យខ្លះមានប្រជាប្រិយខ្លាំងនៅក្នុងវិស័យខ្លះ (ពោលគឺ ការប្រើពាក្យ MSM ជាទូរទៅត្រូវបានគេកំណត់ត្រឹមសុខភាពសាធារណៈ និងវិស័យមេរោគអេដស៍។ ជាការគួរឲ្យចាប់អារម្មណ៍ នៅក្នុងប្រទេសកម្ពុជា MSM ត្រូវបានគេបកប្រែថា ប្រុសស្រឡាញ់ប្រុស (បុរសស្រឡាញ់បុរស) ដែលមិនត្រឹមត្រូវមានន័យថាជាការរួមភេទរវាងមនុស្សពីរនាក់ប៉ុណ្ណោះទេ ប៉ុន្តែវាបន្ថែមន័យផ្សេងៗទៀត ដូចជា ចំណង់ អារម្មណ៍ សេចក្តីស្រឡាញ់ ផ្គាក់ផ្គួម សម្ព័ន្ធ

[153] ‶SIM″ is an abbreviation for ‶Subscriber Identity Module″ – or your mobile phone card where information is stored.

មេត្រី និងស្នេហា។ ពាក្យខ្លះអាចត្រូវបានគេនិយមប្រើច្រើននៅតាមខេត្តដទៃទៀត ឬលែងត្រូវបានគេប្រើ ឬបំភ្លេចចោល។ ប្រភពនៃពាក្យជាក់លាក់មិនត្រូវបានគេដឹង ប៉ុន្តែជាការពិតពាក្យជាច្រើនត្រូវបានគេបង្កើតថ្មី ដើម្បីធ្វើការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធរវាងមិត្តភក្តិស្និទ្ធស្នាលស្ងាត់ៗ ដោយមិនចង់ឲ្យអ្នកដទៃទៀតនៅក្បែរនោះយល់ពីអ្វីដែលពួកគេនិយាយ - ប្រភេទនៃភាសា "សម្ងាត់" ។ ពាក្យខ្លះសំដៅទៅលើពាក្យដែលប្រើដោយរាជវង្ស និងក្រុមអ្នកមានក្នុងចំណោមពួកគេខ្លួនឯង។ មនុស្សចាស់ៗខ្លះបានអះអាងថា *"សូម្បីតែនៅក្នុងរបបខ្មែរក្រហម យើងមានភាសាបែបនេះដែរ ដែលមានតែយើងទេដែលយល់"* ។ បាតុភូតនេះកើតមាននៅក្នុងប្រទេស សហគមន៍ និងវប្បធម៌ផ្សេងៗ។ មនុស្សបង្កើតវិធីផ្សេងៗដើម្បីប្រាស្រ័យទាក់ទងជាមួយគ្នា ប្រសិនបើមានការមាក់ងាយឬរើសអើង ដូច្នេះគេត្រូវការភាពសម្ងាត់ និងត្រូវមានភាសាឬពាក្យរួមគ្នា ប្រសិនបើគេគេជាសមាជិកសហគមន៍មួយនោះ" ។

ពាក្យដែលប្រើ មិនគួរមានលក្ខណៈមើលងាយទេ ហើយត្រូវតែអាចទទួលយកចំពោះបុគ្គលទាំងនោះ។ ក្រុមដទៃខ្លះទៀត ជំទាស់ទៅនឹងការប្រើពាក្យដោយអ្នកដែលគេចាត់ទុកថាជា "អ្នកក្រៅ" ហើយពួកគេអាចប្រើពាក្យខ្លះសម្រាប់ខ្លួនឯងផ្ទាល់។ ឧទាហរណ៍ *ខ្ទើយ* មានអត្ថន័យមើលងាយ និងត្រូវបានគេចាត់ទុកថាជាការមាក់ងាយនៅពេលប្រើទូទៅ ប៉ុន្តែនៅពេលប្រើដោយមិត្តភក្តិនៅក្នុងបណ្តាញMSM និងមនុស្សប្លូរភេទ គេចាត់ទុកថាអាចទទួលយកបាន ឬអាចត្រូវបានប្រើសម្រាប់ជាការកំប្លែងនិងចំអកលេង។ ដូច្នេះ បរិបទ ទឹកដមសម្លេង បែបបទនៃការនិយាយ និងចេតនាពីក្រោយការប្រើពាក្យនេះ អាចមានសារៈសំខាន់ដូចពាក្យនោះផ្ទាល់អញ្ចឹងដែរ។ ថ្មីៗនេះអង្គការក្រៅរដ្ឋាភិបាលខ្លះអះអាងថា ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានកែលម្អការប្រើពាក្យរបស់ខ្លួនសម្រាប់ LGBT - *ភេទទីបី* ត្រូវប្រើប្រាស់កាន់តែញឹកញាប់ និងត្រូវបានគេចាត់ទុកថា ជាពាក្យមួយដែលអាចទទួលយកបាន។

ពាក្យដែលគេរើសយកមកប្រើខ្លះ (សរសេរទៅតាមសម្លេងភាសាអង់គ្លេស) ហើយការពន្យល់និងការប្រើប្រាស់ មានពិពណ៌នាក្នុងតារាងខាងក្រោម[154]៖

[154] ពាក្យក្នុងស្រុកភាគច្រើនបំផុតនៅក្នុងតារាងនេះ គឺចេញមកពី (១) តាន់ ផុង Tan, Phong. (២០០៨) "ជាតិពន្ធុសាស្ត្រនៃទំនាក់ទំនងផ្លូវភេទបុរសនិងបុរសនៅក្នុងប្រទេសកម្ពុជា", UNESCO Cambodia; PACT Cambodia & ICRFW. (2010) (២) ការយល់ដឹង និងការប្រឈមនឹងការមាក់ងាយចំពោះ MSM និងមនុស្សប្លូរភេទ - ឯកសារជំនួយស្មារតីសម្រាប់សកម្មភាពសម្របសម្រាប់បរិបទកម្ពុជា (៣) Catalla, TAP, Sovanara K និង Van Mourik, G. (2003). "ក្រៅស្រមោល - ឥរិយាបថផ្លូវភេទរវាងប្រុសនិងប្រុសក្នុងប្រទេសកម្ពុជា"។សម្ព័ន្ធភាពមេរោគអេដស៍/ជំងឺអេដស៍អន្តរជាតិ និងអង្គការខាណា និង (៤) Salas, Vicente និង Srun, S. (2013). "ការស្វែងយល់អំពីការផាត់ចេញពីសង្គមនៃមនុស្សស្រីស្រឡាញ់ស្រីដូចគ្នា មនុស្សប្រុសស្រឡាញ់ប្រុស និងមនុស្សប្លូរភេទនៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ និងវិធីដោះស្រាយ។ "របាយការណ៍ស្រាវជ្រាវ។ ផ្នែកសម្របសម្រួលគាំពារសង្គម ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មជនបទ (SPCU-CARD)

| ពាក្យខ្មែរ | ពិពណ៌នា/អត្ថន័យ |
|---|---|
| ប្រុសស្រឡាញ់ប្រុស Bros slan bros | មនុស្សប្រុសដែលស្រឡាញ់ប្រុសដទៃទៀត (ពោលគឺ សម្ព័ន្ធភាពផ្លូវភេទចំណង់) |
| ខ្ទើយ (Katoey) | មនុស្សជាតិដែលមានប្រដាប់ភេទ ពាក់កណ្ដាលប្រុស ពាក់កណ្ដាលស្រី (វចនានុក្រមវិទ្យាស្ថានព្រះពុទ្ធសាសនា ជួន ណាត); "បុគ្គលដែលមិនគ្រប់លក្ខណៈខាងផ្លូវភេទ" , បុគ្គលដែលមានប្រដាប់ភេទនៃភេទទាំងពីរ; បុរសដែលស្លៀកពាក់ដូចស្រី ឬស្រីដែលស្លៀកពាក់ដូចប្រុស។ |
| LG, LB, LT | Lesbian Girl, Lesbian Boy, Lesbian Tom - ជាទូទៅ ប្រើដោយមនុស្សស្រីស្រឡាញ់ស្រីដូចគ្នានៅទីក្រុងដែលមានវ័យក្មេង ដើម្បីបែងចែកភាពខុសគ្នារវាងមនុស្សស្រីស្រឡាញ់ភេទដូចគ្នាដែលមានចរិតស្រី (LG) ពីមនុស្សស្រីស្រឡាញ់ប្រុសដូចគ្នាដែលមានចរិតប្រុស (LB) ពីអ្នកដែលប្ដូរភេទ (LT ឬ Lesbian Tom) |
| ប្រុសលក់ខ្លួន (Pros Luk Kloun) | មនុស្សប្រុសដែលលក់ខ្លួនសម្រាប់រួមភេទ |
| បុរសដែលរួមភេទជាមួយបុរស មានសក់ខ្លី (MSM short hair) | មនុស្សប្រុសម្នាក់ដែលត្រូវបានគេសម្គាល់ថា ជា "ប្រុស១០០%" ប៉ុន្តែដែលរួមភេទជាមួយបុរសដទៃទៀត សក់វែង ឬសក់ខ្លី, គេស្គាល់ផងដែរថាជា រឹងបឹង) ឬ បុរសម្នាក់ដែលកំណត់អត្តសញ្ញាណជាបុរសម្នាក់ និងស្លៀកពាក់សំលៀកបំពាក់ប្រុស ប៉ុន្តែមានចរិតជាស្រីខ្លះ និងជាអ្នកដែលរួមភេទជាមួយបុរសដទៃទៀត សក់វែង ឬសក់ខ្លី។ |
| បុរសដែលរួមភេទជាមួយបុរស មានសក់វែង (MSM long hair) | មនុស្សប្រុសម្នាក់ដែលកំណត់អត្តសញ្ញាណជាស្រី និងចង់តែងខ្លួនដូចជាស្រី។ សូមមើល ទន់ភ្លន់ |
| រឹងបឹង (Reng Peng) | មនុស្សប្រុសម្នាក់ដែលមានចរិតប្រុស រឹងមាំ ខ្លាំង ពោរពេញដោយថាមពលស្ថិតស្ថាញ ធ្វើការងារធ្ងន់ធ្ងរ; សូមមើលផងដែរ៖ MSM សក់ខ្លី |
| Sbian | អក្សរកាត់នៃ lesbian - ប្រើជាចម្បងដោយអ្នកឯកទេសខាងអប់រំ និងអ្នករស់នៅទីក្រុង |
| ស៊ីមពីរ (SIM Pi) | ន័យត្រង់ "ស៊ីមកាតពីរ" ដែលសំដៅលើមនុស្សដែលរួមភេទជាមួយ ឬមានសម្ព័ន្ធមេត្រីសង្វាសជាមួយដៃគូ ដែលមានភេទផ្ទុយគ្នា និងភេទដូចនឹងខ្លួន (ស៊ីមពីរ) |
| ស្រីស្រឡាញ់ស្រី (Srey Slan Srey) | មនុស្សស្រីដែលស្រឡាញ់មនុស្សស្រីផ្សេងទៀត ។ ជាពាក្យសម្រាប់ទាំងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រុសប្ដូរភេទ |
| ស្រីស្រស់ (Srey Sros) | ន័យត្រង់ "ស្រីស្អាត" ។ ពាក្យដែលនិយមប្រើដោយស្រីបំលែងភេទ ដើម្បីសំដៅលើខ្លួន ឯង។ |
| ទន់ភ្លន់ (Toun Phloun) | មនុស្សប្រុសដែលមានបុគ្គលលក្ខណៈស្រដៀងស្រី ទន់ភ្លន់ និងស្រគត់ស្រគំ ច្រើនតែគេចចេញពីអំពើហិង្សា ជៀសវាងការងារធ្ងន់ និងចូលចិត្តពន្លឺ ការងារផ្ទះ; សូមមើលផងដែរ៖ "MSM សក់វែង" |

*Empowered lives.*
*Resilient nations.*

**United Nations Development Programme**
**UNDP Asia-Pacific Regional Centre**
United Nations Service Building, 3rd Floor
Rajdamnern Nok Avenue, Bangkok 10200, Thailand
Email: aprc.th@undp.org
Tel: +66 (0)2 304-9100
Fax: +66 (0)2 280-2700
Web: http://asia-pacific.undp.org/

August 2014